# ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០២០

## កុមារខ្មែរចំនួន១៧នាក់កំពុងស្ថិតនៅមណ្ឌលថែទាំមួយកន្លែងនៅក្នុងប្រទេសថៃ បន្ទាប់ពីអាជ្ញាធរប្រទេសនេះបានធ្វក់ចូលបង្ក្រាបលើទីតាំង៤កន្លែងនៅតំបន់ឆ្នេរ Patong ក្នុងខេត្តភូកេត កាលពីចុងសប្តាហ៍មុន

http://www.rfi.fr/km/cambodia/Chidrens-in-Thailand -29-02-2020

នេះបើតាមអាជ្ញាធរជាតិប្រឆាំងការជួញដូរមនុស្សរបស់កម្ពុជា។ ប៉ុន្តែគេមិនទាន់ដឹងថា តើនឹងត្រូវបញ្ជូនកុមារទាំងនោះមកកម្ពុជាវិញឬយ៉ាងណាទេ ដែលបញ្ហានៅត្រង់ថាឪពុកម្តាយរបស់ពួកគេកំពុងតែរស់នៅប្រទេសថៃដែរ។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សកម្ពុជា បានប្រាប់វិទ្យុបារាំងអន្តរជាតិRFIនៅថ្ងៃសៅរ៍នេះថា ស្ថានទូតខ្មែរនៅទីក្រុងបាងកកកំពុងធ្វើកិច្ចការនេះជាមួយអាជ្ញាធរថៃ ខណៈសមត្ថកិច្ចកំពុងស្វែងរកចាប់ខ្លួនបណ្តាញមេខ្យល់នៅប្រទេសខ្មែរ។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ថា កុមារខ្មែរចំនួន១៧នាក់នោះ កំពុងស្ថិតនៅមណ្ឌលថែទាំមួយកន្លែងនៅក្នុងប្រទេសថៃ បន្ទាប់ពីអាជ្ញាធរប្រទេសនេះបានធ្វក់ចូលបង្ក្រាបលើទីតាំង៤កន្លែងនៅតំបន់ឆ្នេរ Patong ក្នុងខេត្តភូកេត កាលពីចុងសប្តាហ៍មុន។

នេះបើតាមការចុះផ្សាយរបស់សារព័ត៌មានថៃ Phuket News នៅថ្ងៃទី២៤ ខែកុម្ភៈ គឺកុមារខ្មែរទាំងនោះត្រូវបានគេប្រើឲ្យដើរសុំទានឬលក់របស់របរ ដោយដាក់កំហិតក្នុងមួយថ្ងៃឲ្យបាន៣០០០បាត ។ហើយកុមារខ្លះក្នុងចំណោមនោះត្រូវរងការធ្វើទារុណកម្មលើរាងកាយ នៅពេលពួកគេមិនអាចរកលុយបានគ្រប់ចំនួន។ កុមារទាំងនោះភាគច្រើនអាយុក្រោម១៥ឆ្នាំ ពួកគេធ្វើការដោយគ្មានថ្ងៃសម្រាក។ តាមការសាកសួរទៅលើកុមារទាំងនោះ គឺក្រុមមេខ្យល់បានសន្យាផ្តល់ប្រាក់ឲ្យឪពុកម្តាយពួកគេចំនួន៥០០០បាតក្នុងមួយខែ តែជាក់ស្តែងឪពុកម្តាយពួកគេមិនដែលបានទទួលលុយនោះឡើយ។

ករណីនេះ លោកស្រី ជូ ប៊ុនអេង នៅមិនទាន់អាចសន្និដ្ឋានបានថាជាករណីជួញដូរមនុស្សឬយ៉ាងណាទេដោយត្រូវការរបាយការណ៍លំអិតបន្ថែមពីអាជ្ញាធរពាក់ព័ន្ធដែលកំពុងសាកសួរទៅលើឪម្តាយរបស់កុមារទាំងនោះដែលកំពុងរស់នៅប្រទេសថៃ។ ហើយនេះក៏បញ្ហាមួយដែលអាជ្ញាធរពិបាកសម្រេចចិត្តថានឹងបញ្ជូនកុមារទាំងនោះមកកម្ពុជាវិញឬយ៉ាងណា?

បើតាមសារព័ត៌មានថៃ Phuket News ក្នុងប្រតិបត្តិការចុះបង្ក្រាបករណីសង្ស័យការជួញដូរមនុស្សនៅតំបន់ឆ្នេរ Patong ក្នុងខេត្តភូកេតនោះ ប៉ូលីសថៃបានចាប់ខ្លួនមនុស្ស២នាក់ ដែលម្នាក់ជាជនជាតិថៃ និងម្នាក់ទៀតមិនមែនជាជនជាតិថៃនោះទេ។ តែបើតាមលោកស្រី ជូ ប៊ុនអេង នេះមិនមែនជាករណីទី១ដែលអាជ្ញាធរថៃបង្ក្រាបលើករណីសង្ស័យជួញដូរមនុស្សនេះ ខណៈអាជ្ញាធរកម្ពុជាកំពុងស្វែងរកចាប់ខ្លួនបណ្តាញមេខ្យល់នៅប្រទេសខ្មែរផងដែរ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ February 28 at 4:17 PM

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៤និង៤០នាទី ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០២នាក់នេះ មាន ១. ឈ្មោះ វ៉ុន វីរៈ ភេទប្រុស អាយុ ៣១ឆ្នាំ ទីលំនៅ បច្ចុប្បន្នស្ថិតក្នុងភូមិជួនម៉ៅ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និង២. ឈ្មោះ ម៉ក់ មិនា ភេទស្រី អាយុ ២៧ឆ្នាំ ទីលំនៅបច្ចុប្បន្នស្ថិតក្នុងឃុំស្អាង ស្រុកស្អាង ខេត្តកណ្ដាល។ នគរបាលប៉ុស្តិ៍បានធ្វើការអប់រំ ណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## លោកប៉ាវស៊ីណា រកឃើញក្រុមហ៊ុនកាស៊ីណូ ចំនួន៣ នៅប៉ោយប៉ែត កំពុងបំពានច្បាប់ និង កេងប្រវ័ញ្ចកម្លាំងញើសឈាមបុគ្គលិក និយោជិត

https://dap-news.com/ ByVNT108 Posted on March 2, 2020

ភ្នំពេញ៖ ក្នុងកិច្ចប្រជុំតាមដាន លក្ខខណ្ឌការងាររបស់ក្រុមហ៊ុនផ្សេងៗ ជាមួយតំណាងសហជីព ចលនាកម្មករ ប្រចាំក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១ ខែ មីនា លោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករ បានរកឃើញក្រុមហ៊ុនកាស៊ីណូចំនួន៣ មិនបានអនុវត្តតាមសេចក្តីប្រកាស របស់ក្រសួងការងារ និងបណ្ដុះបណ្តាលវិជ្ជាជីវៈ ទាក់ទងនិងការបើកប្រាក់រំលឹក អតីតភាពការងារ និងប្រាក់បំណាច់ការងារ។

លោក ប៉ាវ ស៊ីណា បានឲ្យដឹង តាមរយៈគេហទំព័រហ្វេសប៊ុកថា ក្រុមហ៊ុន កាស៊ីណូ ចំនួន ៣ ដែលមិនបានអនុវត្តតាមសេចក្តីប្រកាស របស់ក្រសួងការងារ ទាក់ទងនិង ការបើកប្រាក់រំលឹក អតីតភាពការងារមុនឆ្នាំ២០១៩ និងបើកប្រាក់បំណាច់ការងារ ដែលចាប់អនុវត្តពីឆ្នាំ២០១៩ តទៅនោះរួមមាន ក្រុមហ៊ុន ៖

ទី១-កាស៊ីណូ ហ្រ្គេន ដាយអឹម៉ុនស៊ីធី

ទី២-កាស៊ីណូ រីហ្សត ដែលកាស៊ីណូ ក្រុមហ៊ុនទាំងពីរ បានបើកជូនបុគ្គលិកតែប្រាក់បំណាច់ការងារ ដែលអនុវត្តពីឆ្នាំ២០១៩ ទៅមុខតែប៉ុណ្ណោះ រីឯ ប្រាក់រំលឹកអតីតភាពការងារ ដែលនៅសល់មុនឆ្នាំ២០១៩ ពុំផ្តល់ជូនបុគ្គលិកនិយោជិតនោះទេ ។

រីឯទី៣- ក្រុមហ៊ុនកាស៊ីណូ ឌី អិន អេ គី មិនបានបើក ទាំងប្រាក់រំលឹកអតីតភាពការងារ និងប្រាក់បំណាច់ការងារ តែម្តង ។

ប្រធានសហជីពរូបនេះបញ្ជាក់ថា “ការមិនយកចិត្តទុកពីសំណាក់មន្ត្រីពាក់ព័ន្ធ បានធ្វើអោយថៅកែក្រុមហ៊ុនកាស៊ីណូទាំងនេះ កំពុងតែបំពានច្បាប់ និងកេងប្រវ័ញ្ច កម្លាំងញើសឈាមបុគ្គលិកនិយោជិត ។ ខ្ញុំសូមស្នើឲ្យថ្នាក់ដឹកនាំក្រសួងការងារ មេត្តាពិនិត្យមើលករណីនេះផង”៕

# ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២០

## សម្តេច ហេង សំរិនៈ សន្តិភាព និងការអភិវឌ្ឍដែលមានបច្ចុប្បន្ននេះ ត្រូវបានចូលរួមចំណែកយ៉ាងសកម្មពីស្ត្រីគ្រប់ស្រទាប់វណ្ណៈ

http://www.freshnewsasia.com/ 2020-03-04

**(ភ្នំពេញ)៖** សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នាព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០ បានទទួលជួបគណៈប្រតិភូស្ត្រី មកពីស្ថាប័នសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល ដឹកនាំដោយ លោកស្រីវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដើម្បីអបអរសាទរខួបទី១០៩ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២០ ខាងមុខនេះ។

ក្នុងមតិស្វាគមន៍ដល់អង្គពិធីនៅវិមានរដ្ឋសភា លោក ឡេង ប៉េងឡុង អគ្គលេខាធិការរដ្ឋសភា បានឲ្យដឹងថា សម្តេចប្រធានរដ្ឋសភា តែងតែចំណាយពេលវេលារៀងរាល់ឆ្នាំ ដើម្បីទទួលជួបប្រតិភូស្ត្រីមកពីគ្រប់វិស័យបែបនេះ ដើម្បីអបអរសាទរទិវាអន្តរជាតិនារី និងការចូលរួមរបស់សម្តេចក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា។

លោកស្រី អ៊ឹង កន្ថាផាវី បានធ្វើរបាយការណ៍ជូនអង្គពិធីពីលទ្ធផលការងាររបស់ក្រសួងកិច្ចការនារី។ លោកស្រីបានបញ្ជាក់ថា ភាពរីកចម្រើនទាក់ទងទៅនឹងសមភាពយេនឌ័រ ទទួលបានលទ្ធផលជាវិជ្ជមានច្រើនវិស័យ ធ្វើឲ្យមានការផ្លាស់ប្តូរជាបណ្តើរៗនូវផ្នត់គំនិត និងទស្សនៈរបស់សង្គម។ រាជរដ្ឋាភិបាលបានបង្កលក្ខណៈភាពដល់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេសស្ត្រី និងក្មេងឲ្យទទួលបានឱកាស និងអត្ថប្រយោជន៍ស្មើគ្នា ដូចបុរស និងក្មេងប្រុស ជំរុញសង្គមគ្រួសារឲ្យផ្តល់ការវិនិយោគដោយស្មើភាពលើកការអប់រំ ឲ្យកូនប្រុស កូនស្រី រៀនសូត្របានកម្រិតខ្ពស់ មានជំនាញបច្ចេកទេស និងមុខរបរ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារខ្លួនក៏ដូចជាទទួលបាននូវភាពរីកចម្រើនផ្នែកសុខភាព។ លោកស្រីរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា វិសមភាពយេនឌ័រនៅកម្ពុជាមានការរីកចម្រើននៅគ្រប់វិស័យ ទាំងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច។ វិស័យសាធារណៈ និងនយោបាយ ចំនួនស្ត្រីក្នុងតួនាទីធ្វើការសម្រេចចិត្តមានការកើនឡើងជាបន្តបន្ទាប់ ទាំងបរិមាណនិងគុណភាព នៅតាមមុខតំណែង និងឋានន្តរស័ក្តិ ពីមួយអាណត្តិទៅមួយអាណត្តិ។

បើតាមរដ្ឋមន្ត្រីក្រសួងកិច្ចការនារី នៅក្នុងមុខងារសាធារណៈចំនួនស្ត្រីមានការកើនឡើងពី៣២% នៅឆ្នាំ២០០៧ ដល់៤១% នៅឆ្នាំ២០១៩។ ចំនួនស្ត្រីដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមក្រុង ស្រុក ខណ្ឌ រហូតអគ្គនាយក និងថ្នាក់ស្មើមានចំនួន ២៥% ស្ត្រីជាអភិបាលខេត្តមានចំនួន១ ស្ត្រីជាអភិបាលរងខេត្ត រងរាជធានីមានចំនួន២៦រូប ស្ត្រីជាអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួន៦រូប ស្ត្រីជាអភិបាលរងក្រុង ស្រុក ខណ្ឌ មានចំនួន១៩៤រូប។ នៅក្នុងឆ្នាំ២០១៩ មន្ត្រីការទូតជាស្ត្រីទៅបំពេញការងារ ជាឯកអគ្គរាជទូតមានចំនួន៤រូប និងស្ត្រីជាទីប្រឹក្សា លេខាធិការ និងគណនេយ្យករអមស្ថានទូត និងស្ថានកុងស៊ុលប្រចាំប្រទេស មានចំនួន៥៥រូប។ លោកស្រីបានលើកឡើងថា ចំពោះវិស័យសេដ្ឋកិច្ចវិញ របាយការណ៍វេទិកាសេដ្ឋកិច្ចពិភពលោកឆ្នាំ២០២០ បានបង្ហាញថាកម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទី២៥ ក្នុងឆ្នាំ២០២០ បើធៀបទៅនឹងចំណាត់ថ្នាក់ទី៤៥ ក្នុងឆ្នាំ២០១៨ ក្នុងចំណោមប្រទេសចំនួន១៥៣ ដែលនេះបានបង្ហាញថា ការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចគឺសកម្ម។ អត្រាស្ត្រីចូលរួមក្នុងកម្លាំងពលកម្មកម្រិតខ្ពស់មានដល់៧៩% នៅក្នុងឆ្នាំ២០១៧។ សហគ្រិនភាពស្ត្រី មានការកើនឡើងហើយ៦៥% នៃសហគ្រាសខ្នាតតូច និងមធ្យម ដែលបានចុះបញ្ជី គឺមានស្ត្រីជាអ្នកគ្រប់គ្រងឬម្ចាស់សហគ្រាស។

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន បានអបអរសាទរចំពោះការប្រារព្ធទិវាអន្តរជាតិនៅឆ្នាំនេះ ក្រោមប្រធានបទ «មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ»។ សម្តេចបានគូសបញ្ជាក់ថា ប្រធានបទនេះពិតជាមានសារៈសំខាន់និងសមស្របបំផុត ដែលបញ្ជាក់ពីគុណតម្លៃរបស់ស្ត្រីកម្ពុជា ដែលបានរួមចំណែកលះបង់កម្លាំងកាយចិត្ត ដើម្បីសន្តិភាព និងការអភិវឌ្ឍសង្គម។ សម្តេចបានកោតសរសើរចំពោះការខិតខំរបស់រាជរដ្ឋាភិបា

ល ដែលមានក្រសួងកិច្ចការនារី បានជំរុញនិងលើកកម្ពស់សមត្ថភាពស្ត្រី ចូលរួមក្នុងការងារសង្គម នយោបាយ សេដ្ឋកិច្ច កាន់តែច្រើនឡើង។ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន បានគូសបញ្ជាក់ថា សន្តិភាពនិងការអភិវឌ្ឍ ដូចសព្វថ្ងៃនេះ គឺមានការចូលរួមចំណែកយ៉ាងសកម្មពីស្ត្រីគ្រប់ ស្រទាប់វណ្ណៈ។ សម្តេចបានមានប្រសាសន៍បន្តថា សុខសន្តិភាព ស្ថិរភាពនយោបាយ ជាកត្តាសំខាន់ចាំបាច់ ក្នុងការជំរុញលើកកម្ពស់ការអភិវឌ្ឍលើគ្រប់វិស័យ និងគ្រប់ទីកន្លែង។ សន្តិភាពបានផ្តល់ឱកាសល្អឱ្យបុរស ស្ត្រី កូនប្រុស ស្រី រស់នៅជួបជុំក្រុមគ្រួសារ បានសិក្សារៀនសូត្រខ្ពង់ខ្ពស់ មានចំណេះដឹង ជំនាញបច្ចេកទេស និងមុខរបរ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារខ្លួន រួមចំណែកកសាង និងអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែមានភាពរីកចម្រើនរុងរឿង និងប្រជាជនរស់នៅប្រកបដោយវិបុលភាព និងសុខុដុមរមនា។

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន បានបញ្ជាក់ថា រដ្ឋសភាដែលជាស្ថាប័ននីតិប្បញ្ញត្តិ និងជាដៃគូ ដ៏សំខាន់របស់ស្ថាប័ននីតិប្រតិបត្តិ បានយកចិត្តទុកដាក់ខ្ពស់ក្នុងការបំពេញតួនាទីរបស់ខ្លួនដូចជា ពិនិត្យ ពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ ផ្តល់សច្ចាប័នលើអនុសញ្ញា កតិកាសញ្ញា និងពិធីសារអន្តរជាតិពាក់ព័ន្ធ ដែលជាលិខិតបទដ្ឋានគតិយុត្ត សម្រាប់ជាមធ្យោបាយឆ្ពោះទៅរកសមភាពយេនឌ័រ និងកិច្ចការពារសិទ្ធិ ក៏ដូចជាផលប្រយោជន៍របស់ស្ត្រីឱ្យមានប្រសិទ្ធភាពបំផុត។ ដើម្បីជំរុញប្រសិទ្ធភាពក្នុងការលើកកម្ពស់វិសមភាពយេនឌ័រនៅកម្ពុជាឲ្យកាន់រីកចម្រើនថែមទៀត សម្តេចប្រធានរដ្ឋសភាបានផ្តល់អនុសាសន៍ មួយចំនួនដល់ស្ថាប័នពាក់ព័ន្ធពិចារណា ដើម្បីយកទៅអនុវត្តជាក់ស្តែង ដោយក្នុងនោះ សម្តេចជំរុញឲ្យបន្តយកចិត្តទុកដាក់បញ្ជ្រាបសមភាពយេនឌ័រ នៅក្នុងក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគត្តិយុត្ត លិខិតតូបករណ៍អន្តរជាតិ និងសេចក្តីសម្រេចនានា។

សម្តេចបានលើកទឹកចិត្តដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍជាតិ អន្តរជាតិទាំងអស់ បន្តចូលរួមចំណែកគាំទ្រការលើកកម្ពស់ស្ថានភាពជីវភាព សិទ្ធិ ឋានៈ តួនាទី សុខុមាលភាពរបស់ស្ត្រី និងក្មេងស្រី និងការផ្តល់សេវាជួយជនរងគ្រោះដោយអំពើហិង្សា ប្រកបដោយគុណភាព និងប្រសិទ្ធភាព។ បន្តពង្រឹងសមត្ថភាពនៅគ្រប់តំបន់ ពិសេសតំបន់ដាច់ស្រយាល តាមរយៈការពង្រីកផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ បច្ចេកទេសជំនាញខ្លីៗ ក្នុងគោលដៅធានានូវកំណើនជីវភាពរស់នៅ ការប្រកបមុខរបបចិញ្ចឹមជីវិតប្រចាំថ្ងៃ ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ សម្តេចបានស្នើឲ្យបន្តយកចិត្តទុកដាក់ពង្រឹងសមត្ថភាពស្ត្រី និងក្មេងស្រីសម្រាប់បន្តវេន្ត ដោយយកចិត្តទុកដាក់ក្នុងការអប់រំក្មេងស្រីតាំងពីមតេយ្យសិក្សា ការលើកទឹកចិត្តក្មេងស្រីកុំឱ្យលះបង់ការសិក្សានៅគ្រប់កម្រិត និងការទប់ស្កាត់មិនឱ្យមានអំពើហឹង្សា ការរើសអើង ព្រមទាំងពង្រីកសេវាគាំទ្រដល់ក្មេងស្រីនៅក្នុងសាលា និងឲ្យមានការអនុវត្តឱ្យសកម្មផុលផុស នៃយុទ្ធនាការដើម្បីប្រយុទ្ធប្រឆាំង និងបង្ក្រាបអំពើចោរកម្ម ឃាតកម្ម ការប្លន់ប្រដាប់អាវុធ ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស អំពើហិង្សាគ្រប់រូបភាពលើស្ត្រី និងកុមារ៕

## អគ្គស្នងការនគរបាលជាតិ ចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិនិត្យផ្តល់យោបល់លើការសិក្សាស្រាវជ្រាវការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា

http://cambodiapolice.com/policekh/ 9:55 am 4 មីនា 2020

**ភ្នំពេញ ៖** ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ នេះ អគ្គស្នងការនគរបាលជាតិ បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិនិត្យផ្តល់យោបល់លើការសិក្សាស្រាវជ្រាវការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) បានសហការជាមួយអង្គការ APLE បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិនិត្យផ្តល់យោបល់លើការសិក្សាស្រាវជ្រាវការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ ញ៉េប សុភាព អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។ កិច្ចប្រជុំនេះ ក៏មានការចូលរួមពីមន្ត្រីជាន់ខ្ពស់នគរបាលជាតិ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាក្រុមការងារបច្ចេកទេសមកពីក្រសួងស្ថាប័នពាក់ព័ន្ធ មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក និងអង្គការដៃគូពាក់ព័ន្ធនានា។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណង៖ ពិនិត្យ និងផ្តល់យោបល់លើកម្រងសំណួរការអង្កេតស្តីពីការទប់ស្កាត់គ្រោះថ្នាក់ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា។

សូមជម្រាបថា កិច្ចប្រជុំនេះ មានរយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃអង្គារ-ពុធ ១០កើត-១១កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣-០៤ ខែមីនា ឆ្នាំ២០២០៕

## ពលករ ខ្មែរ ម្នាក់បើកគោយន្តកន្ត្រៃក្រឡាប់បោកនឹងដើមឈើ បណ្តាលឲ្យស្លាប់បាត់បង់ជីវិតយ៉ាងអាណោចអាធ័ម

https://www.facebook.com/officialworker/ 03-03-2020

03.03.20 មានករណីបុរសពលករខ្មែរម្នាក់បើកគោយន្តកន្ត្រៃក្រឡាប់បោកនឹងដើមឈើបណ្តាលឲ្យស្លាប់បាត់បង់ជីវិតយ៉ាងអាណោចអាធ័ម ហេតុការណ៍គ្រោះថ្នាក់នេះបានកើតឡើងកាលពីវេលាម៉ោង ១២:យប់ឈានចូលថ្ងៃអង្គារ ទី០៣ ខែមីនា ឆ្នាំ២០២០ ចំណុចកើតហេតុនៅក្នុងភូមិសារម៉េត ឃុំគោកឡាន ស្រុកតាប់ថាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ជនរងគ្រោះមាន ឈ្មោះ Pring Brem ភេទប្រុស អាយុ៤០ឆ្នាំ ស្រុកកំណើតរស់នៅខេត្តសៀមរាប បានស្លាប់បាត់បង់ជីវិតភ្លាមៗនៅនឹងកន្លែងកើតហេតុ ។

## ធ្វើជាគ្រូបង្រៀន តែអសីលធម៌ ហ៊ានបើកហាងខារ៉ាអូខេ បង្កប់សេវាផ្លូវភេទ ត្រូវបានរកឃើញសុទ្ធតែពុំទាន់គ្រប់អាយុ

http://www.cen.com.kh/ March 2, 2020

គ្រូបង្រៀនម្នាក់អាយុ ៥១ ឆ្នាំ នៅឯខេត្តសុរិន្ទ ភាគខាងត្បូងប្រទេសថៃ (ជិតព្រំដែនកម្ពុជា) ស្ថិតក្នុងចំណោមម្ចាស់ហាងខារ៉ាអូខេចំនួន ៣ ដែលត្រូវបានចាប់ខ្លួនពីបទលក់សេវាកម្មផ្លូវភេទ ទៅលើក្មេងស្រីថៃមិនទាន់គ្រប់អាយុ ។ នាងៗ ១៩ នាក់ ដែលត្រូវបានគេគិតថាជាអ្នករកស៊ីផ្លូវភេទ ត្រូវបានគេនាំទៅមន្ទីរឃុំឃាំង បន្ទាប់ពីការវាយឆ្មក់នៅហាងខារ៉ាអូខេទាំងនោះ។

អាជីវកម្មត្រូវបានបិទ ហើយម្ចាស់ហាងទាំងនោះ ក៏កំពុងប្រឈមនឹងបទចោទប្រកាន់ជាច្រើន រួមមានការជួញដូរមនុស្ស និងការរំលោភបំពានលើអនីតិជន។ អាជ្ញាធរខេត្តបានព្រមានថា មន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនឹងត្រូវប្រឈមនឹងការដាក់ទណ្ឌកម្មយ៉ាងតឹងរ៉ឹង បន្ទាប់ពីករណីនេះលេចឡើងថា ម្ចាស់ម្នាក់ក្នុងចំណោមនោះ គឺជាគ្រូបង្រៀនសាលាសាធារណៈ។

លោក Narong Thipsiri ប្រធានការិយាល័យអនុវត្តច្បាប់សម្រាប់មន្ទីររដ្ឋបាលខេត្តសុរិន្ទ បានទទួលស្គាល់ថា ការជួញដូរមនុស្សគឺជាបញ្ហាធ្ងន់ធ្ងរនៅក្នុងខេត្ត។ លោកបាននិយាយថា នោះគឺជាការរំលោភលើច្បាប់របស់ប្រទេសថៃ និងក៏រំលោភសិទ្ធិមនុស្សដែលត្រូវបានកេងប្រវ័ញ្ច និងអសីលធម៌ផងដែរ៕ ប្រែសម្រួលដោយ៖ លឹម ហុង (ប្រភព៖ The Thai Examiner.com)

# ពលករខ្មែរចូលរួមជាមួយពលករចម្រុះជាតិសាសន៍រាប់រយនាក់តវ៉ានៅទីក្រុងបាងកកឱ្យរដ្ឋាភិបាលថៃរក្សា GSP

https://www.rfa.org/ ដោយ អាស៊ីសេរី 2020-03-03

ពលករខ្មែរប្រមាណ ២០នាក់ នៅព្រឹកថ្ងៃទី៣ មីនា ចូលរួមតវ៉ាជាមួយពលករចម្រុះជាតិសាសន៍នៅមុខទីស្នាក់ការកណ្ដាលប្រចាំតំបន់របស់អង្គការសហប្រជាជាតិ នៅក្រុងបាងកក ប្រទេសថៃ ដើម្បីឱ្យជួយជំរុញទៅរដ្ឋាភិបាលថៃឱ្យគោរពសិទ្ធិការងារ ដើម្បីរក្សាការអនុគ្រោះពន្ធ GSP របស់សហរដ្ឋអាមេរិក។ ក្រុមអ្នកតវ៉ាបានដាក់ឧបករណ៍បំពងសំឡេងលើកបដា និងកាន់ទង់ជាតិតំណាងប្រទេសនីមួយៗ ឈរស្រែកតវ៉ានៅក្រោមកម្ដៅថ្ងៃនៅទីក្រុងបាងកក ទាមទារឱ្យរដ្ឋាភិបាលថៃគោរពសិទ្ធិមនុស្ស។

តំណាងពលករខ្មែរម្នាក់ដែលបានចូលរួមតវ៉ានៅទីក្រុងបាងកក លោក ស៊ុម សីហា ប្រាប់អាស៊ីសេរីក្រោយពេលចប់តវ៉ាថា ការតវ៉ានេះមានពលករចម្រុះជាតិសាសន៍ប្រមាណ៨០០នាក់ រួមមានកម្ពុជា ភូមា លាវ និងថៃ ចូលរួមសម្ដែងមតិយ៉ាងពេញលេញ។លោកបន្ថែមថា មូលហេតុដែលចូលរួមតវ៉ានៅមុខទីស្នាក់ការកណ្ដាលប្រចាំតំបន់របស់អង្គការសហប្រជាជាតិ នៅក្រុងបាងកក ដោយសារពួកគេជាពលករចម្រុះជាតិសាសន៍ ហើយនាំគ្នាសម្ដែងមតិដើម្បីឱ្យស្ថាប័ននេះជួយដាក់សម្ពាធដល់រដ្ឋាភិបាលឱ្យគោរពសិទ្ធិការងារ ដើម្បីរក្សាការអនុគ្រោះGSP ទៅលើទំនិញដែលនាំទៅលក់នៅសហរដ្ឋអាមេរិក ប្រមាណ១ពាន់៣០០លានដុល្លារ (១.៣០០) អាមេរិកក្នុងមួយឆ្នាំៗ ដើម្បីឱ្យពួកគេបានធ្វើការងារនៅប្រទេសនេះបន្តទៀត៖ «ប៉ុន្តែបើសិនជារដ្ឋាភិបាលថៃមិនព្រម ស្ដារសិទ្ធិមនុស្សនិងសិទ្ធប្រជាធិបតេយ្យទេ គឺហ្នឹងបន្តដាក់ទណ្ឌកម្មបន្ថែមទៀត អីចឹងហើយ ផលប៉ះពាល់គឺពលករបរទេសមានច្រើនលាននាក់។អីចឹងខ្ញុំជឿថាគេមិនមែនដកកម្មករជនជាតិគេទេ គេប្រាកដជាដកពលករបរទេសហើយ គេមិនសុខចិត្តឱ្យពលរដ្ឋថៃបាត់បង់ការងារទេ។នេះហើយជាបញ្ហាប្រឈម ហើយស្របពេលដែលកម្ពុជាបាត់បង់ EBA និងបាត់បង់ការងារទៀត ហើយ ពលករខ្មែរនៅថៃបាត់បង់ការងារទៀត តើឱ្យពួកគាត់ទៅធ្វើការនៅទីណា?»។ លោកបន្ថែមថា ប៉ូលិសថៃបានសម្រួលឱ្យក្រុមអ្នកតវ៉ា សម្ដែងមតិរហូតដល់ចប់កម្មវិធី ដោយពុំមានការអុកឡុករំខានដល់ពួកគេនោះឡើយ។

ស្រដៀងគ្នានេះដែរ ពលករខ្មែរម្នាក់ទៀត លោក ឆន សុខឿន ថ្លែងថា ពលករទាំងអស់មានសិទ្ធិសម្ដែងមតិពេញលេញ ដោយមិនមានការធ្វើទុក្ខបុកម្នេញពីអាជ្ញាធរឡើយ។ ពលកររូបនេះ បញ្ជាក់ទៀតថា ពួកគេព្រួយបារម្ភខ្លាចអត់ការងារធ្វើនៅពេលសហរដ្ឋអាមេរិកផ្ដាច់ប្រព័ន្ធអនុគ្រោះពន្ធ GSP ពីប្រទេសថៃ នៅថ្ងៃទី២៥ខែមេសាខាងមុខ៖ «គ្រប់ជាតិសាសន៍ទាំងអស់ចូលរួមគឺយើងមានសិទ្ធិពេញលេញបានស្រែកដូចគ្នាទាំងអស់។ថ្ងៃនេះខ្ញុំកាន់ទង់ជាតិខ្មែរនិងបដាផ្សេងៗដែលពាក់ព័ន្ធនឹងការទាមទាររបស់ពលករ។ខ្ញុំមានអារម្មណ៍ថាសប្បាយដែរដែលខ្ញុំរស់នៅប្រទេសគេហើយមានសិទ្ធិតវ៉ាខ្លាំងជាងនៅប្រទេសខ្មែរទៅទៀត ខ្ញុំរំភើបណាស់ដែលឃើញប្រទេសគេមានប្រជាធិបតេយ្យរហូតដល់៩៥ភាគរយបែបនេះ»។ លោកបន្ថែមថា ក្រោយពេលពួកលោកតវ៉ាប្រមាណ ៣ម៉ោង មានតំណាងរដ្ឋាភិបាលថៃម្នាក់ឈ្មោះសុផន អថាវង្ស (Sophorn Athavung) បានឡើងប្រកាសនៅមុខក្រុមពលករដោយយល់ព្រមទទួលសំណើរបស់ក្រុមអ្នកតវ៉ា ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីរបស់ថៃ នៅចុងខែមីនាដើម្បីពិភាក្សា និងសម្រេចជុំវិញការស្នើសុំរបស់ពលករនេះ។

ប្រទេសថៃ នាំទំនិញទៅដាក់លក់នៅសហរដ្ឋអាមេរិក ដោយរួចផុតពីកាតព្វកិច្ចបង់ពន្ធ ក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP របស់អាមេរិក គិតជាទឹកប្រាក់ប្រមាណ១ពាន់៣០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។ សហរដ្ឋអាមេរិកនឹងផ្ដាច់ការអនុគ្រោះពន្ធនេះ ដោយសាររដ្ឋាភិបាលថៃ មិនបានគោរពសិទ្ធិការងារទៅលើពលករបរទេសឱ្យបានត្រឹមត្រូវតាមច្បាប់ ដែលពួកគេកំពុងធ្វើការក្នុងប្រទេសថៃ ជាពិសេសពលករធ្វើការងារនៅលើទូកនេសាទ និងផ្នែកឧស្សាហកម្មអាហារសមុទ្រ ដែលថៃបានចេញច្បាប់ការពារដល់ពួកគេរួចមកនោះ។

ក្រុមអ្នកតវ៉ាទាំងនោះ ជាតំណាងពលករចម្រុះជាតិសាសន៍ប្រចាំនៅតំបន់ឧស្សាហកម្មក្នុងខេត្តជុំវិញទីក្រុងបាងកក ដោយមានជនជាតិថៃ ដែលជាមេសហជីពនាំដឹកនាំតវ៉ា។ ក្រុមពលករបានត្រឡប់ទៅកន្លែងធ្វើវិញ បន្ទាប់ពីតំណាងមន្ត្រីរដ្ឋាភិបាលថៃចុះជួបពួកគេ។ ទោះជាយ៉ាងណាក្រុមអ្នកតវ៉ានឹងប្រមូលគ្នាតវ៉ាជាថ្មីទៀតក្នុងឆាប់ៗ ប្រសិនបើរដ្ឋាភិបាលថៃមិនបានដោះស្រាយតាមការស្នើសុំរបស់ពលករនោះ៕

## លោក Prayut Chan-o-cha កោះហៅការប្រជុំមួយ ដើម្បីពិភាក្សាអំពីវិធីដោះស្រាយ ការវិលត្រឡប់របស់ពលករថៃពីកូរ៉េខាងត្បូងប្រមាណ ១0,000នាក់

https://khmerpress.news/ cily sokMarch 4, 2020 at 11:01 am

លោកនាយករដ្ឋមន្ត្រីថៃ Prayut Chan-o-cha នឹងកោះប្រជុំបន្ទាន់មួយនៅថ្ងៃពុធនេះ ដើម្បីពិភាក្សាអំពីអ្វីដែលត្រូវធ្វើចំពោះពលករថៃខុសច្បាប់ប្រមាណ ១០,០០០នាក់ ដែលលោកជឿថា អាចនឹងព្យាយាមវិលត្រឡប់មកពីប្រទេសកូរ៉េខាងត្បូងវិញ ដើម្បីគេចចេញពីវីរុស COVID-19 នៅទីនោះ។ ការប្រកាសនេះបានធ្វើឡើងបន្ទាប់ពីក្រសួងសុខាភិបាលកាលពីថ្ងៃចន្ទ បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងអំពីវិធីដោះស្រាយ ទាក់ទងនឹងការវិលត្រឡប់របស់ពលករថៃពីប្រទេសកូរ៉េខាងត្បូង បន្ទាប់ពីប្រជាជនថៃចំនួន ១៣៨នាក់ ដែលត្រូវបានបញ្ជូនមកពីក្រុងវូហាន (ចិន) កាលពីខែមុននោះ ត្រូវចំណាយពេលពីរសប្តាហ៍ដើម្បីធ្វើចត្តាឡីស័ក។ លោកឧត្តមសេនីយ៍ Prayut Chan-o-cha បាននិយាយថា ប្រទេសកូរ៉េខាងត្បូងនឹងធ្វើចត្តាឡីស័កលើពលករទាំងនោះរយៈពេល ១៤ថ្ងៃមុនពេលអនុញ្ញាតឱ្យពួកគេវិលត្រឡប់មកប្រទេសថៃវិញ ហើយនៅពេលពួកគេមកដល់ប្រទេសថៃពួកគេអាចរំពឹងថានឹងដាក់នៅដោយឡែករយៈពេល ១៤ថ្ងៃទៀត។ ក្រសួងការបរទេសបាននិយាយថា ការិយាល័យអន្តោប្រវេសន៍កូរ៉េខាងត្បូងបានបញ្ជូនព័ត៌មានថា មានប្រជាជនថៃជាង ៥,០០០នាក់ ចាប់តាំងពីខែធ្នូ ឆ្នាំ២០១៩ ដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០នេះ ដែលមានបំណងវិលត្រឡប់មកផ្ទះវិញ។ លោក Prayut និយាយថា៖ «បញ្ហាគឺថាតើត្រូវគ្រប់គ្រងមនុស្សយ៉ាងច្រើនបែបនេះបែបណា ប្រសិនបើពួកគេទាំងអស់ត្រូវធ្វើចត្តាឡីស័កមុនពេលចូលផ្ទះរៀងខ្លួន។ ដូច្នេះរដ្ឋាភិបាលត្រូវតែរកវិធានការត្រឹមត្រូវ។ ខ្ញុំដឹងថាប្រជាជនមិនមានទំនុកចិត្តនិងភ័យខ្លាច … ប៉ុន្តែមន្ត្រីសុខាភិបាលសាធារណៈ និងបុគ្គលិកពេទ្យគឺបានត្រៀមខ្លួនយ៉ាងល្អ»។ គួរឱ្យដឹងដែរថា ទោះបីជានាយករដ្ឋមន្ត្រីបាននិយាយថា មានចំនួនពលករថៃប្រហែល ១០,០០០នាក់ នៅក្នុងប្រទេសកូរ៉េខាងត្បូងក៏ដោយ ក៏ការប៉ាន់ស្មានមួយចំនួនបានបង្ហាញថា ចំនួនពួកគេគឺខ្ពស់ជាង ១៤,០០០នាក់៕ ប្រភព៖ Khmer Note

## ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២០

## កម្ពុជាបង្កើតសន្ធិសញ្ញាបើកផ្លូវឱ្យមានការផ្ទេរអ្នកទោសទៅវិញទៅមកជាមួយវៀតណាម

http://www.rfi.fr/km/cambodia/ ចុះផ្សាយនៅថ្ងៃ: 04/03/2020 ដោយៈវណ្ណ សុគន្ធា

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាការផ្ទេរអ្នកទោសរវាងកម្ពុជា និងវៀតណាម បានទៅដល់ដៃរដ្ឋសភាជាតិហើយ។ កាលពីថ្ងៃអង្គារ គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភាបានបើកកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ មុនបញ្ជូនទៅកាន់គណៈកម្មាធិការអចិន្ត្រៃយ៍ដើម្បីលើកទៅប្រជុំសភាពេញអង្គនាពេលខាងមុខ។ បើតាមរដ្ឋសភាកម្ពុជា សន្ធិសញ្ញាថ្មីនេះគឺអាចឱ្យកម្ពុជាមានសិទ្ធិស្នើសុំអ្នកទោសដែលជាជនជាតិខ្មែរហើយជាប់ទោសនៅវៀតណាមមកអនុវត្តទោសបន្តនៅកម្ពុជាវិញ។

លោកឡេង ប៉េងឡុង អគ្គលេខាធិការ និង ជាអ្នកនាំពាក្យរដ្ឋសភាជាតិកម្ពុជា បានពន្យល់ពីសារៈសំខាន់នៃសន្ធិសញ្ញាថ្មីនេះថា ប្រសិនបើជនជាតិកម្ពុជាណាម្នាក់បានប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសវៀតណាម ហើយត្រូវបានវៀតណាមកាត់ទោសតាមច្បាប់នោះ គឺកម្ពុជាអាចស្នើសុំផ្ទេរអ្នកទោសនោះពីវៀត

ណាមមកអនុវត្តទោសបន្តនៅប្រទេសកម្ពុជាវិញបានតាមរយៈសន្ធិសញ្ញាផ្ទេរអ្នកទោសរវាងកម្ពុជា និងវៀតណាមនេះ។ លោកថា សន្ធិសញ្ញានេះ គឺនឹងជួយការពារសិទ្ធិអ្នកទោសដែលជាជនជាតិខ្មែរ។

បើតាមលោកឡេង ប៉េងឡុង អ្នកទោសជាជនជាតិខ្មែរដែលជាប់ទោសនៅប្រទេសវៀតណាមអាចជួបការលំបាកច្រើន ទាំងការមិនចេះភាសាវៀតណាម ស្ថានភាពស្នាក់នៅ ហើយបងប្អូនសាច់ញាតិក៏ពិបាកក្នុងការទៅសួរសុខទុក្ខទៀត។ ដូច្នេះហើយ លោកសង្កត់ធ្ងន់ថា តាមរយៈសន្ធិសញ្ញាថ្មីនេះ គឺអ្នកទោសខ្មែរអាចយកមកកម្ពុជាវិញបានដែលផ្តល់ភាពងាយដល់ពួកគេ។ ចំពោះភាពខុសគ្នានៃទំហំដាក់ទោសទណ្ឌរវាងកម្ពុជា និងវៀតណាម តួយ៉ាង វៀតណាមមានទោសប្រហារជីវិត ឯកម្ពុជាមានត្រឹមទោសដាក់ពន្ធនាគារអស់ជីវិតនោះ អ្នកនាំពាក្យរដ្ឋសភាបានអះអាងថា បញ្ហានេះ រដ្ឋាភិបាលកម្ពុជា និងវៀតណាមនឹងពិភាក្សា និងសម្របសម្រួលគ្នាបន្ថែមទៀត។

សូមជម្រាបជូនថា សន្ធិសញ្ញាផ្ទេរអ្នកទោសនេះ គឺកម្ពុជាធ្វើជាលើកទី១ហើយជាមួយនឹងប្រទេសវៀតណាម។ វៀតណាម ក៏ដូចជាថៃ និង ប្រទេសឡាវជាដើម គឺមានតែបត្យាប័នជាមួយគ្នាតែប៉ុណ្ណោះ។ លោកជិន ម៉ាលីន រដ្ឋលេខាធិការ និង ជាអ្នកនាំពាក្យក្រសួងយុត្តិធម៌កម្ពុជា បានគូសបញ្ជាក់ថា សន្ធិសញ្ញាផ្ទេរអ្នកទោស និងបត្យាប័ន គឺមានភាពខុសគ្នា។ ខុសគ្នានៅត្រង់ថា បត្យាប័ន គឺជាកិច្ចសហការចាប់បញ្ជូនជនល្មើសទៅកាត់ទោសនៅក្នុងប្រទេសដែលបានស្នើសុំ។

ចំណែក សន្ធិសញ្ញាស្តីពីការផ្ទេរអ្នកទោសនេះវិញ គឺអនុវត្តទៅលើអ្នកដែលត្រូវបានកាត់ទោសជាស្ថាពរ ហើយកំពុងអនុវត្តទោស។ ដូច្នេះហើយ កម្ពុជាអាចស្នើសុំផ្ទេរអ្នកទោសនោះ មកអនុវត្តទោសបន្តនៅក្នុងប្រទេសកំណើតវិញបាន ហើយវៀតណាមក៏អាចធ្វើបានដូចគ្នានេះដែរជាមួយកម្ពុជា។ បើតាមលោកជិន ម៉ាលីន ក្រៅពីប្រទេសវៀតណាមនេះ កម្ពុជាក៏គ្រោងនឹងធ្វើសន្ធិសញ្ញាផ្ទេរអ្នកទោសនេះជាមួយបណ្តាប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ផងដែរ៕

## កិច្ចប្រជុំពិភាក្សាលើការផ្លាស់ប្តូរបទពិសោធន៍ និងពិគ្រោះយោបល់រកពីចំណុចខ្លាំង និងចំនុចខ្សោយ

http://cambodiapolice.com/policekh/ 10:31 am 5 មីនា 2020

មណ្ឌលគិរី ៖ នៅសាលប្រជុំស្នងការដ្ឋាន នគរបាល ខេត្តមណ្ឌលគិរី បានរៀបចំបើកកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់រកពីចំនុចខ្លាំង និងចំនុច ខ្សោយ ក្នុងកិច្ចប្រជុំជាមួយអង្គការការពារសិទ្ធិមនុស្សកម្ពុជាហៅកាត ( c.p.u )កាលពីព្រឹកថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ នាវេលាម៉ោង៩និង០០នាទី ។

កិច្ចប្រជុំនេះ បានធ្វើឡើង ក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ទោ ទិត្យ ប៉ុណា អនុប្រធាននាយកដ្ឋានបច្ចេកទេស និងវិទ្យាសាស្ត្រក្រសួងមហាផ្ទៃ និងក្រុមការងាររួមដំណើរចំនួន៥នាក់ និងស្ត្រីចំនួន១នាក់ ព្រមទាំងលោក ថែម បេក ខេម នាយកប្រត្តិបត្រ នៃអង្គភាពអង្ការការពារកុមារហៅតាត់ (c.p.u) លោកស្រីឧត្តមសេនីយ៍ត្រី ហ៊ួន គឹមហេង ស្នងការរងទទួលផែនការងារការពារការជួញដូរមនុស្សនិងការពារអនីតិជន ព្រមទាំងលោកវរសេនីយ៍ឯក នន់ សុវណ្ណារ៉ា នាយការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារនីតិជន និងមន្ត្រីជំនាញក្រោមឱវាទ ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះសរុបចំនួន៧ រូបដែលបានចូលរួម។

ទន្ទឹមគ្នាក្នុងឱកាសនោះផងដែរ លោកស្រីឧត្តមសេនីយ៍ទោ ហ៊ួន គឹមហេង ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ស្នងការដ្ឋាននគរបាលខេត្តបានមានមតិស្វាគមន៍ចំពោះគណៈប្រតិភូនិងបានលើកឡើងលើនៅចំណុចការងារមួយចំនួន ដែលសំរេចបាននិងចំណុចមួយដែលមានភាពចន្លោះខ្វះខាតដែលនឹងយកទៅអនុវត្តន៍នាពេលខាងមុខ។

បន្ទាប់មកឯកឧត្តម ឧត្តមសេនីយ៍ទោ ទិត្យ ប៉ុណា អនុប្រធាននាយកដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រក្រសួងមហាផ្ទៃ បានសំដែងនៅការកោតសរសើរដល់កម្លាំងនគរបាលដែលបានខិតខំក្នុងការប្រឆាំងការងារជួញដូរមនុស្ស និងការពារអនីតិជនបានល្អប្រសើរគួរជាទីមោទនៈ៕

## ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០២០

## អនុវត្តនូវ ចំណុចសំខាន់ៗ ចំនួន៧ ជួយលើកកម្ពស់សិទ្ធិ សេរីភាព របស់ស្ត្រី

http://www.cen.com.kh/ March 6, 2020

ភ្នំពេញ៖ សម្តេចតេជោនាយករដ្ឋមន្ត្រី បានអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងជនរួមជាតិទាំងអស់ អនុវត្តនូវចំណុចសំខាន់ៗ ចំនួន៧ ដែលបង្ហាញឱ្យឃើញ ពីការដើរតួនាទីយ៉ាងសំខាន់ របស់សុខសន្តិភាព នៅក្នុងសង្គមជាតិ ជាពិសេសសុខសន្តិភាពនេះ បានចូលរួមចំណែក ជួយដល់ការលើកកម្ពស់ សិទ្ធិសេរីភាពរបស់ស្ត្រី ។ នៅព្រឹកថ្ងៃសុក្រ ទី៦ ខែមីនា ឆ្នាំ២០២០នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីអបអរសាទរ ទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី១០៩ ឆ្នាំ២០២០ នៅមជ្ឈមណ្ឌលកោះពេជ្រ ក្រោមប្រធានបទ មានសន្តិភាព មានការលើកកម្ពស់ មានសមភាពយេនឌ័រ ដែលបង្ហាញឱ្យឃើញ ពីការដើរតួនាទី យ៉ាងសំខាន់ របស់សុខសន្តិភាព នៅក្នុងសង្គមជាតិ ជាពិសេសសុខសន្តិភាពនេះ បានចូលរួមចំណែក ជួយដល់ការលើកកម្ពស់សិទ្ធិ សេរីភាព របស់ស្ត្រី និងជួយឱ្យស្ត្រី មានតម្លៃកាន់តែខ្ពស់ឡើង នៅក្នុងសង្គម។

សម្តេចតេជោ នាយករដ្ឋមន្ត្រី បានថ្លែងអំណរព្រះគុណ និងថ្វាយព្រះពរជ័យសិរីមង្គល សម្តេចព្រះវររាជមាតាជាតិខ្មែរ និងព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គទាំងទ្វេ តែងតែយកព្រះទ័យ ទុក្ខដាក់អំពីសុខទុក្ខ នឹងជីវភាពរបស់កូនចៅ ពិសេសការលើកកម្ពស់ សមភាពយែនឌ័រ របស់ស្ត្រី និងក្មេងស្រីកម្ពុជា។ សម្តេចតេជោ នាយករដ្ឋមន្ត្រី បានកោតសរសើរ ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី ក្រសួងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិទាំងអស់ ដែលបានរួមចំណែក គាំទ្រការលើកម្ពស់ស្ថានភាព ជីវភាព សិទ្ធិ ឋានៈតួនាទី សុខុមាលភាព ស្ត្រី និងកុមារ និងការផ្តល់សេវាកម្ម ជួយជនរងគ្រោះ ដោយអំពើហឹង្សា ប្រកដោយគុណភាព និងប្រសិទ្ធភាព ។ សម្តេចតេជោ នាយករដ្ឋមន្ត្រី បានអំពាវនាវ ដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងជនរួមជាតិទាំងអស់ អនុវត្តនូវចំណុចសំខាន់ៗ ចំនួន៧ ដូចខាងក្រោម៖

១)ត្រូវរួមគ្នាយកចិត្តទុកដាក់ តាមរយៈការផ្តល់អាទិភាព ចំពោះការបង្កើនចំនួនស្ត្រី ដែលមានតួនាទីជាថ្នាក់ដឹកនាំ នៅតាមវិស័យផ្សេងៗ និងគ្រប់កម្រិត។

២)ត្រូវរួមគ្នាពង្រឹងការអនុវត្តច្បាប់ និងត្រូវពន្លឿនដំណើរការកាត់ក្តីស្ត្រី ដែលជាប់ទោសឱ្យទាន់ពេលវេលា គ្រប់គ្រងការ ប្រើប្រាស់ប្រព័ន្ធ Internet នៅទូទាំងប្រទេស ឱ្យមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់បញ្ហាជាច្រើន ដែលពាក់ព័ន្ធទៅនឹងអំពើហិង្សា ការកេងប្រវ័ញ្ចលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធ Internet និងបណ្តាញផ្សព្វផ្សាយ ជាច្រើនដែល ធ្វើឲ្យបាត់សណ្តាប់ធ្នាប់សង្គម។

៣)ក្រសួងអប់រំយុវជន និងកីឡា ត្រូវធ្វើការណែនាំ ដល់គ្រប់ក្រសួងស្ថាប័ន ទាំងអស់ឱ្យអនុវត្តវិន័យ ផ្តល់ឱកាសដល់ ក្មេងស្រីនៅគ្រប់កម្រិត ជាពិសេសឪពុកម្តាយអប់រំ កូនចៅឲ្យមានសីលធម៌ល្អ នៅក្នុងសង្គម។

៤)ត្រូវបន្តការវិយោគ លើការសិក្សា របស់ក្មេងស្រី នៅគ្រប់កម្រិតសិក្សា ជាពិសេស ក្នុងជំនាញវិទ្យាសាស្ត្របច្ចេកវិទ្យា ដើម្បីអោយដើរ ទាន់សម័យបច្ចេកវិទ្យា ជឿនលឿន នៃសង្គមជាតិ។

៥)ក្រសួងវប្បធម៌ ក្រសួងព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយ ទាំងអស់ត្រូវបន្តពង្រឹង និងលើកកម្ពស់ សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរយើង តាមរយៈការបង្កើត កម្មវិធីអប់រំ ដែលបង្ហាញអំពី អត្តសញ្ញាណស្ត្រីខ្មែរ ជាពិសេសតាមរយៈការស្លៀកពាក់ ប្រកបដោយភាពថ្លៃថ្នូរ និងមានលក្ខណៈជាស្ត្រីខ្មែរ។

៦)រួមគ្នាទប់ស្កាត់ ការចម្លងមេរោគអេដស៍ថ្មី និងកុំឲ្យមានការរើសអើងស្ត្រី ផ្សព្វផ្សាយស្រាបៀរ រួមទាំងអ្នកស្រឡាញ់ភេទដូចគ្នា។

៧)សម្ដេចតេជោ បន្តអំពាវនាវ ដល់ប្រជាពលរដ្ឋ ទាក់ទងទៅនឹងជំងឺកូវីដ១៩ ទោះបីជាប្រទេសកម្ពុជា មិនមានជំងឺនេះក៏ដោយ ក៏បងប្អូនប្រជាពលរដ្ឋ ត្រូវតែចូលរួមថែរក្សា សុខភាពឲ្យបានល្អប្រសើរតាមរយៈការធ្វើអនាម័យ តាមការណែនាំ របស់ក្រសួងសុខាភិបាល។ ជម្រើសនៃការភ័យខ្លាច មិនមែនជាជម្រើសល្អនោះទេ ផ្ទុយទៅវិញ ការថែរក្សាសុខភាព គឺជាជម្រើសដ៏ល្អ ដើម្បីទប់ស្កាត់នៃជំងឺនេះ៕ដោយៈកូឡាប

## នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចុះបង្ក្រាប់ ហាងម៉ាស្សា King Sora MASSAGE ឃាត់ខ្លួនស្រី-ប្រុស ជាជនជាតិវៀតណាមចំនួន២២នាក់ ពាក់ព័ន្ធករណី បំរើផ្លូវភេទ

http://nokorwatnews.com/ 05-03-2020

ភ្នំពេញ៖ កម្លាំងនគរបាលនាយដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ បានចុះបង្ក្រាប់និងឃាត់ខ្លួននារីរងគ្រោះចំនួន១២នាក់ជាជនជាតិវៀតណាម និងស្រីប្រុសមេការ៥នាក់ និងសន្តិសុខ៥នាក់ផងដែរ នៅហាងម៉ាស្សា King Sora MASSAGE បង្កប់បំរើសេវាផ្លូវភេទ ក្នុងនោះក៏មានការសម្របសម្រួលពី លោក ឆាយ ហុងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ មានការដឹកនាំ ចុះធ្វើការបង្ក្រាប់ ជាក់ស្តែង ដោយលោក វរសេនីយឯក សំបូរ ម៉ាន់ណារិទ្ធ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃអគ្គស្នងការនគរបាលជាតិ។ ប្រតិបត្តិការណ៍ឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង៣រសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០ ទីតាំងផ្ទះលេខ៥១B តាមបណ្ដោយផ្លូវលេខ៣៥០ នៅ ហាងម៉ាស្សា King Sora MASSAGE ក្នុងសង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

តាមប្រភពព័ត៌មានពីនគរបាលបានអោយដឹងទៀតថា នៅមុនពេលឈានដល់ការចុះបង្ក្រាប់នៅទីតាំងនេះ កម្លាំងនគរបាលជំនាញ បានធ្វើការស្រាវជ្រាវ ឃើញថាទីតាំងខាងលើនេះ បើកហាងម៉ាស្សា កោសជប់ មានបង្កប់បំរើសេវាផ្លូវភេទ ឃាត់ខ្លួននិងមនុស្សប្រុសស្រីជា មេការ៥នាក់ និងសន្តិសុខ៥នាក់ទៀតរួមនិង នារីរងគ្រោះចំនួន១២នាក់ ជាជនជាតិវៀតណាម បំរើសេវាផ្លូវភេទ និងដកហូតបានវត្ថុតាងស្រោមអនាម័យ ok មួយចំនួនធំ។

តាមប្រភពព័ត៌មានពីជនរងគ្រោះបានអោយដឹងថា ជារៀងរាល់ថ្ងៃទីតាំងហាងបានបើករកស៊ី២៤ម៉ោង ដោយភ្ញៀវខ្លះចូលមកម៉ាស្សានិងភ្ញៀវខ្លះចូលមករួមភេទម្តង។ សូមបញ្ជាក់ផងដែរក្រោយចប់ប្រតិបត្តិការ ទីតាំងខាងលើនេះត្រូវបានខ្ទមបេបិទជាបណ្ដោះអាសន្ន ដើម្បីរងចាំគោលការជាថ្មីចំពោះទីតាំងខាងលើនេះ។

បច្ចុប្បន្ន មនុស្សប្រុសស្រីជាមេការ៥នាក់ និងសន្តិសុខ៥នាក់ទៀតរួមនិង នារីរងគ្រោះចំនួន១២នាក់ជាជនជាតិវៀតណាម ត្រូវនគរបាលនាំមក នាយដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ សាកសួនិងឃុំខ្លួនបណ្ដោះអាសន្នដើម្បីចាត់ការតាមនីតិវិធី។ ស រស្មី

## ឃាត់ខ្លួនបុរសម្នាក់ ពាក់ព័ន្ធករណីចែកចាយរូបភាពនិងវីដេអូអាសអាភាសក្នុងបណ្ដាញសង្គម

http://kleykley.sabay.com.kh/ 05-03-2020 ម៉ោង 14:42

- ដោយការចង្អុលបង្ហាញពីលោកនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បានបើកការស្រាវជ្រាវ និងស៊ើបអង្កេតរហូតដល់មានការឃាត់ខ្លួន

បុរសម្នាក់ ក្រោមការដឹកនាំបញ្ជាផ្ទាល់ពី ឧត្តមសេនីយ៍ឯក ជា ពៅ ប្រធាននាយកដ្ឋាន ព្រមទាំងមានការសម្របសម្រួលពី លោក កែវ សុជា ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- ជនសង្ស័យឈ្មោះ យល់ ដារ៉ា ភេទប្រុស អាយុ ១៨ឆ្នាំ បានសារភាពថា កាលពីដើមខែ មករា ឆ្នាំ ២០២០ ខ្លួនពិតជាបានចាប់ផ្តើមបង្កើតគណនីហ្វេសប៊ុក និង Telegram ក្លែងក្លាយដើម្បីធ្វើសកម្មភាពផលិតរក្សាទុកនិងចែកចាយ រូបភាពនិង វីដេអូអាសអាភាសកុមារ នារីខ្មែរនិងបរទេស ធ្វើអាជីវកម្ម នៅក្នុងបណ្តាញសង្គមហ្វេសប៊ុក និងបណ្តាញទំនាក់ទំនង Telegram ក្នុងគោលបំណងរកប្រាក់ចំនូលពីការទាញយកអ្នកទស្សនានិង លក់វីដេអូទាំងនោះ ហើយប្រភពវីដេអូទាំងនោះខ្លួនបានទាញយកពីបណ្តាញសង្គមផ្សេងៗ។បច្ចុប្បន្នជនសង្ស័យត្រូវបានបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីចាត់វិធានការតាមផ្លូវច្បាប់។
- គួរបញ្ជាក់ថាបច្ចុប្បន្ននេះ មានជនឆ្លៀតឱកាសបង្កើត Group Chat និង Channel Telegram ដើម្បីចែកចាយ រូបភាពអាសអាភាស និងមានពេលខ្លះមានរូបអាសអាភាសកុមារ ដែលជាអំពើល្មើសច្បាប់យ៉ាងធ្ងន់ធ្ងរ។ លោក ឧត្តមសេនីយ៍ឯក ជា ពៅ ប្រធាននាយកដ្ឋាន បានព្រមាននឹងចាត់វិធានការបន្តទៀតចំពោះករណីល្មើសខាងលើនេះ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ពីសមត្ថកិច្ចថៃចំនួន ០១ នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 05-03-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៧និង៤០នាទី ថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃចំនួន ០១ នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរមាន ឈ្មោះ ញ៉ញ ឡេន ភេទស្រី អាយុ ៣៨ឆ្នាំ ទីលំនៅបច្ចុប្បន្នស្ថិតក្នុងភូមិអូល ឃុំត្រពាំងរាំង ស្រុកជំគិរី ខេត្តកំពត និងបានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## កម្ពុជាឡាវ បន្តថែរក្សា សន្តិសុខ សណ្តាប់ធ្នាប់ តាមព្រំដែន និងការបង្កាទប់ស្កាត់ បង្ក្រាបបទល្មើសឆ្លងដែន

http://www.cen.com.kh/ March 6, 2020

ឡាវ៖ ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងមហាផ្ទៃកម្ពុជានិងក្រសួងសន្តិសុខសាធារណៈឡាវបន្តពង្រឹងលើវិស័យសន្តិសុខ តាមរយៈការផ្លាស់ប្តូរបទពិសោធន៍ និងការចែករំលែកព័ត៌មាន សំដៅគ្រប់គ្រងការចេញចូលឆ្លងកាត់ព្រំដែន ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ តាមព្រំដែន និងការបង្កាទប់ស្កាត់ បង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ។

នៅរសៀលថ្ងៃព្រហស្បតិ៍ ទី៥ ខែមីនា ឆ្នាំ២០២០នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូ ជាន់ខ្ពស់ក្រសួងមហាផ្ទៃ អញ្ជើញដល់ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ ការអញ្ជើញដល់របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី ព្រមទាំងគណៈប្រតិភូ អមដំណើរនាឱកាសនោះ ត្រូវបានទទួលបដិសណ្ឋារកិច្ច និងស្វាគមន៍ ពីសំណាក់លោកឧត្តមសេនីយ៍ឯក វិល័យ ឡាខាំហ្វង រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈឡាវ ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ និងមានរៀបចំពិធីត្រួតពល កងកិត្តិយស នៃក្រសួងសន្តិសុខសាធារណៈឡាវ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងលោកឧត្តមសេនីយ៍ឯក វិល័យ ឡាខាំហ្វង បានអញ្ជើញជួបពិភាក្សា ផ្លាស់ប្តូរយោបល់គ្នា អំពីសភាពសន្តិសុខ នយោបាយ និងសេដ្ឋកិច្ច ការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុស

ច្បាប់ ការផ្លាស់ប្តូរគណៈប្រតិភូ និងបណ្តុះបណ្តាលធនធានមនុស្ស ការងារឃុំខ្លួនអ្នកទោស ព្រមទាំងកិច្ចការសំខាន់ៗមួយចំនួនទៀត ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ទៅវិញទៅមកនៃប្រទេសទាំងពីរ។

បន្ទាប់មកសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងលោកឧត្តមសេនីយ៍ឯក វិល័យ ឡាខាំហ្វង បានអញ្ជើញធ្វើជាសហប្រធាន ដឹកនាំកិច្ចប្រជុំវាយតម្លៃលទ្ធផល កិច្ចសហប្រតិបត្តិការឆ្នាំ២០១៩ និងចុះហត្ថលេខា លើកំណត់ហេតុ នៃសហប្រតិបត្តិការឆ្នាំ២០២០ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ។ កិច្ចប្រជុំដែលក្រសួងទាំងពីរ ផ្លាស់វេនគ្នារៀបចំជារៀងរាល់ឆ្នាំនេះ គឺដើម្បីអនុវត្តនូវយន្តការ សហប្រតិបត្តិការទ្វេភាគីប្រចាំឆ្នាំ ក្នុងគោលដៅលើកកម្ពស់ ការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ អភិវឌ្ឍរវាងខេត្តជាប់ព្រំដែន នៃប្រទេសទាំងពីរ ព្រមទាំងដើម្បីពង្រឹង កិច្ចសហប្រតិបត្តិការ ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៃប្រទេសទាំងពីរ។

សម្តេចក្រឡាហោម ស ខេង និងលោកឧត្តមសេនីយ៍ឯក វិល័យ ឡាខាំហ្វង នៅតែបន្តចាត់ទុក កិច្ចសហប្រតិបត្តិការ រវាងក្រសួងទាំងពីរ ថាជាកិច្ចការមួយដ៏មានសារសំខាន់ ក្នុងវិស័យសន្តិសុខ តាមរយៈការផ្លាស់ប្តូរបទពិសោធន៍ និងការចែករំលែកព័ត៌មាន សំដៅគ្រប់គ្រងការចេញចូល ឆ្លងកាត់ព្រំដែន ការថែរក្សា សន្តិសុខសណ្តាប់ធ្នាប់ តាមព្រំដែន និងការបង្កាទប់ស្កាត់ បង្ក្រាបបទល្មើសឆ្លងដែន គ្រប់ប្រភេទ។

ភាគីទាំងពីរក៏បានបង្ហាញការជឿជាក់ថា កំណត់ហេតុកិច្ចសហប្រតិបត្តិការ ឆ្នាំ២០២០ នឹងបន្តក្លាយជាឯកសារ តម្រង់ទិសសម្រាប់អាជ្ញាធរ ខេត្តជាប់ព្រំដែន និងបណ្តាអង្គភាព ពាក់ព័ន្ធចំណុះក្រសួងទាំងពីរ យកទៅអនុវត្តប្រកប ដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការលើកកម្ពស់ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការថែរក្សាសន្តិសុខ ស្ថិរភាពតំបន់ព្រំដែន ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីលើកកម្ពស់ជីវភាពប្រជាជនតាមបណ្តោយព្រំដែន។

នៅក្នុងឱកាសនោះដែរ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញលោកឧត្តមសេនីយ៍ វិល័យ ឡាខាំហ្វង ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ក្រសួងសន្តិសុខសាធារណៈឡាវ បំពេញទស្សនកិច្ច ចូលរួមកិច្ចប្រជុំពិនិត្យ វាយតម្លៃលទ្ធផល កិច្ចសហប្រតិបត្តិការឆ្នាំ២០២០ និងចុះហត្ថលេខាលើកំណត់ហេតុកិច្ចសហប្រតិបត្តិការ ឆ្នាំ២០២១ ក្នុងពេលវេលាសមស្រប ហើយជាការឆ្លើតតប លោកឧត្តមសេនីយ៍ឯក ក៏បានទទួលការអញ្ជើញនេះ ដោយក្តីរីករាយបំផុត ៕ដោយៈកូឡាប

## ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២០

### លោក ហ៊ុន សែន បង្កើនថវិកា៥០០លានរៀល ឱ្យក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ដើម្បីផ្តល់សេវាយុត្តិធម៌ដល់ស្ត្រី និងក្មេងស្រីរងគ្រោះ

https://www.rfa.org/khmer/ ដោយ ហេង រស្មី 2020-03-06

រដ្ឋាភិបាលកម្ពុជា បង្កើនថវិកាប្រមាណ៥០០លានរៀលក្នុង១ឆ្នាំ ដល់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ក្នុងគោលដៅជួយដល់ស្ត្រី និងក្មេងស្រីរងគ្រោះ ឱ្យអាចស្វែងរកសេវាយុត្តិធម៌ តាមរយៈក្រុមមេធាវីរបស់រដ្ឋាភិបាល។ សង្គមស៊ីវិល រំពឹងការបែងចែង និងប្រើប្រាស់ថវិកាប្រព្រឹត្តត្រឹមត្រូវចំទិសដៅ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា ដំណើរការរឿងក្តីលើស្ត្រីជាប់ពន្ធនាគារ ត្រូវតែពន្លឿនឱ្យទាន់ពេលវេលា។ លោកបន្តថា រដ្ឋាភិបាល សម្រេចដំឡើងថវិកាជាតិប្រមាណ៥០០លានរៀល ឬប្រមាណ១២ម៉ឺន៥ពាន់ដុល្លារ ក្នុងមួយឆ្នាំ ឱ្យទៅក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ក្នុងកិច្ចការផ្តល់សេវាផ្នែកច្បាប់ និងការស្វែងរកយុត្តិធម៌ដល់ស្ត្រីក្រីក្រ និងក្មេងស្រីរងគ្រោះពីអំពើហិង្សា ដែលគ្មានលទ្ធភាពរកមេធាវី ការពាររឿងក្តីរបស់ខ្លួនបាន។ លោកបញ្ជាក់ថា ក្រុមមេធាវីរបស់រដ្ឋាភិបាល គឺជាដៃគូធ្វើការជាមួយក្រុមប្រឹក្សាជាតិដើម្បីស្ត្រីក្នុងកិច្ចការងារនេះ។

ការថ្លែងដូច្នេះធ្វើឡើង នៅព្រឹកថ្ងៃទី៦ ខែមីនា ក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី១០៩ នៅមជ្ឈមណ្ឌលកោះពេជ្រ ក្រោមប្រធានបទ «មានសន្តិភាព មានការលើកកម្ពស់ មានសមភាពយេនឌ័រ» ៖ រាជរដ្ឋាភិបាលបានបង្កើតច្បាប់ គោលនយោបាយ ផែនការសកម្មភាពជាតិ ការផ្តល់សេវាជាពហុវិស័យ និងវិធានការជាច្រើនទៀត ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធជាច្រើន រួមទាំងអង្គការសង្គមស៊ីវិល ដើម្បីជួយជនរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានបង្កើតថវិកាជូនដល់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រីចំនួន៥០០លានរៀល ក្នុងមួយឆ្នាំ ដើម្បីជួយដល់ស្ត្រី និងក្មេងស្រីរងគ្រោះ ក្នុងការស្វែងរកសេវាយុត្តិធម៌។ ក្រៅពីនេះ លោក ហ៊ុន សែន ក៏តម្រូវឱ្យក្រសួងពាក់ព័ន្ធទាំងអស់ អនុវត្តច្បាប់ឱ្យបានម៉ត់ចត់ ក្នុងការគ្រប់គ្រងនិងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេត Internet នៅទូទាំងប្រទេស ឱ្យមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់បញ្ហានានា ទាក់ទងនឹងអំពើហិង្សា ការកេងប្រវ័ញ្ចលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធ Internet និងបណ្តាញផ្សព្វផ្សាយជាច្រើនដែលធ្វើឱ្យបាត់សណ្តាប់ធ្នាប់សង្គម។

អនុប្រធានការពារផ្លូវច្បាប់នៃក្រសួងកិច្ចការនារី អ្នកស្រី ស ស៊ីណែត ប្រាប់អាស៊ីសេរីថា ថវិកាសរុប៥០០លានរៀលនេះ ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី នឹងបែកចែកទៅថ្នាក់ក្រោមជាតិ តាមរយៈមន្ទីរកិច្ចការនារី ដើម្បីផ្តល់សេវាគាំពារផ្នែកច្បាប់ដល់ជនរងគ្រោះ ក្នុងអំពើហិង្សា ទាក់ទងនឹងយេនឌ័រ៖ លុយ៥០០លាននេះ យើងជួយទៅលើសេវាសម្រាប់ជួយជនរងគ្រោះ ក្នុងការធ្វើដំណើរ ថ្លៃហូបចុក ឬទាក់ទងនឹងកិច្ចអន្តរាគមន៍របស់អ្នកផ្តល់សេវាចុះទៅ។ មួយវិញទៀត យើងយកលុយមួយចំណែកក្នុងលុយ៥០០លានរៀលនេះ ដើម្បីទៅធ្វើសហការជាមួយមេធាវី ដើម្បីឱ្យមេធាវីគាត់ដំណើរការនីតិវិធី តាំងពីចាប់ផ្តើមករណីរហូតដល់បញ្ចប់ករណី។ អ្នកស្រី ស ស៊ីណែត ឱ្យដឹងទៀតថា ការផ្តល់សេវាដល់ជនរងគ្រោះជាស្ត្រី និងក្មេងស្រី គឺមានពីរករណី។ ករណីទី១ គឺ ជនរងគ្រោះអាចមកស្វែងរកតម្រូវការរបស់ខ្លួន ដូចជាការប្រឹក្សាយោបល់ ផ្លូវចិត្ត ឬស្នើសុំជំនួយផ្នែកច្បាប់ ពីក្រសួងកិច្ចការនារីដោយផ្ទាល់ នោះក្រសួងនឹងរៀបចំជូន។ អ្នកស្រីបន្តថា ចំពោះករណីទី២ ប្រសិនបើក្រសួងកិច្ចការនារី មិនអាចផ្តល់សេវាទៅតាមតម្រូវការរបស់ជនរងគ្រោះទេ នោះក្រសួងនឹងរៀបចំសម្របសម្រួល ហើយបញ្ជូនជនរងគ្រោះទៅរកសេវាចាំបាច់នៅក្នុងមូលដ្ឋានរបស់ពួកគេ៖ «ទន្ទឹមហ្នឹង កិច្ចការនារី ក៏មិនធ្វើការម្នាក់ឯងទេ នៅពេលដែលយើងចុះទៅជួយអន្តរាគមន៍ ឬក៏ផ្តល់សេវាដល់ជនរងគ្រោះ គឺយើងមានការសហការយ៉ាងជិតស្និតជាមួយសមត្ថកិច្ចដែលនៅជិតនោះ។ បើករណីហ្នឹង ចូលជាករណីបទល្មើសព្រហ្មទណ្ឌ បើកិច្ចការនារីទទួលករណីហ្នឹងមុន គឺកិច្ចការនារីត្រូវបញ្ជូនទៅសមត្ថកិច្ច ភ្លាម ដើម្បីធ្វើពាក្យបណ្តឹង ឱ្យសមត្ថកិច្ចធ្វើការជាមួយជនរងគ្រោះ ដើម្បីធ្វើនីតិវិធី ស្វែងរក និងចាប់ជនល្មើស។ បន្ទាប់មកកិច្ចការនារី មានការសម្របសម្រួលក្នុងការរកសេវាពាក់ព័ន្ធមួយចំនួនទៀត ដែលជាតម្រូវការរបស់ជនរងគ្រោះ»។

នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្សលីកាដូ លោក អំ សំអាត លើកឡើងថា ស្ត្រីរងគ្រោះអំពើហិង្សាក្នុងគ្រួសារ កុមារីរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ រួមទាំងស្ត្រីពពោះ ស្ត្រីមានកូនតូច និងអនីតិជនដែលជាស្ត្រី ជាប់នៅក្នុងពន្ធនាគារ គឺពួកគាត់មិនមានលទ្ធភាពទៅរកមេធាវី ជួយការពាររឿងក្តីបានទេ។ លោកបន្តថា បើរដ្ឋាភិបាលប្រើប្រាស់ថវិកាប្រមាណ៥០០លានរៀលនេះ ប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាព នោះពិតជាអាចជួយក្រុមស្ត្រីរងគ្រោះទាំងនោះបាន។ ដើម្បីលើកស្ទួយនិងគាំទ្រទៅដល់ស្ត្រីនិងកុមារីរងគ្រោះដោយអំពើហិង្សានេះ លោក អំ សំអាត ក៏ស្នើដល់រដ្ឋាភិបាលធ្វើយ៉ាងណា ការពង្រឹង និងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ជាពិសេសនោះ គឺការកែទម្រង់ប្រព័ន្ធតុលាការ ឱ្យឈរលើគោលការណ៍ឯករាជភាព ដើម្បីផ្តល់យុត្តិធម៌ពេញលេញដល់ជនរងគ្រោះ៖ «យើងគាំទ្រហើយបន្ថែមថវិកា ដើម្បីគាំទ្រ និងការពារទៅស្ត្រី និងកុមារីរងគ្រោះ ក៏ប៉ុន្តែធ្វើយ៉ាងសុំឱ្យការអនុវត្តឱ្យមានប្រសិទ្ធភាព ហើយគ្រប់ស្ថាប័នទាំងអស់ត្រូវចូលរួមផងដែរ រួមទាំងបញ្ហាសំខាន់ គឺតុលាការតែម្តង»។

ប្រទេសកម្ពុជា បានបង្កើតបទដ្ឋានច្បាប់មួយចំនួន ដែលជានាការពារទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារី ដើម្បីឱ្យស្របតាមបទដ្ឋានច្បាប់អន្តរជាតិ ដែលរដ្ឋាភិបាលបានផ្តល់សច្ចាប័ន។ ក្នុងនោះរួមមានច្បាប់ប្រឆាំង ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ទប់ស្កាត់អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ច្បាប់គ្រប់គ្រងទឹកអាស៊ីដផែនការជាតិលើកទី២ទប់ស្កាត់អំពើហិង្សាលើស្ត្រីរួមនឹងបទដ្ឋានពាក់ព័ន្ធមួយចំនួនទៀត។ ទោះជាយ៉ាងនេះក្តី អ្នកឃ្លាំមើលសិទ្ធិមនុស្សនៅកម្ពុជារិះគន់ថា ច្បាប់ទាំងនោះមិនត្រូវបានរដ្ឋាភិបាលយកទៅអនុវត្តឱ្យស្មើភាពគ្នានៅឡើយទេ បណ្តាលឱ្យមានអយុត្តិធម៌សង្គម ដែលជនក្រីក្រ និងអ្នកគ្មានអំណាចក្លាយជាជនរងគ្រោះ៕

## ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២០

## សម្តេច ស ខេង ដាស់តឿន គ្រប់អង្គភាព ត្រូវយកចិត្តទុកដាក់ លើការងារយេនឌ័រ

https://dap-news.com/national/ By KD102 Posted on March 11, 2020

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដាស់តឿន និងក្រើនរំលឹក ដល់គ្រប់អង្គភាព ស្ថាប័នក្រោមចំណុះក្រសួង ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យយកចិត្ត ទុកដាក់ជួយដល់ក្រុមការងារ យេនឌ័រក្រសួង និងក្រុមការងារយេនឌ័រ តាមបណ្តាអគ្គនាយកដ្ឋាន។ ក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១០៩ ឆ្នាំ២០២០ ក្រោមប្រធានបទ "មានសន្តិភាព មានការលើក កម្ពស់សមភាពយេនឌ័រ"នាព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ សម្តេចស ខេង មានប្រសាសន៍ថា «ក្នុងនាមជាថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ខ្ញុំតែងតែដាស់តឿន ក្រើនរំលឹក ដល់គ្រប់អង្គភាព ស្ថាប័នក្រោមចំណុះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយកចិត្តទុកដាក់ ជួយដល់ក្រុមការងារយេនឌ័រក្រសួង និងក្រុមការងារយេនឌ័រ តាមបណ្តាអគ្គនាយកដ្ឋាន ដើម្បីបែងចែងតួនាទី ការងារភារកិច្ច ការទទួលខុសត្រូវ សិទ្ធិអំណាច ឱកាស ធនធាន និងផលប្រយោជន៍ ប្រកបដោយសមធម៌រវាងស្ត្រី និងបុរស»។

សម្តេចបន្តថា ជាបណ្តើរៗ នារីក្នុងវិស័យទាំងបី គឺកងកម្លាំងនគរបាលជាតិ រដ្ឋបាល ស៊ីវិល និងអង្គភាពពន្ធនាគារ បាន បង្កើតនូវទិន្នន័យថ្មី នៃការកើនឡើងនូវចំនួនស្ត្រី ក្នុងតួនាទីដឹកនាំអង្គភាពនៅគ្រប់កម្រិត រៀងរាល់អាណត្តិ និងខិតខំបង្កើនបរិមាណស្ត្រី ដើម្បីបន្តវេនដឹកនាំទៅអនាគត។ សម្តេចបន្ថែមថា ក្រសួងមហាផ្ទៃ មិនទាន់បានធ្វើឲ្យកំណើន ជាអត្រាភាគរយស្ត្រី ក្នុងមុខតំណែងគ្រប់ឋានានុក្រម បានសមស្របនៅឡើយ តែជាបណ្តើរៗ ក្រសួងបានរៀបចំយុទ្ធសាស្ត្រ សម្រាប់ការបង្កើនចំនួនស្ត្រី ឲ្យបានសមស្របពី មួយឆ្នាំ ទៅមួយឆ្នាំ ផ្អែកលើភាពចាំបាច់គោលការណ៍ និងច្បាប់កំណត់ រួមទាំង ការខិតខំបង្កើនសមត្ថភាព ពង្រឹងការទទួលខុសត្រូវ ដល់មន្ត្រី ទាំងស្ត្រី និងបុរស ដែល ត្រូវបានបង្ហាញឡើងតាមរយៈ កិច្ចខិតខំប្រឹងប្រែងបង្កើតស្នាដៃ ប្រកបដោយស្មារតីទទួលខុសត្រូវ និងការអភិវឌ្ឍ ដែលជាលក្ខខណ្ឌ ត្រូវលើកទឹកចិត្ត។

ដើម្បីធ្វើឲ្យសម្រេចគោលដៅ ក្នុងផែនការយុទ្ធសាស្ត្រ សមភាពយេនឌ័ររបស់ក្រសួងមហាផ្ទៃ ក្នុងនាមថ្នាក់ដឹកនាំ ក្រសួងមហាផ្ទៃ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ ពីការប្តេជ្ញាចិត្តជាថ្មី ដូចខាងក្រោម ៖

ទី១-ត្រូវលុបបំបាត់ឲ្យបានដាច់ខាត ការរើសអើងយេនឌ័រ ក្នុងក្រសួងមហាផ្ទៃដែលនាំ ឲ្យមានភាពលំអៀងរវាង ស្ត្រី និងបុរស ក្នុងការវាយតម្លៃអំពី គុណ ភាព ការងាររបស់មន្ត្រី។

ទី២-ពិនិត្យលទ្ធភាព និងលក្ខខណ្ឌដើម្បីជ្រើសរើស និងតែងតាំងស្ត្រីក្នុងមុខតំណែងដឹកនាំអង្គភាព ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបន្ថែមទៀត ជាពិសេស ជាប្រធានអង្គភាព និងអភិបាលខេត្ត ក្រុង-ស្រុក-ខណ្ឌ ដើម្បីបង្កើនអត្រាចូលរួមរបស់ស្ត្រី ឲ្យបានសមស្រប និងលើកវិធានការ ដើម្បីបង្កើនចំនួនមន្ត្រីជ្រើសរើសថ្មីជាស្ត្រី ឲ្យបានសមស្រប។

ទី៣-អង្គភាពក្រោមចំណុះក្រសួងមហាផ្ទៃទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការពង្រឹងវិន័យ របៀបរបបការងារ ក្រមសីលធម៌មន្ត្រីសាធារណៈ ក្រមសីលធម៌កងកម្លាំងនគរបាល និងក្រមសីលធម៌មន្ត្រីពន្ធនាគារ ដោយសហការគ្នាបំពេញភារកិច្ចឲ្យបានល្អ ដើម្បីលើកតំកើនតំលៃស្ត្រី។

ទី៣-មន្ត្រីក្រសួងមហាផ្ទៃទាំងអស់ ត្រូវខិតខំធ្វើការងារឲ្យស្មើដៃគ្នា និងខិតខំពង្រឹងសមត្ថភាព រៀនសូត្របន្ថែមទៀត នូវមុខជំនាញ ដែលបម្រើឲ្យភារកិច្ច ដែលខ្លួនទទួលខុសត្រូវ ដើម្បីក្លាយជាធនធានដ៏ មានតម្លៃសម្រាប់ប្រទេសជាតិ។

និងទី៤-យកចិត្តទុកដាក់បម្រើ ប្រជាពលរដ្ឋឲ្យបានល្អ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងបំណងប្រាថ្នារបស់ ប្រជាពលរដ្ឋគ្រប់និន្នាការ ដោយមិនទុកឲ្យអ្នកណាម្នាក់ នៅក្រៅរង្វង់នៃ ការទទួលខុសត្រូវឡើយ ៕
ដោយ៖ អេង ប៊ូឆេង

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 10-03-2020

នៅរសៀលថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 10-03-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១០និង១៥នាទី ថ្ងៃទី១០ ខែមីនា ឆ្នាំ ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃចំនួន ០១នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរនេះ មានមានឈ្មោះភ័ណ្ឌ ភ័ក្រ ភេទប្រុស អាយុ ២៥ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្ថិតក្នុងភូមិចំការថ្មី ឃុំនរាយណ៍ ស្រុកឈូក ខេត្តកំពត និងបានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

# ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០២០

## ពលករខ្មែរធ្វើការនៅថៃខ្លះមិនហ៊ានទៅលេងស្រុក ព្រោះខ្លាចចៅកែផ្អាកពីការងារ ១៤ថ្ងៃ ពិនិត្យជំងឺកូវិដ១៩

https://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា 2020-03-11

ពលករខ្មែរធ្វើការងារនៅប្រទេសថៃមួយចំនួនប្រឈមនឹងការខកខានមិនបានទៅលេងបុណ្យចូលឆ្នាំខ្មែរនៅស្រុកកំណើត ដូចឆ្នាំមុនៗ ឡើយ។ បញ្ហាអាចមិនបានទៅលេងស្រុកនេះ ដោយសារតែពួកគេមិនចង់ប្រឈមឱ្យថៅកែថៃផ្អាកការងារប្រមាណ ២សប្ដាហ៍ ដើម្បីត្រួតពិនិត្យសុខភាពរកជំងឺកូវីដ១៩ នៅពេលត្រឡប់មកវិញ។

ពលករខ្មែរធ្វើការងារនៅក្រុមហ៊ុនកាប់សាច់ជ្រូកមួយកន្លែងនៅខេត្តជាប់ទីក្រុងបាងកក លោក មាស ប៉ូហៅ តា ឥណ្ឌា ថ្លែងនៅថ្ងៃទី១១ មីនាថា ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរឆ្នាំនេះលោកមិនបានទៅលេងស្រុកកំណើត

នោះទេ ដោយសារថៅកែថៃមិនអនុញ្ញាតច្បាប់ឱ្យទៅផ្ទះ ព្រោះខ្លាចត្រឡប់មកវិញមានជំងឺកូវិត១៩ ហើយឆ្លងដល់ពលករដទៃនៅក្នុងក្រុមហ៊ុននេះ៖ «ទី១ គេថា យើងដាក់ច្បាប់ភ្លាមៗ ហេតុផលទី២ ប្រទេសគេកំពុងតែជ្រួលច្របល់អីចឹងគេមិនអាចឱ្យនាំមនុស្សចូលប្រទេសគេបានទេ ហើយខ្ញុំថាគ្រាន់តែទៅយកកូនខ្ញុំក៏គេមិនឱ្យខ្ញុំទៅផ្ទះដែរ។ បើនិយាយទៅគេចង់និយាយថា ប្រទេសគេមិនមែនសម្រាប់ដាក់មនុស្សពេលមានបញ្ហាអីនាំចូលមកនៅអីចឹងទេ»។ លោកបន្តថា ពលករខ្មែរប្រមាណ ៥០ភាគរយក្នុងចំណោលពលករ ១ពាន់នាក់ (១.០០០) ដែលធ្វើការជាមួយលោកក៏មិនបានទៅលេងស្រុកកំណើតដែរ ពីព្រោះខ្លាចថៅកែមិនឱ្យចូលធ្វើការវិញ ស្របពេលដែលរោងចក្រជាច្រើនកន្លែងក៏បានជូនដំណឹងដល់ពលករទាំងឡាយដែលត្រឡប់ទៅផ្ទះនឹងត្រូវដាក់នៅកន្លែងត្រួតពិនិត្យដាច់ដោយឡែកចន្លោះពី ១៤ ទៅ ២១ថ្ងៃ ដើម្បីពិនិត្យជំងឺផ្លូវដង្ហើមកូវីដ១៩។

ពលករធ្វើការនៅប្រទេសថៃម្នាក់ទៀត លោក សារ ផៃ ឱ្យដឹងថា ថៅកែរោងចក្រ និងក្រុមហ៊ុនសាងសង់ជាច្រើនកន្លែង នៅតំបន់ដែលលោកធ្វើការ បានជូនដំណឹងដល់ពលករឱ្យផ្អាកធ្វើការងារចំនួន ១៤ថ្ងៃ ដើម្បីតាមដានជំងឺផ្លូវដង្ហើម ប្រសិនបើពួកគេទៅលែងស្រុកខ្មែរនោះ៖ «បាទ! គេអត់ឱ្យយើងចុះទៅលេងស្រុកទេ ទី១ គេការពាររោគកូវីដ១៩ ហ្នឹងផង ហើយណាមួយពេលចូលឆ្នាំបើយើងនាំគ្នាទៅផ្ទះច្រើនធ្វើក្រុមហ៊ុនគេខ្វះមនុស្សធ្វើការ។ ខាងខ្ញុំគេបានប្រាប់មុន មិនមែនថាយើងទៅផ្ទះហើយមកវិញគេអត់ទទួលទេ គ្រាន់តែថា បើយើងឡើងមកវិញ គេហ្នឹងឱ្យយើងសម្រាកពី១៤ថ្ងៃ ទៅ ២២ថ្ងៃ។បើតាមខ្ញុំសួរគេមកទីមួយ អ្នកមិនទៅផ្ទះអ្នកខ្លះខ្លាចបញ្ហាពេលទៅមកវិញគេឱ្យសម្រាកពីការងារហ្នឹង អ្នកខ្លះថាគាត់មិនសូវមានលុយកាក់អីចឹង»។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកទទួលបន្ទុកពលករលោក ចិន សំណាង និងអ្នកនាំពាក្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយបន្ថែមជុំវិញបញ្ហានេះបានទេនៅថ្ងៃទី១១ មីនា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

ទោះជាយ៉ាងណាប្រធានផ្នែកពលករចំណាកស្រុកនៃអង្គការសិទ្ធិការងារសង់ត្រាល់ លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា ពលករខ្មែរនៅប្រទេសថៃមួយចំនួនប្រឈមនឹងអត់ការងារធ្វើ ប្រសិនបើពួកគេត្រឡប់ទៅលេងបុណ្យចូលឆ្នាំប្រពៃណីខ្មែរនៅពេលខាងមុខ ដោយសារតែផលប៉ះពាល់សេដ្ឋកិច្ចនៅក្នុងប្រទេសនេះ ដែលបណ្តាលមកពីជំងឺកូវីដ១៩។ លោកបញ្ជាក់ទៀតថា រហូតមកទល់ពេលនេះ មានរោងចក្រនិងក្រុមហ៊ុនខ្លះបានប៉ះពាល់អាជីវកម្មរបស់ខ្លួន និងកាត់បន្ថយបុគ្គលិកបណ្តើរៗហើយ៖ «យើងពិបាកនិយាយថាវាយ៉ាងម៉េចណាស់ ព្រោះវាជាវិធានការមួយដែលខាងក្រុងហ៊ុននីមួយៗគេមានការព្រួយបារម្ភអីចឹង ដោយសារខ្ញុំទើបមកពីថៃដែរ ស្តាប់ទៅថាខាងថៅកែមួយៗ ហ្នឹងដូចជាបារម្ភរឿងមិនទុកចិត្តស្រុកខ្មែរយើងហ្នឹងវាយ៉ាងម៉េចយ៉ាងម៉ាអីចឹង ដោយសារតែមានព័ត៌មានថៃមួយចំនួនធ្លាប់និយាយអំពីការធ្វេសប្រហែស មិនសូវយកចិត្តទុកដាក់ក្នុងការពារជំងឺអីចឹង»។ មន្ត្រីសង្គមស៊ីវិលរូបនេះ បន្ថែមថា ដើម្បីកុំប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរបស់ពលករនៅពេលខាងមុខ គឺរដ្ឋាភិបាលគួរតែត្រៀមការងារផ្នែកសំណង់នៅក្នុងស្រុក និងពង្រីកការដាំដុះឱ្យបានច្រើន ដើម្បីឱ្យពួកគេមានការងារធ្វើរកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារ។

របាយការណ៍របស់ក្រសួងការងារបង្ហាញថា ពលករខ្មែរធ្វើការប្រទេសថៃមានជាង ១លាន ១សែននាក់ (១.១០០.០០០)។ ប៉ុន្តែរបាយការណ៍របស់អង្គការសង់ត្រាល់ ឱ្យដឹងថា មានពលករខ្មែរស្របច្បាប់ និងខុសច្បាប់ប្រមាណ ២លាននាក់ (២.០០០.០០០) កំពុងធ្វើនៅប្រទេសថៃ៕

## លាឈ្មោះជាពលករស្រុកថៃ វិលមកចាប់មុខរបរខ្លួនឯងក្នុងស្រុកកំណើត

http://nokorwatnews.com/ 11-03-2020

**បន្ទាយមានជ័យ៖**តស៊ូអស់រយៈពេល១៨ឆ្នាំធ្វើជាពលករចំណាក់ស្រុកទៅប្រទេសថៃ លោក គឿន សុគង់ អាយុ ៤១ឆ្នាំ រស់នៅភូមិកោះស្នួល ឃុំទួលពង្រ ស្រុកម៉ាឡៃខេត្តបន្ទាយមានជ័យបាននិយាយថាលោកបានលាឈ្មោះជាពលករស្រុកថៃវិលមកប្រកបរបរផ្ទាល់ខ្លួនក្នុងស្រុកកំណើតវិញ។លោកថាលោកបានទៅរស់នៅប្រទេសថៃអស់រយៈពេល១៨ឆ្នាំក្នុងភាពជាពលករក្នុងចំការដំណាំមួយកន្លែង។ដោយមិនមានភាពរីកចម្រើនក្នុងជីវភាព និងដោយមានទុនខ្លះក្នុងចំណេះដឹងដាំដំណាំ លោកនិងក្រុមគ្រួសារបានដឹកដៃគ្នាវិលមកស្រុកកំណើតវិញ ដោយជ្រើសរើសមុខរបរជាអ្នកដាំត្រសក់ផ្អែមនឹងដាំបន្លែមត្រសក់ផ្អែរ។

ជួបជាមួយអ្នកយកព័ត៌មានយើងលោក គឿង សុគង់ ក្នុងទឹកមុខញញឹមញញ៉ែម បាននិយាយរៀបរាប់ថាក្រោយពីរើសយករបរដាំត្រសក់ផ្អែមអស់រយៈពេល១៣ឆ្នាំ ជីវភាពហាក់មានការប្រែប្រួលខ្លាំង ទោះជាហាត់បន្តិចក្តីលោកបានពង្រីកផ្ទៃដីដាំដុះជារៀងរាល់ឆ្នាំ ដោយឆ្នាំទី១ក្នុងកម្រិតសាកល្បងដាំត្រឹមតែ៣រ៉ៃប៉ុណ្ណោះ។បន្ទាប់ពីមានភាពជោគជ័យនិងឱកាសទីផ្សាររបស់ត្រសក់ផ្អែម លោកបានធ្វើការពង្រីកផ្ទៃដីដាំរហូតដល់ទៅ៦ហិកតា ដោយជួលគេបន្ថែមក្នុងតម្លៃ៣៦០០បាតជាង៤០ម៉ឺនរៀល។

លោក គឿង សុគង់ បានអោយដឹងថា ត្រសក់ផ្អែមធ្វើការដាំត្រឹមតែ២ខែ៥ថ្ងៃប៉ុណ្ណោះគឺអាចប្រមូលបានហើយ ក្រោយប្រមូលផលត្រសក់ផ្អែមលោកបន្តដាំត្រសក់ផ្អែរឡើងវិញ ព្រោះត្រសក់ផ្អែមមិនអាចដាំលើដីដដែលក្នុងឆ្នាំតែមួយទេ។លោកមិនសង្ឃឹមលើទីផ្សារក្នុងស្រុកប៉ុន្មានទេ គឺតិចតួចណាស់ ទីផ្សារដែលផ្តល់ក្តីសង្ឃឹមនិងប្រមូលទិញពីផលដែលធ្វើបានគឺផ្គត់ផ្គង់ទៅទីផ្សារប្រទេសថៃ។លោកក៏បានបញ្ជាក់ផងដែរថាទោះជាទីផ្សារក្នុងស្រុកតូចតែឃើញថាត្រសក់ផ្អែមមានការពេញនិយមសម្រាប់បងប្អូនអ្នកដំណើរ។ត្រសក់ផ្អែមលក់ក្នុងតម្លៃ៥ពាន់រៀលក្នុងមួយគីឡូលក់ក្នុងស្រុក លក់ដុំទៅអោយឈ្មួញថៃក្នុងមួយគីឡូ២០ទៅ២១បាត បើប្រៀបធៀបនិងឆ្នាំមុន២៧បាតថោកជាងឆ្នាំមុនដល់ទៅ៦បាត។

ទោះជាមានការធ្លាក់ថ្លៃយ៉ាងនេះក្តី លោក គឿង សុគង់ នៅតែមានការញញឹមព្រោះលោកអះអាងថាមិនប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពនិងការរស់នៅរបស់លោកឡើយ ដោយថាទោះជាមានការធ្លាក់ថ្លៃក៏លោកអាចរក់កម្រៃពីលក់ក្នុងមួយរដូវបានពី៧ទៅ៨ពាន់ដុល្លាដែរ ហើយបើប្រៀបធៀបនិងឆ្នាំដែលលក់បានថ្លៃគឺមួយរដូវ១ម៉ឺន២ពាន់ដុល្លាអាមេរិក ចំណូលនេះលោកអាចផ្គង់ផ្គង់ក្នុងក្រុមគ្រួសារនិងកូនរៀន៤នាក់បានដោយរលូន។ ដោយៈវណ្ណា

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរ ចំនួន ០១នាក់ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 11-03-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នារសៀលថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរ ចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទល្មើស ឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រក តាស៊ីម ខេត្ត ព្រះវិហារ ៕

# ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០

## កម្ពុជា-អូស្ត្រាលី បន្តពង្រឹងលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យកាន់តែប្រសើរ

http://bayontv.com.kh/ 12/03/2020

ភ្នំពេញ៖ តាមរយៈជំនួបការងារ រវាងមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលប្រទេសកម្ពុជានិងអូស្ត្រាលី នៅព្រឹកថ្ងៃទី ១២ មីនា ឆ្នាំ២០២០នេះ ភាគីទាំងពីរបានអះអាងថា នឹងបន្តកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកាន់តែប្រសើរទៅមុខថែមទៀត។ ក្រោយចប់ជំនួបការងារ រវាងឯកឧត្តម Pablo Chiho

Kang ឯកអគ្គរដ្ឋទូតថ្មីប្រទេសអូស្ត្រាលីប្រចាំកម្ពុជា និងឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ឯកឧត្តម ង៉ុយ រិទ្ធ អនុរដ្ឋលេខាធិការ បានមានប្រសាសន៍ប្រាប់ក្រុមអ្នកសារព័តមានថា ថ្នាក់ដឹកនាំកម្ពុជាទាំងក្រសួងការងារ នឹងត្រៀមសហការជាមួយឯកអគ្គរដ្ឋទូត ដើម្បីជួយសម្រួលដល់បេសកកម្មការទូត ប្រកបដោយជោគជ័យ ក្នុងន័យថា ឲ្យទំនាក់ទំនងប្រទេសទាំង២ កាន់តែមានលក្ខណៈស៊ីជម្រៅ ក្នុងការរួមចំណែកយ៉ាងសកម្មលើការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនាពេលកន្លងមក សម្រេចបានជោគជ័យ ក្នុងការបង្កើតឱកាសការងារ និងធានាបាននូវសុខដុមនីយកម្មរវាងកម្មករនិយោជិត និងនិយោជក។ ឯកឧត្តមអនុរដ្ឋលេខាធិការបានបញ្ជាក់ទៀតថា ក្នុងជំនួបនោះ ពាក់ព័ន្ធទៅនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ភាគីអូស្ត្រាលីចង់ស្វែងយល់បន្ថែមទៅលើវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើយ៉ាងណាឱ្យអាណាព្យាបាល ព្រមទាំងយុវជនមានការយល់ដឹង ងាកមកចូលរៀនផ្នែកជំនាញវិជ្ជាជីវៈនៅកម្ពុជាកាន់តែច្រើន ដើម្បីឆ្លងតបទៅនឹងតម្រូវទីផ្សាររីកចម្រើន នៃសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន។ ក្នុងនោះ អូស្ត្រាលីសន្យានឹងផ្តល់នូវអាហារូបករណ៍ដល់សិស្សនិស្សិត មន្ត្រីរាជការ បានបន្តការសិក្សានៅប្រទេសអូស្ត្រាលីផងដែរ។

ឯកឧត្តមបន្ថែមថា អូស្ត្រាលីបានជួយកម្ពុជាលើក្រមសីលធម៌ទីភ្នាក់ងារជ្រើសរើសឯកជន ធ្វើយ៉ាងណាទប់ស្កាត់ការជួញដូរមនុស្ស ជាបញ្ហាធ្វើប៉ះពាល់សិទ្ធពលករទេសន្តរប្រវេសក៍។ កម្ពុជា នឹងបន្តកិច្ចសហប្រតិបត្តិការថ្មីៗបន្ថែមទៀតទៅលើសុវត្ថិភាព សន្តិសុខការងារ កន្លងមកនេះអូស្ត្រាលីបានធ្វើការជាមួយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ហើយចំពោះសុវត្ថិភាពអគារ យើងចង់អូស្ត្រាលីជួយជាបច្ចេកទេសនូវសុវត្ថិភាព និងសន្តិសុខការងារនៅកន្លែងធ្វើការផងដែរ ក្នុងការទប់ស្កាត់នូវបញ្ហាសុវត្ថិភាពការងារនេះដែរ៕

## លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ផ្តល់អនុសាសន៍ ៩ ចំណុច សម្រាប់ជាទិសដៅអនុវត្តបន្តរបស់រដ្ឋបាលខេត្តស្វាយរៀង

http://bayontv.com.kh/ 12/03/2020

ស្វាយរៀង៖ លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលខេត្តស្វាយរៀង នារសៀល ថ្ងៃព្រហស្បតិ៍ ៤ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។ ថ្លែងក្នុងឱកាសនោះ លោកជំទាវ ក៏បានពាំនាំនូវការសាកសួរសុខទុក្ខពី សំណាក់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន នូវក្តីនឹករលឹក ចំពោះអង្គពិធីទាំងមូល។ លោកជំទាវ បានបន្តទៀតថា សន្និបាតរយៈពេល ពេញមួយថ្ងៃនេះ គឺបានប្រមូលនូវធាតុចូលយ៉ាងច្រើន ដែលជាផ្នែកដ៏សំខាន់សម្រាប់ដាក់ចេញជាទិសដៅអនុវត្តសម្រាប់ឆ្នាំ២០២០ ដែលជាឆ្នាំទី២ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា ។ លោកជំទាវក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ដែលជាថ្នាក់ដឹកនាំនៃរដ្ឋបាលគ្រប់ថ្នាក់ និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន មន្ត្រីរាជការ កងកម្លាំងមានសមត្ថកិច្ចទាំងអស់ ដែលបានរួមគ្នាបំពេញតួនាទី ភារកិច្ច ប្រកបដោយការទទួលខុសត្រូវ សម្រេចបាននូវលទ្ធផលគួរជាទីមោទនៈ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេស។ ទន្ទឹមនឹងលទ្ធផលដែលខេត្តស្វាយរៀងសម្រេចបានលទ្ធផលល្អយ៉ាង ណាក៏ដោយ លោកជំទាវក៏បានស្នើឲ្យ រដ្ឋបាលខេត្ត ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ត្រូវរួមសហការគ្នាដូចខាងក្រោម៖

១.ត្រូវថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយនិងរួមគ្នាទប់ស្កាត់ប្រឆាំងដាច់ខាតសកម្មភាពបដិវត្តព័ណ៌។

២. អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវបន្តថែរក្សាពង្រឹងសន្តិសុខ សណ្តាប់ ធ្នាប់ សាធារណៈ សុវត្ថិភាពសង្គមឲ្យបានល្អប្រសើរ ក្នុងការចូលរួមអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព និងមានការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋាន ទប់ស្កាត់នូវការប្រើប្រាស់ និងជួញដូរគ្រឿងញៀន និងចូលរួមអនុវត្ត និងគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា ។

៣. ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សម្រាប់បម្រើដល់សកម្មភាពសេដ្ឋកិច្ច ការវិនិយោគ ការធ្វើពាណិជ្ជកម្ម កសិកម្ម ជាពិសេស ផ្តោតលើសក្តានុពលទេសចរណ៍ក្នុងខេត្ត ដោយត្រូវពង្រឹង គុណភាពសេវាពាក់ព័ន្ធនឹងវិស័យទេសចរណ៍ សំដៅបង្កើតការងារ បង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

៤. ផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងគុណភាពសំណង់ សំរាម កាកសំណល់រឹងរាវ និងការគ្រប់គ្រងបរិស្ថាន បញ្ហាសណ្តាប់ធ្នាប់ អនាម័យ សោភណ្ឌភាព ដែលចាំបាច់ត្រូវគិតគូរអំពីវិធានការ និងដំណោះស្រាយ លើបញ្ហាប្រឈមទាំងនោះឲ្យបានសមស្រប និងទាន់ពេលវេលា។

៥. អំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តខាងផ្នែកនយោបាយយ៉ាងមុតមាំក្នុងការជំរុញកិច្ចដំណើរការ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឲ្យមានការវិវត្តទៅមុខជាបន្តបន្ទាប់ ដោយផ្តោតជាសំខាន់ ទៅលើការផ្ទេរមុខងារ ធនធាន និងការទទួលខុសត្រូវទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតប សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

៦. អំពីការផ្តល់សេវាសាធារណៈ និងការដោះស្រាយបញ្ហាប្រឈមនៅមូលដ្ឋាន ត្រូវបន្តជំរុញ និងលើកកម្ពស់ការផ្តល់សេវាសាធារណៈនានាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដើម្បីឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ ដែលកាន់តែមានការកើនឡើង ក្នុងពេលដែលប្រទេសជាតិយើងកំពុងមានការអភិវឌ្ឍរីកចម្រើន យ៉ាងឆាប់រហ័ស។

៧.អាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំលើកកម្ពស់ការថែរក្សាការពារបូរណភាពទឹកដីអធិបតេយ្យភាពជាតិនិងបង្កើនការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនិងទប់ស្កាត់នូវបទល្មើសឆ្លងដែន។

៨.ការពង្រឹងរបៀបរបបការងារក្រុមប្រឹក្សា និងគណៈអភិបាល មេឃុំ ចៅសង្កាត់ ត្រូវដើរតួនាទីជាស្នូលក្នុងការពង្រឹងកិច្ចដំណើរការអភិបាលកិច្ច របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវពង្រឹងនូវទំនាក់ទំនង និងគណនេយ្យភាពរវាងក្រុមប្រឹក្សា និងគណៈអភិបាល និងរវាងមេឃុំ ចៅសង្កាត់ ជាមួយក្រុមប្រឹក្សារបស់ខ្លួន ស្របតាមច្បាប់រៀបចំអង្គការ និងគោលការណ៍ណែនាំនានាជាធរមាន។

៩. ស្នើឲ្យមន្ទីរសុខាភិបាលខេត្តស្វាយរៀង បន្តយកចិត្តទុកដាក់ក្នុងការអប់រំ ផ្សព្វផ្សាយ ដើម្បីទប់ស្កាត់នូវជម្ងឺ កូរ៉ូណា ឬ COVID-19 ៕

## សន្ធិសញ្ញាស្តីពីការផ្ទេរអ្នកទោសរវាងកម្ពុជា-វៀតណាម ត្រូវបានអនុម័ត

https://thmeythmey.com/ 13, Mar 2020 , 11:06 am

រដ្ឋសភាកម្ពុជា បានអនុម័តសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងកម្ពុជានិងវៀតណាម ក្នុងកិច្ចប្រជុំពេញអង្គវិសាមញ្ញ នាព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ដោយមានការចូលរួមពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។

សន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត អាចឲ្យកម្ពុជា ស្នើសុំយកទណ្ឌិតជាជនជាតិខ្មែរ ដែលជាប់ពន្ធនាគារនៅវៀតណាម មកឃុំក្នុងពន្ធនាគារកម្ពុជា ហើយវៀតណាម ក៏អាចស្នើសុំដូច្នេះវិញដែរ។ មន្ត្រីបកស្រាយកន្លងមកថា ការបង្កើតសន្ធិសញ្ញានេះ គឺដើម្បីផលប្រយោជន៍ប្រជាជនប្រទេសទាំងពីរ ជាពិសេសសម្រាប់អ្នកជាប់ពន្ធនាគារ។

ក្រៅពីសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត នៅមានរបៀបវារៈ៥ផ្សេងទៀត ក៏ត្រូវបានរដ្ឋសភាកម្ពុជា អនុម័តផងដែរ រួមមាន សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, សេចក្តី

ព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីពីរ ស្តីពីវិសោធនកម្ម កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន, សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីបី ស្តីពីវិសោធនកម្ម កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន, សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្ម កិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន, និង សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌរវាងកម្ពុជានិងវៀតណាម។

សេចក្តីព្រាងច្បាប់និងសន្ធិសញ្ញាទាំងនេះ នឹងត្រូវបញ្ជូនទៅព្រឹទ្ធសភា ដើម្បីពិនិត្យនិងអនុម័តបន្ត មុននឹងថ្វាយទៅអង្គព្រះមហាក្សត្រ ឡាយព្រះហស្តប្រកាសដាក់ចូលជាធរមាន៕

## ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២០

## រដ្ឋសភាអនុម័ត លើសន្ធិសញ្ញាស្តីពីការផ្ទេរ ទណ្ឌិតនិងច្បាប់ ជួយគ្នាទៅវិញទៅមក ក្នុងវិស័យព្រហ្មទណ្ឌ រវាងកម្ពុជា និងវៀតណាម

https://dap-news.com/ ByPH104 Posted on March 13, 2020

ភ្នំពេញ ៖ សមាជិករដ្ឋសភា ចំនួន១១៦រូប បានលើកដៃអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ។ ការអនុម័តសេចក្តីសេចព្រាងច្បាប់នេះ ធ្វើឡើងក្នុងសម័យប្រជុំវិសាមញ្ញរដ្ឋសភា នីតិកាលទី៦ នាព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ក្រោមអធិបតីភាពសម្តេច ហេងសំរិន ប្រធានរដ្ឋសភា និងមានការចូលរួមពីសំណាក់សម្តេចតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រី ព្រមទាំងសមាជិកស មាជិការរដ្ឋសភាចំនួន១១៨រូប ។

យោងតាមសេចក្តីថ្លែងហេតុ របស់រាជរដ្ឋាភិបាល បានលើកឡើងថា សន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ត្រូវបានរៀបចំឡើង ដោយរាជរដ្ឋាភិបាល នៃប្រទេសទាំងពីរ ដោយបានឆ្លងកាត់ការប្រជុំយ៉ាងល្អិតល្អន់ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមច្បាប់នៃភាគីនីមួយៗ និងតាមច្បាប់អន្តរជាតិ ។ ប្រភពបានបន្តថា សន្ធិសញ្ញានេះ មានគោលបំណងលើក កម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងការផ្ទេរទណ្ឌិត ដើម្បីផ្តល់ឱកាសដល់ទណ្ឌិត អាចធ្វើសមាហរណកម្ម ទៅក្នុងសង្គម និងក្នុងគោលបំណងធ្វើកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តសាលក្រមព្រហ្មទណ្ឌ ដោយសន្ធិសញ្ញានេះមាន២០មាត្រា ។

នៅព្រឹកថ្ងៃដដែលរដ្ឋសភា ក៏បានអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងប្រទេសកម្ពុជា និងវៀតណាម ដោយសំឡេង១១៥ផងដែរ ។ សន្ធិសញ្ញានេះមានគោល បំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ សំដៅប្រយុទ្ធប្រឆាំង នឹងបទល្មើសប្រកបដោយប្រសិទ្ធភាព ដោយឈរលើមូលដ្ឋានគោរពអធិ បតេយ្យភាពគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍រួមសងខាង ហើយជាផ្នែកមួយ នៃកិច្ចសហប្រតិបត្តិការ អន្តរជាតិ ក្នុងការចូលរួមយ៉ាងសកម្ម ក្នុងក្របខណ្ឌច្បាប់អន្តរជាតិ ក្នុងវិស័យព្រហ្មទណ្ឌ នឹងឧក្រិដ្ឋកម្មឆ្លងដែន ។ សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌនេះមាន២៤មាត្រា ៕ដោយ៖ ស សំណាង

## បទល្មើសទៅលើកុមារ២៧៤ករណី ក្នុងឆ្នាំ២០១៩ ក្នុងនោះបទល្មើសឃាតកម្មលើកុមារ២៤ករណី

http://www.cen.com.kh/ March 13, 2020

ភ្នំពេញ៖ អង្គភាពការពារកុមារ បានផ្តល់ជូននូវរបាយការណ៍ប្រចាំឆ្នាំ២០១៩ ដល់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃ។ អង្គភាពការពារកុមារ ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយនគរបាលជាតិកម្ពុជា បានធ្វើការស៊ើប

អង្កេតបទល្មើស ទៅលើកុមារចំនួន២៧៤ករណី ក្នុងឆ្នាំ២០១៩ ដែលក្នុងនោះមានបទល្មើសឃាតកម្ម ទៅលើកុមារចំនួន២៤ករណី នេះបើតាមការផ្សាយរបស់ អង្គការ Child Protection Unit នៅថ្ងៃទី១៣ខែមីនានេះ។

នៅទីស្តីការក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ២០២០ លោក ប៊ុន ហុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យលោក James McCabe នាយកទទួល បន្ទុកប្រតិបត្តិការ របស់អង្គភាពការពារកុមារ CPU ព្រមទាំងសហការី ចូលជួបសម្តែងការគួរសម និងរាយការណ៍អំពីសកម្មភាពការងារប្រចាំ២០១៩ របស់ខ្លួននាពេលកន្លងមក។ អង្គភាពការពារកុមារបានកោតសរសើរយ៉ាងខ្លាំង ទៅដល់ក្រសួងមហាផ្ទៃ ចំពោះការខឹតខំប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការ ក្នុងការប្រឆាំងបទល្មើសលើកុមារ។ អង្គភាពការពារកុមារ ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយនគរបាលជាតិកម្ពុជា បានធ្វើការស៊ើបអង្កេតបទល្មើស ទៅលើកុមារចំនួន២៧៤ករណីក្នុងឆ្នាំ២០១៩ ដែលក្នុងនោះមានបទល្មើសឃាតកម្ម ទៅលើកុមារចំនួន២៤ករណី។ ជាលទ្ធផលនៃការស៊ើបអង្កេតទាំងនេះ អត្រានៃការចាប់ខ្លួនជនល្មើសគឺស្មើ ៨៧% ដែលនេះជាលទ្ធផលយ៉ាងល្អមួយ និងបង្ហាញពីការប្តេជ្ញាចិត្តរបស់នគរបាលជាតិកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រឆាំងបទល្មើសទៅលើកុមារ និងធ្វើឲ្យប្រាកដថាគ្រប់ជនដែលបានប្រព្រឹត្តបទល្មើសទាំងនេះនឹងត្រូវទទួលការផ្តន្ទាទោស។

លោក ប៊ុន ហុន បានវាយតម្លៃចំពោះសកម្មភាពការងារអង្គភាពការពារកុមារ CPU ដែលបានអនុវត្តតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសកិច្ចសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងការរំលោភបំពានលើកុមារកម្ពុជា និងជំនួយបច្ចេកទេសនានា ដល់កងកម្លាំងនគរបាលជាតិកម្ពុជា។ លោក បានបន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា តែងតែចាត់ទុកអង្គការសង្គមស៊ីវិលជាដៃគូអភិវឌ្ឍន៍ដ៏ល្អ សម្រាប់ព្រះរាជាណាចក្រកម្ពុជា ហើយក្នុងនាមក្រសួងមហាផ្ទៃ នៅតែបន្តគាំទ្រសកម្មភាពការងាររបស់អង្គភាពការពារកុមារ CPU។

លោក Jame McCabe បានថ្លែងអំណរគុណដល់ក្រសួងមហាផ្ទៃដែលតែងតែយកចិត្តទុកដាក់ និងផ្តល់កិច្ចសហការយ៉ាងល្អប្រសើរ ដល់សកម្មភាពការងាររបស់អង្គភាពខ្លួន ហើយបានប្រគល់របាយការណ៍ស្តីពីសកម្មភាពការងារឆ្នាំ២០១៩ ជូន លោករដ្ឋលេខាធិការ ។ អង្គភាពការពារកុមារទន្ទឹងរង់ចាំ នឹងបន្តកិច្ចសហការដ៏ល្អមួយនេះ ជាមួយនគរបាលជាតិកម្ពុជា និងក្រសួងមហាផ្ទៃ ក្នុងការប្រឆាំងបទល្មើសទៅលើកុមារ ថែមទាំងបទល្មើសលើកុមារ តាមបណ្តាញអ៊ីនធឺណិតផងដែរ នៅក្នុងឆ្នាំ២០២០។ សូមអបអរសាទរដល់គ្រប់បុគ្គល និងស្ថាប័នពាក់ព័ន្ធដែលបានជួយក្នុងការងារដ៏សំខាន់មួយនេះ ដើម្បីប្រឆាំងបទល្មើសទៅលើកុមារ៕ដោយៈបញ្ញាស័ក្តិ

## រថយន្តឈ្នួលដឹកពលករខ្មែរពីប៉ាតាយ៉ាទៅព្រំដែនឡែមជួបគ្រោះថ្នាក់ចរាចរណ៍តាមផ្លូវ

https://www.facebook.com/officialworker/ March 14 at 3:39 PM

កាលពីថ្ងៃទី 14.03.20 ករណីរថយន្តឈ្នួលដឹកពលករខ្មែរពីប៉ាតាយ៉ាទៅព្រំដែនឡែម ជួបគ្រោះថ្នាក់ចរាចរណ៍តាមផ្លូវបណ្តាលឲ្យមានមនុស្សស្លាប់បាត់បង់ជីវិតនៅកន្លែងកើតហេតុចំនួន ០២នាក់ និងរងរបួសធ្ងន់ស្រាល ចំនួន ០៥នាក់ ហេតុការណ៍នេះបានកើតឡើងនៅថ្ងៃសៅរ៍ ទី១៤ ខែមីនា ឆ្នាំ២០២០ ចំណុចកើតហេតុស្ថិតក្នុងស្រុកម៉ាខាមគូ ខេត្តរ៉ាក់យ៉ង ប្រទេសថៃ។

## អគ្គីភ័យឆាបឆេះបន្ទប់ស្នាក់នៅពលករខ្មែរ ធ្វើការសំណង់ប្រមាណជាង ៣០០បន្ទប់ នៅក្នុងខេត្តអយុធ្យា

https://www.facebook.com/officialworker/ Yesterday at 2:32 AM

កាលពីថ្ងៃទី 15.03.20 មានករណីអគ្គីភ័យឆាបឆេះបន្ទប់ស្នាក់នៅពលករខ្មែរ ធ្វើការសំណង់ប្រមាណជាង ៣០០បន្ទប់ នៅក្នុងខេត្តអយុធ្យា ហេតុការណ៍នេះបានកើតឡើងនៅយប់ឈានចូលថ្ងៃអាទិត្យ ទី១៥ ខែមីនា ឆ្នាំ ២០២០ ចំណុចកើតហេតុស្ថិតនៅក្នុងឃុំខ្លងសួនភ្លូ ស្រុកអយុធ្យា ខេត្តអយុធ្យា ប្រទេសថៃ ។ យោងតាមរបាយការណ៍បឋមពីកន្លែងកើតហេតុបានអោយដឹងថា មានពលករខ្មែរប្រមាណជាង ២៨៣នាក់ ស្នាក់នៅទីនោះ ក្នុងនោះដែរមានមនុស្សរងរបួសរលាកភ្លើងមួយចំនួនផងដែរ ដោយសាររត់គេចពីអគ្គីភ័យ។

## ពលករមួយចំនួននៅតែគ្មានជំនឿស្ថានទូតខ្មែរនៅថៃអាចជួយពួកគេកុំបាត់បង់ការងារពេលទៅលេងចូលឆ្នាំខ្មែរ

https://www.rfa.org/khmer/news/ ដោយ វ៉ែន សុមេធ 2020-03-13

ពលករខ្មែរមួយចំនួនធ្វើការងារនៅប្រទេសថៃនៅតែព្រួយបារម្ភខ្លាចបាត់បង់ការងារក្នុងពេលទៅលេងបុណ្យចូលឆ្នាំខ្មែរនៅពេលខាងមុខ។ ពួកគេហាក់គ្មានជំនឿនឹងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកដែលប្រកាសឱ្យពលករទៅលេងស្រុកកំណើតក្នុងថ្ងៃបុណ្យប្រពៃណីជាតិដោយអះអាងថា នឹងមិនមានការបាត់បង់ការងារនោះទេ។

ពលការិនីខ្មែរធ្វើការសំណង់នៅទីក្រុងបាងកកកញ្ញា សារិន ស្រីនិច្ច ប្រាប់អាស៊ីសេរីនៅថ្ងៃទី១៣មីនាថាពលករធ្វើការនៅក្រុមហ៊ុនជាមួយកញ្ញាប្រមាណ ២០០នាក់ កំពុងព្រួយបារម្ភខ្លាចថៅកែមិនទទួលឱ្យចូលការងារវិញ ប្រសិនបើពួកគេទៅលេងបុណ្យចូលឆ្នាំប្រពៃណីខ្មែរលើសពី ៧ថ្ងៃនោះ។ ពលការិនីមានស្រុកកំណើតនៅខេត្តព្រៃវែងរូបនេះបន្តថានៅពេលនេះមានពលករប្រមាណ៤០ភាគរយហើយ ដែលសម្រេចមិនទៅលេងស្រុកកំណើតអំឡុងពេលបុណ្យប្រពៃណីជាតិនេះ ដោយសារខ្លាចត្រឡប់មកវិញមិនទាន់ថ្ងៃកំណត់ ដែលថៅកែអនុញ្ញាតច្បាប់ឱ្យឈប់សម្រាក៧ថ្ងៃនោះ៖ «ខាងស្ថានទូតចេញមកខ្ញុំអត់ដឹងទេព្រោះកន្លែងខ្ញុំធ្វើការគឺប្រកាសអីចឹងបណ្ដោយបើសិនជាអ្នកទៅផ្ទះលើលើសពី៧ថ្ងៃហ្នឹងគែគេអត់ទទួលយកវិញទេ មិនមែននៅតែកន្លែងខ្ញុំមួយទេកន្លែងផ្សេងក៏ដូចគ្នាដែរ ។វាពិបាកដែរបើគេអត់ទទួលយកយើងធ្វើការទេគឺលិខិតឆ្លងដែនហ្នឹង ត្រូវទាំងអស់បណ្ដោយដូចថាយើងត្រូវធ្វើសារថ្មីព្រោះនៅពេលយើងទៅរកកន្លែងការងារផ្សេងគេអត់យកលិខិតឆ្លងដែនហ្នឹងទេគឺ គេត្រូវឱ្យវាយបិទប៉ាសស្ព័រហ្នឹងហើយត្រូវធ្វើប៉ាសស្ព័រថ្មីឱ្យគេហើយត្រូវបង់លុយសាថ្មី»។

ស្រដៀងគ្នានេះដែរពលករខ្មែរធ្វើការនៅខេត្តជាប់ទីក្រុងបាងកកម្នាក់ទៀតលោក មាស ប៉ូវ៉ាថ្លែងថាថៅកែរបស់លោកមិនឱ្យពួកគេទៅលេងស្រុកកំណើតអំឡុងពេលនេះឡើយ ពីព្រោះខ្លាចឆ្លងជំងឺកូវីត១៩នៅពេលត្រឡប់មកកន្លែងធ្វើការវិញ។ លោកបញ្ជាក់ទៀតថា ថៅកែក៏បានព្រមានចំពោះរូបលោកថា ប្រសិនបើទៅលេងផ្ទះនៅពេលនេះ គេនឹងមិនទទួលឱ្យចូលធ្វើការងារវិញឡើយ៖ «បើស្ថានទូតគាត់និយាយថាមានការបើកទូលាយឱ្យពលករទៅបុណ្យចូលឆ្នាំប្រពៃណីខ្មែរយើងអីចឹងតែនៅតាមក្រុមហ៊ុនផ្សេងៗវាពិបាកមិនដូចដែលស្ថានទូតនិយាយទេគឺ មានការរឹតបន្តឹងច្រើន។បើកន្លែងខ្ញុំវាពិបាកណាស់គេមិនចង់ឱ្យយើងទៅផ្ទះទេមានកន្លែងខ្លះសុំគេទៅឡើងផ្ទះក៏អត់បានទៅដែរហើយសូម្បីតែកូនខ្ញុំនៅខាងរោងចក្រផ្សេងសុំគេទៅយកប្អូននៅព្រំដែននោះក៏គេអត់ឱ្យចូលទៅខ្មែរដែរ។គេថាបើសិនជាចូលទៅខ្មែរមកវិញគេនឹងផ្អាកការងារ១៤ថ្ងៃគេឱ្យទៅត្រឹមព្រំដែន»។

ពលករខ្មែរទាំងនេះ បានប្រតិកម្មនឹងការលើកឡើងរបស់មន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកដែលថា នឹងជួយដល់ពលករឱ្យបានទៅលេងបុណ្យចូលឆ្នាំប្រពៃណីខ្មែរគ្រប់ៗ គ្នា ដោយពុំបាត់បង់ការងារនោះ គឺជារឿងដែល

មិនអាចធ្វើទៅរួចឡើយ ពីព្រោះកន្លងមកពួកគេធ្លាប់ទាក់ទងទៅស្ថានទូតឱ្យជួយជាច្រើនករណីមកហើយប៉ុន្តែមិនអាចជួយពួកគាត់បានម្តងណានោះទេក្រោមហេតុផលថាមន្ត្រីស្ថានទូតមានគ្នាតិច។

កាលពីថ្ងៃទី១២ មីនាមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកទទួលបន្ទុកផ្នែកពលករលោក គឹម ចំរើន បានប្រកាសឱ្យពលករខ្មែរ ដែលធ្វើការងារនៅប្រទេសថៃទៅបុណ្យចូលឆ្នាំខ្មែរនៅស្រុកកំណើតបានជាធម្មតា និងថៅកែមិនហាមឃាត់ពលករទៅលេងស្រុកកំណើតនោះឡើយ។ លោកបន្តថាអ្នកទៅលេងស្រុកកំណើត នៅពេលត្រឡប់មកប្រទេសថៃវិញចូលធ្វើការជាធម្មតាដដែល ដោយមិនបាត់បង់ការងារនោះទេ។ លោកបញ្ជាក់ទៀតថាពលករដែលត្រឡប់មកពីលេងស្រុកវិញឆ្លងដែនចូលប្រទេសជាធម្មតា ដោយពុំមានដាក់ឱ្យនៅដាច់ដោយឡែកចំនួន១៤ថ្ងៃដើម្បីតាមដានសុខភាពនោះទេ ប្រសិនបើពួកគាត់មានសុខភាពល្អ ប៉ុន្តែចំពោះពលករណាដែលមានកម្តៅក្នុងខ្លួនខ្លាំងនឹងត្រូវដាក់ដោយឡែកតាមដានសុខភាព ១៤ថ្ងៃ ទើបអនុញ្ញាតឱ្យឆ្លងដែនចូលធ្វើការវិញបានព្រោះខ្លាចមានជំងឺកូវីដ១៩ (COVID19)៖ «គេខ្លាចយើងហ្នឹងឆ្លងជំងឺកូវីដ១៩ ហ្នឹងហើយបើយើងឆ្លងមែនគេហ្នឹងបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យដោយមិនគិតថ្លៃសេវាទេ ព្រោះរដ្ឋាភិបាលថៃកំណត់ហើយគឺអ្នកឆ្លងជំងឺនេះគឺអត់មានគិតថ្លៃសេវាព្យាបាលទេ។អីចឹងបងប្អូនយល់ ហើយចំណុចហ្នឹងករណី១៤ថ្ងៃហ្នឹងគឺករណីដែលគេពិនិត្យឃើញបងប្អូនមានកម្តៅលើ៣៧.៥អង្សា ហើយបើសិនគេហាមមិនឱ្យបងប្អូនធ្វើសុំឱ្យបងប្អូនជូនដំណឹងមកស្ថានទូតហើយស្ថានទូតរង់ចាំជួយបងប្អូន»។ លោកបន្ថែមថាការធ្វើបែបនេះដោយសារតែជំងឺកូវីដ១៩ កំពុងតែរាតត្បាតខ្លាំងនៅលើពិភពលោកហើយគ្មានថ្នាំព្យាបាលជំងឺនេះនៅឡើងទេ។

ទោះជាយ៉ាងណាប្រធានផ្នែកពលករចំណាកស្រុកនៃអង្គការសិទ្ធិការងារសង់ត្រាល់ លោក ឌី ថេ ហូយ៉ា លើកឡើងថា ពលករខ្មែរនៅប្រទេសថៃមួយចំនួនប្រឈមនឹងថៅកែបញ្ឈប់ពីការងារប្រសិនបើពួកគេទៅលេងផ្ទះអំឡុងពេលបុណ្យចូលឆ្នាំខ្មែរនោះ។លោកបន្តថា បញ្ហានេះបណ្តាលមកពីផលប៉ះពាល់សេដ្ឋកិច្ចនៅក្នុងប្រទេសថៃដោយសារជំងឺផ្លូវដង្ហើម កូវីដ១៩៖ «តាមការប្រមើលមើលហ្នឹង វាមានបញ្ហាធំ២។ ទីមួយ បញ្ហា GSP របស់អាមេរិកដកហ្នឹងមួយផ្នែកទៅអីចឹងមានបញ្ហាជំងឺកូវីដ១៩ បន្ថែមលើបញ្ហាដែលមានស្រាប់ទៀតទៅ តែយើងមិនដឹងថា វាប៉ះពាល់កម្រិតណាទេ។ ប៉ុន្តែបើសិនជាអាមេរិកដកGSPហើយជំងឺកូវីដហ្នឹងអូសបន្លាយទៅយូរទៀតខ្ញុំមើលឃើញថាវាមានវិបត្តិធ្ងន់ធ្ងរមែនទែនលើផ្នែកសេដ្ឋកិច្ចនៅប្រទេសថៃ»។

របាយការណ៍របស់ក្រសួងការងារបង្ហាញថា ពលករខ្មែរធ្វើការប្រទេសថៃមានជាង ១ លាន ១ សែននាក់ (១.១០០.០០០)។ ប៉ុន្តែរបាយការណ៍របស់អង្គការសង់ត្រាល់ ឱ្យដឹងថាមានពលករខ្មែរស្របច្បាប់និងខុសច្បាប់ប្រមាណ ២លាននាក់ (២.០០០.០០០) កំពុងធ្វើនៅប្រទេសថៃ៕

## ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២០

### អគ្គស្នងការនគរបាលជាតិ ជួបពិភាក្សាការងារជាមួយ ឯកអគ្គរដ្ឋទូតអូស្ត្រាលីថ្មី ប្រចាំកម្ពុជា

http://nokorwatnews.com/ 18-03-2020

ភ្នំពេញ ៖ នៅព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០នេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានទទួលជួបពិភាក្សាការងារជាមួយ លោក Pablo Kang ឯកអគ្គរដ្ឋទូតអូស្ត្រាលីថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា។ ជំនួបពិភាក្សាដ៏មានសារសំខាន់នេះ ក៏មានការចូលរួមពីនាយនគរបាលជាន់ខ្ពស់ អគ្គស្នងការដ្ឋាននគរបាលជាតិ និងមន្ត្រីជាន់ខ្ពស់ស្ថានទូតអូស្ត្រាលីផងដែរ។ ក្នុងជំនួបពិភាក្សាដ៏មានសារសំខាន់នេះ ភាគីទាំងពីរបានលើកឡើងពីកិច្ចសហប្រតិបត្តិការល្អរវាងកងកម្លាំងអនុវត្តច្បាប់នៃប្រទេសទាំងពីរ កម្ពុជា-អូស្ត្រាលី និងការពង្រឹងការផ្លាស់ប្តូរព័ត៌មានលើការប្រយុទ្ធប្រឆាំងបទល្មើសនានា ដូចជា៖ បទល្មើសគ្រឿងញៀន និងអំពើជួញដូរមនុស្ស។

នៅចំពោះមុខ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ លោក Pablo Kang បានថ្លែងការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់នគរបាលជាតិកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មម៉ូតូធំ ជាពិសេសក្រុមការងារព័ត៌មានទាន់ហេតុការណ៍ (Hot Line) ជាមួយជនបរទេស។ លោក Pablo Kang បន្តថា អូស្ត្រាលីនៅតែបន្តជួយដល់កម្ពុជាលើការងារបណ្តុះបណ្តាលដល់នគរបាលជាតិកម្ពុជាបន្ថែមទៀត។

ជាមួយគ្នានោះ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ក៏បានថ្លែងអំណរគុណដល់អូស្ត្រាលី ដែលកន្លងមកបានជួយដល់នគរបាលជាតិកម្ពុជា លើការពង្រឹងសមត្ថភាពដល់នគរបាលប៉ុស្តិ៍រដ្ឋបាលតាមរយៈគម្រោងនគរបាលសហគម (CPI)៕ដោយៈសុខខេមរា

## ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២០

## អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរម្នាក់មកស្រុកកំណើតវិញបន្ទាប់ពីដោះលែងពីពន្ធនាគារ

http://nokorwatnews.com/ 19-03-2020

ខេត្តឧត្តរមានជ័យ៖ អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរម្នាក់មកស្រុកកំណើតវិញ បន្ទាប់ពីដោះលែងពីពន្ធនាគារពីបទឆ្លងដែនខុសច្បាប់កាប់ឈើក្រញូងក្នុងទឹកដីថៃ។ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០នេះស្ថិតនៅច្រកអន្តរជាតិជាំស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំ បានអោយដឹងថាប្រជាពលរដ្ឋខ្មែរដែលត្រូវបានភាគីថៃបញ្ជូនមកវិញនោះ គឺមាន ឈ្មោះ ឡាំង លេង ភេទប្រុស អាយុ ៣៩ ឆ្នាំ រស់នៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្តខេត្តព្រះវិហារ។ពលករឈ្មោះឡាំងលេងត្រូវថៃចាប់ខ្លួននៅថ្ងៃទី៦ខែមេសាឆ្នាំ២០១៧កន្លងទៅនេះ ពីបទឆ្លងដែនកាប់ឈើក្រញូងដោយចូលតាមច្រកតាថាវ ហើយបញ្ជូនខ្លួនយកទៅដាក់ពន្ធនាគារនៅស្រុកខាន់តាឡាក់ខេត្តស៊ីសាកេតប្រទេសថៃ។ ចាប់ពីពេលនោះមករហូតដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២០ នេះទើបរួចផុតទោស ដោះលែងអោយមានសេរីភាពរឿងវិញ៕ ប៉ែន នួន

## ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២០

## សម្តេច ស ខេង ប្រាប់ទៅអាជ្ញាធរមូលដ្ឋានណែនាំដល់ពលរដ្ឋទើបមកពីប្រទេសថៃដាក់ខ្លួនឯងដាច់ដោយឡែកពីគេ

http://kampucheathmey.com/ 23/3/2020 8:28 Am

សម្តេចក្រឡាហោម ស ខេង ឧបនាយកដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានស្នើទៅអាជ្ញាធរមូលណែនាំដល់ប្រជាពលរដ្ឋដែលទើបត្រលប់មកពីថ្ងៃឱ្យដាក់ខ្លួនឯងនៅដាច់ដោយឡែក ឬមានករណីសង្ស័យត្រូវមកធ្វើតេស្តកំហាកនៅវិទ្យាស្ថានប៉ាស្ទ័រ ដើម្បីរកមេរោគ Covid-19 ។

តាមរយៈសារសម្លេងក្នុងប្រព័ន្ធទំនាក់ទំនងសង្គមសម្តេចបានលើកឡើងថា សេចក្តីរាយការណ៍កាលពីថ្ងៃទី ២២ ខែមីនា មានប្រជាពលរដ្ឋខ្មែរបានសម្រុករិលមកពីប្រទេសថៃចូលកម្ពុជាតាមច្រកព្រំដែនកម្ពុជា–ថៃខ្ទង់៣ពាន់នាក់ ពិសេសនៅច្រកដូង (ច្រកឡែម) ស្ថិតនៅស្រុករៀង ខេត្តបាត់ដំបង ហើយមិនមានការត្រួតពិនិត្យកម្តៅស្វែងរកមេរោគ Covid-19 នោះទេ។ ដូច្នេះសម្តេចបានស្នើឱ្យអាជ្ញាធរខេត្តពិសេសភូមិ–ឃុំ ដោយឱ្យគាត់នៅដោយឡែកពីគេចំនួន១៤ថ្ងៃ។ "អញ្ចឹងអភិបាលខេត្តបាត់ដំបងបានជូនដំណឹងហើយ។ អញ្ចឹងខ្ញុំសុំបន្ថែមទៀតឱ្យខេត្តសាមុីមួយៗណែនាំទៅមូលដ្ឋានភូមិឃុំ ស្រុកឱ្យផ្តល់ព័ត៌មាន បានន័យថា អ្នកទើបមកពីថៃហ្នឹងផ្តល់ព័ត៌មានមក ដើម្បីឱ្យពេទ្យទៅពិនិត្យ ហើយបើមានការសង្ស័យទុកគាត់នៅដាច់ដោយឡែកសិនកុំឱ្យប៉ះពាល់ជាមួយអ្នកដទៃ ក្នុងផ្ទះគាត់ហ្នឹង

សូម្បីគ្រួសារហ្នឹងក៏មិនឱ្យប៉ះដែរ"។ សម្តេចបានបន្ថែម។ ប្រជាពលរដ្ឋខ្មែរខ្ទង់ពាន់នាក់បានសម្រុកមកកាន់ច្រកដូង(ច្រកទ្បែម)នៃខេត្តបាត់ដំបង បន្ទាប់ពីទទួលដំណឹងថា ត្រូវអាជ្ញាធរកម្ពុជា–ថៃប្រកាសបិទកាលពីថ្ងៃទី២២ ខែមីនា ម្សិលមិញនេះ។ការសម្រុកចូលមកច្រើននេះមិនមានការត្រួតពិនិត្យសុខភាពឡើយ ហើយគ្រប់គ្នានឹងធ្វើដំណើរទៅតាមស្រុកភូមិខេត្តរៀងៗខ្លួន ដែលជាបញ្ហាប្រឈមមួយដល់ការឆ្លងរីករាលដាលនៃ Covid-19។

គិតត្រឹមថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ កម្ពុជាបានប្រកាសរកឃើញអ្នកឆ្លង Covid-19 ចំនួន ៨៤ នាក់។ (ស្រី ២១នាក់ ប្រុស៦៣នាក់ ដែលក្នុងនោះមានចិន១នាក់ (នៅខេត្តព្រះសីហនុ បានជាសះស្បើយ) អង់គ្លេស៣នាក់ (ក្នុងនោះមាន១នាក់បានជាសះស្បើយហើយ) កាណាដា១នាក់ បែលហ្សិក១នាក់ បារាំង៣៣នាក់ (ក្នុងនោះមាន កូនប្រុសបង្កើតអាយុ៤ខែ) ម៉ាឡេស៊ី១២នាក់ និងខ្មែរ៣៣នាក់។

## ពលករខ្មែរជាច្រើននាក់ កំពុងសម្រុកចេញពីប្រទេសថៃ ក្រោយពីក្រុមហ៊ុនជាច្រើនត្រូវបិទទ្វារ

http://kampucheathmey.com/ 23/3/2020 6:43 Am

ប្រទេសថៃ ៖ ពលករាប់ពាន់នាក់ ដែលបម្រើការងារនៅក្នុងប្រទេសថៃ ដែលក្នុងនោះភាគច្រើនគឺមាន ៖ ពលករខ្មែរ ឡាវ និង ភូមា កំពុងសម្រុកធ្វើដំណើរទៅកាន់ក្រុមហ៊ុនដឹកជញ្ជូនដើម្បីវិលត្រឡប់ទៅកាន់ប្រទេសរៀងៗខ្លួនវិញ ដោយម្នាក់ៗមានសម្ភារជាប់ខ្លួនយ៉ាងសំពីងសំពោងផងដែរ ក្រោយពីមានក្រុមហ៊ុនជាច្រើន នៅក្នុងទីក្រុងបាងកក ត្រូវបានបិទទ្វារជាបណ្តោះអាសន្ន ខណៈដែលមេរោគ COVIC-19 កំពុងរាតត្បាតយ៉ាងខ្លាំងនៅក្នុងប្រទេសថៃ និងបណ្តាប្រទេសនានា នៅលើសកលលោក។ ប៉ុន្មានថ្ងៃចុងក្រោយនេះ គេសង្កេតឃើញថា មានពលករជាច្រើន ចម្រុះជាតិសាសន៍ បានប្រមូលផ្តុំគ្នានៅក្នុងក្រុមហ៊ុនដឹកជញ្ជូន « ម៉ឈីត » ដែលស្ថិតនៅកណ្តាល ទីក្រុងបាងកក ដើម្បីវិលត្រឡប់ទៅកាន់ប្រទេសដែលជាស្រុកកំណើតរបស់ពួកគេវិញ ដោយសារតែថ្មីៗនេះ មានការជូនដំណឹងពីក្រសួងសុខាភិបាលស្តីអំពីការរាតត្បាតរបស់មេរោគ COVIC-19 នៅក្នុងប្រទេសថៃ ស្របពេលដែលច្រកព្រំដែនជាច្រើនត្រូវបានបិទជាបណ្តោះ អាសន្ន រយៈពេល ១៤ ថ្ងៃ។

ទន្ទឹមនឹងនេះ ក៏គេសង្កេតឃើញថា ក្រុមហ៊ុនជាច្រើននៅក្នុងទីក្រុងបាងកក ក៏បានប្រកាសបិទទ្វារជាបណ្តោះអាសន្នផងដែរ គឺមានរយៈពេល ២១ ថ្ងៃ ដែលបញ្ហានេះហើយទើបតម្រូវឲ្យពលករជាច្រើននាក់ចាំបាច់ត្រូវធ្វើដំណើរវិលត្រឡប់ទៅកាន់ស្រុកកំណើតវិញផងដែរ ដើម្បីរង់ចាំស្ថានការណ៍មានភាពធូរស្រាលឡើងវិញ។

ដោយឡែកនៅក្នុងក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្តក្រុង របស់ក្រុមហ៊ុន ម៉ឈីត គឺក្រសួងសាធារណការរបស់ប្រទេសថៃ ក៏មានការរឹតបន្តឹងទៅលើការពិនិត្យសុខភាពរបស់អ្នកធ្វើដំណើរផងដែរ ដូចជាការពិនិត្យកម្តៅ និងការពិនិត្យទៅលើការឈឺថ្កាត់របស់ពលករជាដើម ដើម្បីជួយការពារដល់ចម្លងមេរោគដល់អ្នកដទៃ ដែលកំពុងធ្វើដំណើររួមគ្នា ដោយឡែកពលករ និងអ្នកដំណើរភាគច្រើន សុទ្ធសឹងតែបានពាក់ម៉ាស់ទាំងអស់ក្នុងការធ្វើដំណើរដើម្បីការពារទៅលើសុខភពរបស់ខ្លួនគេផ្ទាល់៕ សោ និយមរ័ត្ន

## ច្រកព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែតបន្តបើក១យប់ទល់ភ្លឺដើម្បីឲ្យពលករខ្មែរ សម្រុកឆ្លងដែនមុនព្រំដែនបិទម៉ោង៦ព្រឹកថ្ងៃ២៣មីនា

http://www.rasmeinews.com/ March 23, 2020, 7:24 AM ដោយ ៖ ភ្នំស្វាយ

ច្រកព្រំដែនអន្តរជាតិខ្លងលឹកស្រុកអារញ្ញប្រាថេតខេត្តស្រះកែវ -ប៉ោយប៉ែតក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យបន្តបើកមួយទល់ភ្លឺ ដើម្បីឲ្យពលរដ្ឋខ្មែរ ថៃសម្រុកឆ្លងដែនមុនព្រំដែនបិទម៉ោង៦ព្រឹក ថ្ងៃទី២៣ ខែមីនានេះ។ ក្នុងនោះ គេសង្កេតឃើញថា អ្នកសម្រុកឆ្លងដែនចុងក្រោយមានសមាសភាពជាពលករ ខ្មែរដែលទៅធ្វើការនៅប្រទេសថៃបន្តវិលត្រឡប់ច្រើនជាងគេ ។ បន្ទាប់មក ភ្ញៀវបរទេសចម្រុះនិងពលរដ្ឋកម្ពុជានិងពលរដ្ឋថៃដែលត្រូវវិល

មកប្រទេសខ្លួនវិញ ។ ប៉ុន្តែក្នុងនោះ ក៏មានពលរដ្ឋកម្ពុជានិងពលរដ្ឋថៃដែលត្រូវនាំយកឥវ៉ាន់ឬរបស់ប្រើប្រាស លុយ កាក់ជាដើមក៏ឆ្លងដែនទៅ ឆ្លងមកប្រទេសកម្ពុជាឬប្រទេសថៃដើម្បីស្នាក់នៅចំនួន១៤ថ្ងៃ ជារយៈពេលដែលព្រំដែន ត្រូវបិទពីម៉ោង៦ព្រឹកថ្ងៃទី២៣ខែមីនា។

សូមបញ្ជាក់ថា ច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត-ខ្លងលឹក និងច្រកតំបន់២ទៀត(ម៉ាឡៃ -ណងព្រីនិងបឹង ត្រកួន -តាប្រាយ៉ា) ត្រូវបិទ១៤ថ្ងៃ បន្ទាប់ពីអាជ្ញាធរខេត្តស្រះកែវ ចេញលិខិតប្រកាសកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ ២០២០និង ហើយនិងកិច្ចប្រជុំទ្វេភាគីរវាងលោកអ៊ុំរាត្រី អភិបាលខេត្តបន្ទាយមានជ័យ ព្រះរាជាណាចក្រកម្ពុជានិង លោក វ៉ាផាន់ សុវាណុន អភិបាលខេត្តស្រះកែវព្រះរាជាណាចក្រថៃ នៅស្រុកអារញ្ញប្រាថេតកាលពីព្រឹកថ្ងៃទី២២ ខែមីនា។ គឺបិទរយៈពេល១៤ថ្ងៃ គិតពីម៉ោង៦ព្រឹក ពីថ្ងៃទី២៣ ខែមីនាដល់ដល់ម៉ោង១០យប់ ថ្ងៃទី៥ ខែមេ សា។ ច្រកខ្លងលឹក -ប៉ោយប៉ែត បិទតែមនុស្សនិងរទេះអូសដឹកឥវ៉ាន់ប៉ុណ្ណោះ ឯរថយន្តដឹកទំនិញធុនធំ (ពិសេសពី ថៃមកកម្ពុជា) នៅដំណើរការធម្មតាទេ ។ ឯច្រកព្រំដែនតំបន់២ទៀត គឺបិទទាំងមនុស្សទាំង ទំនិញ ។

ការបិទដែលស្នើឡើងនេះដោយសារមូលហេតុស្ថានភាពនៃការរីករាលដាលវីរុសកូវីដ១៩(COVID-9) រាល ដាលជាសាកលទូទាំងពិភពលោកនិងនៅកម្ពុជា ពិសេសការឆ្លងដែនរវាងប្រជាពលរដ្ឋនៃខេត្តបន្ទាយមានជ័យ ព្រះ រាជាណាចក្រកម្ពុជានិងខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ ។ រយៈពេលបិទច្រកព្រំដែននេះ មិនដូចគ្នាទេ ។គឺតាម តម្រូវការនៃខេត្តសាមុីជាប់ព្រំដែនកម្ពុជាដែលភាគច្រើនបានបិទពីថ្ងៃទី១៩ខែមីនរហូតទាល់តែស្ថានភាពមេរោគ/ជ ម្ងឺកូវីដ ១៩ នេះធូស្រាលឡើងវិញ៕

## លោក ហេង សួរ អំពាវនាវពលករខ្មែរត្រឡប់ពីប្រទេសថៃ កុំប្រញាប់ស្និទ្ធស្នាលជាមួយគ្រួសារ

http://www.freshnewsasia.com/ 2020-03-22

**(ភ្នំពេញ)៖** លោក ហេង សួរ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអ្នកនាំពាក្យ បានអំពាវនាវដល់ប្រជាពលរដ្ឋទើបត្រឡប់មកពីបរទេស កុំប្រញាប់ស្និទ្ធស្នាលជាមួយក្រុមគ្រួសារ ដោយរង់ចាំឱ្យ បានរយៈពេល១៤ថ្ងៃតាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីបង្ការការឆ្លងរាលដាលជំងឺបង្កដោយមេរោគកូវី ដ១៩ (COVID-19)។ ការអំពាវនាវរបស់លោក ហេង សួរ បានធ្វើឡើងនៅចំពេលប្រជាពលរដ្ឋខ្មែរបម្រើការងារនៅ ប្រទេសថៃ កំពុងនាំគ្នាសម្រុកត្រឡប់មកស្រុកកំណើតវិញនៅថ្ងៃអាទិត្យ ទី២២ ខែមីនា ឆ្នាំ២០២០នេះ។ ប្រជា ពលរដ្ឋខ្មែរដែលបម្រើការងារនៅក្នុងប្រទេសថៃ នៅថ្ងៃនេះបាននាំគ្នាសម្រុកត្រឡប់មកស្រុកកំណើតវិញ ដោយមិន ដឹងពីមូលហេតុនោះឡើយ។ តាមច្រកព្រំដែននៃខេត្តជាប់ប្រទេសថៃដូចជា នៅខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យជាដើម ត្រូវបានគេរាយការណ៍ថា មានពលរដ្ឋខ្មែរច្រើនជាងពាន់នាក់បាននាំគ្នាត្រឡប់មកស្រុក កំណើតវិញ។

ការត្រឡប់មកស្រុកយ៉ាងគំហុករបស់ប្រជាពលរដ្ឋខ្មែរ ដែលធ្វើការនៅក្នុងប្រទេសថៃនេះ នាំឱ្យមានការ ព្រួយបារម្ភខ្លាចពួកគេនាំមកទាំងមេរោគកូវីដមកជាមួយ ខណៈការឆ្លងមេរោគកូវីដ១៩នៅប្រទេសថៃមានការកើន ឡើង។ មកដល់ត្រឹមថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០នេះ ប្រទេសថៃ មានអ្នកឆ្លងមេរោគកូវីដ១៩ហួតដល់ជិត ៦០០ នាក់ហើយ។ ការឆ្លងនេះ មានអត្រាខ្ពស់ក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ។ ផ្តើមចេញពីការបារម្ភខ្លាចអ្នកត្រ ឡប់មកពីប្រទេសថៃនេះនាំទាំងមេរោគកូវីដ១៩ មកចម្លងដល់សាច់ញាតិ និងក្រុមគ្រួសារនៅក្នុងស្រុកនេះហើយ ទើបលោក ហេង សួរ ចេញមកអំពាវនាវកុំឱ្យមានទំនាក់ទំនងស្និទ្ធស្នាលរវាងអ្នកត្រឡប់មកពីប្រទេសថៃជាមួយ ក្រុមគ្រួសារ និងសាច់ញាតិ។

លោក ហេង សួរ បានអំពាវនាវនៅលើទំព័រ Facebook យ៉ាងដូច្នេះ «បងប្អូនដែលទើបមកពីខេត្តឆ្ងាយ ឬបរទេស មេត្តាកុំអាលស្និទ្ធស្នាលជាមួយក្រុមគ្រួសារពេក! សូមរង់ចាំ ១៤ថ្ងៃសិន ប្រសិនជាអ្នកស្រឡាញ់គ្រួសារអ្នក»។ ពាក់ព័ន្ធនឹងពលរដ្ឋខ្មែរទើបត្រឡប់មកពីប្រទេសថៃនេះដែរ រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាអ្នកនាំពាក្យក្រសួង លោកស្រី ឱ វណ្ណឌីន បានចេញមកអំពាវនាវផងដែរ ដល់អ្នកត្រឡប់មកពីប្រទេសថៃ ត្រូវដាក់ខ្លួនឯងឱ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ដោយមិនត្រូវមានទំនាក់ទំនងជាមួយក្រុមគ្រួសារនោះទេ។ បន្ថែមពីលើនោះ ត្រូវអនុវត្តន៍តាមវិធានអនាម័យទាំងឡាយដែលដាក់ចេញដោយក្រសួងសុខាភិបាល ដើម្បីបញ្ចៀសការចម្លងមេរោគកូវីដ១៩។

លោកស្រី ឱ វណ្ណឌីន ក៏បានអំពាវនាវដល់អាជ្ញាធរនៅតាមមូលដ្ឋានចូលរួមទប់ស្កាត់ការចម្លងមេរោគនេះតាមរយៈស្រង់ស្ថិតិរបស់ប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃ ហើយណែនាំឱ្យពួកគាត់អនុវត្តន៍តាមវិធានរបស់ក្រសួងសុខាភិបាលដែលបានដាក់ចេញនោះ។ លោកស្រីអ្នកនាំពាក្យ បានអំពាវនាវទៅកាន់អ្នកទើបត្រឡប់មកពីថៃត្រូវតាមដានសុខភាពរបស់ខ្លួន បើមានអ្វីខុសប្រក្រតី ឬមានរោគសញ្ញាណាមួយសង្ស័យពាក់ព័ន្ធជំងឺបង្កដោយមេរោគកូវីដ១៩ សូមប្រញាប់ទាក់ទងទៅកាន់ក្រុមគ្រូពេទ្យ ឬរាយការណ៍តាមលេខទូរស័ព្ទ ១១៥។ លោកស្រី ឱ វណ្ណឌីន បានអំពាវនាវដោយទទូចដល់ប្រជាពលរដ្ឋខ្មែរឱ្យចូលរួមអនុវត្តន៍វិធាន និងដំបូន្មានរបស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ឬកាត់បន្ថយការឆ្លងរាលដាលមេរោគកូវីដ១៩នៅក្នុងសហគមន៍ ឬនៅក្នុងភូមិឋានដែលខ្លួនរស់នៅ៕

## ឯកឧត្តម គួច ចំរើន ផ្ញើសារសំលេងជាបន្ទាន់ឲ្យមន្ត្រីចុះណែនាំពលករត្រលប់ពីថៃ កុំឲ្យប៉ះពាល់ក្រុមគ្រួសារ ឬអ្នកភូមិ និងនៅដាច់ដោយឡែក១៤ថ្ងៃសិន

https://khmernote.com.kh/ March 22, 2020 Khmernote

យោងតាមការបង្ហោះបញ្ជាក់ពី រដ្ឋបាលខេត្តព្រះសីហនុ បានឲ្យដឹងថា មុននេះមានសារជាសំលេងបន្ទាន់មួយរបស់ ឯកឧត្តម គួច ចំរើន អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ ជូនលោកអភិបាលក្រុងស្រុក មន្ទីរអង្គភាព កងកម្លាំងប្រដាប់អាវុធទាំងអស់ ដើម្បីអោយជួយមើលកិច្ចការងារមួយដ៏សំខាន់ដែលទាក់ទងទៅនឹងបងប្អូនប្រជាពលរដ្ឋ និងពលកររបស់យើង ដែលបានវិលត្រឡប់ពីប្រទេសថៃវិញនៅថ្ងៃនេះ។

ឯកឧត្តម គួច ចំរើន ក៏បានស្នើថា ឲ្យមន្ត្រីមូលដ្ឋានត្រូវតែធ្វើការណែនាំឲ្យបានច្បាស់លាស់ទៅដល់គ្រប់ពលករ ដែលត្រលប់ពីថៃ គឺសុំឲ្យពួកគាត់មកដល់ក្រុមគ្រួសារហើយ ត្រូវស្នាក់នៅដាច់ដោយឡែក កុំឲ្យមានការប៉ះពាល់ក្រុមគ្រួសារ ឬអ្នកភូមិផ្សេងទៀតក្នុងរយៈពេល១៤ថ្ងៃ ហើយក្នុងរយៈពេលនេះប្រសិនបើមានបញ្ហាសុខភាពសូមប្រញាប់ទាក់ទងទៅគ្រូពេទ្យ ដើម្បីធ្វើការពិនិត្យសុខភាពជាបន្ទាន់៕

## ថ្ងៃនេះច្រកទ្វារអន្តរជាតិប៉ោយប៉ែតកកស្ទះខុសប្លែកពីរាល់ដង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១៤:៣២ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ បន្ទាប់ពីវីរុសកូវីដ-១៩កំពុងរាតត្បាតលើពិភពលោកគួរឲ្យព្រួយបារម្ភ ម្យ៉ាងស្របពេលដែលភាគីថៃប្រកាសបិទច្រកទ្វារអន្តរជាតិ និងច្រករបៀងនានាជាច្រើនកន្លែងតាមខេត្តជាប់ព្រំដែនកម្ពុជា ដើម្បីទប់ស្កាត់ជំងឺប្រភេទនេះ គេសង្កេតឃើញអ្នកស្រុក និងពលករសម្រុកឆ្លងកាត់ព្រំដែនអន្តរជាតិប៉ោយប៉ែតខ្លងលឹកខុសពីសព្វមួយដងនាថ្ងៃទី២២ មីនា ឆ្នាំ២០២០ នេះ។ ចំណុចរង្វង់មូលនិងមាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតថ្ងៃទី២២ មីនា ឆ្នាំ ២០២០ មានការកកស្ទះស្ទើរពេញមួយថ្ងៃ ដោយសារយានយន្ត និងអ្នកស្រុកឆ្លងកាត់ព្រំដែនចូលទៅទិញរបស់របរនិងទំនិញផ្សេងៗទុកហូបបន្ទាប់ពីមានព័ត៌មានថា ភាគីថៃនឹងបិទច្រកទ្វារអន្តរជាតិប៉ោយប៉ែត

យៈពេល១៤ថ្ងៃចាប់ពីថ្ងៃទី២៣ មិនា។ ដោយឡែកក៏មានពលករវិលត្រឡប់ពីថៃជាហូរហែនៅច្រកទ្វារអន្តរជាតិខាងលើនេះខុសសព្វមួយដងដូចគ្នា។

ពេលសាកសួរ ក្រុមពលករខ្លះអះអាងថា ដំបូងពួកគាត់ប្រុងឆ្លងកាត់ច្រកទ្វារអន្តរជាតិដូងក្នុងស្រុកកំរៀង ខេត្តបាត់ដំបង ប៉ុន្តែដោយសារភាគីថៃបិទច្រកទ្វារអន្តរជាតឡែមឈមច្រកអន្តរជាតិដូងកម្ពុជា ទើបពួកគាត់នាំគ្នាបន្តដំណើរមកឆ្លងកាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតវិញ ។ ចំណែកពលករខ្លះក៏ធ្វើដំណើរពីខេត្តនានាលើដីថៃមកឆ្លងព្រំដែនអន្តរជាតិប៉ោយប៉ែតតែម្តង។ រីឯពលករមួយចំនួនធំនិយាយថា ការវិលត្រឡប់មកចូលរួមពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនាពេលខាងមុខ។

ដោយឡែកពលករមួយចំនួនតូចនិយាយថា ពួកគាត់វិលត្រឡប់មកស្រុកដោយមិនឲ្យថៅកែដឹងទេ ព្រោះខ្លាចភាគីថៃបិទព្រំដែនយូរ និងម្យ៉ាងព្រួយបារម្ភអំពីការឆ្លងវីរុសកូវីដ-១៩តែម្តង។ ការកកស្ទះច្រកទ្វារអន្តរជាតិប៉ោយប៉ែតនៅថ្ងៃទី២២ មីនានេះ សមត្ថកិច្ចប្រចាំការនៅចំនុចវង្វង់មូលច្រកទ្វារអន្តរជាតិប៉ោយប៉ែតម្នាក់បង្ហើបឱ្យដឹងថា ដោយសាអ្នកស្រុកនាំគ្នាបើកបរយានយន្តចូលទៅផ្សាររុងក្លឿងទិញទំនិញនិងម្ហូបអាហារទុកបរិភោគនៅពេលភាគីថៃបិទច្រកអន្តរជាតិបណ្តោះអាសន្ន១៤ថ្ងៃ។ ពាក់ព័ន្ធនឹងជំនួបប្រជុំរវាងអាជ្ញាធរខេត្តបន្ទាយមានជ័យជាមួយអាជ្ញាធរខេត្តស្រះកែវលើទឹកដីថៃក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ កាលពីព្រឹកថ្ងៃទី២២ មីនា ឆ្នាំ២០២០នេះ បើតាមប្រភពពីសមត្ថកិច្ចដែលបានទៅចូលរួមបង្ហើបឱ្យដឹងថា ជាលទ្ធផលភាគីថៃបានជូនដំណឹងដូចខាងក្រោម ៖

១-បិទការធ្វើដំណើរចេញ-ចូលរបស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិរយៈពេល១៤ថ្ងៃ គិតចាប់ពីថ្ងៃទី២៣ មីនា ឆ្នាំ២០២០ ដល់ថ្ងៃទី៥ មេសា, ២-ចំពោះមធ្យោបាយដឹកទំនិញធុនធំនៅដំណើរការជាធម្មតា ប៉ុន្តែតម្រូវឲ្យមានអ្នកបើកបរតែម្នាក់គត់, ៣-អ្នកជំងឺសង្គ្រោះបន្ទាន់អនុញ្ញាតឲ្យចូលជាធមតា និង៤-មធ្យោបាយផ្សេងៗដូចជារថយន្តលក្ខណៈគ្រួសារ ម៉ូតូ រទេះរុញ កម្មករ អាជីវករលក់ដូរក្នុងផ្សាររុងក្លឿមិនអនុញ្ញាតឲ្យចេញចូលឡើយ៕ (កែសម្រួលដោយ ៖ ធីតា)

## ពលករខ្មែរជាង១០០នាក់ បានវិលត្រឡប់មកកាន់ខេត្តព្រះវិហារ ហើយដាក់ឲ្យនៅដាច់ដោយឡែក

---

http://kampucheathmey.com/ 23/3/2020 11:23 Am

ព្រះវិហារ ៖ ពលករខ្មែរចំនួនជាង១០០នាក់ គិតត្រឹមម៉ោង៨និង៣០នាទីព្រឹក បានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ហើយដោយមានការចុះណែនាំផ្ទាល់ពីមន្ត្រីមន្ទីរសុខាភិបាលខេត្ត និងអាជ្ញាធរ បានដាក់បងប្អូនទាំងនោះ ឲ្យនៅដោយឡែក។ នេះបើតាមប្រភពពីមន្ទីរព័ត៌មានខេត្តព្រះវិហារ គោរពរាយការណ៍ជូនលោកខៀវ កាញារីទ្ធ ហើយត្រូវបានលោករដ្ឋមន្ត្រីរូបនេះ ធ្វើការផ្សព្វផ្សាយនៅលើហ្វេសប៊ុកផ្លូវការរបស់ខ្លួននៅព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០។ មន្ទីរព័ត៌មានខេត្តព្រះវិហារ បានគោរពរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងព័ត៌មានដូច្នេះថា «ឯកឧត្តមរដ្ឋមន្ត្រីជូនជ្រាប ៖ ចំនួនប្រជាពលករខ្មែរ ១១៨នាក់ ស្រី៦៣នាក់ ដែលបានវិលត្រឡប់មកកាន់ស្រុកកំណើតវិញគិត ត្រឹមម៉ោង ៨:៣០នាទី ថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២០ ដែលមានដូចខាងក្រោម ៖

១/ស្រុករវៀងចំនួន១៨នាក់ ស្រី ១៤នាក់ មកពីប្រទេស (ថៃ១៣, ចិន០២នាក់,ម៉ាឡេស៊ី០៣នាក់) ។

២/ស្រុកគូលែនចំនួន១៣នាក់ ស្រី០៥នាក់ (ថៃ១១នាក់,ម៉ាឡេស៊ី០១នាក់ និងកូរ៉េ០១នាក់) ។

៣/ក្រុងព្រះវិហារចំនួន០៦នាក់ ស្រី០៥នាក់ (ថៃ) ។

៤/ស្រុកជ័យសែនចំនួន០៤នាក់ ស្រី០២នាក់ (ថៃ) ។

៥/ស្រុកត្បែងមានជ័យចំនួន០៥នាក់ ស្រី០២ (ថៃ) ។

៦/ស្រុកសង្គមថ្មីចំនួន៣០នាក់ ស្រី១២នាក់ (ថៃ) ។

៧/ស្រុកឆែបចំនួន៣១នាក់ ស្រី២២នាក់(ថៃ) ។

៨/ស្រុកជាំក្សាន្តចំនួន១១នាក់ ស្រី០៣នាក់។

ប្រភពបន្តថា «ដោយមានការចុះណែនាំផ្ទាល់ពីមន្ត្រីមន្ទីរសុខាភិបាលខេត្ត និងអាជ្ញាធរ បានដាក់បងប្អូនទាំងនោះឲ្យនៅដោយឡែក។ ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់»។ គួរបញ្ជាក់ថា អ្នកឆ្លងជំងឺកូវីដ១៩ នៅកម្ពុជា គិតត្រឹមម៉ោង១០ព្រឹក ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ មានចំនួនសរុប៨៦នាក់ហើយ ក្នុងនោះបានជាសះស្បើយ២នាក់ (ចិន១នាក់ អង់គ្លេស១នាក់)៕ **សម្រួលដោយ ៖ មនោ**

## ពលករប្រជាពលរដ្ឋខ្មែរ បានបង្ខំចិត្តឆ្លងកាត់តាមអូរច្រករបៀង (ស្លាបឆ្វេង) របស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 22-03-2020

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ចាប់ពីវេលាម៉ោង ១២និង១០នាទីយប់ រហូតដល់ម៉ោង ០៤និង០០នាទីទាបភ្លឺ មានពលករប្រជាពលរដ្ឋខ្មែរ បានបង្ខំចិត្តឆ្លងកាត់តាមអូរច្រករបៀង (ស្លាបឆ្វេង) របស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ខណៈពេលប្រទេសថៃ ធ្វើការបិទច្រកទ្វារព្រំដែនជាបណ្តោះអាសន្ន បានរកឃើញ និងនាំពួកគាត់មកទីតាំងប៉ុស្តិ៍ ដើម្បីសួរនាំ។ បន្ទាប់ពីសួរនាំរួច កម្លាំងប៉ុស្តិ៍សហការណ៍ជាមួយ មន្ត្រីចត្តាឡីស័ក បានពិនិត្យសុខភាព របស់ពួកគាត់ និងសួរនាំពត៌មានរបស់ពួកគាត់ ដើម្បីបំពេញចូលក្នុងសេចក្តីប្រកាសសុខភាព របស់អ្នកដំណើរបានគ្រប់ៗគ្នា ចប់សព្វគ្រប់៕

## ប្រជាពលរដ្ឋខ្មែរ ដើរឆ្លងកាត់ចេញពីប្រទេសថៃ ចូលប្រទេសកម្ពុជា តាមអូរភ្លឹមខាងស្តាំប៉ុស្តិ៍ត្រួតពិនិត្យ ចម្ងាយប្រហែល ១.៣៥០ម៉ែត្រ

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នាវេលាម៉ោង ០៦និង៣០នាទី ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ មានប្រជាពលរដ្ឋខ្មែរ ដើរឆ្លងកាត់ចេញពីប្រទេសថៃ ចូលប្រទេសកម្ពុជា តាមអូរភ្លឹមខាងស្តាំប៉ុស្តិ៍ត្រួតពិនិត្យ ចម្ងាយប្រហែល ១.៣៥០ម៉ែត្រ។ កម្លាំងនគរបាលប៉ុស្តិ៍ បានឲ្យដឹងថា ពលរដ្ឋខាងលើនេះ ត្រូវបានឃាត់ទុកដោយអាជ្ញាធរខេត្តប៉ៃលិន ០១ក្រុម ដឹកនាំដោយអភិបាលខេត្ត និងមានការចូលរួមពី រដ្ឋបាលខេត្ត, កម្លាំងស្នងការដ្ឋាននគរបាលខេត្ត, កម្លាំងរាជអាវុធហត្ថ, កម្លាំងរបស់មន្ទីរពេទ្យខេត្ត និងការិយាល័យទំនាក់ទំនងព្រំដែនប្រចាំច្រកព្រំ។ បន្ទាប់មកមន្ត្រីមន្ទីរពេទ្យខេត្ត បានអប់រំណែនាំ និងពិនិត្យ សុខភាព ជូនដល់ប្រជាពលរដ្ឋ ក្រោយមកឯកឧត្តម ផាន់ ចាន់ អភិបាល នៃគណៈអភិបាលខេត្ត បានធ្វើការអប់រំណែនាំដល់ពួកគាត់ ដើម្បីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ១៩ រួច ឲ្យប្រជាពលរដ្ឋទាំងនោះ វិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 20-03-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង៥០នាទី ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០២នាក់នេះ មាន ១. ឈ្មោះ ចាន់ សារិន ភេទប្រុស អាយុ ៥៤ឆ្នាំ មានទីលំនៅ

បច្ចុប្បន្ន ស្ថិតក្នុងភូមិថ្មី ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង និង២. ឈ្មោះ លឹម សារឿន ភេទប្រុស អាយុ ៣៧ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិបាំងរលឹម ក្រុងប៉ៃលិន ខេត្តប៉ៃលិន។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ពលករខ្មែរប្រមាណ៥00នាក់ កំពុងជាប់លើដីថៃ ក្រោយបិទច្រកព្រំដែន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១២:០២ មុំត សារុន

ខេត្តបន្ទាយមានជ័យ ៖ គិតត្រឹមម៉ោងជាង១១ថ្ងៃត្រង់ទី២៣ មីនា នេះ មានពលករខ្មែរកំពុងជាប់គាំងនៅលើទឹកដីថៃ ។ បើតាមអាជ្ញាធរថៃបានប្រាប់ខាងកម្ពុជាថា គឺពលករខ្មែរដែលកំពុងជាប់គាំង គឺមានប្រមាណ៥០០នាក់ ។ សូមបញ្ជាក់ថា៖ ព្រឹកនេះថៃបិទទ្វារច្រកថ្មើរជើងទាំងសងខាង (មានវីដេអូ) គួររំលឹកថា ភាគីថៃ កាលពីព្រឹកថ្ងៃទី២៣ មីនា ដដែល ស្ថិតនៅច្រកទ្វារព្រំដែនខាងថ្មើរជើងទាំងសងខាងស្ពានមិត្តភាពកម្ពុជា-ថៃនៃច្រកទ្វារអន្តរជាតិប៉ោយប៉ែតខ្លងលឹក ត្រូវបានភាគីថៃបិទជាស្ថាពរលើកលែងតែផ្លូវធំលើស្ពានព្រំដែនបើកជាធម្មតាតាំងពីម៉ោង៦ព្រឹក ។

កាលពីវេលាម៉ោងជិត១២យប់រំលងអធ្រាត្រថ្ងៃទី២២ មីនា ទើបតែបិទទ្វារព្រំដែន ដោយសារថយន្តនិងរទេះដឹកទំនិញឆ្លងព្រំដែនបន្តធ្វើចរាចរណ៍ ហើយពលករវិលត្រឡប់ពីដីថៃក៏មានជាហូរហែ ។ ចំណែកដងផ្លូវចាប់ពីចំណុចរង្វង់រហូតដល់មាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតកាលពីថ្ងៃទី២២ មីនា មានការកកស្ទះតាំងពីព្រឹករហូតដល់យប់។ ទិដ្ឋភាពពេលរាត្រីថ្ងៃទី២២ មីនា ដងផ្លូវចាប់ពីចំណុចរង្វង់មូលរហូតដល់ស្ពានព្រំដែន គេសង្កេតឃើញរថយន្តតូចធំរទេះអូសទំនិញកកស្ទះពេញផ្លូវ២ទៅ៣ជួរ ។ ចំណែកទីតាំងបំពេញបែបបទប័ណ្ណព្រំដែនចូលប្រទេស (Border Pass)និងទីតាំងបំពេញបែបបទចូលប្រទេសArrival គេឃើញពលករវិលត្រឡប់ពីថៃយ៉ាងច្រើនកុះកររហូតដល់ពេលបិទព្រំដែន ។ ភ្ញៀវឆ្លងកាត់ព្រំដែនចូលប្រទេសត្រូវបានមន្ត្រីនិងសមត្ថកិច្ចជំនាញធ្វើកាប្រើឧបករណ៍វាស់ស្ទង់កំដៅគ្រប់គ្នាក្រែងមានអ្នកផ្ទុកវីរុសកូវីដ-១៩។

## ព្រឹទ្ធសភា ឯកភាពទាំងស្រុងចំពោះសេចក្តីព្រាងច្បាប់ចំនួន៦ ដែលអនុម័តដោយរដ្ឋសភា

http://www.freshnewsasia.com/ 2020-03-23

**(ភ្នំពេញ)៖** សេចក្តីព្រាងច្បាប់បង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ រួមទាំងសេចក្តីព្រាងច្បាប់ចំនួន៥ផ្សេងទៀត បានឆ្លងផុតព្រឹទ្ធសភាហើយ នៅក្នុងសម័យប្រជុំវិសាមញ្ញ នាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០នេះ ក្រោមអធិបតីភាពសម្តេច សាយ ជុំ ប្រធានព្រឹទ្ធសភា។ សមាជិកព្រឹទ្ធសភា ដែលចូលរួមសម័យប្រជុំវិសាមញ្ញនេះ មានចំនួន៥២រូប ដែលបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់សរុបចំនួន៦ ដែលរៀបចំដោយរាជរដ្ឋាភិបាល ហើយត្រូវបានអនុម័តដោយរដ្ឋសភា ក្នុងសម័យប្រជុំវិសាមញ្ញកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០។ **សេចក្តីព្រាងច្បាប់ទាំង៦នោះរួមមាន៖**

**១៖** សេចក្តីព្រាងច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**២៖** សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

**៣៖** សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

៤៖ សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

៥៖ សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៦៖ សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម៕

## ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២០

### ពលរដ្ឋខ្មែរជាង៤00នាក់ ជាប់គាំលើទឹកដីថៃ ត្រូវបានអនុញ្ញាតិ ឲ្យឆ្លងដែនមកកម្ពុជាហើយ នៅវេលាម៉ោង១រសៀលនេះ

https://dap-news.com/national/ BySKK106 Posted on March 23, 2020

ប៉ោយប៉ែត៖ ពលរដ្ឋខ្មែរជាង៤០០នាក់ ដែលជាប់គាំលើទឹកដីថៃ ត្រូវបានអនុញ្ញាតិឲ្យឆ្លងដែន មកកម្ពុជាហើយ នៅវេលាម៉ោង១រសៀលនេះ ក្រោយពីខាងអាជ្ញាធរថៃ ពិនិត្យសុខភាពរួច។ នគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិប៉ោយប៉ែត បានឲ្យដឹងថា ពលរដ្ឋទាំងនោះបានចូលមកដល់កម្ពុជាហើយ ពេលនេះត្រូវបានអាជ្ញាធរ ដឹកជញ្ជូនយកទៅដាក់នៅមណ្ឌលសំចតបណ្តោះអាសន្ន ដាក់ដាច់ដោយឡែកពីគេ ដើម្បីតាមដានជម្ងឺ និងត្រួពិនិត្យសុខភាពសិន។

បញ្ជាក់ថា នៅថ្ងៃនេះគេបានឃើញវត្តមានលោក អ៊ុ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានដឹកនាំមន្ត្រីរាជការ កម្លាំងប្រដាប់អាវុធគ្រប់ផ្នែកពាក់ពន្ធ័ បានចុះពិនិត្យសស្ថានភាពច្រក និងចុះសួរសុខទុក្ខដល់បងប្អូនពលករដែលត្រឡប់មកពីប្រទេសថៃផងដែរ៕

### អាជ្ញាធរខេត្តកណ្តាល គ្រោងយកសាលារៀន២កន្លែង ត្រៀមព្យាបាលពលករកម្ពុជា វិលត្រឡប់មកពីថៃវិញ មានផ្ទុកជំងឺ covid-១៩

http://www.cen.com.kh/ March 23, 2020

ខេត្តកណ្តាល៖ អាជ្ញាធរខេត្តកណ្តាល គ្រោងនឹងយកសាលារៀនចំនួន២កន្លែង ដើម្បីត្រៀមក្នុងករណីមានការឆ្លងធ្ងន់ធ្ងរ សម្រាប់ជាកន្លែងដាក់ និងព្យាបាលអ្នកជំងឺ covid-១៩ ក្នុងខេត្តកណ្តាល ស្របពេលដែលមានពលករកម្ពុជាប្រហែល១០០០នាក់ បានត្រឡប់មកក្នុងប្រទេសកម្ពុជា តាមច្រកដូង ខេត្តបាត់ដំបង កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០។

នៅព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ លោក គង់ សោភ័ណ្ឌ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល បានអញ្ជើញដឹកនាំកិច្ចប្រជុំ ស្តីពីការចាត់វិធានការ ទប់ស្កាត់ជំងឺកូវីដ ១៩ និងវិធានការចំពោះប្រជាពលរដ្ឋ ដែលបានត្រឡប់មកពីប្រទេសថៃ។ ក្នុងកិច្ចប្រជុំនេះដែរ មានការអញ្ជើញចូលរួមពី កងកម្លាំងទាំង៣ អភិបាលស្រុក ក្រុង និងមន្ទីរអង្គភាពជុំវិញខេត្ត សរុប៩០នាក់។ មានប្រសាសន៍ក្នុងកិច្ចប្រជុំលោកគង់សោភ័ណ្ឌ អភិបាលខេត្តកណ្តាល បានបញ្ជាក់ថា ដោយពលករកម្ពុជាប្រហែល១០០០នាក់ បានត្រឡប់មកក្នុងប្រទេសកម្ពុជា តាមច្រកដូង ខេត្តបាត់ដំបង កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០។ លោកបានស្នើឲ្យមន្ត្រីជំនាញ និងលោកអភិបាលក្រុង ស្រុក ពិសេសអាជ្ញាធរ ភូមិ ឃុំ ត្រូវមានវិធានការដូចជា៖ កំណត់ចំនួនពលករ ទើបចូលមកពីប្រទេសថៃឲ្យបានជាក់លាក់ តាមភូមិ ឃុំ ស្រុកនីមួយៗ។ ដាក់ពួកគាត់ឲ្យនៅដាច់ដោយឡែកចំនួន១៤ថ្ងៃ ហើយបើមានការសង្ស័យ ត្រូវនាំគាត់ទៅពិនិត្យ និងព្យាបាលជាបន្ទាន់។

លោកអភិបាល ក៏បានបញ្ជាក់បន្ថែមទៀតថា ខេត្តកណ្ដាល គ្រោងនឹងយកសាលារៀនចំនួន២កន្លែង ដើម្បីត្រៀមក្នុងករណីមានការឆ្លងធ្ងន់ធ្ងរ សម្រាប់ជាកន្លែងដាក់ និងព្យាបាលអ្នកជំងឺ covid-១៩ ក្នុងខេត្តកណ្ដាល។ លោកអភិបាលខេត្ត ក៏បានជំរុញឲ្យមន្ទីរអង្គភាពពាក់ព័ន្ធ និងអភិបាលក្រុង ស្រុកត្រូវបន្តចុះអប់រំ និងផ្សព្វផ្សាយ ជាលក្ខណៈយុទ្ធនាការជាប្រចាំ ក្នុងមូលដ្ឋានភូមិ ឃុំ ស្រុករបស់ខ្លួន នៅវិធីសាស្ត្រការធ្វើអនាម័យឲ្យបានញឹកញាប់ កុំមានការប្រមូលផ្តុំគ្នា ចេញក្រៅពាក់ម៉ាស់ឲ្យបានត្រឹមត្រូវ និងការបង្ការនៃការឆ្លងវីរុសកូវីដនេះ(covid19)។ ហើយលោកអភិបាលខេត្ត បានឧបត្ថម្ភ ដល់គ្រប់ស្រុក ក្រុង ក្នុងស្រុក ក្រុង នីមួយៗថវិកា៥លានរៀល និងបានណែនាំដល់ស្រុក ក្រុង រៀបចំបង្កើតគណៈកម្មការ ក្នុងការចាត់តាំងអនុវត្តឲ្យបានច្បាស់លាស់ ក្នុងការទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩នេះ៕ដោយៈកូឡាប

## រកឃើញពលករ១០នាក់ មានអាការៈលើសកំដៅ ខណៈពលករជាង៥០០នាក់ផ្សេងទៀត បានអនុញ្ញាតឲ្យទៅផ្ទះជាធម្មតា

https://dap-news.com/national/ ByTR110 Posted on March 23, 2020

**ភ្នំពេញ៖** ក្នុងចំណោមពលករជិត៦០០នាក់ ដែលបានធ្វើដំណើរចាកចេញពីប្រទេសថៃ តាមច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត ត្រូវបានអាជ្ញាធរ និងក្រុមគ្រូពេទ្យពិនិត្យរកឃើញភាពមិនប្រក្រតីចំនួន១០នាក់ ដោយមានអាការៈក្តៅខ្លួន ហើយត្រូវបាន ក្រុមគ្រូពេទ្យ បញ្ជូនទៅមន្ទីរពេទ្យបង្អែកជីថ្មី ដើម្បីយកទៅពិនិត្យព្យាបាលបន្ត។ គិតត្រឹមម៉ោង៧យប់ថ្ងៃ ២៣ ខែមីនា ឆ្នាំ២០២០នេះពលករដែលត្រឡប់ពីប្រទេសថៃ ប្រមាណជិត៦០០នាក់ ទាំងនៅស្ថានីយ៍រថភ្លើង និងមណ្ឌលសំចត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ត្រូវបានអាជ្ញាធរសម្រេច អនុញ្ញាតិឲ្យបន្តដំណើរទៅស្រុកកំណើតរៀងៗខ្លួនហើយ ក្រោយពីក្រុមគ្រូពេទ្យ ពិនិត្យឃើញថាពួកគាត់ គ្មានជម្ងឺក្លូត១៩។

បើតាមការសាកសួរបានឲ្យដឹងថា ភាគច្រើនពលរដ្ឋទាំងនោះគឺមកពីខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង បាត់ដំបង កំពង់ធំ សៀមរាប និងបន្ទាយមានជ័យ។ ទន្ទឹមគ្នានៃការវិលត្រឡប់នេះ អាជ្ញាធរ បានចែកបាយម្នាក់១ប្រអប់ ទឹកសុទ្ធ១ដប ហើយក៏មានការជួយការពារសុវត្ថិភាព ពីសំណាក់កម្លាំងនគរបាល និងកងរាជអាវុធ យ៉ាងយកចិត្តទុកដាក់ផងដែរ។ ចំណែក ពលករជាង៥០០នាក់ផ្សេងទៀត ពេលនេះ កំពុងរករថយន្តឈ្នួល ជិះទៅស្រុកកំណើតរៀងៗខ្លួនៗ ៕

## ពលរដ្ឋខ្មែរមកពីថៃ តាមច្រកអន្តរជាតិអូរស្មាច់ខេត្តឧត្តរមានជ័យជិត ៤០០នាក់ ត្រូវបានត្រួតពិនិត្យ តែមិនឃើញមានរោគសញ្ញា COVID-19 នោះឡើយ

http://www.freshnewsasia.com/ 2020-03-23

(ឧត្តរមានជ័យ)៖ ប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ ស្ថិតក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោងជិត ៤០០នាក់ ត្រូវបានធ្វើការត្រួតពិនិត្យ តែរកពុំឃើញមានប្រជាពលរដ្ឋណាម្នាក់សង្ស័យ និងមានរោគសញ្ញាមានជំងឺ COVID-19 នោះទេ។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានថ្លែងប្រាប់ភ្នាក់ងារព័ត៌មាន Fresh News ឲ្យដឹងនៅរសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០នេះថា «គិតត្រឹមម៉ោង ៣៖៤០នាទីថ្ងៃនេះ ប្រជាពលរដ្ឋខ្មែរ ៣៩៩នាក់ ក្នុងនោះមានស្រី ១៧០នាក់ ដែលត្រឡប់មកពីប្រទេសថៃ តាមច្រកអន្តរជាតិអូស្មាច់ ត្រូវបានធ្វើការត្រួតពិនិត្យ តែរកមិនឃើញមានពលរដ្ឋណាម្នាក់ សង្ស័យមានផ្ទុកជំងឺកូវីដ១៩ទេ។ លោក ឃ្លោក ហួត បានថ្លែងបញ្ជាក់ទៀតថា ក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ៣៩៩នាក់ ដែលបានធ្វើការត្រួតពិនិត្យនោះ មាន ១១២នាក់ រស់នៅក្នុងខេត្តឧត្តរមានជ័យ ក្នុងនោះមានស្រី ៦៦នាក់ផងដែរ ក្រៅពីនោះគឺរស់នៅតាមបណ្ដាខេត្តផ្សេងៗ។

លោកបញ្ជាក់ទៀតថា «សកម្មភាពត្រួតពិនិត្យក្នុងឱកាសនោះ យើងបានធ្វើការសួរនាំ ក៏ដូចជាការវាស់កំដៅ តែមិនមានអ្នកណាមួយសង្ស័យថា មានជំងឺកូវីដ១៩ទេ និងបានចែកសេចក្តីណែនាំ ពីការដាក់ខ្លួនដាច់ដោយឡែកចំនួន ១៤ថ្ងៃ ពេលទៅដល់លំនៅដ្ឋានវិញ»។

ជាមួយគ្នានោះលោកវេជ្ជបណ្ឌិត ឃ្លោក ហួត បានថ្លែងបញ្ជាក់ថា គណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ខេត្ត បានបើកកិច្ចប្រជុំមួយក្រោមវត្តមានលោក ប៉ែន កុសល្យ អភិបាលខេត្ត និងជាប្រធានគណៈកម្មការប្រយុទ្ធជំងឺកូវីដ១៩ខេត្ត បានសម្រេចយកទីតាំងវិទ្យាល័យតេជោ ហ៊ុន សែន ធ្វើជាទីតាំងសម្រាប់ដាក់បំរុងនៅពេលមានហានិភយ័ណាមួយកើតឡើងមានជំងឺកូវីត១៩ ដោយពេលនេះយើងបានរៀបចំគ្រែ និងសម្ភារមួយចំនួនហើយ លោកបានបញ្ជាក់ទៀតថា សម្រាប់ខេត្តឧត្តរមានជ័យរហូតមកដល់ល្ងាចថ្ងៃនេះ គឺមិនទាន់មាននណាម្នាក់មានជំងឺកូវីត១៩ទេ៕

## ស្នងការនគរបាលខេត្តតាកែវ ណែនាំសមត្ថកិច្ចមូលដ្ឋានទាំងអស់ កំណត់ចំនួនពលករមកពីក្រៅប្រទេស ជាពិសេសថៃ ឱ្យបានច្បាស់លាស់ និងឱ្យនៅដាច់ដោយឡែក ១៤ថ្ងៃ

http://www.freshnewsasia.com/ 2020-03-23

**(តាកែវ)៖** ស្នងការនគរបាលខេត្តតាកែវ លោកឧត្តមសេនីយ៍ទោ សុខ សំណាង បានដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ ដល់ស្នងការរងនគរបាលទាំងអស់ ឲ្យបញ្ជាបន្តទៅអធិការនគរបាល តាមបណ្តាក្រុងស្រុក និងនាយនគរបាលប៉ុស្តិ៍ទាំង១០០ ត្រូវចាត់ការជាបន្ទាន់តាមដាន និងកំណត់ចំនួនមនុស្សទាំងអស់ ដែលបានមកពីក្រៅប្រទេស ជាពិសេសប្រទេសថៃ ដើម្បីណែនាំពួកគេ រស់នៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ការពារ COVID-19។

ភ្លាមៗក្រោយទទួលបានបទបញ្ជាពីលោកស្នងការ, លោកវរសេនីយ៍ឯក ធឹង រតនៈ ស្នងការរងទទួលផែនការងារគ្រប់គ្រងធនធានមនុស្ស នៃស្នងការដ្ឋាននគបាលខេត្តតាកែវ បានណែនាំដល់សមត្ថកិច្ចមូលដ្ឋាននៅក្នុងស្រុកគីរីវង់ ទាំងអស់ត្រូវចុះតាមដាន និងកំណត់ចំនួនពលករមកពីក្រៅប្រទេស ឱ្យបានច្បាស់លាស់ ហើយត្រូវចុះធ្វើការអប់រំពួកគាត់ ឱ្យនៅដាច់ដោយឡែកពីគេចំនួន ១៤ថ្ងៃសិន ដោយមិនត្រូវឱ្យពួកគាត់ នៅជិត ឬស្និតស្នាលមួយក្រុមគ្រួសារ បងប្អូន ឬអ្នកជិតខាងឡើយ ដើម្បីធ្វើយ៉ាងណាទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ នៅក្នុងសហគមន៏របស់បងប្អូនប្រជាពលរដ្ឋ។

ថ្លែងនៅចំពោះមុខសមត្ថកិច្ចមូលដ្ឋាននៅក្នុងស្រុកគីរីវង់ នៅព្រឹកថ្ងៃទី២៣ ខែមិនា ឆ្នាំ២០២០នេះ លោកវរសេនីយ៍ឯក ធឹង រតនៈ បានថ្លែងថា ដើម្បីចាត់វិធានការ ទប់ស្កាត់ជំងឺកូវីត១៩ និងវិធានការចំពោះប្រជាពលរដ្ឋដែលបានត្រឡប់មកពីក្រៅប្រទេស សមត្ថកិច្ចទាំងអស់ជាពិសេសសមត្ថកិច្ចប៉ុស្តិ៍ ត្រូវចុះតាមដាន និងកំណត់ចំនួនពលករមកពីក្រៅប្រទេសឱ្យបានច្បាស់លាស់ ហើយត្រូវចុះធ្វើការអប់រំពួកគាត់ឱ្យនៅដាច់ដោយឡែកពីគេចំនួន ១៤ថ្ងៃសិន ដោយមិនត្រូវឱ្យពួកគាត់នៅជិត ឬស្និតស្នាលជាមួយក្រុមគ្រួសារ បងប្អូន ឬអ្នកជិតខាងឡើយ។ ការធ្វើបែបនេះ ដើម្បីបញ្ចៀសការឆ្លងជំងឺកូវីដ១៩ ប្រសិនបើពួកគាត់កើតមាន ទៅលើក្រុមគ្រួសារ អ្នកជិតខាង ឬនៅក្នុងសហគមន៍របស់គាត់។

ស្នងការរងខេត្តតាកែវ ធឹង រតនៈ បានបន្ថែមទៀតថា ប្រសិនបើមានការសង្ស័យទៅលើបងប្អូនពលករណាម្នាក់ ដោយសុខភាពពួកគាត់មិនស្រួល ឬមានកំដៅក្នុងខ្លួន ឡើងលើសពី៣៨ ត្រូវនាំគាត់ទៅពិនិត្យ និងព្យាបាលជាបន្ទាន់នៅមន្ទីរពេទ្យស្រុក ឬទៅដល់មន្ទីរពេទ្យខេត្ត ដើម្បីគេយកសំណាកទៅធ្វើតេស្តបន្ត ដើម្បីរកជំងឺកូវីដ១៩ នៅវិទ្យាស្ថានប៉ាស្ទ័រ ម្យ៉ាងទៀតនៅមន្ទីរពេទ្យខេត្តគេបានត្រៀមបន្ទប់ទុករួចរាល់អស់ហើយ សម្រាប់ព្យាបាលអ្នកជំងឺកូវីដ១៩ ដាច់ដោយឡែកពីគេ។

លោកស្នងការរងខេត្តតាកែវ ក៏បានណែនាំដល់សមត្ថកិច្ចមូលដ្ឋានត្រូវបន្តចុះអប់រំ និងផ្សព្វផ្សាយឲ្យបានជាប់ជាប្រចាំដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានភូមិ ឃុំ ស្រុករបស់ខ្លួន ពីវិធីសាស្រ្តការសំអាត ការធ្វើអនាម័យឱ្យបានញឹកញាប់តាមរយៈលាងដៃនឹងសាប៊ូ ឬអាកុល ហាមការជួបជុំមនុស្សច្រើនដើម្បីធ្វើយ៉ាងណាទប់ស្កាត់ កុំឲ្យជំងឺកូវីដ ១៩នេះ រីករាលដាលនៅក្នុងសហគមន៍ បងប្អូនប្រជាពលរដ្ឋ៕

## ពិតជាល្អខ្លាំងណាស់ ! ប្រជាពលរដ្ឋធ្វើដំណើរមកពីក្រៅប្រទេស ត្រូវបានអាជ្ញាធរចុះពិនិត្យសុខភាព និងណែនាំឱ្យនៅដោយឡែកចំនួន ១៤ថ្ងៃ

https://khmernews.news/ ស៊ីហៀង 22-03-2020

ប្រជាពលរដ្ឋធ្វើដំណើរមកពីក្រៅប្រទេស ត្រូវបានអាជ្ញាធរចុះពិនិត្យសុខភាព និងណែនាំឱ្យនៅដោយឡែកចំនួន ១៤ថ្ងៃ គិតចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ប្រជាពលរដ្ឋធ្វើដំណើរមកពីក្រៅប្រទេសបានមកដល់លំនៅដ្ឋានរបស់ខ្លួនវិញ ហើយត្រូវបានអាជ្ញាធរក្រុង ស្រុកឱ្យអនុលោមតាមសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ សូមបងប្អូនប្រជាពលរដ្ឋ ដែលធ្វើដំណើរមកពីក្រៅប្រទេសទាំងអស់ សូមមេត្តាដាក់ខ្លួនឯងឲ្យនៅដោយឡែកចំនួន១៤ថ្ងៃ និងតាមដានសុខភាពបើមានចេញរោគសញ្ញា និងសូមពិគ្រោះជំងឺ អាចទំនាក់ទំនងសេវាសុខាភិបាលរដ្ឋ ឬតាមរយៈទូរស័ព្ទលេខ ១១៥ ។

ដើម្បីអនុវត្តឱ្យស្របតាមសេចក្តីណែនាំ ក៏ដូចជាការចូលរួមទប់ស្កាត់ជំងឺកូវីដ១៩ អាជ្ញាធរក្រុង ស្រុក និងមន្រ្តីជំនាញរបស់សុខាភិបាល បានធ្វើការអប់រំ និងណែនាំបន្ថែមដល់បងប្អូនប្រជាពលរដ្ឋ ដែលទើបធ្វើដំណើរមកពីក្រៅប្រទេសសូមនៅដោយឡែកចំនួន ១៤ថ្ងៃ ទោះបីជានៅលំនៅដ្ឋានរបស់ខ្លួនក៏ដោយ ហើយការចូលរួមរបស់បងប្អូនប្រជាពលរដ្ឋ ដើម្បីចូលរួមការពារទប់ស្កាត់កុំឱ្យមានការចម្លងទៅក្នុងសហគមន៍ ជាកិច្ចការដែលយើងទាំងអស់គ្នាត្រូវធ្វើជាចាំបាច់។ ម្យ៉ាងទៀតសូមបងប្អូនសម្អាតអនាម័យផ្ទាល់ខ្លួនតាមការណែនាំរបស់ក្រសួងសុខាភិបាល ដូចនេះសូមចូលរួមទាំងអស់គ្នា ការពារការចម្លងកូវីដ១៩ ទើបយើងអាចមានជ័យជម្នះ៕ សៀមរាបផ្ទះខ្ញុំ

## ស្ថានីយរថភ្លើង ក្រុងប៉ោយប៉ែត គឺជាទីសំចតទី១ ក្នុងការត្រួតពិនិត្យមេរោគវីរុស កូវីដ-១៩ ចំពោះពលករខ្មែរ ត្រឡប់មកពីថៃ

https://dap-news.com/national/ ByYVC111 Posted on March 23, 2020

ភ្នំពេញ ៖ ដើម្បីរួមចំណែកទប់ស្កាត់ វីរុស កូវីដ-១៩ (COVID-19) ក្រសួងសាធារណការ និងដឹកជញ្ជូនបានឲ្យដឹងថា ស្ថានីយរថភ្លើងក្រុងប៉ោយប៉ែត ជាទីសំចតទី១ សម្រាប់ដំណើរការត្រួតពិនិត្យសុខភាពពលករខ្មែរដែលទើបវិលត្រឡប់មកពីថៃ ជាង ៦០០នាក់។

យោងតាមគេហទំព័រហ្វេសប៊ុករបស់ ក្រសួងសាធារណការ នារសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ បានបញ្ជាក់ថា "ដើម្បីរួមចំណែកទប់ស្កាត់ វីរុសកូវីដ១៩ ស្ថានីយរថភ្លើងក្រុងប៉ោយប៉ែត ត្រូវបានជ្រើសរើសជាទីសំចតទី១ សម្រាប់ដំណើរការត្រួតពិនិត្យសុខភាព ជូនបងប្អូនពលករ ដែលទើបវិលត្រឡប់មកពីប្រទេសថៃ ចំនួនជាង ៦០០នាក់"។

សូមរំលឹកថា គិតត្រឹមថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២០ នេះ កម្ពុជារកឃើញអ្នកឆ្លងជំងឺ កូវីដ-១៩ ចំនួន៨៦ករណី ខណៈក្រសួងសុខាភិបាល និងភាគីពាក់ព័ន្ធមួយចំនួនទៀត កំពុងបន្តស្វែងរក និងធ្វើតេស្តលើអ្នកពាក់ព័ន្ធផ្សេងទៀត ៕ដោយ ៖ អេង ប៊ូធេង

## អភិបាលក្រុងស្រុកត្រូវគ្រប់គ្រងឱ្យបានច្បាស់លាស់ចំពោះពលករទើបត្រឡប់មកពីក្រៅប្រទេស

http://www.rasmeinews.com/ March 23, 2020, 9:44 PM

ដោយបូកគោ/កំពត៖ គ្រប់អភិបាលក្រុងស្រុកត្រូវគ្រប់គ្រងឱ្យបានច្បាស់លាស់ចំពោះពលករដែលទើបវិលត្រឡប់មកពីក្រៅប្រទេស ដើម្បីងាយស្រួលក្នុងការតាមដាន និងបញ្ចៀសនូវករណីពាក់ព័ន្ធជំងឺឆ្លងកូវីដ១៩។ ក្នុងកិច្ចប្រជុំបន្ទាន់របស់គណៈកម្មការខេត្ត ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ កាលពីព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ លោកជាវ តាយអភិបាលខេត្តកំពតបានមានប្រសាសន៍ថា គ្រប់អភិបាលក្រុងស្រុកត្រូវយករបាយការណ៍ឱ្យបានដាក់លាក់តាមរយៈអាជ្ញាធរភូមិ ឃុំ សង្កាត់ អំពីចំនួនប្រជាពលរដ្ឋពិសេសពលករដែលទើបនឹងវិលត្រឡប់មកពីប្រទេសថៃ។ នេះជាកិច្ចការចាំបាច់ដែលត្រូវអនុវត្តបន្ទាន់ព្រោះសកម្មភាពនៃការសម្រុកចូលរបស់ពលករអាចកើតមាននូវករណីចម្លងជំងឺកូវីដ១៩មកពីក្រៅ។

លោកអភិបាលខេត្ត បានបញ្ជាក់ថា ផ្អែកតាមការណែនាំរបស់ក្រសួងសុខាភិបាល គឺចាំបាច់ត្រូវតែដាក់អ្នកទាំងនោះឱ្យនៅដាច់ដោយឡែកក្នុងផ្ទះរយៈពេល១៤ថ្ងៃ។ លើសពីនេះ ក៏ត្រូវក្រើនរំលឹកពួកគាត់កុំឱ្យស្និទ្ធស្នាលជាមួយសមាជិកគ្រួសារគ្រា ដែលមិនទាន់ប្រាកដថា តើមានផ្ទុកមេរោគចម្លងមកពីក្រៅ ឬមិនមាននោះ។ ម្យ៉ាងទៀតអាជ្ញាធរមូលដ្ឋានត្រូវណែនាំប្រជាពលរដ្ឋឱ្យបង្កើនការងារអនាម័យ បរិស្ថានលម្អសោភ័ណភាពជុំវិញផ្ទះ ពិសេសលាងសម្អាតដៃជាប្រចាំ និងការបរិភោគចំណីអាហារជាដើម។S/

## ពលករមកពីក្រៅប្រទេស គួរយកចិត្តទុកដាក់ចំពោះសុខភាពនិងការស្នាក់នៅដោយឡែក ១៤ថ្ងៃ

http://www.rasmeinews.com/ March 24, 2020, 8:48 AM

ចាប់តាំងពីយប់ថ្ងៃសៅរ៍ ទី២១ ខែមីនា បន្តដល់ថ្ងៃអាទិត្យ និងរហូតដល់ថ្ងៃចន្ទ ទី២៣ ខែមីនា ប្រជាពលរដ្ឋខ្មែរ ដែលទៅធ្វើការនៅក្រៅប្រទេស ពិសេសនៅប្រទេសថៃ បានវិល ត្រឡប់មក កាន់ស្រុកកំណើតយ៉ាងច្រើន។ កំណើននៃការវិលត្រឡប់មកកាន់ស្រុកភូមិវិញនេះ ចំពេលនៃ ការឆ្លងរាលដាលជំងឺកូវីដ១៩ ទាំងនៅប្រទេសកម្ពុជា ក៏ដូចជាប្រទេស ជាច្រើននៅទូទាំងពិភព លោក ក៏ដូចជាប្រទេសថៃ ជាដើម។

ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ចាប់ពីរាជរដ្ឋា ភិបាល ក្រសួងសុខាភិបាល ក៏ដូចជាអាជ្ញាធរខេត្តរាជធានី ស្រុកខណ្ឌក្រុង ឃុំសង្កាត់ និងថ្នាក់ភូមិ បានបន្តណែនាំ ដល់ប្រជាពលរដ្ឋចំណាកស្រុក ដែលទើបត្រឡប់មកមូលដ្ឋាន ទាំងក្នុងនិង ក្រៅប្រទេស សូមផ្តោតលើគោលការណ៍សុខាភិបាលសំខាន់ៗ រួមមានត្រូវរស់នៅដាច់ដោយ ឡែកគ្នា កុំប្រមូលផ្តុំ ក្នុងរយៈពេល ១៤ថ្ងៃ ទៅពិនិត្យសុខភាពជាប្រចាំនិងត្រូវចូលរួមអនាម័យ ជាប្រចាំ តាមការណែនាំរបស់ក្រសួង សុខាភិបាល។ល។

ជាមួយគ្នានោះ កាលពីថ្ងៃចន្ទ ទី២៣ ខែមីនា អាជ្ញាធររាជធានី-ខេត្តនានា បានចាប់ ផ្តើមប្រជុំ និងកំណត់ជាបន្តបន្ទាប់ យកអគារសាលារៀន និងអគារសាធារណៈមួយ ចំនួន ក្នុងរាជធានី ខេត្ត ធ្វើជាទីតាំង សម្រាប់ការដាក់ឲ្យស្នាក់នៅដាច់ដោយឡែក និងពិនិត្យព្យាបាលអ្នកជំងឺ កូវីដ១៩ ប្រសិនបើអត្រាឆ្លងមានកំណើន។ វិធានការនេះ បានដាក់ចេញបន្ទាប់ពីមានបញ្ជា ដោយផ្ទាល់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន។

ការចុះពិនិត្យនិងរៀបចំសាលារៀន និងអគារសាធារណៈតាមបណ្តាខេត្តនានា ដើម្បី រៀបចំជាទីតាំងសម្រាប់ដាក់ឱ្យនៅដាច់ដោយឡែកនូវរាល់ប្រជាជនទាំងឡាយណា ដែល មានការសង្ស័យខ្ពស់បានធ្វើឡើង នៅក្របខ័ណ្ឌទូទាំងប្រទេស។ ការពិនិត្យទីតាំងទាំងនោះ ដើម្បីធានាថា វានឹងសមស្រប សម្រាប់ការប្រើប្រាស់នៅក្នុងស្ថានភាពដ៏ចាំបាច់ពិសេសអនុ លោមតាមគោលការណ៍វេជ្ជសាស្ត្រសុខាភិបាល ដែលណែនាំដោយក្រសួងសុខាភិបាល កម្ពុជា និងអង្គការសុខភាពពិភពលោក។

ការកំណត់យកទីតាំងត្រៀមសម្រាប់ការដាក់ឱ្យនៅដាច់ដោយឡែកនិងសម្រាប់ពិនិត្យព្យាបាល អ្នកជំងឺកូវីដ ១៩ របស់រដ្ឋបាលខេត្តទូទាំងប្រទេស បានធ្វើឡើង បន្ទាប់ពីសម្តេចតេជោបាន ប្រកាសបទបញ្ជាផ្ទាល់មាត់ តាមរយៈបណ្តាញទំនាក់ទំនងសង្គម ឱ្យអភិបាលខេត្ត ដឹកនាំ មន្ត្រីពាក់ព័ន្ធ ពិសេសមន្ទីរសុខាភិបាលខេត្ត កំណត់យកទីតាំងមួយចំនួន ដូចជា សណ្ឋាគារ ផ្ទះសំណាក់ សាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាល ជាដើម ទុកសម្រាប់ដាក់ឱ្យនៅ ដាច់ដោយឡែក និងព្យាបាលអ្នកជំងឺកូវីដ១៩។ សម្តេចតេជោ ក៏បានណែនាំរដ្ឋបាលខេត្ត ត្រូវប្រមូលផ្តុំកម្លាំងសរុប រៀបចំតទឹក ភ្លើង និងរៀបចំបន្ទប់អនាម័យ ឱ្យបានត្រឹមត្រូវនៅតាម ទីតាំងកំណត់ទាំងនោះ។

វិធានការចាំបាច់ទាំងនេះ បានដាក់ចេញ បន្ទាប់ពីកម្ពុជា បានរកឃើញអ្នកមានផ្ទុកជំងឺកូវីដ១៩ កើនឡើងជាបន្តបន្ទាប់ និងបន្ទាប់ពីមានប្រជាពលរដ្ឋខ្មែរជាច្រើននាក់បានវិលត្រឡប់មកពី ប្រទេសថៃ ជាបន្តបន្ទាប់ ខណៈដែលនៅប្រទេសថៃ កំពុងរីករាលដាល ឆ្លងជំងឺកូវីដ១៩ ដែលនាំឱ្យមានការព្រួយបារម្ភចំពោះសុខភាពពួកគាត់។ តាមបណ្តាញទំនាក់ទំនង ដូចគ្នានឹងសម្តេចតេជោ កាលពីល្ងាចថ្ងៃអាទិត្យម្សិលមិញ សម្តេច ក្រឡាហោម ស ខេង ក៏បានណែនាំឱ្យអាជ្ញាធរខេត្ត រហូតដល់ឃុំភូមិ ត្រូវរួមគ្នាចុះអប់រំណែនាំ ប្រជាពលរដ្ឋ ដែលបានវិលត្រឡប់ពីថៃ ទៅដល់ស្រុកកំណើត ត្រូវអនុវត្តវិធានការដាក់ឱ្យនៅ ដោយឡែក ១៤ថ្ងៃ និងត្រូវពិនិត្យតាមដានសុខភាពពួកគាត់ឱ្យបានជាប់ជាប្រចាំ។

នៅព្រឹកថ្ងៃចន្ទ ទី២៣មីនា តាមភូមិឃុំនានា អាជ្ញាធរឃុំមេប៉ុស្តិ៍ បានចុះជួបអ្នកទើបមកមកពី ប្រទេសថៃ បានណែនាំអប់រំពីវិធានការសុខភាព ហើយចែកម៉ាស់ដល់ក្រុមគ្រួសារអ្នក ទាំងនោះ។ ប៉ុន្តែការរស់នៅរបស់អ្នកមកពីថៃ បន្តនៅជួបជុំគ្នា អង្គុយជិត ពិសេសក្មេងៗ នៅលាយឡំគ្នា នឹងអ្នកដែលទើបវិលត្រឡប់មកដល់ផ្ទះទាំងនោះនៅឡើយ។

កាលពីថ្ងៃទី១៦ ខែមីនាកន្លងទៅ ក្រសួងសុខាភិបាល បានចេញសេចក្តីណែនាំ ស្តីពីនីតិវិធី ដាក់ខ្លួនឲ្យនៅដាច់ដោយឡែកក្នុងរយៈពេល ១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ នៅតាមផ្ទះ ជាលក្ខណៈបុគ្គល រួមមានៈ បន្ទប់ត្រូវមានខ្យល់ចេញចូលល្អ។ ប្រសិនបើបន្ទប់ តែមួយ មិនអាចធ្វើបាន ត្រូវរក្សាចម្ងាយយ៉ាងហោចណាស់ពីរម៉ែត្រ ពីសមាជិកគ្រួសារផ្សេង ទៀត។ កាត់បន្ថយការប្រើប្រាស់កន្លែងទំនេររួម និងកាត់បន្ថយកន្លែងរស់នៅរួមគ្នា ( ផ្ទះបាយ បន្ទប់ទឹក ជាដើម )។ ក្នុងអំឡុងពេល ១៤ថ្ងៃនេះ ត្រូវតាមដានសុខភាពផ្ទាល់ខ្លួន និងរោគសញ្ញា រួមមាន កំដៅ ក្អក ឈឺបំពង់ក ហត់ ឬពិបាកដកដង្ហើម ឬរោគសញ្ញាផ្សេងៗទៀត។

ក្រសួងសុខាភិបាល បានណែនាំថា បើមានរោគសញ្ញាណាមួយខាងលើ ឬបញ្ហាសុខភាព ផ្សេងៗ ត្រូវរាយការណ៍ជាបន្ទាន់ ទៅកាន់ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ឬអភិបាលរាជធានី ខេត្ត ឬប្រធានមន្ទីរសុខាភិបាលរាជធានីខេត្ត ឬប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ឬប្រធានមន្ទីរពេទ្យបង្អែក ដែលនៅជិតផ្ទះរបស់លោកអ្នក។ អនុវត្តអនាម័យលាងដៃឲ្យបាន ញឹកញាប់ ជាពិសេសបន្ទាប់ពីប៉ះពាល់ជាមួយទឹករំអិលផ្លូវដង្ហើម។ ខ្ទប់ច្រមុះ និងមាត់ដោយ ប្រើកែងដៃ ឬក្រដាសអនាម័យ នៅពេលក្អក ឬកណ្តាស់ រួចបោះចោលក្រដាសអនាម័យនោះ ចោលភ្លាម ទៅក្នុងធុងសំរាមត្រឹមត្រូវ។ ត្រូវសម្អាតបន្ទប់ស្នាក់នៅ និងបន្ទប់ទឹកឲ្យបានជា ប្រចាំ។ ត្រូវសម្អាតជានិច្ច និងបោកគក់សម្លៀកបំពាក់ ស្រោមពូកខ្នើយ និងគ្រឿងបរិក្ខាប្រើ ប្រាស់ផ្សេងៗ។

ក្នុងវិធានការដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីដ ១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គលនេះ ក្រសួងសុខាភិបាល ក៏បានណែនាំដល់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីសុខាភិបាលមូលដ្ឋាន ត្រូវតាមឃ្លាំមើលជានិច្ច ដើម្បីឲ្យប្រាកដថា បុគ្គល ដែលត្រូវ បានធ្វើចត្តាឡីស័កដោយខ្លួនឯង ( ដាក់ឲ្យនៅដាច់ដោយឡែក ) អនុវត្តបានត្រឹមត្រូវតាមការ ណែនាំខាងលើនេះ។ យ៉ាងណាក៏ដោយ ដើម្បីឲ្យប្រាកដថា វិធានការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក រយៈ ពេលល ១៤ថ្ងៃ អាចអនុវត្តខ្ជាប់ខ្ជួន នៅតាមភូមិឃុំទូទាំងប្រទេសដែលមានអ្នកទើបវិលត្រឡប់មកពីក្រៅ ប្រទេស ពិសេសប្រទេសថៃ និងអ្នកចំណូលថ្មី គួរតែបង្កើតកន្លែងសុវត្ថិភាពមួយ

ដោយយក សាលារៀន នៅក្នុងភូមិឃុំនីមួយៗ សម្រាប់ដាក់ឲ្យអ្នកទាំងនោះ រស់នៅរយៈពេល ១៤ថ្ងៃ ហើយអនុវត្តនូវវិធានទាំងឡាយ ដែលក្រសួងសុខា ភិបាល បានណែនាំ។

ការធ្វើដូច្នេះ ដើម្បីសុខសុវត្ថិភាពតាមភូមិឃុំផង និងក៏ដើម្បីសុខសុវត្ថិភាពរបស់បងប្អូន ដែលទើបចូលមកក្នុងភូមិឃុំទាំងនោះផ្ទាល់តែម្ដង។ សូមកុំភ្លេចថា បើសិនជាអ្នកណា ម្នាក់មានបញ្ហាសុខភាព ដូចរបៀបកើតផ្ដាសាយក្ដៅខ្លួនខ្លាំង សូមរកពេទ្យ និងប្រាប់អាជ្ញាធរ ជាបន្ទាន់ ព្រោះថា ដើម្បីជួយខ្លួនអ្នកជំងឺផ្ទាល់ផង និងដើម្បីជួយដល់ក្រុមគ្រួសារអ្នកភូមិផង របងជាមួយផង។ អ្នកឆ្លងជំងឺរលាកសួតដ៏កាចសាហាវនេះ នៅក្នុងប្រទេសយើងត្រូវបានព្យាបាលជាសះស្បើយ ជាបន្តបន្ទាប់ ហើយក៏មិនមានជនណាម្នាក់ ស្លាប់ដោយសារជំងឺកូវីដ១៩នៅក្នុងប្រទេសយើង នៅឡើយដែរ៕ ដោយ: ម៉េងឆៃ

## ក្រោយថៃប្រកាសបិទព្រំដែន ពលរដ្ឋខ្មែរជាង២០០នាក់សម្រុកចេញពីថៃតាមច្រកព្រំ ក្នុងខេត្តប៉ៃលិន តែមានការពិនិត្យយ៉ាងតឹងរឹងដើម្បីទប់ស្កាត់ COVID-19

http://www.freshnewsasia.com/ 2020-03-23

**(ប៉ៃលិន)៖** ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០នេះ ដោយសារស្ថានភាពរីករាលដាលនៃវីរុស COVID-19 បានបង្ខំឲ្យពលករខ្មែរដែលធ្វើការនៅខេត្តចាន់បុរី ប្រទេសថៃ ប្រមាណជាង២០០នាក់ វិលត្រឡប់មកកាន់ស្រុកកំណើតវិញ តាមព្រំដែនក្នុងភូមិសាស្ត្រខេត្តប៉ៃលិន គ្រាច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន បានបិទមិនឲ្យចេញចូលទៀមក។

ពលករខ្មែរដែលឆ្លងដែនមក បានឲ្យដឹងឡើងថា នៅក្នុងប្រទេសថៃ ពួកគាត់មានការព្រួយបារម្ភជាខ្លាំងចំពោះជំងឺ COVID-19 ផង រួមទាំងអត់ការងារធ្វើផងនោះ បានបង្ខំឲ្យពួកគាត់សម្រេចចិត្ត វិលត្រឡប់មកកាន់ស្រុកកំណើតវិញ ហើយដោយច្រកទ្វារព្រំដែនត្រូវបានបិទ ដូច្នេះពួកគាត់ខ្លះត្រូវបង្ខំចិត្ត ឆ្លងព្រំដែន តាមអូរតាមព្រៃដែលប្រឈមនឹងគ្រោះថ្នាក់ដោយសារគ្រាប់មីន។

ជាក់ស្ដែងនៅថ្ងៃនេះ លោក ផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន បានជួបពិភាក្សាជាមួយភាគីថៃ ដោយអនុញ្ញាតឲ្យពលករប្រមាណជាង១០០នាក់ ចេញតាមច្រកព្រំដែនព្រំ ដើម្បីវិលត្រឡប់ទៅកាន់ស្រុកកំណើតរៀងៗខ្លួនវិញ។ លោក ផាន់ ចាន់ធុល បានបញ្ជាក់ថា ពលករខ្មែរដែលឆ្លងដែនត្រលប់មកវិញនេះ អាជ្ញាធរមិនបានអនុវត្តន៍ដាក់ឲ្យនៅដាច់ឡែកនោះទេ ដោយគ្រាន់តែកំណត់អត្តសញ្ញាណ ពិនិត្យឆែកកំដៅ ពិនិត្យសុខភាពយ៉ាងតឹងរឹង និងលាងសំអាតដៃ ជងខ្លួនដោយសារជាតុសម្លាប់មេរោគ រួចហើយអនុញ្ញាតឲ្យពួកគាត់វិលត្រឡប់ទៅកាន់លំនៅដ្ឋានរៀងៗខ្លួនវិញ។

ក្នុងឱកាសនោះ នាយឧត្តមសេនីយ៍ អ៊ី ឈាន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត និងលោកស្រី បាន ស្រីមុំ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន បានដឹកនាំក្រុមការងារ និងយុវជន ស.ស.យ.ក, យុវជនកាកបាទក្រហម ចូលរួមសហការជាមួយអាជ្ញាធរខេត្ត និងមន្រ្តីចត្តាឡីស័ក ធ្វើការកំណត់អត្តសញ្ញាណ ពិនិត្យឆែកកំដៅ និងលាងសំអាតដៃ ជូនពលករដែលត្រលប់មកពីប្រទេសថៃ។

សូមបញ្ជាក់ថា ពលករកម្ពុជាដែលសម្រុកឆ្លងព្រំដែនមកពីប្រទេសថៃ ក្នុងភូមិសាស្ត្រខេត្តប៉ៃលិន គិតចាប់តាមពីម៉ោង០៨៖៣០នាទីព្រឹកថ្ងៃទី២៣ ខែមីនា រហូតដល់ម៉ោង០២រសៀល គឺមានចំនួនសរុប២២០នាក់ ស្រី ១០៣នាក់ ក្នុងនោះមានកុមារ ចំនួន២៥នាក់ផងដែរ៕

## អភិបាលខេត្តស្វាយរៀង អំពាវនាវឲ្យប្រជាពលរដ្ឋ ទើបមកពីក្រៅប្រទេស រស់នៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ដើម្បីតាមដាន COVID-19

http://www.freshnewsasia.com/ 2020-03-23

**(ស្វាយរៀង)៖** លោក ម៉ែន វិបុល អភិបាលអភិបាលខេត្ត និងជាប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ខេត្តស្វាយរៀងនា រសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ បានអញ្ជើញដឹកនាំ កិច្ចប្រជុំគណៈកម្មការដើម្បីដាក់ចេញវិធានការចំពោះមុខឆ្លើយតបទៅនឹងស្ថានការ នៃការរីករាលដាល នៃជំងឺកូវីដ-១៩ ដែលកំពុងកើតមាននាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ក្នុងតំបន់ និងនៅលើពិភពលោក ។

កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីអភិបាលរងខេត្ត លោកនាយក នាយករងរដ្ឋបាលសាលាខេត្ត កងកម្លាំងទាំង៣ប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធលោកនាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្តនិងមន្ត្រីពាក់ព័ន្ធមួយចំនួន។ លោកអភិបាលខេត្ត បានបញ្ជាក់ថា រហូតមកដល់ពេលនេះ នៅក្នុងប្រទេសកម្ពុជារបស់យើងមានអ្នកឆ្លងជំងឺកូវីដ-១៩ ចំនួន ៨៦នាក់ នៅតាមបណ្តារាជធានី-ខេត្ត ចំនួន១៣ ហើយបើទោះបីជាខេត្ត ស្វាយរៀង មិនទាន់មានអ្នកឆ្លងជំងឺកូវីត-១៩ ក៏ពិតមែន ប៉ុន្តែយើងក៏មិនត្រូវធ្វេសប្រហែសនោះដែរ គឺត្រូវតែមានវិធានការការពារឲ្យបានម៉ឺងម៉ាត់ដើម្បីបង្ការ ទប់ស្កាត់នូវការឆ្លងរាលដាល នៃជំងឺនេះ ដោយរដ្ឋបាលខេត្ត គឺនៅតែបន្ត និងអនុវត្តឲ្យកាន់តែសកម្មថែមទៀតនូវការផ្សព្វផ្សាយអប់រំណែនាំឲ្យកាន់តែទូលំទូលាយ និងផុសផុសជូនប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋានទូទាំងខេត្តវិធានការបង្ការ វិធានការអនាម័យ និងវិធានការចត្តាឡីស័កដែលណែនាំដោយក្រសួងសុខាភិបាល ព្រមទាំងបង្កើន និងពង្រឹងការអនុវត្តវិធានការទាំងនេះ នៅតាមបណ្តាអង្គភាពរដ្ឋ ឯកជន និងរោងចក្រ សហគ្រាសទាំងអស់នៅក្នុងខេត្ត។

ដោយឡែក ចំពោះបងប្អូនប្រជាពលរដ្ឋដែលទើបត្រឡប់មកពីធ្វើការនៅប្រទេសថៃ ឬប្រទេសផ្សេងទៀត អភិបាលខេត្ត បានណែនាំដល់គណៈកម្មការខេត្ត ជាពិសេសអាជ្ញាធរមូលដ្ឋាន ត្រូវតាមដាន និងក្តាប់ឲ្យបានច្បាស់លាស់នូវស្ថិតិប្រជាពលរដ្ឋដែលបានចូលមកដល់មូលដ្ឋាន និងរាយការណ៍ជាប្រចាំថ្ងៃមករដ្ឋបាលខេត្ត ជាពិសេសត្រូវអប់រំណែនាំពួកគាត់ឲ្យបានយល់ និងអនុវត្តឲ្យបានខ្ជាប់ខ្ជួន អំពីវិធានការនៃការដាក់ខ្លួនឯងឲ្យនៅដាច់ដោយឡែកក្នុងរយៈពេល១៤ថ្ងៃ នៅតាមផ្ទះជាលក្ខណៈបុគ្គល ហើយក្នុងករណីមានការសង្ស័យ ត្រូវនាំគាត់ទៅពិនិត្យ និងព្យាបាលជាបន្ទាន់។ ក្នុងឱកាសនោះ លោកអភិបាលខេត្ត និងក្រុមការងារ ក៏បានចុះពិនិត្យជាក់ស្តែងនៅទីតាំងសណ្ឋាគារវ៉េ និងផ្ទះសំណាក់ស្វាយរៀងដែលគ្រោងនឹងប្រើប្រាស់ជាទីកន្លែងត្រៀមបម្រុង ទុកសម្រាប់ការពិនិត្យ ព្យាបាលជំងឺកូវីត-១៩ ផងដែរ៕

## មន្ត្រីនគរបាលខេត្តតាកែវ សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះកំណត់អត្តសញ្ញាណ ពលករមកពីថៃ និងណែនាំឲ្យពួកគាត់ នៅដាច់ដោយឡែកពីក្រុមគ្រួសារសិន

http://www.cen.com.kh/ March 23, 2020

តាកែវ៖ លោកឧត្តមសេនីយ៍ត្រីវង់ ណារុធ និងលោកវរសេនីយ៍ឯក ធឹង រតនៈ ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តតាកែវ នៅព្រឹកថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២០ នេះ បានចុះផ្សព្វផ្សាយការងារបន្ទាន់មួយ ដល់មន្ត្រីនគរបាលមូលដ្ឋាន នៅស្រុកគីរីវង់ទាំងអស់ ត្រូវសហការជាមួយ និងអាជ្ញាធរមូលដ្ឋាន ចុះត្រួតពិនិត្យកំណត់ចំនួនពលករ ឱ្យបានជាក់លាក់ និងណែនាំឱ្យពួកគេនៅដាច់ដោយឡែក១៤ថ្ងៃសិន ហើយបើសង្ស័យត្រូវនាំមកពិនិត្យភ្លាម ។

សូមបញ្ជាក់ផងដែរថា ចំពោះវិធានការបន្ទាន់នេះ គឺក្រោមការបញ្ជាផ្ទាល់របស់លោកឧត្តមសេនីយ៍ទោ សុខ សំណាង ស្នងការនគរបាលខេត្តតាកែវ ក្នុងកិច្ចការចាត់វិធានការ ទប់ស្កាត់ការឆ្លងរីករាលដាលជំងឺcovid-19 ចំពោះពលរដ្ឋ ដែលបានត្រឡប់មកពីប្រទេសថៃ ដោយមិនបានធ្វើការពិនិត្យសុខភាព។

មានប្រសាសន៍នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយនោះដែរលោក ធឹង រតនៈ ស្នងការរងទទួលផែនគ្រប់គ្រងធនធានមនុស្សបានលើកឡើងថា ដោយមានពលករកម្ពុជាជាច្រើននាក់ បានវិលត្រឡប់មកពីប្រទេសថៃ ចូលក្នុងប្រទេសកម្ពុជា តាមច្រកនានា នៅខេត្តជាប់ព្រំដែន នៃប្រទេសថៃ នាពេលថ្មីៗនេះ មានចំនួនច្រើន ហើយពលករដែលបានត្រឡប់មក គឺនូវពុំទាន់បានធ្វើការពិនិត្យសុខភាពបានត្រឹមត្រូវនូវឡើយ ដូច្នេះទើបតម្រូវឲ្យកងកម្លាំងនគរបាលទាំងអស់ រួមសហការជាមួយមេឃុំ មេភូមិ ចុះកំណត់អត្តសញ្ញាណពួកគាត់ ដែលជាពលករចំណាកស្រុក ក្នុងគោលបំណងតែមួយ គឺរួមគ្នាទប់ស្កាត់ការឆ្លងរីករាលដាលជំងឺរលាកសួតថ្មី ហៅ COVID-19 ដោយត្រូវអប់រំណែនាំពួកគាត់ ឲ្យនៅដាច់ដោយឡែកចំនួន១៤ថ្ងៃ ដោយមិនត្រូវឱ្យពួកគាត់ នៅជិតឬស្និទ្ធស្នាលជាមួយ ក្រុមគ្រួសារ ឬអ្នកជិតខាងឡើយ ដើម្បីបញ្ចៀសការឆ្លង ទៅក្រុមគ្រួសារ ឬអ្នកជិតខាង ហើយបើមានការសង្ស័យ ត្រូវនាំគាត់ទៅពិនិត្យ និងព្យាបាលជាបន្ទាន់៕ដោយៈតាកែវ

## លេខទូរស័ព្ទអាជ្ញាធរខណ្ឌទាំង១៤ សម្រាប់ពលរដ្ឋមកពីបរទេស ជាពិសេសមកពីថៃ ត្រូវជូនដំណឹងពីកន្លែងស្នាក់នៅ ដើម្បីបង្ការ ទប់ស្កាត់ COVID-19

http://nokorwatnews.com/ 23-03-2020

ភ្នំពេញ៖ រដ្ឋបាលរាជធានីភ្នំពេញ បង្ហាញលេខទូរស័ព្ទរបស់អាជ្ញាធរខណ្ឌទាំង១៤ សម្រាប់ប្រជាពលរដ្ឋទាំងអស់ដែលទើបត្រឡប់មកពី ធ្វើការនៅប្រទេសថៃ និងបណ្តាប្រទេសផ្សេងៗមួយចំនួនទៀត ត្រូវអនុវត្តតាមការណែនាំ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺCOVID-19 ។ នេះបើតាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ នៅថ្ងៃទី២៣ខែមីនា ឆ្នាំ២០២០នេះ ។

ក្នុងសេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ ក៏បានភ្ជាប់ជាមួយលេខទូរស័ព្ទថ្នាក់ដឹកនាំ និងអាជ្ញាធរខណ្ឌទាំង១៤ ក្នុងរាជធានីភ្នំពេញ ដើម្បីឲ្យប្រជាពលរដ្ឋដែលទើបមកពីបរទេស រាយការណ៍ពីកន្លែងស្នាក់នៅ ដើម្បីអាជ្ញាធរអាចក្តោបក្តាប់បាន និងងាយស្រួលណែនាំបន្ត។

សូមបញ្ជាក់ថា គិតត្រឹមម៉ោង១១ព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានកូវីដ១៩ នៅកម្ពុជា មានចំនួនសរុប៨៦នាក់ហើយ ក្នុងនោះមាន(ស្រី២១នាក់ ប្រុស៦៣នាក់ ដែលក្នុងនោះមានចិន១នាក់ (នៅខេត្តព្រះសីហនុ បានជាសះស្បើយ) អង់គ្លេស ៣នាក់ (ក្នុងនោះមាន១នាក់បានជាសះស្បើយហើយ) កាណាដា១នាក់ បែលហ្សិក១នាក់ និងបារាំង៣៣នាក់ (ក្នុងនោះមានកូនប្រុសបង្កើតអាយុ៤ខែ) ម៉ាឡេស៊ី១២នាក់ និងខ្មែរ៣៣នាក់ ៕សហការី

## ក្រសួងពាក់ព័ន្ធ អំពាវនាវព្រមគ្នា ឲ្យពលករមកពីបរទេស «នៅដាច់ពីគេ១៤ថ្ងៃ»

https://thmeythmey.com/ 23, Mar 2020 , 10:19 pm ដោយ: អ៊ូ សុខមាន

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង ឃាត់ប្រជាពលរដ្ឋខ្មែរ ដែលដើរឆ្លងកាត់ចេញពីប្រទេសថៃ ចូលប្រទេសកម្ពុជា ដើម្បីពិនិត្យកម្តៅនិងសាកសួរព័ត៌មានពួកគេ មុននឹងអនុញ្ញាតឲ្យចូលកម្ពុជា។

ភ្នំពេញ៖ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងការងារ ធ្វើសេចក្តីអំពាវនាវក្នុងពេលតែមួយ ទៅដល់ពលករគ្រប់រូប ដែលទើបនឹងវិលត្រឡប់មកពីបរទេស ត្រូវដាក់ឬឃុំខ្លួនឯងនៅដាច់ដោយឡែកពីគេ (ចត្តាឡីស័ក) រយៈពេល១៤ថ្ងៃ ដើម្បីបង្ការនិងទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ (COVID-19) ដល់សមាជិក

គ្រួសារឬអ្នកដទៃ។ ក្រសួងទាំងនេះ សង្កត់ធ្ងន់ថាក្នុងរយៈពេល១៤នេះ អ្នកដែលទើបនឹងមកពីបរទេសគ្រប់រូប មិនត្រូវស្និទ្ធស្នាលជាមួយក្រុមគ្រួសារឡើយ។

ការអំពាវនាវនេះ បានធ្វើឡើងក្រោយលេចឮព័ត៌មានថា ប្រជាពលរដ្ឋខ្មែរ ដែលបម្រើការងារនៅប្រទេសថៃ នាំគ្នាសម្រុកចូលមកស្រុកកំណើតរៀងៗខ្លួនវិញ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០។ លើសពីនេក្រសួង និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ បានទាមទារឲ្យពលរដ្ឋគ្រប់រូប ដែលទើបមកពីបរទេស និងមកពីខេត្តឆ្ងាយៗ ត្រូវរក្សាអនាម័យជាប្រចាំ និងជឿទៅលើការណែនាំរបស់ពេទ្យ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងមេរោគកូវីដ-១៩ ដែលកំពុងឆ្លងរាលដាល នាពេលបច្ចុប្បន្ន។

បន្ទាប់ពីមានលេចឡើងនូវព័ត៌មានថា ប្រជាពលរដ្ឋខ្មែរទាំងអ្នករកស៊ី និង ធ្វើការងារនៅប្រទេសថៃ នាំគ្នាសម្រុកចូលកម្ពុជាវិញ នៅតាមច្រកព្រំដែននានា នៅខេត្តបាត់ដំបង បន្ទាយមានជ័យ និង ឧត្តរមានជ័យ ជាដើម នោះ អ្នកស្រីវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល បានអំពាវនាវដល់អ្នកទាំងនោះ ឲ្យតាមដានសុខភាព និងកុំស្និតស្នាលជាមួយសមាជិកគ្រួសារក្នុងរយៈពេល១៤ថ្ងៃ ដើម្បីចូលរួមអនុវត្តវិធានការ និងការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីបញ្ចៀសការចម្លងមេរោគកូវីដ-១៩ នៅក្នុងសហគមន៍ឬនៅក្នុងភូមិឋានដែលខ្លួនរស់នៅ។ អ្នកស្រី បញ្ជាក់ថា៖«បើសុខភាពលោក-អ្នកមានអ្វីខុសប្រក្រតី ឬមានរោគសញ្ញាណាមួយសង្ស័យពាក់ព័ន្ធជំងឺបង្កដោយមេរោគកូវីដ-១៩ សូមប្រញាប់ទាក់ទងទៅកាន់ក្រុមគ្រូពេទ្យដែលនៅជិតបំផុត ឬរាយការណ៍តាមលេខទូរសព្ទ ១១៥»។ អ្នកនាំពាក្យក្រសួងសុខាភិបាលរូបនេះ ក៏អំពាវនាវដល់អាជ្ញាធរនៅតាមមូលដ្ឋានផងដែរ ឲ្យចូលរួមទប់ស្កាត់ការចម្លងមេរោគកូវីដ-១៩ តាមរយៈការស្រង់ស្ថិតិប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ហើយណែនាំពួកគាត់ ឲ្យអនុវត្តវិធាននានារបស់ក្រសួងសុខាភិបាលដែលបានដាក់ចេញកន្លងមក។

ជាមួយគ្នានេះ លោក ហេង សួរ រដ្ឋលេខាធិការនិងជាអ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បង្ហោះវីដេអូឃ្លីបលើគណនីហ្វេសប៊ុកលោក ដោយអំពាវនាវដល់ពលករទើបត្រឡប់មកពីបរទេសនិងតំបន់ឆ្ងាយៗ កុំឲ្យមានទំនាក់ទំនងជិតស្និទជាមួយសាច់ញាតិ និងការជួបជុំណាមួយជាមួយមិត្តភក្តិ ឬព្យាយាមនៅដាច់ដោយឡែកពីគេក្នុងរយៈពេល១៤ ដើម្បីតាមដានសុខភាពខ្លួនឯង។ លោក និយាយដូច្នេះថា៖«បងប្អូនដែលទើបមកពីខេត្តឆ្ងាយ ឬបរទេស មេត្តាកុំអាលស្និទ្ធស្នាលជាមួយក្រុមគ្រួសារពេក។ សូមរង់ចាំ១៤ថ្ងៃសិន បើអ្នកស្រឡាញ់គ្រួសារអ្នក»។ លោក ហេង សួរ បានលើកឡើងថា ថ្វីដ្បិតពលរដ្ឋដែលមកកម្ពុជាធ្វើដំណើរចេញពីតំបន់ឬកន្លែងមានសុវត្ថិភាព ដោយមិនមានការឆ្លងមេរោគកូវីដ-១៩ ក៏ពិតមែន ប៉ុន្តែក្នុងអំឡុងពេលដែលពួកគេ ធ្វើដំណើរមកស្រុកកំណើតរៀងៗខ្លួនវិញ គឺមិនដឹងថាឆ្លងកាត់ និងប៉ះពាល់ជាមួយអ្វីខ្លះនោះទេ។ ដូច្នេះ ហានិភ័យនៃការឆ្លងមេរោគនានា ពិសេសមេរោគកូវីដ-១៩ គឺមាន ដែលទាមទារឲ្យលោក-អ្នកយកចិត្តទុកដាក់ ការពារសុខភាពខ្លួនឯង ក៏ដូចជាសុខភាពក្រុមគ្រួសារ និងមិត្តភក្តិ ពីការឆ្លងមេរោគកូវីដ-១៩។

ចំណែក សម្តេច ស ខេង បានមានប្រសាសន៍ថា មានពលរដ្ឋខ្មែរមិនតិចជាង១ពាន់នាក់ទេ ដែលបាននាំគ្នាចាកចេញពីប្រទេសថៃ ចូលមកកម្ពុជា តាមច្រកទ្វារអន្តរជាតិដូងក្នុងខេត្តបាត់ដំបង ហើយបន្តធ្វើដំណើរទៅផ្ទះកំណើតរៀងៗខ្លួន ដោយមិនបានត្រួតពិនិត្យសុខភាពអ្វីឡើយ ពិសេសមិនបានត្រួតពិនិត្យរកអ្នកសង្ស័យផ្ទុកមេរោគកូវីដ-១៩។ គេបានឮប្រសាសន៍របស់សម្តេច តាមរយៈសំឡេង ដែលត្រូវបានចែករំលែកតៗគ្នាតាមបណ្តាញសង្គម កាលពីថ្ងៃទី២២ ខែមីនាឆ្នាំ២០២០។ ផ្អែកលើបញ្ហាដែលពលរដ្ឋនាំគ្នាមកស្រុកកំណើតដោយមិនឆ្លងកាត់ការត្រួតពិនិត្យសុខភាពបែបនេះ សម្តេចរដ្ឋមន្ត្រី បានស្នើអភិបាលខេត្តនីមួយៗ ណែនាំមន្ត្រីមូលដ្ឋាន ពិសេសថ្នាក់ភូមិ-ឃុំ ឲ្យរាយការណ៍ចំនួនអ្នកទើបមកពីបរទេស ពិសេសមកពីប្រទេសថៃ ហើយបញ្ជូនគ្រូពេទ្យឲ្យទៅពិនិត្យអ្នកទាំងនោះ។

សម្តេចរដ្ឋមន្ត្រី បន្តថា គ្រប់មូលដ្ឋាននៃខេត្តទាំងអស់ ដែលរកឃើញអ្នកទើបមកពីបរទេស ត្រូវប្រាប់មន្ត្រីជំនាញផ្នែកសុខភាព និងណែនាំអ្នកទាំងនោះឲ្យសម្ងំឬសម្រាកនៅក្នុងផ្ទះចំនួន១៤ ដោយរក្សាគម្លាត មិនប៉ះពាល់

ឬមិនមានទំនាក់ទំនងជិតស្និតជាមួយសមាជិកក្នុងគ្រួសារ និងអ្នកដទៃ ដើម្បីបង្ការការឆ្លងមេរោគកូវីដ-១៩។ រដ្ឋមន្ត្រីមហាផ្ទៃ និយាយដូច្នេះ៖«គ្រប់មូលដ្ឋាន បើសង្ស័យថាពលរដ្ឋក្នុងតំបន់របស់ខ្លួន ពិសេសអ្នកមកពីបរទេសមានផ្ទុកមេរោគកូវីដ-១៩ ត្រូវបញ្ជូនទៅមណ្ឌលសុខភាពដែលនៅជិតបំផុត ដើម្បីយកកំហាក ឬសំណាក ទៅធ្វើតេស្តរកមេរោគកូវីដ-១៩ នៅវិទ្យាស្ថានប៉ាស្ទ័រ នៅរាជធានីភ្នំពេញ»។ លើសពីនេះទៀត សម្តេច បានដាក់កំហិតឲ្យអភិបាលខេត្តនីមួយៗ ត្រូវម្ចាស់ការលើបញ្ហាពលរដ្ឋរស់នៅក្នុងខេត្តរបស់ខ្លួន ដែលបានធ្វើដំណើរមកពីប្រទេសថៃ ឬប្រទេសនានា ដោយត្រូវត្រួតពិនិត្យ និងប្រុងប្រយ័ត្នខ្ពស់ពីការឆ្លងមេរោគមេរោគកូវីដ-១៩។

សូមជម្រាបថា ច្រកទ្វារព្រំដែនគោកទាំង២៤រវាងកម្ពុជា-ថៃ ត្រូវបានបិទជាបណ្ដោះអាសន្ន។ មុនមួយថ្ងៃ-ពីរថ្ងៃនៃការបិទព្រំដែន មានការផ្សព្វផ្សាយតាមបណ្ដាញសង្គមថា ពលរដ្ឋកម្ពុជា បាននាំគ្នាសម្រុកចេញពីប្រទេសថៃ តាមច្រកព្រំដែននានា។ គិតត្រឹមព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ មានជិត១៩០ប្រទេស និងដែនដី បានឆ្លងមេរោគកូវីដ-១៩។ ចំណែក កម្ពុជា បានរកឃើញមនុស្ស៨៦នាក់ហើយ ដែលឆ្លងកូវីដ-១៩ ដោយក្នុងនោះ មាន២នាក់ បានជាសះស្បើយវិញ គឺបុរសជនជាតិចិននិងស្ត្រីជនជាតិអង់គ្លេស៕

## លោកគួច ចំរើន អំពាវនាវ កុំឲ្យមានការរើសអើងចំពោះពលករមកពីប្រទេសថៃ

http://kampucheathmey.com/ 24/3/2020 7:15 Am

ព្រះសីហនុ ៖ លោកគួច ចំរើន អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ កាលពីយប់ថ្ងៃទី២៣ ខែមីនា បានធ្វើការអំពាវនាវឲ្យបងប្អូនទាំងអស់ កុំមានការរើសអើង ចំពោះបងប្អូន និងពលករមកពីប្រទេសថៃ។ អភិបាលខេត្តរូបនេះ បានធ្វើការអំពាវនាវដូច្នេះថា «សូមអំពាវនាវ បងប្អូនទាំងអស់កុំមានការរើសអើងចំពោះបងប្អូន និងពលករមកពីប្រទេសថៃ គ្មាននរណាម្នាក់ចង់កើត ឬចង់មានមេរោគកូវីដ១៩ ក្នុងខ្លួននោះទេ ក៏ប៉ុន្តែជាមួយគ្នានេះ គឺសូមសុំយ៉ាងទទូច ចំពោះបងប្អូន និងពលករមកពីប្រទេសថៃ សូមស្ម័គ្រចិត្ត និងបំពេញកាតព្វកិច្ច ទៅជួបប្រឹក្សា និងទទួលយកការពិនិត្យរកមុខសញ្ញា មេរោគកូវីដ១៩ ដើម្បីធានាថា ពេលយើងទៅផ្ទះ គឺទៅដោយសេចក្តីសុខ និងសុវត្ថិភាព ទាំងចំពោះខ្លួនឯង ក្រុមគ្រួសារ សហគមន៍ និងសង្គមជាតិរបស់យើងទាំងមូល។ សូមអរគុណ»៕

## អាចបិទភូមិ បើរកឃើញអ្នកឆ្លងកូវីដ-១៩ ២ទៅ៣នាក់

https://thmeythmey.com/ 24, Mar 2020 , 9:52 am ដោយ: ថ្មីៗ

បើភូមិណា មានមនុស្សច្រើន អាចថា ពី២ទៅ៣នាក់ ជាពិសេសសំដៅលើអ្នកដែលទើបនឹងមកថៃ និងប្រទេសនានា បានឆ្លងកូវីដ-១៩ ភូមិនោះ អាចនឹងបិទ មិនឲ្យមានការចេញចូលតែម្តង។ នេះបើតាមប្រសាស៍ន៍របស់សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្នុងពិធីជួបសំណេះសំណាលជាមួយមន្ត្រីនគរបាលអន្តោប្រវេសន៍ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ សម្តេចរដ្ឋមន្ត្រី ថ្លែងដូច្នេះថា៖«...អ្នកណាមួយកើតកូវីដ-១៩ គឺថាឃុំមួយផ្ទះហ្នឹង ឬថា ឃុំមួយកំណាត់ភូមិហ្នឹង ឧទាហរណ៍ថាភូមិ ដាច់ដោយឡែកពីគ្នា ៤-៥ផ្ទះអ៊ីចឹងទៅ។ យើង អាចឃុំកន្លែងហ្នឹង កុំឲ្យគាត់ចេញទៅណា ហើយបើថា ភូមិហ្នឹងជាប់គ្នា ហើយមានច្រើននាក់ ២ទៅ៣នាក់អ៊ីចឹងទៅ គឺថា ឃុំទាំងភូមិហ្នឹងតែម្តង ប៉ុន្មានភូមិហ្នឹង។ យើង បានចាត់វិធានការបែបនេះ ហើយបានផ្សព្វផ្សាយកាលពីរសៀលម្សិលមិញហើយ»។ រដ្ឋមន្ត្រីមហាផ្ទៃ អះអាងថា បានពិភាក្សានិងសុំគោលការណ៍បិទភូមិនេះ ជាមួយនឹងសម្តេចនាយករដ្ឋមន្ត្រីរួចហើយ។

គិតត្រឹមថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ពលករខ្មែរជិត១ម៉ឺននាក់ បានសម្រុកចេញពីថៃ មកកម្ពុជាវិញ។ នៅថ្ងៃទី២៣ ខែមីនា គឺថ្ងៃចុងក្រោយ ដែលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រទ្វារព្រំដែនគោកផ្សេងទៀតរវាងកម្ពុជា-ថៃ នៅដំណើរការ។ តែនៅថ្ងៃទី២៤ ខែមីនានេះ ច្រកទ្វារព្រំដែនរវាងកម្ពុជា-ថៃ ត្រូវបានបិទអស់ហើយ។

នេះបើតាមលោក កែវ វណ្ណថន អ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេន៍ ដែលប្រាប់សារព័ត៌មានថ្មីៗ តាមទូរស័ព្ទនៅព្រឹថ្ងៃទី២៤ ខែមីនា។ ក្រសួងពាក់ព័ន្ធនានា អំពាវនាវឲ្យពលករខ្មែរគ្រប់រូប ដែលទើបនឹងមកពីថៃនិងប្រទេសផ្សេងៗឲ្យនៅដាច់ដោយឡែកពីគេរយៈពេល១៤សិន ដើម្បីចៀសវាងការឆ្លងកូវីដ-១៩ ទៅសមាជិកគ្រួសារ ឬអ្នកដទៃ។

## ដោយមានការស្នើសុំពីអាជ្ញាធរកម្ពុជា! អាជ្ញាធរថៃ បានសម្រេចបើកច្រកទ្វារអន្តរជាតិប៉ោយប៉ែត អោយពលករខ្មែរចេញមួយថ្ងៃទៀត

http://neakmeasnews.com/ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ដោយ ជីវ័ន្ត

(ក្រុងប៉ោយប៉ែត)៖ នៅរសៀលថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ដោយពលករធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញមិនទាន់អស់ អាជ្ញាធរខេត្តលោក អ៊ុំ រាត្រីអភិបាលនៃគណៈអភិបាលខេត្ត ដោយមើលឃើញពីទុក្ខលំបាកបងប្អូនប្រជាពលរដ្ឋដែលជាពលករចំណាកស្រុកធ្វើការនៅប្រទេសថៃ ។ និងដោយយោងតាមប្រសាសន៍ណែនាំ លោកនាយឧត្តមសេនីយ៍ សៅ សុខា អគ្គបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានដាក់ចេញនូវទិសស្លោក "ជួយគិត ជួយធ្វើ រួមគ្នាទទួលខុសត្រូវ" ឯកឧត្តម អ៊ុំ រាត្រី បានស្នើសុំអោយអាជ្ញាធរថៃ បើកច្រកទ្វារអន្តរជាតិប៉ោយប៉ែតរយៈពេលមួយទៀត រហូតដល់១០យប់ ដើម្បីអោយពលករខ្មែរមានចំនួន៥០០នាក់ ចេញមកខាងទឹកខ្មែរវិញ ដើម្បីបញ្ជាសការរីករាលដាលឆ្លងជំងឺកូវីដ១៩ ដែលកំពុងផ្ទុះទូទាំងសកលលោក។

ដោយមានការស្នើសុំនិងអន្តរាគមន៍ពីអាជ្ញាធរកម្ពុជាប្រចាំនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខាងគូរភាគីអាជ្ញាធរថៃ បានសម្រេចបើកអោយពលករខ្មែរចេញមួយថ្ងៃទៀត គេសង្កេតឃើញថា៖ ក្រោយពីបើកច្រកទ្វារពំប៉ោយប៉ែតដែនមានពលករខ្មែរចំនួន៥០០នាក់ បាននាំគ្នាសម្រុកចេញមកកម្ពុជា។

ដោយឡែកពលករខ្មែរទាំងនោះ ត្រូវបានអាជ្ញាធរមូលដ្ឋានក្រុងខេត្តយករថយន្តដឹកពលករខ្មែរយកទៅដាក់កន្លែងសុំចតចំនួនពីរកន្លែង(មួយនៅចំណតរថភ្លើងក្រុងប៉ោយប៉ែត និងមួយទៀតនៅមណ្ឌលសំចតដីថ្មី) គ្រប់គ្រងដោយមន្ទីរពេទ្យសុខាភិបាល ដើម្បីពិនិត្យវាស់កំដៅ និងពិនិត្យរកមេរោគជំងឺកូវីដ១៩ រយៈពេល១៤ថ្ងៃសិន ហើយបើមាននរណាម្នាក់ការពិនិត្យពីក្រុមគ្រូពេទ្យជាលតផលវិជ្ជមាន និងបង្ខាំងក្នុងបន្ទប់មួយផ្សេងដាច់ដោយឡែក ហើយបើសិនការពិនិត្យអវិជ្ជមាននោះ ពួកគេអាចវិលត្រឡប់ទៅស្រុកកំណើតវិញ ក្នុងរយៈពេល១៤ថ្ងៃដើម្បីការពារការរីករាលដាលឆ្លងជំងឺកូវីដ១៩ ទៅលើប្រពលរដ្ឋខ្មែរ នេះបើយោងតាមអ្នកពាក្យ ប៉ូលិសអន្តោប្រវេសន៍ ប្រចាំច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅរសៀលថ្ងៃដ៏ដែល លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុថហត្ថខេត្តបន្ទាយមានជ័យ បានចាត់តាំងកម្លាំងអាវុធហត្ថចំនួន៣០នាក់ និងរថយន្តចំនួន០៤គ្រឿង ដើម្បីជួយដឹកជញ្ជូនពលរដ្ឋខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ លោកវរសេនីយ៍ត្រី នួន នីណារ៉ូ មេបញ្ជាការមូលដ្ឋានកងរាជអាវុធក្រុងប៉ោយប៉ែតដែលនៅប្រចាំការនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតនិងចូលរួមការពាររក្សាសន្តិសុខសណ្តាប់ធ្នាប់ផងដែរ៕

## ពលករខ្មែរមកពីថៃរទ្ទង់១ម៉ឺន៥ពាន់នាក់ រាជរដ្ឋាភិបាលអំពាវនាវធ្វើការអប់រំផ្សាយតាមភូមិ ឃុំ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១០:៣៧ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានឲ្យដឹងថា ពលករខ្មែរដែលធ្វើការនៅប្រទេសថៃបានចូលមកស្រុកកំណើតវិញ ក្នុងរង្វង់ប្រមាណ១ម៉ឺន៥ពាន់នាក់។ ការប្រកាសរបស់សម្តេច ស ខេង នេះ បន្ទាប់ពីប្រទេសថៃបានសម្រេចបិទច្រកព្រំដែនមួយចំនួនជាមួយកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ទើបធ្វើឲ្យពលរដ្ឋករខ្មែរធ្វើការនៅថៃ បានសម្រុកចាកចេញមកស្រុកកំណើតវិញ ។

ក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកសារព័ត៌មានព្រឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ សម្ដេច ស ខេង បានបដិសេធសម្លេងថា សម្ដេចឲ្យការបិទផ្សារដែលធ្វើឲ្យទំនិញឡើងថ្លៃ ជាការមិនពិត ។ សម្ដេចបានលើកឡើងថា សម្ដេចបានធ្វើអំពាវនាវដល់មន្ត្រីផ្ទៃក្នុងក្រសួងមហាផ្ទៃថា ជំងឺដែលឆ្លងនោះដោយសារអ្នកខ្លះទៅផ្សារ ហើយទិញរបស់ដោយប្រគល់លុយទើបធ្វើឲ្យមានការឆ្លងក៏មាន ។ សម្ដេចបញ្ជាក់ថា ៖« មនុស្សភាគច្រើនទៅផ្សារ ហើយកាន់លុយទិញទៅវិញទៅមកដែលអាចធ្វើឲ្យឆ្លងផងដែរ ។ ខ្ញុំនិយាយក្នុងន័យអីចឹងទេ មិនមែនអំពាវនាវដល់ប្រជាពលរដ្ឋថា មានការបិទផ្សារនោះទេ» ។ ជាមួយគ្នានោះដែរ សម្ដេចស ខេង ក៏បានលើកឡើងថា ប្រជាពលរដ្ឋខ្មែរដែលមកធ្វើការនៅប្រទេសថៃ ហើយបានមកស្រុកវិញរយៈពេលមកនេះមានរង្វង់ប្រមាណ១ ម៉ឺន៥ពាន់នាក់ ។

សម្ដេចក៏បានលើកឡើងថា ចំពោះការវិលត្រឡប់របស់បងប្អូនពលករខ្មែរមកពីប្រទេសថៃនេះមិនបានធ្វើការត្រួតពិនិត្យសុខភាពអស់ទេ អីញ្ចឹងសម្ដេចបានធ្វើសំណើរទៅសម្ដេច តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ដើម្បីឲ្យរដ្ឋបាលនៅតាមមូលដ្ឋានទៅជួបពលករទាំងនោះនៅផ្ទះពីស្ថានភាពរបស់គាត់ ។ ក្នុងករណីដែលមានករណីឆ្លងជំងឺកូវីដ១៩នេះ អាចនឹងបិទធ្វើដំណើរនៅក្នុងភូមិ ឬកន្លះភូមិអីចឹងព្រោះថា នៅកម្ពុជាមិនដូចជាប្រទេសគេនោះទេ ។ យ៉ាងណាក្ដីសម្ដេច ស ខេង ក៏បានលើកឡើងថានៅកម្ពុជាមិនទាន់ឈានដល់ធ្វើការបង្ខាំងមនុស្សមិនឲ្យចេញពីផ្ទះដូចប្រទេសអីតាលី ឬប្រទេសផ្សេងនោះទេ គឺធ្វើការអំពាវនាវសិន ។ ប៉ុន្តែបើនៅប្រទេសផ្សេងបើមិនស្ដាប់នឹងមានការផាកពិន័យហើយអាចជាប់គុកទៀត ។ សម្ដេចបញ្ជាក់ថា ៖« អាឡូវយើងយកវិធានការពប្រៀបដូចជា ការឃោសនា បោះឆ្នោតអីញ្ចឹង គឺចាក់មេក្រូ ប្រកាសតាមភូមិ រហូដល់ប្រជាពលរដ្ឋយល់ ហើយធ្វើការដូរទីតាំងផ្សេងរហូតដល់ប្រជាពលរដ្ឋយល់» ៕

## សម្ដេច ស ខេង៖កម្ពុជា គ្មានលទ្ធភាព ឃុំពលករខ្មែរ ១៤ថ្ងៃនោះទេ បើរកឃើញពលករ ឆ្លងកូវីដ-១៩ នៅតាមភូមិ ២ឬ៣នាក់ នឹងបិទភូមិនោះចោល

https://dap-news.com/national/ ByPH104 Posted on March 24, 2020

ភ្នំពេញ ៖ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលស្គាល់ថា អាជ្ញាធរខ្មែរ គ្មានលទ្ធភាពឃុំពលករខ្មែរ ១៤ថ្ងៃនោះទេ ដោយសារពួកគាត់សម្រុក មកច្រើនពេក ខណៈសម្ដេចបញ្ជាក់ថា បើសិននៅភូមិណាមួយ រកឃើញពលករឆ្លងកូវីដ-១៩ ចំនួន ២ឬ៣នាក់ អាជ្ញាធរអាចនឹងបិទភូមិនោះចោល ដោយមិនឲ្យមានការ ចេញ-ចូល ។

ក្នុងពិធីជួបសំណេះសំណាលជាមួយ មន្ត្រីនគរបាលអន្តោប្រវេសន៍ នៅអាកាសយានដ្ឋាន អន្តរជាតិភ្នំពេញនាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ សម្ដេច ស ខេង បានថ្លែងថា រយៈពេលប៉ុន្មានថ្ងៃនេះមានពលករខ្មែរ ចូលមកកម្ពុជា ជាង១៥០០០ពាន់នាក់។ សម្ដេចរៀបរាប់ថា ថៃបិទការងារមួយចំនួន ដូចជា ការដ្ឋាន ការ៉ាអូខេ សណ្ឋាគារ ភោជនីយដ្ឋាន ហាងកាត់សក់ ជាដើម ទើបធ្វើឲ្យពលរកខ្មែរមិនមានការងារធ្វើ។ សម្ដេច មានប្រសាសន៍ថា«ដល់ចឹងប្រជាជនយើង ពលករខ្មែរយើងដែលធ្វើការនៅថៃ ដល់លឺគេថាបិទចឹងទៅ ហើយប្រជាជនថៃ ពលករថៃ ធ្វើនៅការនៅថៃមានអារម្មណ៍ចឹង យើងក៏មានអារម្មណ៍ចឹងដែលតាមគ្នាចឹងទៅ ដូច្នេះ រត់សម្រុកមករឿងអីពីមុនមកគាត់មិនមក។ចឹងបញ្ហារបស់យើងហានិភ័យនៅត្រង់ហ្នឹង នៅត្រង់ថា នៅពេលគាត់មកសម្រុកទៅ យើងនិយាយតាមការជាក់ស្ដែង អត់មានលទ្ធភាពត្រួតពិនិត្យ អស់ទេ។ហើយយើងក៏អត់មានលទ្ធភាព ដើម្បីនឹងឃុំពួកគាត់១៤ថ្ងៃដែរ។វាត្រួតពិនិត្យចឹងទៅ ហើយធ្វើបញ្ជី មុខសញ្ញានឹងនៅកន្លែងណាខ្លះ ស្រុក ភូមិ ខេត្តនៅណា ដើម្បីខេត្តសាមីខ្លួន ធ្វើការគ្រប់គ្រងបន្ត»។ សម្ដេចបន្តថា បើសិននៅភូមិណាមួយ មានពលករខ្មែរឆ្លង កូវីដ-១៩ ចាប់ពី ២ទៅ៣នាក់ ភូមិ

នោះ អាចនឹងបិទរយៈមួយពេលសិន ដើម្បីមានវិធានការដោះស្រាយបន្ត ជាពិសេស ធ្វើយ៉ាងណាកុំឲ្យរីករាលដាលទៅភូមិដទៃទៀត ដូច្នេះភាគីពាក់ព័ន្ធត្រូវត្រៀមជានិច្ច កុំឲ្យពលរដ្ឋមានការភ័យខ្លាចឲ្យសោះ។

សម្តេច ស ខេង បញ្ជាក់យ៉ាងដូច្នេះថា «បើសិនមានកន្លែងណាមួយកើតឡើង (កូវីដ-១៩) គឺថា ឃុំមួយផ្ទះហ្នឹង ឬថា ឃុំមួយកំណាត់ភូមិហ្នឹង ឧទាហរណ៍ថា ភូមិដាច់ដោយឡែកពីគ្នា ៤ទៅ៥ផ្ទះ អ៊ីចឹងទៅ។យើងអាចឃុំកន្លែងហ្នឹង កុំឲ្យគាត់ចេញទៅណា ហើយបើថា ភូមិហ្នឹងជាប់គ្នា ហើយមានច្រើននាក់ ២ទៅ៣នាក់ អ៊ីចឹងទៅ គឺថា ឃុំ ទាំងភូមិហ្នឹងតែម្តង ប៉ុន្មានភូមិហ្នឹង»។ ឆ្លៀតឱកាសនោះដែរ រដ្ឋមន្ត្រីមហាផ្ទៃ លើកឡើងថា ចំពោះបញ្ហាបិទព្រលានយន្តហោះនៅកម្ពុជា រាជរដ្ឋាភិបាល គ្មានគោលការណ៍បិទឡើយ ដោយដំណើរការជាធម្មតា ។ រដ្ឋមន្ត្រីមហាផ្ទៃ ថា បើសិន បណ្តាប្រទេសនានា គេបិទជើងហោះ មកកម្ពុជា ស្មើនឹងកម្ពុជាជើងបិទហោះហើរដែរ។ រដ្ឋមន្ត្រីមហាផ្ទៃ អះអាងថា «វិធានការបិទព្រលានយន្តយើងអត់មានទេ។ហើយបិទព្រំដែន យើងបានជជែកជាមួយថៃ និងវៀតណាមដែរ បានស្រុះគ្នាចឹងដំណើរការចឹង រីឯព្រលានយន្តហោះនៅដដែលទេ ទាំង៣ ទាំងភ្នំពេញ កំពង់សោម និងសៀមរាប។ប៉ុន្តែបើសិនណាគេបិទ ប្រទេសគេមិនឲ្យយន្តហោះមក ដូចតែយើងបិទ ដូចគ្នាទេ ហើយយើងបន្តតាមដានថែមទៀត»។

សូមរំលឹកថា គិតត្រឹមវេលាម៉ោង១០ យប់ ថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២០ កម្ពុជារកឃើញអ្នកឆ្លងជំងឺ កូវីដ-១៩ ចំនួន៨៧ករណី ខណៈក្រសួងសុខាភិបាល និងភាគីពាក់ព័ន្ធមួយចំនួនទៀត កំពុងបន្តស្វែងរក និងធ្វើតេស្តលើអ្នកពាក់ព័ន្ធ ផ្សេងទៀត ៕ដោយៈ អេង ប៊ូឆេង

## មីយ៉ាន់ម៉ាអំពាវនាវឲ្យក្រុមពលករដែលមកពីថៃវិញ ត្រូវស្នាក់នៅដាច់ដោយឡែកក្នុងផ្ទះរៀងៗខ្លួន ដើម្បីតាមដានសុខភាព១៤ថ្ងៃ

http://www.freshnewsasia.com/ 2020-03-23

**(មីយ៉ាន់ម៉ា)៖** ក្រសួងសុខាភិបាល និងកីឡាមីយ៉ាន់ម៉ាបានអំពាវនាវពលករទាំងអស់ ដែលត្រឡប់មកពីប្រទេសថៃ អនុវត្តវិធានការស្នាក់ដាច់ដោយឡែក ដោយខ្លួនឯងនៅក្នុងផ្ទះ ខណៈវាជារឿងមិនអាចទៅរួចឡើយក្នុងការរៀបចំកន្លែង ដើម្បីស្នាក់នៅដាច់ដោយឡែករួមគ្នា សម្រាប់មនុស្សក្នុងចំនួនដ៏ច្រើន។ នេះបើតាមការដកស្រង់ចេញផ្សាយដោយ ទីភ្នាក់ងារព័ត៌មានចិនស៊ីនហួរ នៅរសៀលថ្ងៃចន្ទ ទី២៣ ខែមីនា ឆ្នាំ២០២០។

នៅក្នុងជំនួបជាមួយគណៈកម្មាធិការកណ្តាល ដើម្បីបង្ការជំងឺរាតត្បាត រដ្ឋមន្ត្រីសុខាភិបាល និងកីឡាមីយ៉ាន់ម៉ាលោក មីន ហាធ្វេ (Myint Htwe) បានគូសបញ្ជាក់ដូច្នេះថា «អ្នកដែលទើបត្រឡប់មកពីក្រៅប្រទេស ចាំបាច់ត្រូវស្ថិតនៅក្នុងផ្ទះ ១៤ ដើម្បីចូលរួមទប់ស្កាត់ការឆ្លង COVID-19 ហើយត្រូវរាយការណ៍ជូនមជ្ឈមណ្ឌលសុខភាពជារៀងរាល់ថ្ងៃ នៅកំឡុងពេល ស្នាក់នៅដាច់ដោយឡែក»។ លើសពីនេះទៅទៀត លោក Myint ក៏បានអំពាវនាវពលករទាំងអស់ ដែលត្រឡប់មកពីប្រទេសថៃ អនុវត្តវិធានការស្នាក់ដាច់ដោយឡែក ដោយខ្លួនឯងនៅក្នុងផ្ទះ។

គួរបញ្ជាក់ថា មកទល់នឹងពេលនេះ ប្រទេសមីយ៉ាន់ម៉ា និងឡាវផងដែរ មិនទាន់រាយការណ៍ពីករណីឆ្លង COVID-19 សូម្បីមួយករណីនៅឡើយទេ។ ប៉ុន្តែបើតាមលោក Myint Htwe រដ្ឋាភិបាលមីយ៉ាន់ម៉ាបានត្រៀមរួចជាស្រេចហើយ នូវគ្រឿងបរិក្ខាពេទ្យ វិធានការបង្ការ និងការព្យាបាល៕

# ពលករបរទេសរាប់សែននាក់ សម្រុកចាកចេញពីប្រទេសថៃ ដែលមានចំនួនអ្នកឆ្លងកូវីដ១៩ ដល់៧២១នាក់

http://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ: 23/03/2020 - 17:05 ដោយៈឈាង បុប្ផា

បន្ទាប់ពីពលករខ្មែរ ពលករភូមា និងឡាវរាប់សែននាក់ បានសម្រុកចាកចេញពីប្រទេសថៃ កាលពីថ្ងៃចន្ទម្សិលមិញ។ នៅប្រទេសថៃ ជាទីដែលករណីឆ្លងមេរោគកូរ៉ូណាបានកើនឡើងទ្វេដង នៅប៉ុន្មានថ្ងៃចុងក្រោយនេះ រហូតដល់ ៧២១ករណី ជាពិសេសក្នុងទីក្រុងបាងកក អាជ្ញាធរបានសម្រេចបិទមជ្ឈមណ្ឌលពាណិជ្ជកម្ម សាលារៀន និងទីកន្លែងសាធារណៈ ដែលជាហេតុធ្វើឲ្យមនុស្សជាច្រើនគ្មានការងារធ្វើ ជាពិសេសពលករបរទេសមក ពីប្រទេសភូមា ឡាវ និងកម្ពុជា។

ពលករបរទេស បាននាំគ្នាចាកចេញពីរាជធានី បាងកក ដែលអាជ្ញាធរថៃកំពុងបង្កើនការរឹតបន្តឹងបិទផ្លូវ និងកាត់បន្ថយការធ្វើដំណើរ។ តាមការចុះផ្សាយរបស់ទីភ្នាក់ងារព័ត៌មានបារាំង AFP ទោះបីជារដ្ឋាភិបាលថៃអំពាវនាវកុំឲ្យប្រជាជនធ្វើដំណើរចាកចេញពីទីក្រុង ដើម្បីជៀសវាង ការចម្លង រីករាលដាលមេរោគកូរ៉ូណា ពលករដែលភាគច្រើនជាជនអន្តោប្រវេសន៍មកពីប្រទេសឡាវ បានប្រមូលកកកុញ គ្នា នៅស្ថានីយរថយន្តក្រុង ក្នុងក្រុងបាងកក ដើម្បីធ្វើដំណើរចាកចេញពីប្រទេសថៃ។ ពួកគេទាំងនោះមានចំនួន ជាង ៨៤០០០នាក់ ដែលចង់ធ្វើដំណើរទៅកាន់ភាគឦសានប្រទេសថៃ ជាប់ព្រំដែនជាមួយប្រទេសឡាវ។ តាមប្រធានក្រុមហ៊ុនដឹកជញ្ជូន Bangkok Bus ក្រុមហ៊ុនបានព្យាយាមដាក់មនុស្សឲ្យអង្គុយឃ្លាតគ្នា ដើម្បីកាត់បន្ថយលទ្ធភាពឆ្លងមេរោគកូរ៉ូណា។ នៅតំបន់ភាគខាងជើងថៃ ប្រជាជនភូមា ជាង ៩ពាន់នាក់បានធ្វើដំណើរឆ្លងព្រំដែនពីខេត្តតាក ប្រទេសថៃ ចូលទៅទឹកដីភូមា នៅយប់ថ្ងៃចន្ទ។ តាមចៅហ្វាយខេត្តតាក ថៃ ស្ពាន មិត្តភាព ថៃ ភូមា នឹងត្រូវបិទ នៅក្រោយការចាកចេញរបស់ជនអន្តោប្រវេសន៍ភូមា។ ពលករ ភូមា ខ្មែរ និងឡាវ ប្រមាណ ៤លាននាក់ ធ្វើការភាគច្រើននៅតាមរោងចក្រគ្រឿងសមុទ្រ ឬចំការបន្លែ ផ្លែឈើ ក្នុងប្រទេសថៃ។ នៅមុនពលករភូមា និងឡាវ ពលករខ្មែរបរាប់ពាន់នាក់បានធ្វើដំណើរត្រលប់ចូល ប្រទេសវិញ បន្ទាប់ពីមានការកើនឡើងនៃករណីឆ្លងមេរោគកូរ៉ូណានៅប្រទេសថៃ។

តាមកាសែតផ្លូវរដ្ឋភូមា The Global New Light of Myanmar រដ្ឋាភិបាលបានទាមទារឲ្យប្រជាជនដែលធ្វើដំណើរត្រលប់ចូលប្រទេសវិញ ដាក់ឃាំងខ្លួន ឲ្យនៅឆ្ងាយពីគេឯង រយៈពេល ២សប្តាហ៍។ ខុសពីកម្ពុជាដែលមានករណីអ្នកឆ្លងមេរោគកូរ៉ូណា កើនឡើងដល់៨៦នាក់ នៅថ្ងៃចន្ទទី២៣មីនា ភូមា និងឡាវឯណោះវិញគ្មានករណីឆ្លងកូរ៉ូណាវីរុសមួយទេ។ មានប្រជាជន៥៤លាននាក់ ភូមា ជាប្រទេសមានប្រជាជនច្រើនជាងគេដែលគ្មានករណីកូរ៉ូណាវីរុស។ ថ្មីៗនេះ អ្នកសរសេរបាយការណ៍មួយ របស់សកលវិទ្យាល័យHarvard វាយតម្លៃថា វាពិបាកនឹងគួរឲ្យជឿដែលថា ភូមា គ្មានករណីឆ្លងកូរ៉ូណាវីរុស បើគេមើលទៅលើទំនាក់ទំនងជិតស្និទ្ធ និងព្រំដែនជាប់គ្នារវាងចិន និងភូមា។ ដូចជាប្រទេសក្រីក្រផ្សេងទៀត ភូមា និងឡាវមានប្រព័ន្ធសុខាភិបាលខ្សត់ខ្សោយ ខ្វះមន្ទីរពេទ្យ និងគ្រូពេទ្យជំនាញ។ គេបារម្ភថា ប្រទេសអាស៊ីអាគ្នេយ៍ទាំងពីរ នឹងអាចប្រឈមនឹងបញ្ហាធ្ងន់ធ្ងរ ក្នុងករណី មានការរាតត្បាតជំងឺកូវីដ ១៩៕

# ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២០

## សម្តេចតេជោ ដាក់បញ្ជាតាមរក ពលករខ្មែរមកពីថៃ ដើម្បីពិនិត្យសុខភាព ចៀសវាងការចម្លង ជំងឺកូវីដ តាមភូមិ ស្រុក

https://dap-news.com/national/ ByDR103 Posted on March 25, 2020

ភ្នំពេញ៖សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានដាក់បទបញ្ជាតាមរកពលករខ្មែរ ដែលមកពីថៃ ដើម្បីយកមកពិនិត្យសុខភាព ចៀសវាងការរីករាលដាល ជំងឺកូវីដ១៩ នៅក្នុងភូមិ ឃុំ ស្រុក។ ការលើកឡើង របស់ប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីពលករខ្មែរធ្វើការនៅប្រទេសថៃ បានសម្រុកចូល មកស្រុកកំណើតវិញ ប្រមាណជាង១ម៉ឺន ៥ពាន់នាក់ កាលពីពេលកន្លងមកនេះ។ ថ្លែងក្នុងជំនួបសំណេះសំណាល ជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នាព្រឹកថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២០ សម្តេចបានលើកឡើងថា ដំណាក់កាលនេះ ដល់ពេលមានការ មិនទុកចិត្តគ្នាហើយ ប៉ុន្តែគួរដឹងខ្លួនថា បើសង្ស័យគួរ នៅឆ្ងាយពីគេ ។ សម្តេចបន្តថា "ជំងឺបាត់បង់ការជឿទុកចិត្តគ្នា គឺកើតមានហើយ ហើយខ្ញុំចង់រុញ ទូកបណ្តោយទឹក គឺកុំប៉ះពាល់គ្នា។ ប៉ុន្តែខ្ញុំប្រែក្លាយចំណុចនេះ ដោយមកធ្វើលើក ដៃសំពះ ជំនួសការចាប់ដៃគ្នា ហើយចំពោះការមិនទុកចិត្តគ្នា រវាងអ្នកនៅក្បែរគ្នា គឺនៅក្នុងផ្ទះខ្លួនឯង ទៅដូច្នេះវាក៏កាត់បន្ថយ ការឆ្លងបានផងដែរ"។

ចំពោះការរីករាលដាល ជំងឺនេះក្នុងស្រុកភូមិមួយចំនួន ដែលពលករខ្មែរមកពីថៃ នោះត្រូវបានសម្តេចតេជោបញ្ជាក់ទៅកំលាំងទាំងអស់ ចុះតាមមូលដ្ឋាន ធ្វើសកម្មភាពអប់រំ ដើម្បីប្រែក្លាយការភ័យខ្លាច ការសង្ស័យគ្នាទៅវិញទៅមក ឲ្យទៅជាចលនាការពារខ្លួន ទៅវិញ។ សម្តេចបានបញ្ជាក់ថា៖«ដំណាក់កាលការពារការឆ្លង ពីខាងក្រៅបានឆ្លងផុតហើយ ប៉ុន្តែយើងមិនឈប់ការពារនោះទេ។ យើងការពារពីខាងក្រៅផង និងការការពារខាងក្នុង និងការព្យាបាល អ្នកមានជំងឺឲ្យជា»។ សម្តេចបានលើកឡើងថា ជំងឺនេះ គឺជាជំងឺនាំចូលទាំងអស់ មិនមែនកម្ពុជាយើងទៅចម្លងឲ្យគេនោះទេ ។ សម្តេចសង្កត់ធ្ងន់ថា៖« ត្រូវគ្រប់គ្រងបន្ទាន់នូវពលករដែលមកពីថៃ ដែលបានចូលរួចមកហើយ ត្រូវតាមគ្រប់គ្រង អ្នកនឹងដែលការងារនេះ ត្រូវប្រគល់ឲ្យអាជ្ញាធរខេត្ត រៀបចំបណ្តាញចុះ ដើម្បីដាក់ឲ្យនៅដោយឡែក នៅតាមផ្ទះ។ ក្នុងប៉ុន្មាននេះ ខ្ញុំលើកទឹកចិត្តគ្រប់មធ្យោបាយ បានធ្វើការឃោសនា នៅតាមភូមិ»។

សម្តេចបន្ថែមថា ដើម្បីកុំឲ្យពលករមកពីថៃ មានការភ័យខ្លាច ដោយកុំធ្វើការដើរទៅណា ដោយដាក់នៅឲ្យដាច់ដោយឡែកពីគេ១៤ថ្ងៃ។ ប៉ុន្តែនៅពេលដែលរកកម្តៅ ឃើញត្រូវយកមកដាក់ នៅកន្លែងដែលរៀបចំរួចហើយ ។ សម្តេចបញ្ជាក់ថា «ត្រូវធ្វើកិច្ចការងារនេះឲ្យបាន ហើយត្រូវផ្អាកការបញ្ជូនមន្ត្រីទៅចូលរួមកិច្ចប្រជុំ នៅខាងក្រៅ ហើយលុបការប្រជុំអន្តរជាតិ ទាំងអស់នៅកម្ពុជា ។ ខ្ញុំបញ្ជាដាច់ខាត មិនឲ្យមន្ត្រីទៅប្រជុំ នៅខាងក្រៅប្រទេសនោះទេ »។ ជាមួយគ្នានោះដែរ សម្តេចតេជោ បានលើកឡើងថា ជំងឺនេះមិនងាយចប់ទេ ហើយកិច្ចប្រជុំធំៗទាំងអស់ត្រូវបានលុបចោល៕ ដោយ៖ ស សំណាង

## នាយករដ្ឋមន្ត្រី បញ្ជាទៅក្រសួងពាក់ព័ន្ធ ឲ្យធ្វើការជាមួយភាគីថៃ ទទួលយកពលករខ្មែរ មកវិញ ដោយសុវត្ថិភាព

https://dap-news.com/national/ ByPH104 Posted on March 25, 2020

ភ្នំពេញ ៖ នៅព្រឹកថ្ងៃពុធ ទី២៥ ខែមីនា ឆ្នាំ២០២០ ក្នុងពិធីសំណេះសំណាល ជាមួយគ្រូពេទ្យស្ម័គ្រចិត្ត មុនចេញបេសកកម្ម ជាមួយក្រសួងសុខាភិបាល ដើម្បីប្រយុទ្ធជាមួយជំងឺកូវីដ១៩ (COVID-19)សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាឲ្យក្រសួង ពាក់ព័ន្ធធ្វើការជាមួយភាគីថៃ ទទួលយកពលករខ្មែរ មកវិញដោយសុវត្ថិភាព និងមានការត្រួត ពិនិត្យសុខភាពត្រឹមត្រូវ ។

## អាជ្ញាធរក្រុងប៉ោយប៉ែត លាងសម្អាត បាញ់ទឹកសាប៊ូ សម្លាប់មេរោគ ក្នុង ទីធ្លា មណ្ឌលសំចត និង ស្ថានីយ៍រថភ្លើង ក្រុងប៉ោយប៉ែត នៅព្រឹកនេះ

https://www.facebook.com/Matimohachunnews/ សារព័ត៌មាន មតិមហាជន 25-03-2020

ក្រុងប៉ោយប៉ែត ៖ នៅថ្ងៃទី២៥ខែមីនាឆ្នាំ២០២០វេលាម៉ោង១០នឹង៣០នាទីព្រឹកអាជ្ញាធរក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយមានការអញ្ជើញចូលរួម ពី ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ • ឯកឧត្តម ង៉ោ ម៉េងជ្រួន អភិបាលរងខេត្តបន្ទាយមានជ័យ • លោក គាត ហ៊ុល អភិបាលនៃគណៈអភិបាលក្រុងប៉ោយប៉ែត លោក តាន់ គឹមរិទ្ធ សមាជិកាក្រុមប្រឹក្សាក្រុង • ក្រុមការងារ ថ្នាក់ខេត្ត ក្រុង និងមានការចូលរួមពីអាជ្ញាធរសង្កាត់ ភូមិ ប្រជាការពារ ចុះ លាងសម្អាត បាញ់ទឹកសាប៊ូ សម្លាប់មេរោគ ក្នុងទីធ្លានៅមណ្ឌលសំចត និងស្ថានីយ៍រថភ្លើង ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីត្រៀមកន្លែងរក្សា ពលករខ្មែរ ពិនិត្យមើលសុខភាពមុនបញ្ជូនត្រឡប់ទៅ តាមបណ្ដាល ខេត្តរៀងៗខ្លួន ដើម្បី ចូលរួមចំណែក បង្ការ ទប់ស្កាត់ ការរាតត្បាតនៃជំងឺកូវីដ ១៩ ដល់មូលដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ។

នៅក្នុងឱកាស នោះដែរ លោក តាន់ គឹមរិទ្ធ សមាជិកាក្រុមប្រឹក្សាក្រុង បានឧបត្ថម្ភ ថវិការ ៨,០០០,០០០ រៀល ( ប្រាំបីលានរៀល ) តាមរយៈលោក គាត ហ៊ុល អភិបាលនៃគណៈអភិបាលក្រុងប៉ោយប៉ែត ដើម្បី យកទៅចាត់ចែង ប្រើប្រាស់ នៅក្នុងយុទ្ធនាការ ប្រយុទ្ធ បង្ការទប់ស្កាត់ ការរាតត្បាតនៃជំងឺកូវីដ ១៩ ។

## កម្លាំងអាវុធហត្ថប្រើរថយន្ត៤គ្រឿងជួយដឹកជញ្ជូនពលរដ្ឋដែលវិលត្រឡប់ពីថៃទៅស្រុកកំណើតវិញ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 24/03/2020

ខេត្តបន្ទាយមានជ័យ ៖ រថយន្ត៤គ្រឿងនិង កម្លាំងអាវុធហត្ថចំនួន៣០នាក់បានជួយដឹកជញ្ជូនពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃទៅស្រុកកំណើតវិញ ដោយសុវត្ថិភាពដឹកនាំដោយលោកឧត្តមសេនីយ៍ត្រីបោនប៊ិនមេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ និងមេបញ្ជាការរងនៅព្រឹក ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០២០ នៅចំណុចច្រកទ្វារអន្តរជាតិប៉ោយប៉ែត។

លោក បោន ប៊ិន បានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថាការជួយដឹកជញ្ជូនពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃទៅស្រុកកំណើតវិញដោយសុវត្ថិភាពនោះដោយគោរពតាមបទបញ្ជារបស់លោកនាយឧត្តមសេនីយ៍ សៅ សុខា អគ្គបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានដាក់ចេញនូវបទបញ្ជាដល់កំលាំងអាវុធហត្ថខេត្តបន្ទាយមានជ័យ យករថយន្តរបស់អង្គភាពអាវុធមានទាំងប៉ុន្មានយកទៅដឹកពលរដ្ឋដែលបុកមកពីប្រទេសថៃរាប់ពាន់នាក់កកកុញនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត យកទៅស្រុកកំណើរវិញដោយសុវត្ថិភាពដែលអាចធ្វើទៅបាន។លោកឧត្តមសេនីយ៍ត្រី បោន ប៊ិនបានបញ្ជាក់ឲ្យដឹងទៀតថានៅយប់ ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០២០នោះមានពលករខ្មែរចំនួន៥.០០០នាក់ ត្រូវបានភាគីថៃអនុញ្ញាតឲ្យធ្វើដំណើរមកស្រុកកំណើតវិញ ដើម្បីបញ្ចៀសការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ក្នុងនោះពួកពលករទាំង៥.០០០នេះអាជ្ញាធរកម្ពុជាតម្រូវឲ្យទៅនៅមណ្ឌលសំចតមួយរយៈ ដើម្បីត្រួតពិនិត្យសុខភាព បើរកឃើញលើបុគ្គលណាមួយសង្ស័យថាមានផ្ទុកមេរោគ គឺគេទុកឲ្យពួកគាត់នៅទីនោះរយៈពេល១៤ថ្ងៃដើម្បីព្យាបាលបើរកអត់ឃើញសង្ស័យថា មានមេរោគនោះទេ ពួកគាត់ នឹងត្រូវអនុញ្ញាតឲ្យទៅតាមលំនៅឋានរៀងៗខ្លួនវិញ ក្រោមការតាមដានពីអាជ្ញាធរមូលដ្ឋានបន្តទៀត។

លោកបានបញ្ជាក់ឲ្យដឹងទៀតថាកន្លែងសំចតមានចំនួន២កន្លែងទី១ នៅភូមិដីថ្មី ស្ថិតក្នុងសង្កាត់ប៉ោយប៉ែត ទី២ ស្ថិតក្នុងចំណតរ៉ារថភ្លើង ហើយពេលនេះពលករទាំងអស់ស្ថិតក្រោមការយកចិត្តទុកពីអាជ្ញាធរកម្ពុជាយ៉ាងខ្លាំង

។ប្រជាពលរដ្ឋខ្មែរដែលវិលមកស្រុកកំណើតវិញនោះភាគច្រើន នៅតាមព្រំដែនកម្ពុជាថៃ ជាពិសេសនៅខេត្តស្រះកែវប្រទេសថៃ ដើម្បីឲ្យវិលត្រឡប់មកស្រុកកំណើតវិញ ដោយខានមិនបាន ដែលចំនួនប្រជាពលរដ្ឋដែលវិលត្រឡប់ទៅស្រុកកំណើតវិញនោះ គឺមានចំនួនជាង៥ពាន់នាក់ឯណោះ ហើយការធ្វើដំណើរគឺចាប់ពីព្រឹកម៉ោង៧រហូតដល់ម៉ោង ១២យប់ឯណោះ ទើបមានការបិទច្រកទ្វារតែម្តង។

ក្នុងនោះលោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យបានមានប្រសាសន៍ថា ពលរដ្ឋខ្មែរ ដែលដែលមកពីប្រទេសថៃនោះអាជ្ញាធរខេត្តបានប្រមូលពួកគាត់ឲ្យនៅក្នុងមណ្ឌលសំចតមួយរយៈដើម្បីរង់ចាំគ្រូតពិនិត្យសុខភាពពីសំណាក់លោកគ្រូពេទ្យសិនមិនឲ្យធ្វើដំណើរផ្តេសផ្តាសនោះឡើយ ព្រោះខ្លាចពួកគាត់ផ្ទុកនូវមេរោគកូវីដ១៩ យកទៅចម្លងដល់ក្រុមគ្រួសារ ដែលនៅឯស្រុកកំណើតរបស់ខ្លួន។ដូច្នេះត្រូវតែដាក់ពួកគាត់នៅដោយឡែកមួយរយៈ រង់ចាំឲ្យគ្រូពេទ្យពិនិត្យសុខភាពរបស់ពួកគាត់បើសិនជាជនណាសង្ស័យមានផ្ទុកមេរោគ កូវីដ១៩ គឺគេនឹងយកទៅព្យាបាលទៅតាមនីតិវិធីរបស់ពេទ្យ ហើយបើសិនជាជនណា អត់មានផ្ទុកនូវមេរោគនេះ នោះទេ នឹងគេឲ្យត្រឡប់ទៅស្រុកកំណើតវិញនាពេលដ៏ខ្លីខាងមុខនេះផងដែរ៕

## អាជ្ញាធរខេត្តបាត់ដំបង រៀបចំកន្លែងស្នាក់នៅសម្រាប់ពលករមកពីថៃ ដើម្បីធ្វើតេស្តកូវីដ១៩

http://bayontv.com.kh/ 24/03/2020

បាត់ដំបង ៖ អាជ្ញាធរក្រុង ស្រុក ក្នុងខេត្តបាត់ដំបង បានរៀបចំកន្លែងស្នាក់នៅ និងដាក់នៅដាច់ដោយឡែកនូវពល ករខ្មែរ ដែលទើបវិលត្រឡប់ពីប្រទេសថៃ មកកាន់ស្រុកកំណើតវិញ ដើម្បីពិនិត្យធ្វើតេស្តរកវីរុសកូវីដ១៩ រួមទាំងត្រៀមនូវគ្រឿងឧបភោគបរិភោគ សម្រាប់ពួកគេ ក្នុងអំឡុងពេលស្នាក់នៅរយៈពេលខ្លីនេះផងដែរ។

លោក ផេង សិទ្ធី អភិបាលក្រុងបាត់ដំបង នៅថ្ងៃទី២៤ ខែមីនា នេះ បានឲ្យដឹងថា បើតាមតួលេខ បណ្ដោះអាសន្ន យ៉ាងហោចណាស់ មានពលរដ្ឋខ្មែរ ដែលវិលត្រឡប់ពីប្រទេសថៃ និងពីតំបន់ផ្សេងៗ ចំនួនប្រមាណជិត ២០០នាក់ មកដល់ក្រុងបាត់ដំបង ហើយសាលាក្រុង កំពុងជំរុញដល់មន្ត្រីតាមភូមិ សង្កាត់ ចុះស្រង់ស្ថិតិពីការវិលត្រឡប់របស់ពលរដ្ឋទាំងនោះ ដើម្បីមានវិធានការឆ្លើយតប ការពារការចម្លង និងជំរុញឲ្យពួកគេមកធ្វើតេស្តរកកូវីដ–១៩។ លោកបានឱ្យដឹងថា សម្រាប់ក្រុងបាត់ដំបង បានរៀបចំនូវអគារក្នុងសាលាបឋមសិក្សាសាលាបាឡាត់ នៅក្នុងសង្កាត់អូរម៉ាល់ ហើយបច្ចុប្បន្នមន្ត្រីកំពុងរៀបចំបោសសម្អាត រៀបចំបណ្ដាញទឹកភ្លើង បង្គន់ អនាម័យឲ្យបានល្អ សម្រាប់ជាទីស្នាក់នៅបណ្ដោះអាសន្ន របស់ពលករខ្មែរទាំងអស់នេះ ថែមទាំងមាន ការផ្គត់ផ្គង់នូវអាហារផងដែរ។

ក្នុងឱកាសនាំយកគ្រឿងឧបភោគបរិភោគ សម្រាប់ជួយឧបត្ថម្ភដល់សាលាក្រុង ក្នុងការផ្គត់ផ្គង់ ដល់ពលករក្នុងការងារទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ឯកឧត្តម ងិន យន ប្រធានក្រុមការងារចុះ មូលដ្ឋានក្រុងបាត់ដំបង បានជំរុញដល់ក្រុមការងារទាំងអស់ ត្រូវចូលរួមជាមួយអាជ្ញាធរខេត្ត ក្នុងការទប់ ស្កាត់នូវជំងឺកូវីដ១៩ ទាំងថវិកា ទាំងកម្លាំងកាយ តាមរយៈការជួយផ្សព្វផ្សាយ ពីការថែទាំអនាម័យ ការមិន បំផុស បំផុលនូវព័ត៌មានមិនពិតជាដើម។ ក្នុងការងារទប់ស្កាត់នូវការរាតត្បាតជំងឺកូវីដ១៩នេះ រដ្ឋបាលខេត្តបាត់ដំបង បានរៀបចំនូវអគារ វិទ្យាល័យព្រះមុនីវង្ស និងអគាររបស់សណ្ឋាគារ សរុបចំនួន១៨០បន្ទប់ ដើម្បីត្រៀមសម្រាប់ការស្នាក់នៅ របស់ពលរដ្ឋនៅក្នុងខេត្ត ដែលមកធ្វើតេស្តរកជំងឺកូវីដ១៩។ ក្រៅពីនោះ នៅមានរដ្ឋបាលស្រុកមួយចំនួន កំពុងរៀបចំនូវអគារស្នាក់នៅរបស់ពលរដ្ឋ ក្នុងការងារនេះផងដែរ៕

## អភិបាលរងខេត្ត ណែនាំឲ្យអាជ្ញាធរស្រុក ស្រង់ស្ថិតិពលរដ្ឋ វិលត្រឡប់មកពីក្រៅប្រទេសឲ្យបានច្បាស់លាស់ ដើម្បីបង្ការនៃការឆ្លងវីរុសកូវីដ-១៩

http://bayontv.com.kh/ 24/03/2020

កណ្តាល៖ ឯកឧត្តម នៃ ចារី អភិបាលរងខេត្ត បានណែនាំដល់អាជ្ញាធរស្រុក ត្រូវធ្វើការស្រង់ស្ថិតិប្រជាពលរដ្ឋ ដែលទើបត្រលប់មកពីប្រទេសថៃ កូរ៉េ ម៉ាឡេស៊ី និងប្រទេសដទៃផ្សេងទៀត ឲ្យបានច្បាស់លាស់ ដើម្បីបង្ការនៃការឆ្លងវីរុសកូវីដ–១៩។ ឯកឧត្តម នៃ ចារី បានបញ្ជាក់ថា ក្នុងករណីមានប្រជាពលរដ្ឋដែលទើបមកពីប្រទេសផ្សេងក្នុងមូលដ្ឋានរបស់ខ្លួន អាជ្ញាធរស្រុក ត្រូវចាត់មន្ត្រីជំនាញ ចុះធ្វើការពិនិត្យ ជូនពួកគាត់ដល់ផ្ទះ ហើយត្រូវធ្វើការណែនាំ ដល់ពួកគាត់អោយ នៅដាច់ដោយឡែកពីក្រុមគ្រួសារ រយៈពេល១៤ថ្ងៃ ហើយអាជ្ញាធរស្រុកត្រូវរកទីតាំងសមស្របណាមួយជូនពួកគាត់។ ក្នុងករណីមានការសង្ស័យ ត្រូវបញ្ជូនគាត់ទៅមន្ទីរពេទ្យ ដើម្បីធ្វើការពិនិត្យ និងព្យាបាលជាបន្ទាន់។ ថ្លែងនៅព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ឯកឧត្តម នៃ ចារី អភិបាលរងខេត្ត តំណាងឯកឧត្តម គង់ សោភ័ណ្ឌ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល បាននាំយកថវិកា ចំនួន២៩លានរៀល ឧបត្ថម្ភដល់ស្រុកកណ្តាលស្ទឹង ដើម្បីចុះអប់រំ និងផ្សព្វផ្សាយ ជាលក្ខណៈយុទ្ធនាការជាប្រចាំ ក្នុងមូលដ្ឋានភូមិ ឃុំរបស់ខ្លួន នូវវិធីសាស្ត្រការធ្វើអនាម័យអោយបានញឹកញាប់ កុំមានការប្រមូលផ្តុំគ្នា ចេញក្រៅពាក់ម៉ាសឲ្យបានត្រឹមត្រូវ និងការបង្ការនៃការឆ្លងវីរុសកូវីដ–១៩។ ក្នុងឱកាសនោះដែរ ឯកឧត្តមអភិបាលរង បន្ថែមថា ការចុះយុទ្ធនាការផ្សព្វផ្សាយ អប់រំ និងណែនាំជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននេះ គឺអនុវត្តតាមការគោលការណ៍ របស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ស្តីពីវិធានការណ៍បង្ការ ទប់ស្កាត់ ការរីករាលជំងឺកូវីដ១៩ ទូទាំងប្រទេសកម្ពុជា។

សម្រាប់ លោក អ៊ូច សារឿន អភិបាលស្រុកកណ្តាលស្ទឹង បានឲ្យដឹងថា គិតត្រឹមព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ មានបងប្អូនពលករដែលមកពីប្រទេសថៃ ចំនួន១៨នាក់ ហើយស្រុកបានអោយគាត់ពិនិត្យសុខភាពនៅតាមមណ្ឌលសុខភាព ឬ ពេទ្យបង្អែក មិនមានអ្នកផ្ទុកជំងឺកូវីដ–១៩ឡើយ ទើបអនុញ្ញាត អោយគាត់ទៅក្នុងសហគមន៍វិញ ព្រមចាត់មន្ត្រីជំនាញចុះពិនិត្យតាមដានសុខភាពជាប្រចាំនៅលំនៅឋាន ហើយបានណែនាំពួកគាត់ អោយនៅដាច់ដោយឡែកចំនួន១៤ថ្ងៃ ដើម្បីបង្ការការឆ្លងទៅក្រុមគ្រួសារ និងអ្នកជិតខាង៕

## តម្រួតថៃចាប់បញ្ជូនពលករខ្មែរម្នាក់មកកម្ពុជា ក្រុមសមត្ថកិច្ចនគរបាលអូរបើជាន់បញ្ជូនទៅកាន់មណ្ឌលសុខភាព

http://cambodiapolice.com/policekh/ 12:26 pm 24 មីនា 2020

បន្ទាយមានជ័យ៖ ពលករខ្មែរម្នាក់ត្រូវបានកម្លាំងតម្រួតថៃបញ្ជូនមកប្រគល់ឲ្យសមត្ថកិច្ចនគរបាលនៅព្រំដែន ខណៈដែលពល កររូបនេះគាត់បានដើរចេញចូលនៅទឹកដីថៃ ហើយបានដួលបណ្តាលឲ្យគ្រេចចង្កេះឃើញដូច្នោះកម្លាំងសមត្ថកិច្ចនគរបាលប៉ុស្តិ៍រដ្ឋបាលអូរបើជាន់ក៏បញ្ជូនពលកររូបនេះទៅកានមណ្ឌលសុខភាពអូរបើជាន់។

នេះបើយោងតាមការអះអាងរបស់លោកវរសេនីយ៍ទោ សែស វិបុល អធិការនគរបាលស្រុកអូរជ្រៅ នៅព្រឹកថ្ងៃទី២៤ ខែមិនា ឆ្នាំ២០២០នេះ។ លោកអធិការបន្តថា ក្រោយពីខាងគ្រូពេទ្យមណ្ឌលសុខភាពពិនិត្យទៅឃើញថាកម្តៅបានឡើងខ្ពស់ដល់ទៅ៣៧.៥អង្សាសេ គ្រូពេទ្យក៏បញ្ជូនបន្តទៅកាន់មន្ទីរពេទ្យបង្អែកក្រុងប៉ោយប៉ែត ដើម្បីពិនិត្យបន្ត។ លោកអធិការស្រុកអូរជ្រៅដ៏ដែលបន្តថា ពលកររូបនេះមានឈ្មោះ សាន សានិត អាយុ៣៨ឆ្នាំ រស់នៅស្រុកមោងឬស្សី ខេត្តបាត់ដំបង។ ពលកររូបនេះបានទៅរស់នៅប្រទេសថៃធ្វើការនៅទីនោះ(ប្រទេសថៃ)២០ឆ្នាំ មកហើយ។

តម្រួតថៃបានចាប់ខ្លួននៅភូមិអាងសិលាថៃ ស្រុកគោកផ្សូង ខេត្តស្រះកែវ ហើយបានបញ្ជូនមកកម្ពុជា តាមច្រករបៀងទំនប់ដាច់ ភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្ត បន្ទាយមានជ័យ នៅវេលាម៉ោង៧និង៣០នាទីព្រឹក ថ្ងៃទី២៤មិនានេះ។ កែសម្រួលដោយ៖ អនុសេនីយ៍ឯក ឱន សុខស៊ីថា

## កងកម្លាំងនគរបាលបន្តយុទ្ធនាជួយដឹកពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ

http://www.rasmeinews.com/ March 24, 2020, 5:26 PM

ដោយ៖ ប.ជ័យ/ព្រំដែនកម្ពុជា-ថៃ៖មន្ត្រីនគរបាលការពារព្រំដែនបានឱ្យដឹងថា៖យោងការអនុវត្តការណែនាំនិងបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ អាត់ ខែម ស្នងការនគរបាលខេត្តបន្ទាយមានជ័យនោះកងកម្លាំងក្រុងប៉ោយប៉ែត,ស្រុកម៉ាឡៃ,ស្រុកថ្មពួក,ស្រុកស្វាយចេក,នគរបាលការពារព្រំដែនគោករះសេនាតូចលេខ 815,891, 911,807,។ កម្លាំងទាំងអស់នេះបានចាំទទួលដឹកជញ្ជូនប្រជពលរដ្ឋនិងពលករខ្មែរវិលពីប្រទេសថៃនៅច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតច្រកព្រំដែនតំបន់ម៉ាឡៃនិងបឹងត្រកួន។ ឯច្រករបៀងខ្លះទៀតក៏ត្រូវបានបិទហើយតាំងពីថ្ងៃទី២៣ខែមីនាក៏មកទល់ល្ងាចថ្ងៃទី២៤ខែមីនាឆ្នាំ២០២០។ ក៏នៅមានពលករខ្មែរមួយចំនួនបន្តចេញពីប្រទេសថៃមកកម្ពុជាតាមច្រករបៀងនានាក្រោយពីច្រកព្រំដែនបានបិទចំនួន១៤ថ្ងៃពីម៉ោង៦ព្រឹក ថ្ងៃទី២៣ ខែមីនាដល់ម៉ោង១០យប់ថ្ងៃទី៥ខែមេសាឆ្នាំ២០២៩។ ទោះយ៉ាងណាពលករខ្មែររាប់រយនាក់បានបន្តឆ្លងកាត់មកមាតុប្រទេសវិញ៕S/

## ក្រោយបិទព្រំដែនពលករខ្មែរចូលតាមច្រកអន្តរជាតិប៉ោយប៉ែត ត្រូវបានរឹតបន្តឹងការ ពិនិត្យសុខភាពដើម្បីទប់ស្កាត់ជំងឺ COVID-19

http://nokorwatnews.com/ 24-03-2020

ប៉ោយប៉ែត៖ ពលករខ្មែរជាង៥០០នាក់ដែលអាជ្ញាធរថៃ បញ្ជូនមកតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យកាលពីរសៀលថ្ងៃចន្ទ ១៥ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ត្រូវបានរឹត បន្តឹងការពិនិត្យសុខភាពដើម្បីរួមចំណែកទប់ ស្កាត់ការរីករាលដាលវីរុសកូវីដ១៩(COVID-19) ។ ក្នុងឱកាសដឹកនាំក្រុមការងារចុះជួយដល់ពលករនៅច្រកទ្វារប៉ោយប៉ែត លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា៖ ក្រុមការងារគ្រប់ថ្នាក់ កងកម្លាំងមានសមត្ថ កិច្ចបានធ្វើការយ៉ាងសកម្ម ដោយជួយសម្របសម្រួលដល់បងប្អូនពលករខ្មែរយើង ដែលអាជ្ញាធរថៃបញ្ជូនមកតាមច្រកអន្តរជាតិប៉ោយប៉ែតនេះ។ ក្នុងប្រតិបត្តិការជួយដល់បងប្អូនខ្មែរយើង នេះដោយប្រើប្រាស់គ្រប់មធ្យោបាយ តាមវិធានការរឹតបន្តឹងការពិនិត្យសុខភាព និងអប់រំផ្សព្វ ផ្សាយដល់ពួកគាត់ទាំងអស់ នៅមណ្ឌលសំចត និងស្ថានីយរថភ្លើង ក្នុងក្រុងប៉ោយប៉ែត មុន នឹងមានការអនុញ្ញាត ឱ្យចេញទៅមូលដ្ឋានភូមិ ឃុំ ខេត្តរៀងៗខ្លួន ធ្វើការត្រួតពិនិត្យបន្តដើម្បី រួមចំណែកទប់ស្កាត់វីរុសកូវីដ១៩ (COVID-19) ។

អភិបាលខេត្តបន្ទាយមានជ័យ ក៏បានធ្វើការអប់រំណែនាំដល់ពលករដែលចេញមកពី ប្រទេសថៃទាំងអស់ត្រូវដាក់ខ្លួនដាច់ ដោយឡែករយៈពេល១៤ថ្ងៃ ដើម្បីការពារបញ្ចៀសនូវ ការរីករាលដាលពីជំងឺកូវីដ១៩ និងត្រូវស្តាប់សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ហើយបើមានពលករណាមានសុខភាពមិនល្អ រហ័សទាក់ទងទៅលេខ ១១៥ជាបន្ទាន់។ដើម្បីការពារ ខ្លួនអ្នក និងក្រុមគ្រួសារអ្នកត្រូវធ្វើអនាម័យកន្លែងរស់នៅឱ្យបានស្អាត បើចេញក្រៅផ្ទះពាក់ ម៉ាសដើម្បី ការពារត្រូវលាងសម្អាតដៃនឹងសាប៊ូ ឬអាកុលឱ្យបានញឹកញាប់ ។

លោកវេជ្ជបណ្ឌិត កែវ សុភ័ក្រ្កា ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ បានឱ្យដឹងដែរថា ៖ក្នុងចំណោមពលករជាង៥០០នាក់ ដែលបានធ្វើដំណើរចាកចេញពីប្រទេសថៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ត្រូវ

បានអាជ្ញាធរ និងក្រុមគ្រូពេទ្យពិនិត្យរកឃើញភាពមិនប្រក្រតី ចំនួន ១០នាក់ដោយមានអាការៈក្តៅខ្លួនហើយត្រូវបានក្រុមគ្រូពេទ្យបញ្ជូនទៅមន្ទីរ ពេទ្យបង្អែកជីថ្មី ដើម្បីយកទៅពិនិត្យព្យាបាលបន្ត។

សូមបញ្ជាក់ថា គិតត្រឹមម៉ោង៧យប់ថ្ងៃ២៣ ខែមីនា ឆ្នាំ២០២០ ពលករដែលត្រឡប់ ពីប្រទេសថៃ ប្រមាណជាង៥០០នាក់ ទាំងនៅស្ថានីយរថភ្លើង និងមណ្ឌលសំចតក្រុងប៉ោយ ប៉ែត ខេត្តបន្ទាយមានជ័យ ត្រូវបានអាជ្ញាធរសម្រេចអនុញ្ញាតិឱ្យបន្តដំណើរទៅស្រុកកំណើត រៀងៗ ខ្លួនហើយ ក្រោយពីក្រុមគ្រូពេទ្យពិនិត្យឃើញថាពួកគាត់គ្មានជំងឺកូវីត ១៩នោះ។

បើតាមការសាកសួរបានឱ្យដឹងថា ៖ ភាគច្រើនពលរដ្ឋទាំងនោះគឺមកពីខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង បាត់ដំបង កំពង់ធំ សៀមរាប និងខេត្តបន្ទាយមានជ័យ។ ទន្ទឹមគ្នានៃការ វិលត្រឡប់នេះ អាជ្ញាធរបានចែកបាយម្នាក់១ប្រអប់ ទឹកបរិសុទ្ធ១ដប ហើយក៏មានការជួយការ ពារសុវត្ថិភាព ពីសំណាក់កម្លាំងនគរបាល និងកងរាជអាវុធហត្ថយ៉ាងយកចិត្តទុកដាក់ផងដែរ៕ វណ្ណា

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់

General Department of Immigration - GDI

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៧និង០០នាទី ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០២នាក់នេះ មាន ១. ឈ្មោះ ប្រាក់ ផាន់ណា ភេទប្រុស អាយុ ៣៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិអូរក្រូច ឃុំតាតោក ស្រុកសំលូត ខេត្តបាត់ដំបង និង២. ឈ្មោះ ឌួន យើន ភេទប្រុស អាយុ ៣៥ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិព្រៃទទឹង ស្រុកកំពង់ត្រាច ខេត្តកំពត ដោយមានការចូលរួមពី មន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពផងដែរ និងបានធ្វើការអប់រំ ណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## អភិបាលខេត្តបន្ទាយមានជ័យ អំពាវនាវដល់ពលករខ្មែរទាំងអស់នៅប្រទេសថៃ កុំចាញ់បោកមេខ្យល់ដែលធានាថាជូនមកដល់កម្ពុជា និងត្រូវអនុវត្តតាមអាជ្ញាធរថៃ

https://grandnewsasia.com/ 24-03-2020

បន្ទាយមានជ័យ៖ អភិបាលខេត្តបន្ទាយមានជ័យ លោក អ៊ុ រាត្រី បានធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ ពលករយើងទាំងអស់នៅប្រទេសថៃ កុំចាញ់បោកមេខ្យល់ ដែលថាអាចនាំចូលឆ្លងមកប្រទេសកម្ពុជាយើង ដូចជាតាមច្រករបៀង ច្រកតំបន់ជាដើមបាន។ លោកបានថ្លែងដូចនេះក្នុងឱកាសជួប និងណែនាំផ្សព្វផ្សាយវិធានការទប់ស្កាត់កូវីត១៩ ជាមួយពលករខ្មែរប្រមាណជាង៨០នាក់ នៅមណ្ឌលសំចត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាល្ងាចថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ (ដែលត្រូវបានអាជ្ញាធរថៃបញ្ជូនមកដល់ព្រំដែន ហើយខាងកម្ពុជាសហការសម្របសម្រួលបានចេញមកកម្ពុជា)។ លោកអភិបាលខេត្ត ក៏បានសំណូមពរដល់បងប្អូនប្រជាពលរដ្ឋយើងទាំងអស់ សូមផ្តាំផ្ញើប្រាប់បន្តទៅបងប្អូនសាច់ញាតិនៅក្នុងប្រទេសថៃ កុំឲ្យបន្តជឿ និងចាញ់បោកមេខ្យល់ទៀត នាំឲ្យប៉ះពាល់សុខភាព ខាតបង់ប្រាក់ជាដើម។ ផ្ទុយទៅវិញសូមរក្សាការស់នៅ និងធ្វើការនៅក្នុងប្រទេសថៃស្តាប់តាមការណែនាំរបស់អាជ្ញាធរថៃសិនដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជម្ងឺកូវីត១៩ និងសុខភាព សុវត្ថិភាពខ្លួន។

គួរបញ្ជាក់ថា យោងតាមព័ត៌មានសួរនាំជាមួយបងប្អូនពលករខ្មែរនៅប្រទេសថៃ បានឱ្យដឹងថាពួកគាត់បានមកដល់កម្ពុជាត្រូវបានមេខ្យល់យកលុយប្រមាណ ៥០០បាត ទៅ១៥០០បាត ហើយនាំចេញពីប្រទេសថៃមក បើ

ទោះមានការប្រកាសជូនដំណឹងយ៉ាងច្បាស់ហើយពីអាជ្ញាធរថៃ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ បិទច្រក១៤ថ្ងៃ នៅព្រំដែនទាំងអស់ជាមួយកម្ពុជាក៏ដោយ៕

## អភិបាលខេត្តបន្ទាយមានជ័យ ចុះសម្របសម្រួលពលករនៅច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត

https://grandnewsasia.com/ 24-03-2020

បន្ទាយមានជ័យ៖ លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានអញ្ជើញដឹកនាំក្រុមការងារគ្រប់ថ្នាក់ កងកម្លាំងមានសមត្ថកិច្ច បានសហការជួយសម្របសម្រួលដល់បងប្អូនពលករខ្មែរយើង ដែលអាជ្ញាធរថៃបញ្ជូនមកតាមច្រកអន្តរជាតិប៉ោយប៉ែត ប្រមាណជិត ១០០០នាក់ គិតត្រឹមម៉ោង៥ល្ងាចថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០។ ក្នុងប្រតិបត្តិការជួយដល់បងប្អូនខ្មែរយើងពេញ១ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០នេះ ដោយប្រើប្រាស់គ្រប់មធ្យោបាយតាមវិធានការរឹតបន្តឹងការពិនិត្យសុខភាព និងអប់រំផ្សព្វផ្សាយដល់ពួកគាត់ទាំងអស់ នៅមណ្ឌលសំចត និងស្ថានីយ៍រថភ្លើង ក្នុងក្រុងប៉ោយប៉ែត មុននឹងមានការអនុញ្ញាតឲ្យចេញទៅមូលដ្ឋានភូមិ ឃុំ ខេត្តរៀងៗខ្លួន ធ្វើការត្រួតពិនិត្យបន្តដើម្បីរួមចំណែកទប់ស្កាត់ វីរុសកូវីដ១៩ (COVID-19) ។ លោក អ៊ុំ រាត្រី ក៏បានអំពាវនាវដល់ប្រជាពលរដ្ឋដែលទើបតែវិលត្រឡប់មកពីក្រៅប្រទេសវិញត្រូវនៅដាច់ដោយឡែកពីអ្នកដទៃរយៈពេល១៤ថ្ងៃ និងបន្តតាមដានសុខភាពខ្លួនឯង ប្រសិនបើសង្ស័យថាខ្លួនមានផ្ទុកនូវវីរុសកូវីដ 19នេះ សូមទំនាក់ទំនងទៅកាន់លេខទូរស័ព្ទ 115 ឬមន្ទីរពេទ្យដែលនៅជិតលោកអ្នកបំផុត ។

សូមបញ្ជាក់ផងដែរថា គិតមកដល់ពេលនេះ ខេត្តបន្ទាយមានជ័យ មានករណីជំងឺកូវីដ ១៩ កើតឡើងចំនួន០២ នាក់ ម្នាក់ឆ្លងមកពីប្រទេសម៉ាឡេស៊ី និងម្នាក់ទៀតឆ្លងមកពីប្រទេសថៃ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ចូលរួមទប់ស្កាត់ការរីករាលដាលនូវជំងឺនេះដោយប្រកាន់ខ្ជាប់នូវការរស់នៅស្អាត ហូបស្អាត និងលាងដៃជាមួយទឹកសាប៊ូឱ្យបានញឹកញាប់៕

## នៅខេត្តកំពង់ធំ មានពលករខ្មែរ៧៧៤នាក់ បានវិលត្រឡប់មកកាន់ស្រុកកំណើត

http://kampucheathmey.com/ 25/3/2020 8:13 Am

កំពង់ធំ ៖ នៅខេត្តកំពង់ធំ ពលករខ្មែរ ដែលវិលត្រឡប់មកពីបណ្តាប្រទេសជិតខាងកម្ពុជាវិញ គិតត្រឹមម៉ោង១៦និង០០នាទី ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ មានចំនួន៧៧៤នាក់។ នេះបើយោងតាមរបាយការណ៍របស់មន្ទីរព័ត៌មានខេត្តកំពង់ធំ គោរពរាយការណ៍ជូនលោកខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ហើយត្រូវបានលោកធ្វើការផ្សព្វផ្សាយនៅបណ្តាញសង្គមហ្វេសប៊ុក នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០នេះ។ របាយការណ៍នោះ បានបញ្ជាក់ថា សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រី សូមជូនរបាយការណ៍ ស្តីពីទិន្នន័យពលករខ្មែរ វិលត្រឡប់មកពីបណ្តាប្រទេសជិតខាងមកកម្ពុជាវិញ មកដល់មូលដ្ឋានខេត្តកំពង់ធំ គិតត្រឹមម៉ោង16:00នាទី ថ្ងៃទី 24 ខែមីនា ឆ្នាំ 2020 តាមរបាយការណ៍ពីស្នងការនគរបាលខេត្តកំពង់ធំ។

+ សរុបមានចំនួន 774 នាក់ ស្រី 326 នាក់ ក្នុងនោះ :

– មកពីប្រទេសថៃ ចំនួន 765 នាក់ ស្រី 321នាក់

– មកពីប្រទេសម៉ាឡេស៊ី ចំនួន 04នាក់ ស្រី 02នាក់

– មកពីប្រទេសកូរ៉េ ចំនួន 02នាក់ ស្រី01 នាក់

– មកពីប្រទេសជប៉ុន ចំនួន 02 នាក់ ស្រី 01 នាក់

– មកពីប្រទេសចិន ចំនួន 01នាក់ ស្រី

+ ដាក់ស្តែងនៅតាមបណ្តាក្រុង ស្រុក ដូចខាងក្រោម ៖

1.ស្រុកតាំងគោក ចំនួន 147នាក់ ស្រី 58នាក់ ( មកពីប្រទេសថៃ 146នាក់ ស្រី 57 នាក់, មកពីប្រទេសជប៉ុនចំនួន01នាក់ស្រី ) ។

2.ស្រុកបារាយណ៍ ចំនួន 45នាក់ ស្រី 19នាក់ ( មកពីប្រទេសថៃ 42នាក់ ស្រី 18 នាក់ , ម៉ាឡេស៊ី 03នាក់ស្រី01នាក់ )។

3.ស្រុកសន្ទុក ចំនួន 61 ស្រី 28នាក់ ( មកពីប្រទេសថៃ ចំនួន58នាក់ស្រីចំនួន27នាក់ប្រទេសមាឡេស៊ីចំនួន01ស្រីនឹងប្រទេសកូរ៉េចំនួន01ប្រុស ប្រទេសជប៉ុនចំនួន01ប្រុស)។

4.ក្រុងស្ទឹងសែនចំនួន29នាក់ ស្រី14នាក់ ( មកពីប្រទេសថៃ 28នាក់ ស្រី 13 នាក់ និងកូរ៉េ 01នាក់ ស្រី )។

5. ស្រុកកំពង់ស្វាយ ចំនួន 53នាក់ ស្រី 27នាក់ ( មកពីប្រទេសថៃ 52នាក់ ស្រី 26នាក់ និងមកពីប្រទេសចិន01ស្រី)។

6.ស្រុកស្ទោង ចំនួន 333 នាក់ ស្រី 143នាក់ ( មកពីប្រទេសថៃ 333នាក់ ស្រី 143 នាក់, )។

7.ស្រុកប្រាសាទបល្ល័ង្គ ចំនួន 77នាក់ ស្រី 32នាក់ ( មកពីប្រទេសថៃចំនួន77នាក់ស្រី32នាក់) ។

8.ស្រុកប្រាសាទសំបូរ ចំនួន 29នាក់ ស្រី 05នាក់ ( មកពីប្រទេសថៃ) ។

9.ស្រុកសណ្តាន់ ចំនួន 00នាក់ )៕ **សម្រួលដោយ ៖ មនោ**

## អាវុធហត្ថជួយដឹកជញ្ជូនពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃទៅស្រុកកំណើត

http://www.rasmeinews.com/ March 24, 2020, 9:25 PM

ដោយ៖ប.ជ័យ/បន្ទាយមានជ័យ៖ រថយន្ត៤គ្រឿងនិងកម្លាំងចំនួន៣០នាក់នៃកងរាជអាវុធខេត្តបន្ទាយមានជ័យនិងក្រុងប៉ោយប៉ែតបានទៅជួយដឹកជញ្ជូនពលករកម្ពុជាដែលវិលត្រឡប់មកពីប្រទេសថៃទៅស្រុកកំណើតវិញ។ លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យនិងមេបញ្ជាការងកាលពីថ្ងៃទី២៣និង២៤ ខែមីនា ឆ្នាំ២០២០ បានដឹកនាំកម្លាំងទៅធ្វើការងារសង្គមនិងមនុស្សធម៌នោះនៅចំណុចច្រកទ្វារអន្តរជាតិប៉ោយប៉ែត។ លោកមេបញ្ជាការបានឱ្យដឹងថាដឹងថានោះជាការងារអន្តរាគមន៍លើកិច្ចការមនុស្សធម៌និងសង្គមកិច្ច និងក៏ជាការគោរពតាមបទបញ្ជារបស់លោកនាយឧត្តមសេនីយ៍សៅសុខាអគ្គបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានដាក់ចេញនូវបទបញ្ជាដល់ កម្លាំងអាវុធហត្ថខេត្តបន្ទាយមានជ័យ។ គឺយករថយន្តរបស់អាវុធហត្ថដឹកពលរដ្ឋពលករទៅដល់លំនៅស្ថានឯភូមិកំណើតតែម្តង ។

សូមរំលឹកថាកាលពីយប់ថ្ងៃទី២៣ខែមីនាឆ្នាំ២០២០មានពលករខ្មែរធ្វើការនៅប្រទេសថៃដែលត្រឡប់តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែតដោយសារការបិទព្រំដែនកម្ពុជាថៃមានចំនួនប្រមាណ ៥០០នាក់។គឺភាគីថៃអនុញ្ញាតឱ្យវិលមកប្រទេសកំណើតដើម្បី បង្ការការពារ ការ ឆ្លង រីករាលដាល នៃមេរោគជំងឺ កូវីដ ១៩។ ពលករទាំងនោះមន្ត្រីអាជ្ញាធរមានសមត្ថកិច្ចតម្រូវឱ្យទៅស្នាក់នៅក្នុងមណ្ឌលសំចតប៉ោយប៉ែត( POIPETTransitCenter) របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទាស្ថិតនៅមណ្ឌល៤ភូមិប្រជាធម្មសង្កាត់ផ្សារកណ្តាលក្រុងប៉ោយប៉ែតមួយរយៈខ្លី។រួចបន្តដំណើរទៅស្រុកកំណើតហើយដាក់ឱ្យស្ថិតនៅដាច់ដោយឡែកពីគេចំនួន១៤ថ្ងៃដើម្បីតាមដានត្រួតពិនិត្យសុខភាពនិងយកសំណាកទៅពិនិត្យរកមេរោគកូវីត១៩នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

ក្នុងនោះដែរលោកអ៊ុំរាត្រីអភិបាលខេត្តបន្ទាយមានជ័យបានឱ្យដឹងថាពលរដ្ឋនិងពលករខ្មែរមកពីប្រទេសថៃត្រូវអាជ្ញាធរនិងជំនាញពាក់ព័ន្ធបានប្រមូលពួកគាត់ឱ្យនៅក្នុងមណ្ឌលសំចត ដើម្បីត្រួតពិនិត្យសុខភាពនិងផ្តល់ការណែនាំនានាហើយផ្តល់សេវាធ្វើដំណើរទៅដល់ផ្ទះនៅស្រុកកំណើត ៕S/

# ពលករខ្លះ ជាប់នៅព្រំដែនប្រទេសថៃ ដោយសារចូលកម្ពុជាមិនទាន់ការកំណត់បិទព្រំដែន

https://www.rfa.org/khmer/ ដោយ អូន ភាព 2020-03-24

ពលករខ្លះ ត្រូវបានរាយការណ៍ថា កំពុងជាប់នៅព្រំដែន ក្នុងប្រទេសថៃ ដោយសារតែ ពួកគាត់វិលចូលប្រទេសកម្ពុជាមិនទាន់ការកំណត់បិទព្រំដែនរបស់អាជ្ញាធរថៃ។ ព្រះសង្ឃថៃ ជាប់សែស្រឡាយខ្មែរ គង់នៅខេត្តបុរីរម្យ (Buriram) អំពាវនាវឲ្យពលករខ្មែរ គ្មានទីសម្នាក់ ទៅស្នាក់នៅវត្តបណ្ដោះអាសន្នសិន។ ព្រះសង្ឃសញ្ជាតិថៃ ជាប់សែស្រឡាយខ្មែរ ដែលគេស្គាល់ថា លោកតា ស៊ុច បានអំពាវនាវឲ្យពលករខ្មែរ កំពុងជាប់គាំង នៅច្រកព្រំដែនប្រទេសថៃ ទៅស្នាក់នៅបណ្ដោះអាសន្ន ក្នុងវត្តព្រះអង្គ។ ព្រះអង្គប្រាប់អាស៊ីសេរីថា ពលករខ្មែរបានសុំព្រះអង្គស្នាក់នៅក្នុងវត្តជាបន្តបន្ទាប់ ក្នុងខេត្តបុរីរម្យ ហើយព្រះអង្គ បានជួយរកការងារវត្តឲ្យធ្វើក្នុងពេលស្នាក់នៅ ដោយទទួលបានកម្រៃម្នាក់ បីរយបាត (៣០០) ឬ ១០ដុល្លារអាមេរិក ក្នុងមួយថ្ងៃ។ ព្រះអង្គថា មានពលករខ្មែរ ចំនួន ៥ នាក់ កំពុងស្នាក់នៅក្នុងវត្តបានមួយយប់ហើយ គឺមកកាលពីថ្ងៃទី២២ មីនា។ ឯនៅថ្ងៃទី២៣ មីនា ព្រះអង្គ ឲ្យដឹងថា ពលករខ្មែរមួយក្រុមធំ បានទូរស័ព្ទ មកសុំព្រះអង្គស្នាក់នៅ។

ព្រះអង្គឲ្យដឹងថា ទីធ្លាវត្តរបស់ព្រះអង្គ អាចឲ្យពលករខ្មែរស្នាក់នៅបានច្រើនរយនាក់ ហើយព្រះអង្គ ពេញព្រះទ័យនឹងជួយអស់លទ្ធភាព។ ព្រះអង្គប្រាប់ថា ពលករ ដែលគ្មានលទ្ធភាពសូម្បីលុយ ជិះឡានពីព្រំដែន ទៅវត្តក៏មិនបាច់បារម្ភដែរ គឺព្រះអង្គ នឹងចេញថ្លៃឡានឈ្នួលឲ្យ នៅពេលទៅដល់វត្ត។ ព្រះអង្គបន្តថា នៅវត្តមានបាយអង្ករគ្រប់គ្រាន់ឲ្យពលករខ្មែរ ច្រើនរយនាក់បរិភោគ ឯម្ហូបអាហារអាចរកបាននៅតាមស្រែ៖ «មកដល់តាំងពីម្សិលមិញ ឲ្យធ្វើការឲ្យមួយថ្ងៃ ១០ដុល្លារ ម្នាក់ៗ ព្រោះថា នៅ (ថៃ) ក៏មិនបានលុយ ទៅខ្មែរក៏មិនបានលុយ ឲ្យនៅវត្តទៅ។ ១ ថ្ងៃ ១០ដុល្លារ ធ្វើការវត្ត ហូបបាយវត្តទៅ។ មួយក្រុមធំ (ទូរស័ព្ទ) គេសួរថា វត្តទទួលបានប៉ុន្មានរយនាក់ គ្នាប្រាប់ថា ពីរ បីរយ ក៏បានឲ្យតែមកក៏មាន។ វត្តប៉ុណ្ណាណី រីករាយ អង្ករមានដាំទៅ រកកង្កែប រកក្ដាម ស៊ីទៅ»។

ព្រះអង្គ បន្តថា ការជួយពលរដ្ឋខ្មែរ ក្នុងគ្រាអាសន្ននេះ ដោយសារ ព្រះអង្គជំពាក់គុណ ពលរដ្ឋខ្មែរច្រើន ព្រោះច្រើនឆ្នាំមកនេះ ពលរដ្ឋខ្មែរ តែងនិមន្តព្រះអង្គ ទៅទេសនានៅប្រទេសកម្ពុជា និងនៅសហរដ្ឋអាមេរិក។ ព្រះអង្គ ក៏មិនខ្លាចនឹងការឆ្លងជំងឺ ដោយសារជួយពលករដែរ៖ «គ្នា ជាប់គុណខ្មែរច្រើន។ គ្នា បានទៅទេសនាប្រទេសខ្មែរ បានលុយ យកមកកសាងវត្ត គឺដោយសារមកពីខ្មែរហ្នឹង។ ទី២ គ្នា បានទៅអាមេរិកា សុទ្ធតែអ្នកខ្មែរជូចគ្នានិមន្ត។ អ៊ីចឹងណា ហើយឥឡូវគ្នា នឹងកសាងវត្តខ្មែរ ប្រហែលជាពាក់ន្លែងទៀត នៅតែចាំច្បាប់គេឲ្យ។ ចំនួន៥ឆ្នាំមុននេះ គ្នាជួយខ្មែររហូត មិនថា ជាអង្ករ ខោអាវមនុស្សចាស់ ស្បង់ ក្រមា ទៀនចូលវស្សា ធ្វើបុណ្យរាល់ឆ្នាំ។ តែគ្នាមិនធ្លាប់បានថតរូបបង្ហាញគេ ចង់ឲ្យគេឃើញទេ។ អាយុប៉ុនហ្នឹងហើយ បួសមកជាសង្ឃ សិក្សាធម៌ វិន័យ អនិច្ចំ ទុក្ខំ អនត្តា ស្លាប់ថ្ងៃណា ក៏ស្លាប់ទៅ។ បើយើងខ្លាចតែជាប់ពេក ជាប់អ្វី អ៊ីចឹង យើងនឹងជួយពុទ្ធបរិស័ទណាបាន។ ព្រះសង្ឃ ជាទីពឹងពុទ្ធបរិស័ទ បើពឹងមិនបានហើយ បួសធ្វើអ្វី បួសមិនឲ្យគេពឹង»។

មកដល់ពេលនេះ អាជ្ញាធរកម្ពុជា មិនទាន់បង្ហាញរបាយការណ៍តួលេខពលករខ្មែរ ដែលសម្រុកចូលប្រទេសកម្ពុជា កាលពីថ្ងៃទី២២ មីនា និងរបាយការណ៍ ថា បានត្រួតពិនិត្យសុខភាពរបស់ពលករទាំងនោះ ឬអត់ ជាផ្លូវការទេ។ ពលករ សម្រុកចូលប្រទេសកម្ពុជាវិញ ភ្លាមៗ ដោយសារ អាជ្ញាធរថៃ កំណត់ពេលបិទព្រំដែន ទាំងអស់ ចាប់ពីថ្ងៃទី២៣ មីនា ដល់ថ្ងៃទី៥ មេសា ដើម្បីបង្ការហានិភ័យការរាតត្បាតជំងឺកូវីដ១៩ (Covid-19)។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ផ្សព្វផ្សាយតាមហ្វេសប៊ុក(facebook) បង្ហាញថា គ្រប់ច្រកទ្វារអន្តរជាតិកម្ពុជា ថៃទាំងអស់ បានបិទអស់ហើយ នៅថ្ងៃទី២៣ មីនា។ អភិបាលខេត្តខ្លះ បានចុះទៅត្រួតពិនិត្យ នៅច្រកទ្វារអន្តរជាតិ នៅថ្ងៃពេលបិទព្រំដែន និងទៅទទួលយកពលរដ្ឋខ្មែរ ដែលចូលមកកម្ពុជា មិនទាន់ការកំណត់។ នៅច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកទ្វារអន្តរជាតិព្រំ ខេត្តប៉ៃលិន អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បង្ហាញថា អាជ្ញាធរខេត្ត បានទៅទទួលយកពលរដ្ឋខ្មែរ ដែលជាប់ក្នុងទឹកដីថៃ មកវិញ។ នៅម៉ោងប្រមាណ១២ ថ្ងៃត្រង់

អាជ្ញាធរនៅប៉ោយប៉ែតបានចែកនំប៉័ង ទឹកសុទ្ធ ដល់ពលរដ្ឋទាំងនោះ ព្រមទាំងអះអាង ថា បានត្រួតពិនិត្យសុខភាពទៀតផង។

ចំណែកនៅច្រកដូង ច្រកអូរចាន់គិរី ខេត្តបាត់ដំបង អាជ្ញាធរស្រុកកំរៀង បានយករថយន្ត ទៅដឹកយកពលករទាំងអស់ ទៅដាក់នៅវិទ្យាល័យកំរៀង ដើម្បីត្រួតពិនិត្យសុខភាព និងវាស់កម្ដៅ។ នៅច្រកចាំយាម ខេត្តកោះកុង អភិបាលខេត្ត លោកស្រី មិថុនា ភូថង បានចុះទៅពិនិត្យ និងនៅច្រកទ្វារជាំ អាជ្ញាធរខេត្តឧត្តរមានជ័យ និងខេត្តស៊ីសាកេត (Sisaket) បន្តអនុញ្ញាតឲ្យពលរដ្ឋខ្មែរ និងថៃ ត្រលប់ចូលប្រទេសរៀងៗ ខ្លួនវិញ តែមិនឲ្យបរទេសចូលទឹកដីខ្លួនឡើយ។ គ្រប់ច្រកទាំងព្រំដែនខ្មែរ ថៃ ទាំងអស់ អាជ្ញាធរបង្ហាញថា នៅតែដោះដូរទំនិញជាមួយគ្នា បានជាធម្មតា តែមិនអនុញ្ញាតឲ្យពលរដ្ឋបរទេសចេញចូលឡើយ។ ចំពោះពលរដ្ឋខ្មែរ មានជំងឺធ្ងន់ធ្ងរ អាចចូលទៅព្យាបាលជំងឺនៅប្រទេសថៃបាន តែត្រូវត្រួតពិនិត្យរកជំងឺកូវីដ១៩ សិន។

អាស៊ីសេរី មិនអាចសុំការបញ្ជាក់ ពីអាជ្ញាធរថា ពលរដ្ឋខ្មែរ នៅជាប់ក្នុងដីថៃមានទៀត ឬអស់នៅឡើយទេ ដោយសារតែអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ទាំងពីរនាក់ មិនទទួលទូរស័ព្ទ។ ឯអភិបាលខេត្តបាត់ដំបង និងកោះកុង ដែលជាខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ក៏មិនទទួលទូរស័ព្ទដែរ នៅថ្ងៃទី២៣ មីនា។

ប្រធានសមាគមពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា លោក ឌិន ពុទ្ធី ដែលមានមូលដ្ឋាននៅក្រុងប៉ោយប៉ែត ឲ្យដឹងថា ពលករខ្លះ ពិតជាកំពុងជាប់ក្នុងដីថៃមែន ហើយការមកយឺតរបស់ពួកគេ ដោយសារតែថៃ ជូនដំណឹងលឿនពេក ដោយទុកពេលមួយថ្ងៃ ដើម្បីបិទច្រកព្រំដែន។ ដូច្នេះ ពលករខ្លះ ចូលមកមិនទាន់។ លោក ឌិន ពុទ្ធិ បន្តថា ពលរដ្ឋខ្មែរ ដែលសម្រុកចូល កាលពីថ្ងៃទី២២ មីនា ភាគច្រើន ជាអាជីវករលក់ដូរនៅក្នុងផ្សាររុងក្លឿ អ្នករកស៊ីនៅម្ដុំព្រំដែន និងពលករធ្វើការនៅខេត្តជាប់ៗព្រំដែន ដូច្នេះពួកគាត់ ដឹងដំណឹងលឿន ថា ថៃបិទផ្សារ និងព្រំដែន ហើយត្រលប់ចូលមកទាន់ពេលវេលា។ ឯពលករខ្មែរ ធ្វើការនៅទីឆ្ងាយពីព្រំដែន ខ្លះចូលមិនទាន់ និងខ្លះទៀត មិនបានចាកចេញពីប្រទេសថៃទេ៖ «ទុកពេលតែមួយថ្ងៃហ្នឹង ដែលប្រជាពលរដ្ឋត្រូវសម្រុកចេញណា។ អ្នកខ្លះ ចេញអត់ទាន់ទេ ចេញអត់ទាន់។ និយាយទៅ បើមានបញ្ហាអ៊ីចឹងមែន ចង់ឲ្យរដ្ឋាភិបាល ក៏ដូចជាកុងស៊ុល មេត្តាជួយតាមដាន ជួយការពារពួកគាត់ ព្រោះដោយសារពួកគាត់ចេញមកអត់ទាន់ មិនមែនដោយសារពួកគាត់ទេ ដោយសារការជូនដំណឹងហ្នឹង វាលឿនពេក»។

ទោះជាយ៉ាងណា ពលរដ្ឋនៅក្នុងប្រទេសកម្ពុជា នៅតែព្រួយបារម្ភ ពីជំងឺកូវីដ១៩ អាចស្ថិតក្នុងខ្លួនរបស់ពលរដ្ឋខ្មែរ ដែលសម្រុកចូលប្រទេសកម្ពុជា ដោយមិនដឹងខ្លួន ព្រោះមន្ត្រីសុខាភិបាល ក៏មិនបានបង្ហាញវិធានការត្រួតពិនិត្យសុខភាពរបស់ពួកគាត់ នៅព្រំដែនខ្មែរ ថៃដែរ ខណៈពលរដ្ឋទាំងនោះ ធ្វើដំណើរទៅស្រុកកំណើតរៀងៗខ្លួន៕

## មន្ត្រីសុខាភិបាលៈ ពលរដ្ឋខ្មែរ៣៥នាក់វិលត្រឡប់ពីថៃត្រូវបានធ្វើតេស្តរកវីរុសកូរ៉ូណា

https://khmer.voanews.com/ 24 មិនា 2020

ភ្នំពេញ៖ ពលរដ្ឋខ្មែរដែលបានត្រឡប់ចូលកម្ពុជាតាមច្រកព្រំដែនប៉ោយប៉ែតនៃខេត្តបន្ទាយមានជ័យចំនួន៣៥នាក់ ក្នុងចំណោមអ្នកវិលត្រឡប់ជាង ១ម៉ឺន៥ពាន់នាក់ ត្រូវបានមន្ត្រីសុខាភិបាលធ្វើតេស្តរកវីរុសកូវីដ១៩ ខណៈពួកគេសម្រុកមកកម្ពុជាវិញ នៅពេលថៃបានចាប់ផ្តើមបិទច្រកព្រំដែន។ នេះបើយោងតាមលោក កែវ សុភ័ក្ត្រា ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យនៅថ្ងៃអង្គារនេះ។ លោក កែវ សុភ័ក្ត្រា បានថ្លែងប្រាប់ VOA តាមទូរស័ព្ទថា មនុស្សចំនួន៣៥នាក់ ក្នុងចំណោមមនុស្សរាប់រយនាក់ដែលបានចូលមកកម្ពុជាវិញ កាលពីថ្ងៃច័ន្ទ ត្រូវបានយកសំណាកទៅធ្វើតេស្តរកវីរុសមួយនេះ។ លោកបន្តថា លទ្ធផលនៃការធ្វើតេស្តអាចនឹងប្រកាសនៅយប់ថ្ងៃអង្គារនេះ។ លោកមានប្រសាសន៍ថា៖ «អ្នកដែលមានកម្តៅក្នុងចំណោមដែលមកនេះ យើងឃើញមាន៣៥នាក់

ហើយ ដែលយើងយកសំណាកផ្ញើទៅភ្នំពេញតាំងពីយប់មិញម្ល៉េះ។ យប់នេះបែបដឹងហើយលទ្ធផល»។ មន្ត្រីសុខាភិបាលរូបនោះឲ្យដឹងថាពួកគេមានកម្តៅខ្លស់ និងស្អកកជាដើម ហើយបច្ចុប្បន្នពួកគេកំពុងស្ថិតក្នុងមន្ទីរពេទ្យខេត្តបន្ទាយមានជ័យ និងមន្ទីរពេទ្យក្រុងប៉ោយប៉ែតនិងរង់ចាំលទ្ធផលនៃការធ្វើតេស្ត។

ប្រជាពលរដ្ឋខ្មែររាប់ពាន់នាក់បានវិលត្រឡប់ចូលមកកម្ពុជាវិញពីប្រទេសថៃតាមរយៈច្រកព្រំដែនប៉ោយប៉ែតកាលពីចុងសប្តាហ៍ បន្ទាប់ពីប្រទេសថៃបានប្រកាសបិទច្រកព្រំដែនចាប់ពីថ្ងៃច័ន្ទ ដើម្បីបង្ការការរាតត្បាតវីរុសកូវីដ១៩។ ការណ៍នេះធ្វើឲ្យមានការព្រួយបារម្ភអំពីលទ្ធភាពឆ្លងក្នុងប្រទេសកម្ពុជាកាន់តែច្រើន នៅពេលដែលពលរដ្ឋខ្មែរសម្រុកមកបែបនេះ។

ក្នុងពិធីជួបសំណេះសំណាលជាមួយមន្ត្រីនគរបាលអន្តោប្រវេសន៍ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅព្រឹកថ្ងៃអង្គារនេះ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ថា ប្រជាពលរដ្ឋខ្មែរជាង ១៥.០០០ នាក់ បានត្រឡប់ចូលមកកម្ពុជាវិញតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត។ លោកបញ្ជាក់ថា នេះជាចំនួនច្រើន ដែលលោកថា មិនអាចពិនិត្យសុខភាពរបស់ពួកគេទាំងអស់ ឬក៏ដាក់ឲ្យនៅដាច់ដោយឡែកបាននោះទេ។ លោក ស ខេង បានថ្លែងថា៖ «អ៊ីចឹងបញ្ហារបស់យើង ហានិភ័យនៅត្រង់ហ្នឹង នៅត្រង់ថា ដល់ពេលគាត់មកសម្រុកទៅ និយាយតាមការជាក់ស្តែងគឺយើងអត់មានលទ្ធភាពត្រួតពិនិត្យអស់ទេ។ ហើយយើងក៏អត់មានលទ្ធភាពដើម្បីនឹងឃុំពួកគាត់ ១៤ថ្ងៃដែរ»។ លោកបានបញ្ជាឲ្យអាជ្ញាធរតាមខេត្តបន្តត្រួតពិនិត្យ និងស្វែងរកពលរដ្ឋដែលមានរោគសញ្ញានៃវីរុសកូរ៉ូណា។ លោកបន្តថា ប្រសិនបើរកឃើញថា មនុស្សណាមួយក្នុងភូមិមានផ្ទុកវីរុសនោះ ភូមិនោះនឹងត្រូវរឹតបន្តឹងការធ្វើដំណើរ។ លោកបញ្ជាក់ថា៖ «សុំធ្វើម៉េចពន្យល់គាត់ កុំឲ្យប៉ះ ហើយបើសិនមានកន្លែងណាមួយកើត អ្នកណាមួយកើតគឺថា ឃុំមួយផ្ទះហ្នឹង ឬមួយឃុំ មួយកំណាត់ភូមិហ្នឹង។ ឧទាហរណ៍ភូមិវាដាច់ដោយឡែកពីគេបួនប្រាំផ្ទះអ៊ីចឹង យើងអាចឃុំកន្លែងហ្នឹងមិនឲ្យគាត់ចេញទៅណា។ហើយបើថា ភូមិហ្នឹងវាជាប់គ្នា ហើយមានច្រើននាក់ ពីរបីនាក់អ៊ីចឹងទៅ គឺថា ឃុំទាំងភូមិហ្នឹងតែម្តង»។

VOA មិនអាចសុំការអត្ថាធិប្បាយពីលោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យនិងលោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលបានទេ រហូតមកដល់ល្ងាចថ្ងៃអង្គារនេះ។

ស្ថានទូតថៃប្រចាំកម្ពុជាបានឆ្លើយតបសារអេឡិកត្រូនិករបស់ VOA ថា រដ្ឋាភិបាលថៃចាត់វិធានការបិទច្រកព្រំដែននេះ គឺដើម្បីទប់ស្កាត់ការរាតត្បាតវីរុសកូវីដ១៩ ដោយមានការបិទជាបណ្តោះអាសន្នទីតាំងសាធារណៈមួយចំនួន និងផ្អាកការធ្វើដំណើរនានា។ ស្ថានទូតថៃបានសរសេរថា៖«ការមិននៅជុំគ្នា និងការរឹតត្បិតការធ្វើដំណើរ គឺជាវិធានការដើម្បីកុំឲ្យមានការឆ្លងនៃវីរុសនេះ។ វាជាវិធានការសម្រាប់សង្គមទាំងមូល ដែលត្រូវការសហការពីសមាជិកទាំងអស់ក្នុងសង្គម និងគ្រប់វិស័យក្នុងសេដ្ឋកិច្ច»។

លោក ប៉ក់ សំណាង ពលករខ្មែរម្នាក់ដែលធ្វើការនៅរោងចក្រធ្វើម៉ាស៊ីនដេរ ក្នុងខេត្តឈុនបូរីប្រទេសថៃមានប្រសាសន៍ថា លោកចូលមកកម្ពុជាវិញតាមច្រកប៉ោយប៉ែត និងបានមកដល់ស្រុកកំណើតរបស់លោកក្នុងស្រុកអង្គបុរី ខេត្តតាកែវ កាលពីព្រឹកថ្ងៃអង្គារ។ លោកបន្តថា លោកកំពុងស្នាក់នៅផ្ទះដាច់ដោយឡែកម្នាក់ឯង។ លោកមានប្រសាសន៍ថា៖ «យើងចេញមកមនុស្សវាច្រើន។ យើងជិះឡានរួមគ្នាមក មិនដឹងពីណាកើត មិនកើត។ យើងចេះការពារខ្លួនឯងដែរ។ មិនដឹងយើងអាចប៉ះពាល់អ្នកណាខ្លះ។ យើងមិនដឹងគេកើត មិនកើត។ អត់ទាន់ដឹងដែរ។ យើងអត់ហ៊ានចូលមួយគេ។ យើងនៅតែឯងសិន ខ្លាចក្រែងលោយើងឆ្លងរោគអីមកយើងប៉ះពាល់ដល់ប្រពន្ធកូន»។

លោក ស៊ុំ ច័ន្ទគា មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក ប្រចាំខេត្តបន្ទាយមានជ័យប្រាប់ VOA នៅថ្ងៃអង្គារនេះថា លោកបានសង្កេតឃើញការខិតខំប្រឹងប្រែងរបស់អាជ្ញាធរខេត្ត ក្នុងការផ្សព្វផ្សាយព័ត៌មានទាក់ទិននឹងវីរុសកូវីដ១៩ការពិនិត្យសុខភាពរបស់ពលករខ្មែរ និងការរៀបចំសាលារៀនធ្វើជាមន្ទីរពេទ្យតាមបញ្ជារបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែន។ ប៉ុន្តែលោកយល់ថា វានៅតែមិនអាចទប់ស្កាត់ការរាតត្បាតបានទាំង

ស្រុងនោះទេ។ លោកមានប្រសាសន៍ថា៖ «វាបើទាក់ទិនទៅលើអនាម័យ ទៅលើសុខភាពអីផ្សេងៗ គឺវាពិបាក ហើយព្រោះថា មិនមែនជាកន្លែងសម្រាប់អនាម័យកន្លែងអី គ្រាន់តែជាកន្លែងសម្រាប់សិស្សល្មមៗ។ អ៊ីចឹងហើយ យើងគិតថាសុវត្ថិភាពទាក់ទងនឹងជំងឺឆ្លងអីផ្សេងៗ វាមិនសូវអាចការពារបានដែរ។ វានៅតែអាចកើតឡើង។ វានៅតែអាចឆ្លង នៅពេលយើងយកទៅដាក់អ៊ីចឹង»។

កាលពីថ្ងៃច័ន្ទលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឲ្យអភិបាលខេត្តទាំងអស់ រៀបចំតទឹក តភ្លើង និងបង្គន់អនាម័យនៅតាមសាលារៀន ដើម្បីធ្វើជាមន្ទីរពេទ្យជាបន្ទាន់។ នេះជាចំណាត់ការរបស់លោក ក្រោយពលរដ្ឋកម្ពុជាត្រឡប់មកពីប្រទេសថៃ ហើយត្រឡប់ទៅស្រុកកំណើតរបស់ពួកគេ។

គួរបញ្ជាក់ថា រហូតមកដល់ថ្ងៃច័ន្ទ ករណីឆ្លងវីរុសកូរ៉ូណានៅកម្ពុជាមានទៅដល់ ៨៧ ក្នុងនោះមានប្រជាជនខ្មែរមានចំនួន ៣៥នាក់៕

## ពលរដ្ឋខ្មែរនៅតែបន្តវិលត្រឡប់ចូលមកស្រុកកំណើតវិញតាមច្រករបៀងក្រោយផ្ទុះមេរោគប្រភេទថ្មីកូវិដ១៩

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 25 March, 2020

ខេត្តបន្ទាយមានជ័យ ៖ ក្រោយពីមានការប្រកាសបិទច្រកព្រំដែនកម្ពុជាថៃដើម្បីកាត់បន្ថយការរីករាលដាលជម្ងឺថ្មីកូវិត១៩ គេសង្កេតឃើញថាមានពលរដ្ឋខ្មែរដែលចំណាកស្រុកទៅធ្វើការនៅប្រទេសថៃរាប់ម៉ឺននាក់បានបង្ខំចិត្តវិលត្រឡប់មកមាតុប្រទេសវិញ។ការវិលត្រឡប់មកមាតុ ប្រទេសវិញរបស់បងប្អូនប្រជាពលរដ្ឋនេះដែរ រាជរដ្ឋាភិបាលកម្ពុជា ពិសេសអាជ្ញាធរខេត្តបន្ទាយមានជ័យបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការត្រួតពិនិត្យសុខភាពនិងការរស់នៅបណ្តោះអាសន្នរយៈពេល១៤ថ្ងៃ ដើម្បីតាមដានមុននឹងអោយចាកចេញចូលទៅរួមរស់ជាមួយក្រុមគ្រួសារនិងស្រុកភូមិវិញ។ ច្រកត្រូវបានបិទទាំងស្រុងនៅថ្ងៃទី២៣ខែមិនាឆ្នាំ២០២០នេះ ពលរដ្ឋក៏សម្រុកមកខ្លាំងក្នុងថ្ងៃបិទនោះដែរតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនិងច្រករបៀងមួយចំនួន ហើយកំពុងបន្តមកដល់ថ្ងៃទី២៤ខែមិនានេះដែរ តែការសម្រុកចេញថ្ងៃនេះគឺតាមច្រករបៀងចំការគក្រោមការគ្រប់គ្រងរបស់កងការពារព្រំដែន៥០៣ គ្រប់គ្រងដោយលោកឧត្តមសេនីយ៍ត្រី ឃួន ជឿន។

លោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការរងយោធភូមិភាគទី៥ មេបញ្ជាការទិសទីមួយបន្ទាយមានជ័យបានថ្លែងប្រាប់តាមទូរសព្ទ័ថា អាជ្ញាធរថៃបានដឹកបងប្អូនប្រជាពលរដ្ឋខ្មែរចំនួន៨១នាក់តាមរថយន្តយកមកទម្លាក់ចោលនៅមុខច្រករបៀងចំការគ។ ដើម្បីងាយស្រួលដល់ការគ្រប់គ្រងក្នុងការតាមដានសុខភាពរបស់ពួកពលរដ្ឋទាំងនោះ និងក្រោមបទបញ្ជា និងការណែនាំ ពីឯកឧត្តម មេបញ្ជាការរង កងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៥ លោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការរង យោធភូមិភាគទី៥ មេបញ្ជាការទិសទី១បន្ទាយមានជ័យ ដឹកនាំកម្លាំងចុះសហការ បានចុះធ្វើការអប់រំណែនាំបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលទើបតែត្រឡប់មកពីប្រទេសថៃអោយយល់ដឹងអំពីវិធីការពារ ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។ ក្រោយពីបានណែនាំរួច លោកឧត្តសេនីយ៍ មេបញ្ជាការ ក៏បានបញ្ជាអោយកងកម្លាំងទាហាន ដឹកបងប្អូនប្រជាពលរដ្ឋទាំង ៨១នាក់នោះ មកដាក់នៅមណ្ឌលសំចតបណ្តោះអាសន្ន (NPA) ក្រុងប៉ោយប៉ែត ដើម្បីអោយក្រុមគ្រូពេទ្យធ្វើការត្រួតពិនិត្យតាមដានសុខភាព។

សូមបញ្ជាក់ផងដែរថា នៅក្នុងខេត្តបន្ទាយមានជ័យរដ្ឋបាលខេត្តក្រោមការដឹកនាំរបស់ឯកឧត្តម អ៊ុំ រាត្រី បានត្រៀមរៀបចំជាស្រេចទីកន្លែងសម្រាប់ស្នាក់នៅព្យាបាលអ្នកផ្ទុកជំងឺប្រភេទថ្មី កូរ៉ូណា កូវិដ១៩ គឺសណ្ឋាគារព្រះចន្ទ័ ដែលមានទីតាំងនៅគល់ស្ពានសែសិន៕

# ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០២០

## ចៀសវាងឆ្លងតាមភូមិ ស្រុក សម្តេចតេជោ ដាក់បញ្ជាតាមរកពលករខ្មែរមកពីថៃ ទៅពិនិត្យសុខភាព

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១២:៥៨ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានដាក់បញ្ជាឲ្យតាមរកពលករខ្មែរដែលមកពីថៃ ដើម្បីមកពិនិត្យសុខភាពចៀសវាងការរីករាលដាលជំងឺកូវីដ១៩ នៅក្នុងភូមិ ឃុំ ស្រុក ។ ការលើកឡើងរបស់ប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីពលករខ្មែរធ្វើនៅប្រទេសបានសម្រុកចូលមកស្រុកកំណើតវិញ ប្រមាណជាង១ម៉ឺន៥ពាន់នាក់ កាលពេលកន្លងមកនេះ។ ថ្លែងក្នុងជំនួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នាព្រឹកថ្ងៃទី២៥ ខែមីនា អាឡូវដល់ពេលការមិនទុកចិត្តគ្នាហើយ ក្នុងការឆ្លងជំងឺប៉ុន្តែគួរដឹកខ្លួនថា បើសង្ស័យគួរនៅឆ្ងាយពីគេ ។ សម្តេចបន្តថា អាឡូវជំងឺបាត់បង់ការជឿទុកចិត្តគ្នា គឺកើតមានហើយ ហើយខ្ញុំចង់រុញទូកបណ្តោយទឹក គឺកុំប៉ះពាល់គ្នា ។ ប៉ុន្តែខ្ញុំប្រែក្លាយចំណុចនេះ ដោយមកធ្វើលើកដៃសំពះ ជំនួសការចាប់ដៃគ្នា ហើយចំពោះការមិនទុកចិត្តគ្នារវាងអ្នកនៅក្បែរគ្នា គឺនៅក្នុងផ្ទះខ្លួនឯងទៅ ដូច្នេះវាក៏កាត់បន្ថយការឆ្លងបានផងដែរ ។

ចំពោះការរីករាលដាលជំងឺនេះ ក្នុងស្រុកភូមិមួយចំនួនដែលពលករខ្មែរមកពីថៃនោះត្រូវបានសម្តេចតេជោបញ្ជាក់ទៅកម្លាំងទាំងអស់ ចុះតាមមូលដ្ឋានធ្វើសកម្មភាពអប់រំ ដើម្បីប្រែក្លាយការភ័យខ្លាច ការសង្ស័យគ្នាទៅវិញទៅមកឲ្យទៅជាចលនាការពារខ្លួនទៅវិញ ។ ដោយថា បើអ្នកខ្លាចកុំដើរ បើអ្នកសង្ស័យកុំចាប់ដៃខ្ញុំ ។ សម្តេចបានបញ្ជាក់ថា ៖«ដំណាក់ការការការពារការឆ្លងពីខាងក្រៅបានឆ្លងផុតហើយ ប៉ុន្តែយើងមិនឈប់ការពារនោះទេ ។យើងការពារពីខាងក្រៅផង និងការការពារខាងក្នុង និងការព្យាបាលអ្នកមានជំងឺឲ្យជា» ។

សម្តេចបានលើកឡើងថាជំងឺនេះ គឺជាជំងឺនាំចូលទាំងអស់ មិនមែនកម្ពុជាយើងទៅចម្លងឲ្យគេនោះទេ ។ សម្តេចសង្កត់ធ្ងន់ថា ៖« ការងារត្រូវគ្រប់បន្ទាន់នូវពលករដែលមកពីថៃដែលបានចូលរួចមកហើយ ត្រូវតាមគ្រប់គ្រងអ្នកនឹងដែលការងារនេះត្រូវប្រគល់ឲ្យអាជ្ញាធរខេត្ត រៀបចំបណ្តាញចុះ ដើម្បីដាក់ឲ្យនៅដោយឡែកនៅតាមផ្ទះ ។ ក្នុងប៉ុន្មាននេះខ្ញុំលើកទឹកចិត្ត គ្រប់មធ្យោបាយបានធ្វើការឃោសនានៅតាមភូមិ» ។ សម្តេចថា ដើម្បីកុំឲ្យពលករមកពីថៃមានការភ័យខ្លាច ដោយកុំធ្វើការដើរទៅណា ដោយដាក់នៅឲ្យដាច់ដោយឡែកពីគេ១៤ថ្ងៃ ។ ប៉ុន្តែនៅពេលដែលរកកម្តៅ ឃើញត្រូវយកមកដាក់នៅកន្លែងដែលរៀបចំរួចហើយ ។ សម្តេចបញ្ជាក់ថា៖«ត្រូវធ្វើការកិច្ចការងារនេះឲ្យបាន ហើយត្រូវផ្អាកការបញ្ជូនមន្ត្រីទៅចូលរួមកិច្ចប្រជុំនៅខាងក្រៅ ហើយលុបការប្រជុំអន្តរជាតិទាំងអស់នៅកម្ពុជា ។ ខ្ញុំបញ្ជាដាច់ខាតមិនឲ្យមន្ត្រីទៅប្រជុំនៅខាងក្រៅប្រទេសនោះទេ » ។

ជាមួយគ្នានោះដែរសម្តេចតេជោ បានលើកឡើង ជំងឺនេះមិនងាយចប់ទេ រហូតដល់កាលពីថ្ងៃទី២៤ ខែមីនា ជប៉ុន និងគណៈកម្មការអូឡាំពិក បានលើកពេលវេលាកិច្ចប្រជុំអូឡាំពិក ហើយកិច្ចប្រជុំមេដ្ឋមឡាងឆាំងនៅឡាវក៏បានលុបចោល ហើយកិច្ចប្រជុំធំៗទាំងអស់ត្រូវបានលុបចោល៕

## អភិបាលខេត្តកំពង់ស្ពឺ អំពាវនាវឲ្យពលករ ដែលវិលពីបរទេស ២៤៦នាក់ ទើបមកដល់ក្នុងខេត្ត ឲ្យនៅដោយឡែកពីញាតិរបស់ខ្លួន ១៤ថ្ងៃ ដើម្បីទប់ស្កាត់ COVID-19

http://www.freshnewsasia.com/ 2020-03-25

**(កំពង់ស្ពឺ)៖** លោក វ៉ី សំណាង អភិបាលខេត្តកំពង់ស្ពឺ បានលើកឡើងថា ពលករចំណូលស្រុកគិតមកដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០នេះ បានវិលមកកាន់ស្រុកកំណើតមានចំនួន ២៤៦នាក់ ដែលបានចេញចំណាកស្រុកទៅធ្វើការនៅបរទេស។ លោក វ៉ី សំណាង បានអំពាវនាវដល់អ្នកចំណូលស្រុកថា បងប្អូនត្រូវរក្សាខ្លួនឲ្យនៅដាច់ដោយឡែកសាច់ញាតិ បងប្អូន និងកុំជួបជុំក្នុងកម្មវិធីផ្សេងៗដើម្បីការពាររោគឆ្លង COVID-19 ដែលជាជម្ងឺឆ្លង

រាត្បាតជាសកល។ លោកអភិបាលបន្តថា «**អាជ្ញាធរខេត្តមានទិន្នន័យច្បាស់លាស់ចំពោះបងប្អូនចំណូលស្រុកមកវិញ ដូច្នេះអាជ្ញាធរមូលដ្ឋាន មានមេភូមិ មេប៉ុស្តិ៍នគរបាល លោកមេឃុំ ត្រូវតែបន្តតាមដាន និងអប់រំពួកគាត់ឲ្យបានយល់ អំពីការបង្ការនៃជម្ងឺឆ្លង COVID-19 បានយល់ដឹងគ្រប់គ្នាៗ**»។ ជាពិសេសនៅតាមអង្គភាព មន្ទីររបស់រដ្ឋត្រូវសម្អាតអនាម័យ ប្រើប្រាស់មធ្យោបាយឃោសនានៅតាមភូមិ-ឃុំ វត្តអារាម រោងចក្រសហគ្រាស ឲ្យបងប្អូនប្រជាពលរដ្ឋបានយល់ពីបញ្ហាការឆ្លង ជាសកលនៅជម្ងឺ COVID-19 នេះឲ្យពួកគាត់បានថៃរក្សាសុខភាពខ្ពស់។

លោក អោ វណ្ណថេន ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ បានឲ្យដឹងថា ពលករចំណូលស្រុកដែលវិលមកវិញពីបរទេសគឺអនុញ្ញាតឲ្យពួករស់នៅតាមផ្ទះរៀងៗខ្លួន តែត្រូវនៅដាច់ដោយឡែក រយៈពេល ១៤ថ្ងៃ និងត្រូវបានតាមដានជាប្រចាំពីមន្ត្រីសុខាភិបាលនៅមូលដ្ឋានដោយផ្ទាល់ដោយប្រើប្រាស់វិធីសាស្ត្ររបស់សុខាភិបាលជាចម្បង។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអះអាងថា រហូតមកដល់ពេលនេះ មានពលករខ្មែរប្រមាណ១៥០០០នាក់ បានត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ បន្ទាប់ពីទទួលដំណឹងថា ប្រទេសថៃមានគម្រោងបិទព្រំដែន ហើយក្នុងចំណោមនោះ ក៏មានពលករមួយចំនួនពុំបានពិនិត្យសុខភាពផងដែរ។

គិតរហូតមកដល់ព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០នេះ នៅកម្ពុជា បានរកឃើញអ្នកជំងឺ COVID-19 ចំនួនសរុប ៩៣នាក់ ក្នុងចំណោមនោះក៏មានអ្នកជំងឺ៦នាក់ បានជាសះស្បើយផងដែរ ដែលមានជនជាតិចិន១នាក់ ជនជាតិអង់គ្លេស១នាក់ និងជនជាតិខ្មែរ៤នាក់ ហើយសម្រាប់ខេត្តបាត់ដំបងមានអ្នកឆ្លងចំនួន៨នាក់ ហើយជាសះស្បើយចំនួន ២នាក់ ដែលអាចឲ្យចេញពីមន្ទីរពេទ្យ នៅពេលនេះ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ បានទទួលពលករខ្មែរចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ៦២នាក់ ស្រី ៤៧នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 25-03-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ចាប់ពីវេលាម៉ោង ០៦និង០០នាទី ដល់វេលាម៉ោង ១១និង០០នាទី បានទទួលពលករខ្មែរ ចូល ប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ៦២នាក់ ស្រី ៤៧នាក់៕ ដោយឡែកពលករខ្មែរ ចូលប្រទេសតាមអូរផ្សារព្រំខាងជើង មានចំនួន ៤១នាក់ ក្នុងនោះស្រី ០៤នាក់ ឆ្លងតាមការសាកសួរ របស់មន្ត្រីសមត្ថកិច្ចយើង និងតាមការឆ្លើយបំភ្លឺ របស់ពលករខ្មែរ ដែលធ្វើដំណើរ វិលត្រឡប់ចូលប្រទេសវិញនោះ បានឲ្យដឹងថា ពួកគាត់ដែលប្រើប្រាស់លិខិតឆ្លងដែន ដែលមានទិដ្ឋាការធ្វើការងារក្នុងស្រុកថៃ រយៈពេលយូរ ត្រូវទាហានឈុតខ្មៅថៃ មិនអនុញ្ញាតឲ្យចូលតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំទេ គឺឲ្យឆ្លងចូលមកកម្ពុជា តាមអូរផ្សារព្រំខាងជើង៕

## ពលករជាង៩០នាក់ចាញ់បោកមេខ្យល់ត្រូវគេដឹកពីប្រទេសថៃ ដាក់ចោលនៅច្រករបៀងចំការគ

http://www.cen.com.kh/ March 25, 2020

បន្ទាយមានជ័យ ៖ ពលកជាង៩០នាក់ ត្រូវមេខ្យល់ដឹកតាមរថយន្តពីប្រទេសថៃមក ទម្លាក់ចោលក្នុងភូមិទព័សៀម ស្រុកតាបប្រាយ៉ា (ថៃ) ទល់មុខច្រករបៀងចំការគ ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០នេះ។ លោកមេភូមិចំការគរហែម សុផាន់ មានប្រសាសន៍ថា កម្លាំងជួរមុខ បានឃើញពលករខ្មែរ ប្រមាណ៩០នាក់ ដើរកាត់ព្រៃមាន ស្លាយប្រដាប់ប្រដាសំពីងសំពោង ក៏ប្រមូលពួកគាត់មិនឲ្យដើរ ចូលមកក្នុងភូមិដោយ សុំអន្តរាគមន៍ពីអាជ្ញាធរ ដឹកពួគាត់មកមណ្ឌលសំចត នៅក្រុងប៉ោយប៉ែត ធ្វើការណែនាំ និងត្រួតពិនិត្យរបស់គ្រូរពេទ្យសិន។

ក្នុងឱកាសជួបពលករ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ណែនាំផ្សព្វផ្សាយវិធាន ការទប់ស្កាត់កូវីដ១៩ ជាមួយពលករចំនួនសរុប៩២នាក់ នៅមណ្ឌលសំចត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃដដែល ដែលអាជ្ញាធរថៃ បញ្ជូនមកដល់ព្រំដែន ហើយអាជ្ញាខេត្តបន្ទាយមានជ័យ បានសហការសម្រប សម្រួល បានយកចេញមកកម្ពុជា។ លោកស្រីសូមអំពាវនាវ ដល់បងប្អូនប្រជាពលរដ្ឋ ពលករយើងទាំងអស់នៅប្រទេសថៃ កុំចាញ់បោកមេខ្យល់ ដែលថាអាចនាំចូលឆ្លងដែន មកប្រទេសកម្ពុជាយើងដូច ជាតាមច្រករបៀង ច្រកតំបន់ជាដើមបាន ។ លោកស្រីបន្ថែមថា៖ សូមបងប្អូនប្រជាពលរដ្ឋ សូមផ្តាំផ្ញើប្រាប់បន្តទៅ បងប្អូនសាច់ញាត នៅក្នុងប្រទេសថៃ កុំឲ្យបន្តជឿ និងចាញ់បោកមេខ្យល់ទៀត នាំឲ្យប៉ះ ពាល់សុខភាពខាតបង់ប្រាក់ជាដើម ។ ហើយសូមរក្សាការស់នៅនិងធ្វើការនៅក្នុងប្រទេស ថៃស្តាប់តាមការណែនាំ របស់អាជ្ញាធរថៃសិន ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ និងសុខភាព សុវត្ថិភាពខ្លួន ។

ក្រោយពីការអប់រំ និងសាកសួរបងប្អូនពលករ ថា ពួកគាត់មកត្រូវបានមេខ្យល់ យកលុយប្រមាណ ៥០០បាត ទៅ១៥០០បាត ដោយអះអាងថា នឹងដឹកតាមរថយន្តមកដល់កម្ពុជា តែត្រូវគេដាក់ចោលទៅវិញ ។ បើទោះមានការប្រកាសជូនដំណឹងយ៉ាងច្បាស់ហើយ ពីអាជ្ញាធរថៃ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ បិទច្រក១៤ថ្ងៃព្រំដែនទាំងអស់ ជាមួយកម្ពុជាក៏ដោយ ៕ដោយៈបញ្ញាស័ក្តិ

## សម្តេច ហ៊ុន សែន៖ សូមបងប្អូនកូនក្មួយពលករដែលទើបវិលត្រឡប់មកពីប្រទេសថៃត្រូវដាក់ខ្លួនឯងអោយនៅដាច់ដោយឡែក១៤ថ្ងៃ

http://nokorwatnews.com/ 25-03-2020

ភ្នំពេញ៖ ពីវិមានសន្តិភាព នៅព្រឹកមិញថ្ងៃទី ២៥ មីនា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងជាប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានបញ្ជាឲ្យស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវធ្វើយ៉ាងណាគ្រប់គ្រងជាបន្ទាន់នូវពលករខ្មែរចំនួនប្រមាណ ១៥,០០០ នាក់ ដែលទើបវិលត្រឡប់មកពីប្រទេសថៃចូលកម្ពុជា កាលពីពេលថ្មីៗនេះ ដើម្បីឲ្យពួកគេអនុវត្តន៍វិធានការ "ដាក់ខ្លួនឯងឲ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ" ។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានបញ្ជាក់ថា ការដាក់ខ្លួនឯងឲ្យនៅដាច់ដោយឡែក គឺមិនសំដៅដល់ការយកពលករទាំងនោះទៅក្រុងទុកនោះទេ ប៉ុន្តែគឺជាការដាក់ខ្លួនឯងនៅក្នុងផ្ទះ ដោយមិនឲ្យប៉ះពាល់ជាមួយសមាជិកគ្រួសារ ហើយត្រូវតាមដានសុខភាពជាប្រចាំ។ ប្រសិនបើមានការសង្ស័យថាអាចមានរោគសញ្ញានេះកើតមានឡើងគឺត្រូវរាយការណ៍ជាប្រញាប់ទៅអាជ្ញាធរ ឬមន្ត្រីសុខាភិបាលភ្លាម។

សម្តេចតេជោនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានចេញបទបញ្ជាបញ្ជាក់ច្បាស់ថា «មន្ត្រី និងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងអស់ ត្រូវតែគ្រប់គ្រងជាបន្ទាន់ នូវពលករមកពីប្រទេសថៃ ដែលបានវិលចូលមកក្នុងប្រទេសរួចមកហើយ គឺត្រូវតាមគ្រប់គ្រងអ្នកទាំងអស់នោះ ដែលត្រូវប្រែគល់ការងារនេះ ឲ្យទៅអជ្ញាធរខេត្តរៀបចំបណ្តាញចុះធ្វើការ ដើម្បីដាក់បងប្អូនកូនក្មួយពលករឲ្យរស់នៅដោយឡែកនៅតាមផ្ទះមួយរយៈសិន។ ក្នុងប៉ុន្មានថ្ងៃកន្លងទៅនេះ ខ្ញុំមានការលើកទឹកចិត្តណាស់ ម្សិលមិញគ្រប់មធ្យោបាយនៃការឃោសនា គឺត្រូវបានធ្វើដោយរថយន្តក្តី ដោយម៉ូតូក្តី ដោយកង់បីក្តី ដែលមានដាក់មេក្រូស្រែកតាមភូមិ»។

សម្តេចតេជោ ហ៊ុន សែន បានអំពាវនាវដល់បងប្អូនពលករទាំងអស់កុំមានការភ័យខ្លាច អ្នកខ្លះថាខ្លាចគេយកទៅក្រុងទុក ឥឡូវបើមិនចង់ឲ្យគេយកទៅក្រុងទុក គឺសូមនៅតែក្នុងផ្ទះទៅ កុំដើរទៅណា ហើយត្រូវដាក់ខ្លួនឯងឲ្យនៅដាច់ដោយឡែកឆ្ងាយពីគេមួយរយៈពេលសិន ហើយបើមានប្រពន្ធកូន កុំអាលទៅជិតប្រពន្ធកូន ខ្លាចឆ្លងដល់ប្រពន្ធកូន គឺមិនមានអ្វីដែលត្រូវភ័យនោះទេ គឺធ្វើបែបនេះដើម្បីជានាសុខភាពរបស់បងប្អូនកូនក្មួយពលករទាំងអស់គ្នាកុំអោយមានឆ្លងជំងឺកូវីឌ-១៩ ពីម្នាក់ទៅម្នាក់ទៀតនៅក្នុងក្រុមគ្រួសារ និងសហគមន៍មួយ៕ សុខខេមរា

## សម្តេច ស ខេង ណែនាំអាជ្ញាធរព្រំដែន ត្រូវកត់ត្រាអត្តសញ្ញាណពលរដ្ឋខ្មែរ មកពីបរទេសវិញ

https://dap-news.com/national/ BySS107 Posted on March 25, 2020

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានធ្វើការណែនាំឲ្យអាជ្ញាធរច្រកទ្វារព្រំដែន ត្រូវកត់ត្រាបានច្បាស់ នូវអត្តសញ្ញាណប្រជាពលរដ្ឋដែល វិលចូលមកប្រទេសវិញ ដើម្បីធានាតាមដានស្រាវជ្រាវរកពួកគាត់ ប្រសិនបើមានបញ្ហាណាមួយ។ ក្នុងជំនួបសំណេះសំណាលជាមួយ មន្ត្រីនៃអង្គភាព និងស្ថាប័ននានា ដែលកំពុងបំពេញភារកិច្ចតាមបណ្តាច្រកទ្វារព្រំដែន នៃភូមិសាស្ត្រខេត្តបាត់ដំបង និងប៉ៃលិន នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ សម្តេច ស ខេង បានថ្លែងថាពលរដ្ឋខ្មែរទំនេរពីការងារនៅថៃ ចាប់ផ្តើមសម្រុកនាំគ្នាវិលត្រឡប់មកកម្ពុជាវិញនាប៉ុន្មានថ្ងៃមុន ដែលធ្វើឱ្យអាជ្ញាធរច្រកទ្វារព្រំដែនជួបការលំបាក ក្នុងការពិនិត្យសុខភាពពួកគាត់ពេលឆ្លងព្រំដែន។ សម្តេចបន្តថា ដោយសារពួកគាត់ធ្វើដំណើរដល់ស្រុកកំណើតហើយនោះ សម្តេចបានសុំគោលការណ៍ពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដើម្បីណែនាំអាជ្ញាធរខេត្ត ក្រុង-ស្រុក-ខណ្ឌ និងភូមិ-ឃុំ ត្រូវគ្រប់គ្រងវត្តមានពួកគាត់ឲ្យបាន និងស្នើឲ្យពួកគាត់នៅដោយឡែក ១៤ថ្ងៃសិន ។

សម្តេច ស ខេង មានប្រសាសន៍ថា "ណែនាំឲ្យអាជ្ញាធរប្រចាំច្រកទ្វារព្រំដែន ត្រូវកត់ត្រាឲ្យបានច្បាស់នូវអត្តសញ្ញាណពលរដ្ឋ ដែលបានវិលចូលមកប្រទេស ដើម្បីធានាតាមដានស្រាវជ្រាវរកពួកគាត់ ប្រសិនបើមានបញ្ហាណាមួយ ហើយជាមួយគ្នានេះ ត្រូវខិតខំពិភាក្សាជាមួយភាគីថៃ ដើម្បីចៀសវាងការអនុញ្ញាតឲ្យឆ្លងកាត់តាមច្រករបៀងដែលនាំឲ្យជួបការលំបាកក្នុងការពិនិត្យសុខភាព និងកំណត់អត្តសញ្ញាណពួកគាត់ ពោលគឺត្រូវកំណត់ច្រកទ្វារច្បាស់លាស់ សម្រាប់ការវិលចូលប្រទេសរបស់ពលរដ្ឋខ្មែរ យើង"។ សម្តេចបន្ថែមថា "ប្រសិនបើមានពលរដ្ឋខ្មែរយើងបន្តធ្វើដំណើរចូលមកប្រទេសវិញនោះ គឺរាជរដ្ឋាភិបាលយើងមិនអាចទប់ស្កាត់ពលរដ្ឋយើងមិនឱ្យវិលមកវិញបានទេ"។ ជាងនេះទៅទៀត រដ្ឋមន្ត្រីមហាផ្ទៃ ណែនាំឱ្យត្រៀមទទួលស្វាគមន៍ពួកគាត់ដោយប្រកាន់អកប្បកិរិយាថ្លៃថ្នូរសុភាពរាបសារ និងទន់ភ្លន់ ប៉ុន្តែត្រូវវិធានការម៉ឺងម៉ាត់តាមក្បួនសុខាភិបាល ដើម្បីធានាសុខសុវត្ថិភាពពួកគាត់ និងក្រុមគ្រួសារនៅឯស្រុកកំណើត។ ជាមួយគ្នានេះក៏ត្រូវមានកិច្ចសហការល្អជាមួយអាជ្ញាធរខេត្តខាងភាគីថៃដែរ៕ ដោយ អេង ប៊ូឆេង

## សម្តេច ស ខេង៖ យើងនៅតែបន្តទទួលពលករខ្មែរពីថៃ តែត្រូវបន្តត្រួតពិនិត្យសុខភាពដ៏តឹងរឹង ដើម្បីទប់ស្កាត់ការរីករាលដាល នៃមេរោគ COVID-19

http://www.freshnewsasia.com/ 2020-03-25

**(បាត់ដំបង)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នារសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ បានអះអាងថា យើងនៅតែបន្តស្វាគមន៍ទទួល ពលករខ្មែរនៅប្រទេសថៃ ដែលបានត្រឡប់មកកម្ពុជាវិញ ហើយត្រូវត្រួតពិនិត្យសុខភាព ឲ្យបានតឹងរឹងដោយធ្វើការវាស់កម្តៅចែកម៉ាសជូនគាត់ ដើម្បីទប់ស្កាត់ការរីករាលដាល នៃមេរោគ COVID-19 ដល់កម្ពុជា។ នៅក្នុងពិធីសំណេះសំណាលជាមួយអាជ្ញាធរខេត្ត និងនគរបាលអន្តោប្រវេសន៍ខេត្តប៉ៃលិន និងខេត្តបាត់ដំបង សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា ដើម្បីទប់ស្កាត់ការរីករាលដាល នៃមេរោគ COVID-19 ដល់កម្ពុជា តាមរយៈពលករខ្មែរឆ្លងដែនពីប្រទេសថៃមកកម្ពុជា ជាបន្តបន្ទាប់ទៀតនេះ អាជ្ញាធរខេត្ត និងនគរបាលអន្តោប្រវេសន៍ខេត្ត នគរបាលរការពារព្រំដែនគោកទាំងពីរ ត្រូវយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងទៅនឹងជំងឺនេះព្រោះឆ្លងសាហាវណាស់ ដោយបច្ចុប្បន្នបានឆ្លងចំនួន១៧០ប្រទេស លើពិភពលោកហើយ។ សម្តេចបានបន្តថា «**ដោយសារតែប្រទេសថៃ បានឆ្លងមេរោគ COVID-19 កើនឡើងដោយគំហុកនោះ ប្រជាពលរដ្ឋខ្មែរយើងគាត់មានការ ភ័យខ្លាចក៏បានវិលត្រឡប់មកផ្ទះសំបែង នៅស្រុកវិញស្រប ពេលជិតដល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរផង**

អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវទទួលគាត់ដោយទន់ភ្លន់ និងកត់យកអត្តសញ្ញាណរបស់ពួកគាត់ផង ដើម្បីងាយស្រួលតាមដានចុះអប់រំ គាត់នៅតាមមូលដ្ឋានខ្នងផ្ទះផ្ទាល់ ឲ្យគាត់យល់និងផ្សព្វផ្សាយតាមមេក្រូជាប្រចាំនៅក្នុងមូលដ្ឋាន បានជ្រាបច្បាស់បានយល់ងាយស្រួលទប់ស្កាត់ការរីករាលដាលនៃការឆ្លងឆ្លងមេរោគនេះ»។

សម្តេចបានរំលឹកផងដែរថា «ថ្ងៃស្អែកនេះជាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ យើងរង់ចាំមើលថៃបានកំណត់យកជាថ្ងៃប្រកាសអាសន្នផងនោះ ទើបពលរដ្ឋខ្មែរនាំសម្រុកចូលមកស្រុកខ្លួនវិញតាមច្រកព្រំដែននៃខេត្តទាំងពីរ»។ ក្នុងឱកាសសំណេះសំណាលនោះ សម្តេចក្រឡាហោម ស ខេង ក៏បានឧបត្ថម្ភថវិកាមួយចំនួនដល់រដ្ឋបាលស្រុក និងអង្គភាពនានានៅក្នុងខេត្តទាំងពីរសម្រាប់ការ ចំណាយផ្គត់ផ្គង់ផ្សេងៗមានដូចខាងក្រោម៖

*ទី១៖ ឧបត្ថម្ភជូនរដ្ឋបាលស្រុកភ្នំព្រឹក ស្រុកសំពៅលូន ស្រុកកំរៀង និងស្រុកសំឡូត ក្នុងមួយស្រុកៗទទួលបានថវិកាចំនួន ២លានរៀល

*ទី២៖ ឧបត្ថម្ភជូនអធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក ស្រុកសំពៅលូន ស្រុកកំរៀង និងស្រុកសំឡូត ក្នុងមួយអធិការដ្ឋានចំនួន ២លានរៀល

*ទី៣៖ ឧបត្ថម្ភជូននគរបាលវរៈការពារព្រំដែនគោកលេខ៨១៧, លេខ៨១៩, លេខ៨២៣ និងលេខ៨១០ ក្នុងមួយវរៈចំនួន ២លានរៀល

*ទី៤៖ឧបត្ថម្ភជូនច្រកទ្វារព្រំដែនអន្តរជាតិភ្នំដីនិងច្រកព្រំដែនអន្តរជាតិដូងក្នុងមួយច្រកៗចំនួន៤លានរៀល

*ទី៥៖ ឧបត្ថម្ភជូនក្រុមចត្តាឡីស័កច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី និងច្រកទ្វារព្រំដែនអន្តរជាតិដូង ក្នុងមួយច្រកទទួលបាន ២លានរៀល

*ទី៦៖ ឧបត្ថម្ភជូនមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ថវិកាចំនួន២លានរៀល

*ទី៧៖ ឧបត្ថម្ភជូនច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន ថវិកាចំនួន៤លានរៀល

*ទី៨៖ ឧបត្ថម្ភជូនស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន ថវិកាចំនួន២លានរៀល

*ទី៩៖ ឧបត្ថម្ភជូនបញ្ជាការដ្ឋានកងរាជអាវុធហត្ថប៉ៃលិន ថវិកាចំនួន២លានរៀល

*ទី១០៖ ឧបត្ថម្ភជូនតំបន់ប្រតិបត្តិការសឹករងខេត្តប៉ៃលិន ថវិកាចំនួន២លានរៀល

*ទី១១៖ ឧបត្ថម្ភជូនវរៈការពារព្រំដែនគោកលេខ៨២១ ថវិកាចំនួន២លានរៀល

*ទី១២៖ ឧបត្ថម្ភជូនយោធាវរៈការពារព្រំដែនលេខ២១ ថវិកាចំនួន២លានរៀល

*ទី១៣៖ឧបត្ថម្ភម៉ាស់ជូនខេត្តបាត់ដំបងចំនួន៣.០០០ម៉ាស់ និងខេត្តប៉ៃលិនចំនួន២.០០០ម៉ាស់ផងដែរ។

## ពលករកម្ពុជាដែលធ្វើការនៅប្រទេសថៃ បន្តឆ្លងព្រំដែនក្នុងភូមិសាស្ត្រខេត្តប៉ៃលិន ខណៈអាជ្ញាធរខេត្តដាក់គ្រូពេទ្យប្រចាំការ ត្រួតពិនិត្យបង្ការការរីករាលដាលជំងឺ COVID-19

http://www.freshnewsasia.com/ 2020-03-25

**(ប៉ៃលិន)៖** នៅថ្ងៃទី២៥ ខែមិនា ឆ្នាំ២០២០ ដោយសារស្ថានភាពរីករាលដាលនៃវីរុស COVID-19 បានបង្ខំឲ្យពលករខ្មែរដែលធ្វើការនៅខេត្តចាន់បុរី ប្រទេសថៃជាង ១០០នាក់ បានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ តាមព្រំដែនក្នុងភូមិសាស្ត្រខេត្តប៉ៃលិន គ្រាដែលច្រកទ្វារព្រំដែនអន្តរជាតិព្រំខេត្តប៉ៃលិន និងច្រកសំខាន់ៗផ្សេងទៀតជាប់ព្រំដែនថៃត្រូវបានបិទ មិនឱ្យចេញចូលទៅមកបានឡើយ។

បើតាមការរៀបរាប់របស់ពលករខ្មែរដែលឆ្លងដែនមក បានឱ្យដឹងឡើងថា នៅក្នុងប្រទេសថៃពួកគាត់មានការព្រួយបារម្ភជាខ្លាំង ចំពោះ COVID-19 ផង រួមទាំងអត់ការងារធ្វើផងនោះ បានបង្ខំឲ្យពួកគាត់សម្រេចចិត្តវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ហើយដោយច្រកទ្វារព្រំដែនត្រូវបានបិទ ដូច្នេះពួកគាត់ខ្លះ ក៏ត្រូវបង្ខំចិត្តត្រឡប់មកកាន់ប្រទេសកម្ពុជាវិញដើម្បីជួបជុំក្រុមគ្រួសារ ហើយជាក់ស្តែងនៅថ្ងៃនេះ លោក ផាន់ ចាន់ធុល អភិបាលខេត្ត

ប៉ៃលិន បានជួបពិភាក្សាជាមួយភាគីថៃដោយ អនុញ្ញាតឱ្យពលករប្រមាណជាង ១០០នាក់ ទើបបើកច្រកឱ្យចេញម្តង ដើម្បីវិលត្រឡប់ទៅកាន់ស្រុកកំណើតរៀងៗខ្លួនវិញ។

លោក ផាន់ ចាន់ធុល បានឱ្យដឹងថា ពលករខ្មែរដែលឆ្លងដែនត្រលប់មកវិញនេះ អាជ្ញាធរមិនបានអនុវត្តន៍ដាក់ឲ្យនៅដាច់ឡែកនោះទេ ដោយគ្រាន់តែកំណត់អត្តសញ្ញាណ ការស្រង់ទិន្នន័យ លំនៅដ្ឋានពិតប្រាកដត្រូវត្រឡប់ទៅវិញ ងាយស្រួលការការពារ និងតាមដានព័ត៌មានផ្សេងៗ ការពិនិត្យផែកកំដៅនិងពិនិត្យសុខភាពយ៉ាងតឹងរ៉ឹង និងលាងសំអាតដៃនិងជងខ្លួនដោយសារជាតុសម្លាប់ មេរោគពីក្រុមមន្រ្តីសុខាភិបាលខេត្ត រួចហើយទើបមានអនុញ្ញាតឲ្យពួកគាត់វិលត្រឡប់ទៅកាន់លំនៅដ្ឋានរៀងៗខ្លួនវិញជាធម្មតា។

យោងតាមរបាយការណ៍របស់នគរបាលអន្តោប្រវេសន៍ប្រចាំការនៅច្រកទ្វារអន្តរជាតិព្រំបានឱ្យដឹងថា ពលករកម្ពុជាដែលឆ្លងព្រំដែនមកពីប្រទេសថៃ ក្នុងភូមិសាស្រ្តខេត្តប៉ៃលិន គិតចាប់តាមពីម៉ោង ០៨និង៣០នាទីព្រឹកថ្ងៃទី២៥ ខែមីនា រហូតដល់ម៉ោង ១២ថ្ងៃត្រង់ គឺមានចំនួនសរុប ១០៣នាក់ ស្រី៥១នាក់ ហើយលទ្ធផលពិនិត្យសុខភាពបឋម គឺអវិជ្ជមានទាំងអស់៕

## រដ្ឋាភិបាលថៃ ដាក់ប្រទេសក្នុងគ្រាមានអាសន្ន ធ្វើឲ្យពលរដ្ឋខ្មែរវិលមកស្រុកកំណើតវិញ

http://www.cen.com.kh/archives/ March 26, 2020

បាត់ដំបង៖ ស្របពេលដែលរដ្ឋាភិបាលថៃ ដាក់ប្រទេសក្នុងគ្រាមានអាសន្ន ហើយបានធ្វើឱ្យពលរដ្ឋខ្មែរនិស្សិត សិស្ស និងអ្នកប្រកបរបរអាជីវកម្មមួយចំនួនបានធ្វើដំណើរវិលមកស្រុកកំណើតវិញ សម្តេចបានមានប្រសាសន៍ថាប្រសិនបើមានពលរដ្ឋខ្មែរយើងបន្តធ្វើដំណើរចូលមកប្រទេសវិញនោះ គឺរាជរដ្ឋាភិបាលយើងមិនអាចទប់ស្កាត់ពលរដ្ឋយើងមិនឱ្យវិលមកវិញបានទេ ហើយសម្តេចបានណែនាំឲ្យអាជ្ញាធរមូលដ្ឋានទទួលស្វាគមន៍ពលរដ្ឋដោយក្តី រាក់ទាក់បំផុត។

នៅរសៀលថ្ងៃពុធ ទី២៥ ខែមីនា ឆ្នាំ២០២០នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជួបសំណេះសំណាលដោយផ្ទាល់ ជាមួយមន្ត្រីនៃអង្គភាព និងស្ថាប័ននានា ដែលកំពុងបំពេញភារកិច្ចតាមបណ្តាច្រកទ្វារព្រំដែន នៃភូមិសាស្ត្រខេត្តបាត់ដំបង និងខេត្តប៉ៃលិន ដែលពិធីជួបសំណេះសំណាលនេះ បានប្រារព្ធឡើងនៅសាលាស្រុកកំរៀង ខេត្តបាត់ដំបង។ អញ្ជើញមានប្រសាសន៍នាឱកាសនោះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានគូសបញ្ជាក់ថាវត្តមានរបស់សម្តេច និងថ្នាក់ដឹកនាំផ្សេងទៀតក្នុងពិធីជួបសំណេះសំណាលនេះ គឺជាការចូលរួមចំណែកផ្តល់ការលើកទឹកចិត្តដល់មន្ត្រីទាំងអស់ដែលកំពុងបំពេញភារកិច្ចតាមបណ្តាអង្គភាពនៅច្រកទ្វារព្រំដែនកម្ពុជា-ថៃ ទាំងនៅខេត្តបាត់ដំបង និងប៉ៃលិន ក្នុងបរិបទដែលពិភពលោក កំពុងប្រឈមខ្លាំងនឹងការរីករាលដាលជំងឺកូវីដ១៩ ដែលពេលនេះបានក្លាយជាវិបត្តិធ្ងន់ធ្ងររបស់ពិភពកលោក។ សម្តេចបានបន្តថា ក្រៅតែបាននិងកំពុងរីករាលដាលនៅបណ្តាប្រទេសស្ទើរទាំងអស់លើពិភពលោក ពិសេសនៅតំបន់អឺរ៉ុប អាមេរិក និងមជ្ឈឹមបូព៌ា បន្ទាប់ពីប្រទេសចិនមានសភាពធូរស្រាលនោះ នៅពេលនេះតំបន់អាស៊ានទាំង១០ប្រទេស សុទ្ធតែមានអ្នកឆ្លងជំងឺកូវីដទាំងអស់ ។ សម្តេចបានបញ្ជាក់អំពីការសម្រេចចិត្តដាក់ប្រទេសក្នុងគ្រាមានអាសន្នរបស់រដ្ឋាភិបាលថៃដើម្បីអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ បន្ទាប់ពីបានបិទការដ្ឋានការងារមួយចំនួន ធ្វើឱ្យពលរដ្ឋថៃនៅទំនេរ ហើយពលរដ្ឋខ្មែរខ្លះនៅទីនោះក៏ទំនេរពីការងារ ។

ព្រោះតែដូច្នេះហើយ សម្តេចបានផ្តល់ការពន្យល់ថាពលរដ្ឋខ្មែរទំនេរពីការងារ និងមានការភ័យខ្លាចផងនោះ បានចាប់ផ្តើមសម្រុ កនាំគ្នាវិលត្រឡប់មកប្រទេសកម្ពុជាវិញនាប៉ុន្មានថ្ងៃមុន ដែលធ្វើឱ្យអាជ្ញាធរច្រកទ្វារព្រំដែនជួបការលំបាកក្នុងការពិនិត្យសុខភាពពួកគាត់ពេលឆ្លងព្រំដែន ។ ដោយសារពួកគាត់បានធ្វើដំណើរដល់ស្រុកកំណើតហើយនោះ សម្តេចបានសុំគោលការណ៍ពីសម្តេចតេជោ ដើម្បីណែនាំអាជ្ញាធរខេត្តក្រុង-ស្រុក-ខណ្ឌ និងភូមិ-ឃុំ ត្រូវ

គ្រប់គ្រងវត្តមានពួកគាត់ឱ្យបាន និងស្នើឱ្យពួកគាត់នៅដោយឡែក១៤ថ្ងៃសិន។ ពាក់ព័ន្ធនឹងការដាក់ប្រទេសក្នុងគ្រាមានអាសន្នរបស់រដ្ឋាភិបាលថៃ សម្តេចបានមានប្រសាសន៍ថាប្រសិនបើមានពលរដ្ឋខ្មែរយើងបន្តធ្វើដំណើរចូលមកប្រទេសវិញនោះ គឺរាជរដ្ឋាភិបាលយើងមិនអាចទប់ស្កាត់ពលរដ្ឋយើងមិនឱ្យវិលមកវិញបានទេ។ សម្តេចបានណែនាំឱ្យត្រៀមទទួលស្វាគមន៍ពួកគាត់ដោយប្រកាន់អកប្បកិរិយាថ្លៃថ្នូរសុភាពរាបសារ និងទន់ភ្លន់ ប៉ុន្តែត្រូវវិធានការម៉ឺងម៉ាត់តាមក្បួនសុខាភិបាល ដើម្បីជានាសុខសុវត្ថិភាពពួកគាត់ និងក្រុមគ្រួសារនៅឯស្រុកកំណើត ។ ជាមួយគ្នានេះក៏ត្រូវមានកិច្ចសហការល្អជាមួយអាជ្ញាធរខេត្តខាងភាគីថៃដែរ ។

សម្តេចបានណែនាំឱ្យអាជ្ញាធរប្រចាំច្រកទ្វារព្រំដែន ត្រូវកត់ត្រាឱ្យបានច្បាស់នូវអត្តសញ្ញាណពលរដ្ឋដែលបានវិលចូលមកប្រទេស ដើម្បីជានាតាមដានស្រាវជ្រាវរកពួកគាត់ ប្រសិនបើមានបញ្ហាណាមួយ ហើយជាមួយគ្នានេះត្រូវខិតខំពិភាក្សាជាមួយភាគីថៃដើម្បីចៀសវាងការអនុញ្ញាតឱ្យឆ្លងកាត់តាមច្រករបៀង ដែលនាំឱ្យជួបការលំបាកក្នុងការពិនិត្យសុខភាព និងកំណត់អត្តសញ្ញាណពួកគាត់ ពោលគឺត្រូវកំណត់ច្រកទ្វារច្បាស់លាស់សម្រាប់ការវិលចូលប្រទេសរបស់ពលរដ្ឋខ្មែរយើង។ សម្តេចក៏បានណែនាំឱ្យត្រៀមផ្តល់ម៉ាស់ជូនពលរដ្ឋទាំងឡាយណាដែលឆ្លងមកពីប្រទេសថៃដោយមិនមានម៉ាស់ប្រើប្រាស់ ហើយត្រូវស្នើសុំពួកគាត់សហការពិនិត្យកំដៅ និងអញ្ជើញពួកគាត់ទៅកន្លែងដែលត្រូវកត់ត្រាអត្តសញ្ញាណសិន។ ក្នុងករណីដែលមានអ្នកជំងឺត្រូវសង្គ្រោះ បន្ទាន់ ហើយអ្នកជំងឺនោះមិនមែនជាអ្នកជំងឺកូវីដ១៩ សម្តេចក៏បានណែនាំអភិបាលខេត្តបាត់ដំបង និងប៉ៃលិន ត្រូវស្នើសុំកិច្ចសហការអនុញ្ញាតឱ្យអ្នកជំងឺនោះចូលទៅព្យាបាលនៅប្រទេសថៃ។ សម្តេចមានជំនឿថាភាគីទាំងពីរកម្ពុជាថៃនឹងមានការពិចារណាដល់ទំនាក់ទំនងទ្វេភាគី ដើម្បីការពារផលប្រយោជន៍ទៅវិញទៅមករវាងប្រទេស និងប្រជាជននៃប្រទេសទាំងពីរ។ ជាក់ស្តែងដូចការបិទការចេញចូលមនុស្សរវាងកម្ពុជា-ថៃ កម្ពុជា-វៀតណាម ដែលភាគីទាំងសងខាងនៅតែបន្តការអនុញ្ញាតឱ្យចេញចូលទំនិញក្រោមលក្ខណ្ឌរឹតបន្តឹងសុវត្ថិភាពនៅពេលដឹកឆ្លងកាត់ព្រំដែន ។

នៅក្នុងឱកាសនោះ សម្តេចបានថ្លែងការកោតសរសើរថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងចំណុះរដ្ឋបាលខេត្ត និងជាពិសេសមន្ត្រី និងកងកម្លាំងនៃអង្គភាព និងស្ថាប័ននានាដែលកំពុងបំពេញភារកិច្ចនៅតាមបណ្តាច្រកទ្វារព្រំដែន។ សម្តេចបានចាត់ទុកការខិតខំប្រឹងប្រែងបំពេញភារកិច្ចនេះហើយដែលធ្វើឱ្យកម្ពុជារក្សាបានសុខសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ ធានាការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ហើយទន្ទឹមនឹងនេះយើងក៏បាននឹងកំពុងរួមសាមគ្គីគ្នាប្រយុទ្ធនឹងសង្គ្រាមជំងឺកូវីដ១៩ ដើម្បីជានាការពារសេចក្តីសុខជូនប្រជាពលរដ្ឋ ដែលនេះហើយគឺជាឧត្តមគតិស្រលាញ់ជាតិ និងប្រជាជន ។

ពាក់ព័ន្ធនឹងការងារផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋអំពីវិធានការការពារខ្លួន និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ សម្តេចក្រឡាហោម ក៏បានថ្លែងការកោតសរសើរចំពោះអាជ្ញាធរមូលដ្ឋានទាំងអស់ ដែលបានរៀបចំការចុះចាត់ផ្សាយសារអេប់រំចល័តគ្រប់ភូមិឃុំដល់ប្រជាពលរដ្ឋ ។ មុននឹងបញ្ចប់សម្តេច បានសម្តែងសេចក្តីសង្ឃឹមជឿជាក់ថាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងកងកម្លាំងចំណុះរដ្ឋបាលខេត្ត និងកំពុងបំពេញការងារនៅតាមបណ្តាអង្គភាពច្រកព្រំដែនកម្ពុជាថៃក្នុងភូមិសាស្ត្រខេត្តបាត់ដំបង និងប៉ៃលិនទាំងអស់ នឹងបន្តខិតខំអនុវត្តតួនាទី និងការទទួលខុសត្រូវបានល្អ និងមានការប្រុងប្រយ័ត្ន ដើម្បីចៀសផុតពីការឆ្លងជំងឺកូវីដ១៩ ៕ ដោយៈកូឡាប

## ពលករពលរដ្ឋខ្មែរវិលត្រឡប់មកកម្ពុជាទាំងអធ្រាត្រតាមអូរច្រករបៀង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ០៨:៥៦ Kian Sokheak

រាជធានីភ្នំពេញ ៖ នៅអធ្រាត្រថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ឈានចូលថ្ងៃទី២៦ ខែមីនា វេលាម៉ោង០១និង០០នាទីយប់ មានពលករប្រជាពលរដ្ឋខ្មែរបានវិលត្រឡប់មកប្រទេសកម្ពុជាឆ្លងកាត់តាមអូរច្រករបៀង( ស្លាបធ្វេង ) របស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ខេត្តបាត់ដំបង ។ នេះបើយោងតាមផេក អគ្គនាយកដ្ឋានអន្តោប្រវេ

សន៍ ។ កម្លាំងនគរបាលប៉ុស្តិ៍បាននាំពួកគាត់មកទីតាំងប៉ុស្តិ៍ ដើម្បីសួរនាំ និងសហការជាមួយមន្ត្រីចត្តាឡីស័កពិនិត្យសុខភាពរបស់ពួកគាត់ ដោយមិនមាននរណាម្នាក់មានឡើងកម្តៅខុសប្រក្រតីនោះទេ និងបានធ្វើការប្រគល់ទទួលប្រជាពលរដ្ឋខាងលើជូនទៅខាងចត្តាឡីស័ក ដើម្បីគ្រប់គ្រង និងអនុវត្តនីតិវិធីបន្ត ៕

## ពលករកម្ពុជាដែលធ្វើការនៅខេត្តចាន់បុរី បង្ខំចិត្តបន្តឆ្លងព្រំដែន មកស្រុកវិញ ក្នុងភូមិសាស្ត្រខេត្តប៉ៃលិន

http://www.cen.com.kh/ March 26, 2020

ប៉ៃលិន៖ បើតាមរបាយការណ៍ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន បានឲ្យដឹងថា នៅថ្ងៃ ទី២៥ ខែមីនា ឆ្នាំ ២០២០ ដោយសារស្ថានភាពរីករាលដាលនៃវីរុសកូវីដ-១៩ បានបង្ខំឲ្យពលករខ្មែរ ដែលធ្វើការនៅខេត្តចាន់បុរី ប្រទេសថៃប្រមាណជាង ១០០នាក់ បានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ តាមព្រំដែនក្នុងភូមិសាស្ត្រខេត្តប៉ៃលិន គ្រាដែលច្រកទ្វារព្រំដែនអន្តរជាតិព្រំខេត្តប៉ៃលិន និងច្រកសំខាន់ៗផ្សេងទៀតជាប់ព្រំដែនថៃត្រូវបានបិទមិនឱ្យចេញចូលទៅមកបានឡើយ។ បើតាមការរៀបរាប់របស់ពលករខ្មែរ ដែលឆ្លងដែនមក បានឱ្យដឹងឡើងថា នៅក្នុងប្រទេសថៃពួកគាត់មានការព្រួយបារម្ភជាខ្លាំង ចំពោះជម្ងឺកូវីត-១៩ ផង រួមទាំងអត់ការងារធ្វើផងនោះ បានបង្ខំឲ្យពួកគាត់សម្រេចចិត្តវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ហើយដោយច្រកទ្វារព្រំដែនត្រូវបានបិទ ដូច្នេះពួកគាត់ខ្លះក៍ ត្រូវបង្ខំចិត្តត្រឡប់មកកាន់ប្រទេសកម្ពុជាវិញដើម្បីជួបជុំក្រុមគ្រួសារ ហើយជាក់ ស្តែង នៅថ្ងៃនេះ ឯកឧត្តម ផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន ក៏បានជួបពិភាក្សាជាមួយភាគីថៃដោយ អនុញ្ញាត ឱ្យពលករប្រមាណជាង ១០០ នាក់ ទើបបើកច្រកឱ្យចេញម្តង ដើម្បីវិលត្រឡប់ទៅកាន់ស្រុកកំណើតរៀងៗខ្លួនវិញ ។

ឯកឧត្តម ផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍ឱ្យដឹងថា៖ ពលករខ្មែរដែលឆ្លងដែនត្រឡប់មកវិញនេះ អាជ្ញាធរមិនបានអនុវត្តន៍ដាក់ឲ្យនៅដាច់ឡែកនោះទេ ដោយគ្រាន់តែកំណត់អត្តសញ្ញាណ ការស្រង់ទិន្នន័យលំនៅដ្ឋានពិតប្រាកដត្រូវត្រឡប់ទៅវិញងាយស្រួលការការពារនិងតាមដានព័ត៌មានផ្សេងៗ ការពិនិត្យផែកកំដៅនិងពិនិត្យសុខភាពយ៉ាងតឹងរឹង និងលាងសំអាតដៃ និងជងខ្លួនដោយសារជាតុសម្លាប់មេរោគពីក្រុមមន្ត្រីសុខាភិបាលខេត្ត រួចហើយទើបមានអនុញ្ញាតអោយពួកគាត់វិលត្រឡប់ទៅកាន់លំនៅដ្ឋានរៀងៗខ្លួនវិញជាធម្មតា។

យោងតាមរបាយការណ៍របស់នគរបាលអន្តោប្រវេសន៍ប្រចាំការនៅច្រកទ្វារអន្តរជាតិព្រំបានឱ្យដឹងថា៖ ពលករកម្ពុជាដែលឆ្លងព្រំដែនមកពីប្រទេសថៃ ក្នុងភូមិសាស្ត្រខេត្តប៉ៃលិន គិតចាប់តាមពីម៉ោង ០៨និង៣០នាទីព្រឹកថ្ងៃទី២៥ ខែមីនា រហូតដល់ម៉ោង ១២ថ្ងៃត្រង់ គឺមានចំនួនសរុប ១០៣នាក់ ស្រី៥១នាក់ ហើយលទ្ធផលពិនិត្យសុខភាពបឋម គឺអវិជ្ជមានទាំងអស់៕ ដោយ៖ បញ្ញាស័ក្តិ

## សម្តេច ស ខេង ណែនាំឱ្យកត់ត្រាច្បាស់លាស់នូវអត្តសញ្ញាណពលរដ្ឋដែលមកពីថៃ

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង 08:15

- សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំឱ្យអាជ្ញាធរប្រចាំច្រកទ្វារព្រំដែន ត្រូវកត់ត្រាឱ្យបានច្បាស់នូវអត្តសញ្ញាណប្រជាពលរដ្ឋដែលបានធ្វើដំណើរពីប្រទេសថៃ វិលចូលមកប្រទេសកម្ពុជា ដើម្បីធានាតាមដានស្រាវជ្រាវរកពួកគាត់ ប្រសិនបើមានបញ្ហាណាមួយ និងពិភាក្សាជាមួយភាគីថៃដើម្បីចៀសវាងការអនុញ្ញាតឱ្យឆ្លងកាត់តាមច្រករបៀង ដែលនាំឱ្យជួបការលំបាកក្នុងការពិនិត្យសុខភាព និងកំណត់អត្តសញ្ញាណពួកគាត់ពេលគឺត្រូវកំណត់ច្រកទ្វារច្បាស់លាស់សម្រាប់ការវិលចូលប្រទេសរបស់ពលរដ្ឋខ្មែរ។ ការណែនាំនេះ បានធ្វើឡើងនៅក្នុងពិធីសំណេះសំណាលដោយផ្ទាល់ជាមួយមន្ត្រីនៃអង្គភាព និងស្ថាប័ននានា

ដែលកំពុងបំពេញភារកិច្ចតាមបណ្តាច្រកទ្វារព្រំដែន នៃភូមិសាស្ត្រខេត្តបាត់ដំបង និងខេត្តប៉ៃលិន នៅសាលាស្រុកកំរៀង ខេត្តបាត់ដំបង កាលពីរសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។

- សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា វត្តមានរបស់សម្តេច និងថ្នាក់ដឹកនាំផ្សេងទៀតក្នុងពិធីជួបសំណេះសំណាលនេះ គឺជាការចូលរួមចំណែកផ្តល់ការលើកទឹកចិត្តដល់មន្ត្រីទាំងអស់ដែលកំពុងបំពេញភារកិច្ចតាមបណ្តាអង្គភាពនៅច្រកទ្វារព្រំដែនកម្ពុជា-ថៃ ទាំងនៅខេត្តបាត់ដំបង និងប៉ៃលិន ក្នុងបរិបទដែលពិភពលោកកំពុងប្រឈមខ្លាំងនឹងការរីករាលដាលជំងឺកូវីដ១៩ ដែលពេលនេះបានក្លាយជាវិបត្តិធ្ងន់ធ្ងររបស់ពិភពកលោក ។ សម្តេចក្រឡាហោមបានបន្តថា ក្រៅតែបាននិងកំពុងរីករាលដាលនៅបណ្តាប្រទេសស្ទើរទាំងអស់លើពិភពលោក ពិសេសនៅតំបន់អឺរ៉ុប អាមេរិក និងមជ្ឈឹមបូព៌ា បន្ទាប់ពីប្រទេសចិនមានសភាពធូរស្រាលនោះ នៅពេលនេះតំបន់អាស៊ានទាំង១០ប្រទេស សុទ្ធតែមានអ្នកឆ្លងជំងឺកូវីដទាំងអស់។
- សម្តេចបានបញ្ជាក់អំពីការសម្រេចចិត្តដាក់ប្រទេសក្នុងគ្រាមានអាសន្នរបស់រដ្ឋាភិបាលថៃដើម្បីអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ បន្ទាប់ពីបានបិទការដ្ឋានការងារមួយចំនួន ធ្វើឱ្យពលរដ្ឋថៃនៅទំនេរ ហើយពលរដ្ឋខ្មែរខ្លះនៅទីនោះក៏ទំនេរពីការងារ ។សម្តេចបានផ្តល់ការពន្យល់ថា ពលរដ្ឋខ្មែរទំនេរពីការងារ និងមានការភ័យខ្លាចផងនោះ បានចាប់ផ្តើមសំរុកនាំគ្នាវិលត្រឡប់មកប្រទេសកម្ពុជាវិញនាប៉ុន្មានថ្ងៃមុន ដែលធ្វើឱ្យអាជ្ញាធរច្រកទ្វារព្រំដែនជួបការលំបាកក្នុងការពិនិត្យសុខភាពពួកគាត់ពេលឆ្លងព្រំដែន ។ ដោយសារពួកគាត់បានធ្វើដំណើរដល់ស្រុកកំណើតហើយនោះ សម្តេចបានសុំគោលការណ៍ពីសម្តេចតេជោ ដើម្បីណែនាំអាជ្ញាធរខេត្តក្រុង-ស្រុក-ខណ្ឌ និងភូមិ-ឃុំ ត្រូវគ្រប់គ្រងវត្តមានពួកគាត់ឱ្យបាន និងស្នើឱ្យពួកគាត់នៅដោយឡែក១៤ថ្ងៃសិន ។
- ពាក់ព័ន្ធនឹងការដាក់ប្រទេសក្នុងគ្រាមានអាសន្នរបស់រដ្ឋាភិបាលថៃ សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា ប្រសិនបើមានពលរដ្ឋខ្មែរយើងបន្តធ្វើដំណើរចូលមកប្រទេសវិញនោះ គឺរាជរដ្ឋាភិបាលយើងមិនអាចទប់ស្កាត់ពលរដ្ឋយើងមិនឱ្យវិលមកវិញបានទេ។ សម្តេចបានណែនាំឱ្យត្រៀមទទួលស្វាគមន៍ពួកគាត់ដោយប្រកាន់អកប្បកិរិយាថ្លៃថ្នូរសុភាពរាបសារ និងទន់ភ្លន់ ប៉ុន្តែត្រូវវិធានការម៉ឺងម៉ាត់តាមក្បួនសុខាភិបាលដើម្បីធានាសុខសុវត្ថិភាពពួកគាត់ និងក្រុមគ្រួសារនៅឯស្រុកកំណើត។ ជាមួយគ្នានេះក៏ត្រូវមានកិច្ចសហការល្អជាមួយអាជ្ញាធរខេត្តខាងភាគីថៃដែរ ។ សម្តេចក៏បានណែនាំឱ្យត្រៀមផ្តល់ម៉ាស់ជូនពលរដ្ឋទាំងឡាយណា ដែលឆ្លងមកពីប្រទេសថៃដោយមិនមានម៉ាស់ប្រើប្រាស់ ហើយត្រូវស្នើសុំពួកគាត់សហការពិនិត្យកំដៅ និងអញ្ជើញពួកគាត់ទៅកន្លែងដែលត្រូវកត់ត្រាអត្តសញ្ញាណសិន។ ក្នុងករណីដែលមានអ្នកជំងឺត្រូវសង្គ្រោះ បន្ទាន់ ហើយអ្នកជំងឺនោះមិនមែនជាអ្នកជំងឺកូវីដ១៩ សម្តេចក៏បានណែនាំអភិបាលខេត្តបាត់ដំបង និងប៉ៃលិន ត្រូវស្នើសុំកិច្ចសហការអនុញ្ញាតឱ្យអ្នកជំងឺនោះចូលទៅព្យាបាលនៅប្រទេសថៃ។
- សម្តេចមានជំនឿថា ភាគីទាំងពីរកម្ពុជាថៃនឹងមានការពិចារណាដល់ទំនាក់ទំនងទ្វេភាគី ដើម្បីការពារផលប្រយោជន៍ទៅវិញទៅមករវាងប្រទេស និងប្រជាជននៃប្រទេសទាំងពីរ។ ជាក់ស្តែងដូចការបិទការចេញចូលមនុស្សរវាងកម្ពុជា-ថៃ កម្ពុជា-វៀតណាម ដែលភាគីទាំងសងខាងនៅតែបន្តការអនុញ្ញាតឱ្យចេញចូលទំនិញក្រោមលក្ខណ្ឌរឹតបន្តឹងសុវត្ថិភាពនៅពេលដឹកឆ្លងកាត់ព្រំដែន៕ អត្ថបទ៖ សោភា

## ខេត្តកំពង់ស្ពឺ មានពលករវិលពីបរទេស២៤៦នាក់ ត្រូវបានណែនាំនៅដាច់ដោយឡែកពីញាតិរបស់ខ្លួន១៤ថ្ងៃ

http://kampucheathmey.com/ 26/3/2020 8:20 Am

កំពង់ស្ពឺ ៖ លោក វ៉ី សំណាង អភិបាលខេត្តកំពង់ស្ពឺ បានអំពាវនាវដល់អ្នកចំណូលស្រុកថា បងប្អូន ត្រូវរក្សាខ្លួនឲ្យនៅដាច់ដោយឡែកសាច់ញាតិ បងប្អូន និងកុំជួបជុំក្នុងកម្មវិធីផ្សេងៗ ដើម្បីការពារពោគឆ្លង(COVID-19) ដែលជាជំងឺឆ្លងរាតត្បាតជាសកល។ ជាមួយគ្នានោះដែរ អភិបាលខេត្តកំពង់ស្ពឺ បានលើកឡើងថា ពលករចំណូលស្រុក គិតមកដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ បានវិលមកកាន់ស្រុកកំណើតមានចំនួន២៤៦នាក់ ក្នុងចំណោម ៧ ១៩៣ នាក់ ដែលបានចេញចំណាកស្រុកទៅធ្វើការនៅបរទេស។ លោកអភិបាលបន្តថា អាជ្ញាធរខេត្ត មានទិន្នន័យច្បាស់លាស់ចំពោះបងប្អូនចំណូលស្រុកមកវិញ ដូច្នេះអាជ្ញាធរមូលដ្ឋាន មានមេភូមិ មេប៉ុស្តិ៍ នគរបាល លោកមេឃុំ ត្រូវតែបន្តតាមដាន និងអប់រំពួកគាត់ឲ្យបានយល់ដឹងអំពី ការបង្ការ នៃជំងឺឆ្លង(COVID-19)គ្រប់គ្នាៗ។ ជាពិសេសនៅតាមអង្គភាព មន្ទីររបស់រដ្ឋ ត្រូវសម្អាតអនាម័យ ប្រើប្រាស់មធ្យោបាយឃោសនានៅតាមភូមិ-ឃុំ វត្តអារាម រោងចក្រ សហគ្រាស ឲ្យបងប្អូនប្រជាពលរដ្ឋបានយល់ពីបញ្ហាការឆ្លងជាសកលនូវជំងឺ(COVID-19)នេះឲ្យពួកគាត់បានថែរក្សាសុខភាពខ្លួនផង។

លោក អោ វណ្ណថេន ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺបានឲ្យដឹងថា ពលករចំណូលស្រុកដែលវិលមកវិញពីបរទេស គឺអនុញ្ញាតឲ្យពួកគាត់រស់នៅតាមផ្ទះរៀងៗខ្លួន តែត្រូវនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ និងត្រូវបានតាមដានជាប្រចាំពីមន្ត្រីសុខាភិបាលនៅមូលដ្ឋានដោយផ្ទាល់ ដោយប្រើប្រាស់វិធីសាស្ត្ររបស់សុខាភិបាលជាចម្បង៕

## ពលករខ្មែរនៅថៃខ្លះអត់ការធ្វើខណៈរដ្ឋាភិបាលថៃប្រកាសប្រើច្បាប់អាសន្នទប់ទល់ជំងឺកូវីដ១៩

https://www.rfa.org/khmer/ ដោយ ខែ សុណង 2020-03-25

ពលករខ្មែរមួយចំនួនធ្វើការងារនៅប្រទេសថៃចាប់ផ្ដើមត្អូញត្អែរអត់ការងារធ្វើបណ្ដើរៗ ហើយបន្ទាប់ពីថៅកែជនជាតិថៃបានផ្អាកធ្វើការរបស់ពួកគេមួយរយៈ ដោយសារផលប៉ះពាល់ពីជំងឺកូវីដ១៩។ ពលករខ្មែរទាំងនេះព្រួយបារម្ភខ្លាចស្ថានការណ៍អូសបន្លាយពេលយូរធ្វើឱ្យដាច់ស្បៀងស្របពេលដែលនាយករដ្ឋមន្ត្រីថៃ បានប្រកាសប្រើច្បាប់ប្រកាសអាសន្ន ថ្ងៃទី២៦ មីនា ដើម្បីទប់ស្កាត់ជំងឺលោកផ្លូវដង្ហើមនេះ។

ពលករខ្មែរម្នាក់ធ្វើការក្នុងហាងលក់ម្ហូបអាហារនៅជាយទីក្រុងបាងកក ប្រទេសថៃ លោក កែវ សុផាត ប្រាប់អាស៊ីសេរីនៅថ្ងៃទី២៤មីនាថា ពួកគាត់ប្រមាណ ២០នាក់ត្រូវបានថៅកែថៃឱ្យផ្អាកការងារប្រមាណ៣ថ្ងៃហើយ។ ពលកររូបនេះបន្តថា អំឡុងពេលអត់ការងារ ពួកគេបានជួលបន្ទប់មួយស្នាក់នៅរួមគ្នា ៤នាក់ ដើម្បីសន្សំប្រាក់សម្រាប់ទិញស្បៀងអាហារដោះស្រាយជីវភាពប្រចាំថ្ងៃ។ លោកបញ្ជាក់ទៀតថា ចាប់ពីតាំងអត់ការងារធ្វើមក ដោយពួកគាត់យូរៗម្ដងទើបនាំគ្នាចេញទៅផ្សារទិញស្បៀងយកមកទុកហូប និងគ្មានប្រាក់ចំណូលសម្រាប់ដោះស្រាយជីវភាពនៅពេលខាងមុខនិង គ្មានប្រាក់ផ្ញើទៅឱ្យឪពុកម្ដាយនៅស្រុកកំណើតនោះឡើយ។ លោកបន្តថា សព្វថ្ងៃនៅសល់ប្រាក់ក្នុងខ្លួនប្រមាណ២ពាន់បាត ឬស្មើជាង៦០ដុល្លារអាមេរិកតែប៉ុណ្ណោះ ពីព្រោះប្រាក់ខែដែលលោកបានបើកពីថៅកែពាក់កណ្ដាលខែនោះបានផ្ញើទៅផ្ទះអស់ហើយ៖«ដេកហូបអត់មានលុយចាយថ្លៃបន្ទប់ យើងស្នាក់នៅព្រោះអត់មានការងារធ្វើ គេផ្អាកយូរមិនដឹងថ្ងៃណាគេបើកឡើងវិញ។ខ្ញុំមានអារម្មណ៍លំបាកនៅក្នុងបន្ទប់ជួលហើយអត់មានលុយបង់ថ្លៃបន្ទប់ ហើយកូននៅផ្ទះក៏អត់មានអីហូបទៀត ដាច់បាយ ។ខ្ញុំមានត្រឹមតែលុយទិញអង្ករទុកហូប

បើលុយផ្ញើទៅផ្ទះគ្មានទេ។ទៅមុខទៀតមិនដឹងយ៉ាងណាខ្ញុំបើការងារក៏អត់ហើយនៅព្រំដែនក៏គេបិទច្រកមិនឱ្យចេញទៅខ្មែរ»។

ស្រដៀងគ្នានេះដែរ ពលករខ្មែរម្នាក់ទៀត លោក សារុន ជិន រៀបរាប់ថា លោកធ្វើការងារក្នុងហាងលក់អាហារនៅប្រទេសថៃជាង ៣ឆ្នាំហើយ គឺពុំដែលជួបប្រទះអត់ការងារដូចពេលនេះទេ។ពលករមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យរូបនេះបន្តថា កន្លងមកលោកតែងសន្សំប្រាក់ផ្ញើទៅស្រុកកំណើតយ៉ាងហោចណាស់ ៦ពាន់បាតឬស្មើប្រមាណ ២០០ដុល្លារអាមេរិកក្នុងមួយខែ ក៏ប៉ុន្តែលោកថា នៅពេលនេះលោកគ្មានប្រាក់ផ្ញើទៅឪពុកម្ដាយដូចពេលមុនៗ ឡើយ ពីព្រោះថៅកែបានផ្អាកការងាររបស់ខ្លួនចាប់ពីថ្ងៃទី២១ មីនា រហូតដល់ពាក់កណ្ដាលខែមេសា ឬរហូតដល់ស្ថានការណ៍រាលដាលជំងឺកូវីដ១៩ ដូចធម្មតា ទើបថៅកែថៃហៅឱ្យចូលធ្វើការវិញ។ ពលកររូបនេះបន្តថា ថវិការបស់លោកអាចចាយវាយបានយ៉ាងយូរ ២សប្ដាហ៍ ទៅមុខទៀត ដូច្នេះនៅពេលអស់ប្រាក់ពីក្នុងហោប៉ៅ ពុំដឹងបានអ្វីហូបចុកនោះទេ៖«កន្លែងគេលក់ដូចរបស់អាំងអី គេខ្លាចឆ្លង ព្រោះអីប្រជាជនមកហូបច្រើនដល់ហើយទៅគេបិទមិនដឹងថាទៅនៅណាទេ។ ខ្មែរយើងគេបិទច្រកអស់ហើយទៅមិនរួចទេឥឡូវ ។ខ្ញុំនៅតែក្នុងបន្ទប់មិនហ៊ានចេញទេខ្លាចវាឆ្លងព្រោះអីខ្លាចវាឆ្លង ព្រោះអីរោគនេះវាឆ្លងខ្លាំងណាស់ ខ្ញុំចេញមួយថ្ងៃ២ដងអីទេទិញទឹកកកយកមកហូប បើទៅផ្សារខ្ញុំមិនហ៊ានទៅទេ ព្រោះមានមនុស្សច្រើន ដល់ហើយទៅក៏នៅតែក្នុងបន្ទប់នេះឯង ខ្ញុំហូបត្រីខកំប៉ុងនិងមីកញ្ចប់»។

ចាប់តាំងពីថ្ងៃទី២១ មីនាមក គឺពលករខ្មែរធ្វើការនៅទីក្រុងបាងកកនិងនៅខេត្តចំនួន៥ជាប់ទីក្រុងបាងកកដែលធ្វើការនៅក្នុងផ្សារទំនើប និងហាងលក់អាហារធំៗ ភាគច្រើនបានផ្អាកការងារមួយរយៈ បន្ទាប់ពីមានបទបញ្ជាពីអាជ្ញាធរខេត្តទាំងនេះដោយសារខ្លាចឆ្លងជំងឺកូវីដ១៩។

ពលការិនីខ្មែរធ្វើការក្នុងហាងលក់ម្ហូបអាហារនៅខេត្តជាប់ទីក្រុងបាងកក លោកស្រី ម៉ន គឹមលី ថ្លែងថា ចាប់តាំងពីថៅកែផ្អាកលក់ម្ហូបអាហារមក គឺបានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់លោកស្រី។ លោកស្រីបន្ថែមថា ក្រុមគ្រួសារនៅស្រុកខ្មែរពឹងផ្អែកទាំងស្រុងលើប្រាក់ចំណូលរបស់ខ្លួន ផ្ញើទៅឱ្យពួកគាត់ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ពីព្រោះពួកគាត់ក្រីក្រ ហើយគ្មានរបរផ្សេងរកប្រាក់ចំណូលឡើយ៖ «បើថាដល់យូរថ្ងៃទៅមុខទៀតគិតអីមិនចេញទេ មុខតែងាប់អស់ហើយ ហើយម្ចាស់បន្ទប់គេមិនបានពន្យារឱ្យទេថ្លៃបន្ទប់គេនោះ ដល់ថ្ងៃដឹងតែគេមកទារប្រាក់ពីយើងហើយ សូម្បីតែថ្ងៃធម្មតាលើសតែ៥ថ្ងៃក៏គេគិត៥០បាតដែរ ហើយនៅនេះមានតែកន្លែងនេះឯងថោកជាងគេ។ខ្ញុំអន់ចិត្តណាស់ គេអ្នកមានអំណាចគេរស់នៅស្រួល តែអ្នកក្រដូចខ្ញុំធ្វើការរហេមរហាមនៅស្រុកថៃ ហើយនៅស្រុកខ្មែរអាជ្ញាធរដូចមិនសូវយកចិត្តទុកដាក់ដល់ពលរដ្ឋទេ ខុសពីប្រទេសថៃគេជួយពលរដ្ឋគេ»។ លោកស្រីបន្តថា សព្វថ្ងៃពួកគាត់ជួលបន្ទប់តម្លៃជាង ១ពាន់បាត ឬស្មើជាង ៣០ដុល្លារអាមេរិកស្នាក់នៅរួមគ្នាជាមួយពលករខ្មែរដទៃទៀតដែលអត់ការងារធ្វើដូចគ្នាដើម្បីសន្សំប្រាក់ចាយវាយឱ្យបានយូរថ្ងៃទៅមុខទៀត។

ក្រៅពីពលករអត់ការងារនេះហើយ មានពលករខ្មែរខ្លះទៀត ដែលទើបតែត្រឡប់មកពីពន្យារសុពលភាពទិដ្ឋាការស្នាក់នៅប្រទេសថៃ ដោយពួកគេបានឆ្លងដែនទៅកម្ពុជានោះ ក៏ត្រូវបានថៅកែថៃឱ្យផ្អាកធ្វើការងារមួយរយៈដែរ ដើម្បីទប់ស្កាត់កុំឱ្យឆ្លងជំងឺ រាតត្បាតនេះ។

ពលករខ្មែរធ្វើការរោងចក្រផលិតគ្រឿងអេឡិចត្រូនិកនៅខេត្តអយុធ្យា (Ayuthtaya) លោក ជា សេងអនុជ ឱ្យដឹងថា នៅកន្លែងលោកធ្វើការមានពលករខ្មែរប្រមាណ១០រួមទាំងលោកផង ត្រូវបានថៅកែដាក់ឱ្យក្នុងបន្ទប់ដាច់ដោយឡែកចំនួន១៤ថ្ងៃ ដើម្បីតាមដានសុខភាព៖ «គេឱ្យយើងនៅក្នុងបន្ទប់ដែលយើងធ្លាប់នៅបន្ទប់ជួល គេប្រាក់ថាឱ្យខ្ញុំនៅក្នុងបន្ទប់កុំឱ្យដើរចេញក្រៅ ហើយជំនួយការខ្មែរយើងគេតាមខ្ញុំរាល់ថ្ងៃ។ខ្ញុំអត់ខកចិត្តទេព្រោះរឿងការពារទាំងអស់គ្នា ព្រោះយើងមើលអត់ឃើញមិនដឹងអ្នកណាឆ្លងជំងឺនេះ អីចឹងយើងត្រូវឱ្យគេធ្វើអីចឹងទៅ»។

នៅរសៀលថ្ងៃទី២៤ មីនា នាយករដ្ឋមន្ត្រីថៃលោក ប្រាយុទ្ធ ចាន់អូចា (Prayut Chan-o-cha) បានប្រកាសថា រដ្ឋាភិបាលថៃនឹងប្រើច្បាប់ប្រកាសអាសន្ន នៅថ្ងៃទី២៦ មីនា ដើម្បីទប់ស្កាត់ជំងឺកូវីដ១៩។ ចំណុចសំខាន់ៗ នៃច្បាប់នេះ គឺមានដូចជា តម្រូវឱ្យប្រជាពលរដ្ឋស្នាក់នៅក្នុងផ្ទះមួយរយៈ ឬក៏កំណត់ផ្ទៃដីក្នុងការធ្វើដំណើររបស់ពលរដ្ឋ ហើយប្រសិនបើជនណាល្មើសនឹងត្រូវរងពិន័យ តាមច្បាប់។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ទទួលបន្ទុកផ្នែកពលករ លោក គឹម ចំរើន និងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី២៤ មីនា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

ទោះជាយ៉ាងណា លោក គឹម ចំរើន បានអំពាវនាវដល់ពលករខ្មែរធ្វើការនៅប្រទេសថៃឱ្យអនុវត្តតាមការណែនាំរបស់រដ្ឋាភិបាលថៃ ដើម្បីចូលរួមទប់ស្កាត់ជំងឺកូវិត១៩។ មន្ត្រីរូបនេះបានប្រកាសនៅក្នុងហ្វេសប៊ុកស្ថានទូតខ្មែរនៅទីក្រុងបាងកក កាលពីថ្ងៃទី២៣ មីនាទៀតថា នៅអំឡុងពេលនេះ ប្រសិនបើពលករណាអស់សុពលភាពទិដ្ឋាការស្នាក់នៅប្រទេសថៃ គឺអាចស្នាក់នៅបន្តបានរហូតដល់ស្ថានការណ៍ប្រក្រតីឡើងវិញ ដោយពុំមានការចាប់ចងនោះទេ។ប្រភពដដែលបន្ថែមថា ខាងស្ថានទូតនឹងផ្តល់ព័ត៌មានជូនដល់ពលករទៀតប្រសិនបើមានការជំណឹងថ្មីពីរដ្ឋាភិបាលថៃ។

ប្រធានផ្នែកពលករចំណាកស្រុកនៃអង្គការសិទ្ធិការងារសង់ត្រាល់ លោកឌី ថេហូយ៉ា មានប្រសាសន៍ថា ពលករខ្មែរដែលអត់ការងារធ្វើនៅក្នុងប្រទេសថៃទាំងនោះ អាចប្រឈមនឹងដាច់ស្បៀង ហើយភាគច្រើនជាពលករទៅធ្វើការដោយខ្លួន គឺមិនមែនអ្នកទៅធ្វើការតាមរយៈ អនុស្សរណៈយោគយល់ អិមអូយូ (MOU) រវាងរដ្ឋាភិបាលកម្ពុជានិងថៃ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនមួយចំនួននាំពលករធ្វើការក្នុងប្រទេសមួយនេះ។លោកបន្ថែមថា ពលករដែលទៅធ្វើការតាមរយៈ អឹមអូយូ (MOU) នេះនឹងទទួលបានប្រាក់ខែ ៥០ភាគរយពីខាងក្រុមហ៊ុន ប្រសិនបើពួកគេត្រូវបានផ្អាកពីការងារដោយសារជំងឺកូវីដ១៩៖ «ហើយប្រសិនបើពលករថៃទទួលបាន ៥០ភាគរយនៃពលករដែលអត់មានការងារធ្វើហ្នឹងពលករខ្មែរក៏ត្រូវទទួលបាន៥០ភាគរយដែរ។មួយទៀតត្រូវជានាបាននូវអ្នកដែលធ្វើការងារក្រៅប្រព័ន្ធហ្នឹងឱ្យទទួលបានប្រាក់ចំណូលដូចប្រទេសថៃដែរ ព្រោះកន្លងមកគាត់ក៏ធ្វើការដែរ ប៉ុន្តែគ្រាន់តែថៅកែមួយចំនួនអត់បានធ្វើប័ណ្ណប.ស.សផ្អាក អីចឹងគាត់អត់ទទួលសិទ្ធិទទួលបាន ៥០ភាគរយហ្នឹងទេ ករណីថាបើត្រូវបញ្ឈប់ពីការងារឬអត់មានការងារធ្វើហ្នឹង»។

ទោះជាយ៉ាងណាលោកថា ករណីនេះប្រសិនបើស្ថានការណ៍អូសបន្លាយយូរ គឺរដ្ឋាភិបាលកម្ពុជាគួរតែត្រៀមស្បៀង ដើម្បីផ្គត់ផ្គង់ដល់ពលករទាំងនោះ សម្រាប់ហូបចុកក្នុងពេលដាច់ស្បៀងនៅពេលខាងមុខ។មន្ត្រីសង្គមស៊ីវិលរូបនេះព្រួយបារម្ភថា ប្រសិនបើរដ្ឋាភិបាលមិនដោះស្រាយរឿងនេះទេ អាចនឹងមានពលករមួយចំនួនធំនាំគ្នាត្រឡប់ទៅផ្ទះវិញ ហើយបណ្តាលឱ្យកកស្ទះនៅតំបន់ព្រំដែនកម្ពុជាថៃជាមិនខាន។

របាយការណ៍របស់ក្រសួងការងារបង្ហាញថា ពលករខ្មែរកំពុងធ្វើការប្រទេសថៃមានជាង ១លាន ១ សែននាក់ (១.១០០.០០០)។ ប៉ុន្តែរបាយការណ៍របស់អង្គការសង់ត្រាល់ ឱ្យដឹងថាមានពលករខ្មែរស្របច្បាប់និងខុសច្បាប់ប្រមាណ ២លាននាក់ (២.០០០.០០០) កំពុងធ្វើនៅប្រទេសថៃ៕

# ជប៉ុនកំពុងសម្លឹងមើលទីផ្សារកម្លាំងពលកម្មនៅកម្ពុជា ខណៈប្រទេសនេះគ្រោងទទួលពលករជំនាញថែទាំអគារពីបរទេសជាង ៣ម៉ឺននាក់

http://www.freshnewsasia.com/ 2020-03-26

(ភ្នំពេញ)៖ ប្រទេសជប៉ុនកំពុងសម្លឹងមើលទីផ្សារការងារនៅប្រទេសកម្ពុជា ក៏ដូចជាកម្លាំងពលកម្មទៅធ្វើការនៅក្រៅប្រទេស ខណៈប្រទេសជាមិត្តរបស់កម្ពុជាមួយនេះ មានគម្រោងត្រូវការជ្រើសរើស ពលករជំនាញពីបរទេសលើផ្នែកថែទាំងអគារ សំណង់ដល់ទៅប្រមាណ ៣០,០០០នាក់ នាពេលខាងមុខនេះ។

ការលើកឡើងនេះត្រូវបានធ្វើឡើងក្នុងជំនួបពិភាក្សាការងាររវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជាមួយគណៈប្រតិភូនៃមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) និងសមាគមថែទាំអគារជប៉ុន ដឹកនាំដោយលោក ហ៊ីរ៉ូស៊ី ហូរីហ្គូឈិ (Hiroshi HORIGUCHI) នាយកគ្រប់គ្រងសមាគមថែទាំអគារជប៉ុន នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ នៅទីស្ដីការក្រសួងការងារ។ អ្វីទៅជាការថែទាំអគារ? ការថែទាំអគារ គឺជាកិច្ចការជំនាញចាំបាច់មួយនៅប្រទេសជប៉ុន ក្នុងនោះមានទាំងការថែទាំអនាម័យ បរិស្ថាន ការគ្រប់គ្រងគុណភាព សុវត្ថិភាព សោភ័ណភាពសំណង់ និងកិច្ចការសម្អាតទាំងក្នុងអគារ និងបរិវេណជុំវិញអគារ ដែលមានការគាំទ្រ និងទទួលស្គាល់ពីក្រសួងសំណង់ និងរាជរដ្ឋាភិបាលជប៉ុន រហូតដល់មានការចេញច្បាប់ពិសេសមួយសម្រាប់ប្រទេសជប៉ុនផងដែរ។ បច្ចុប្បន្ន ទីផ្សារការងារនេះកំពុងមានតម្រូវការយ៉ាងខ្លាំងនៅប្រទេសជប៉ុន, នេះបើតាមការឱ្យដឹងរបស់លោក ហ៊ីរ៉ូស៊ី ហូរីហ្គូឈិ។

លោក ហ៊ីរ៉ូស៊ី បានបន្តថា មកដល់ពេលនេះ សមាគមថែទាំអគារជប៉ុនរបស់លោកមានសមាជិកប្រមាណជាង ២,៨០០ក្រុមហ៊ុន និងមានបុគ្គិលធ្វើការជាជនជាតិជប៉ុន និងពលករមកពីបរទេសប្រមាណ ១,០០០,០០០នាក់។ លោកបានបន្ថែមទៀតថា ដោយសារប្រទេសជប៉ុនកំពុងពើបប្រទះនឹងបញ្ហាកំណើនមនុស្សចាស់កើនឡើងខ្ពស់ រីឯកម្លាំងពលកម្មពេញវ័យកំពុងមានកំណើនយឺតនោះ បានធ្វើឱ្យប្រទេសប្រឈមនឹងកង្វះកម្លាំងពលកម្ម ក្នុងនោះការងារលើជំនាញថែទាំអគារនេះក៏អាចនឹងជួបបញ្ហាដូចគ្នាដែរ។ ដូច្នេះហើយបានជាសមាគមរបស់លោក ត្រូវការជ្រើសរើសកម្លាំងពលកម្មពីក្រៅប្រទេសយកទៅបំពេញការងារក្នុងប្រទេសខ្លួន។ បើតាមការវាយតម្លៃរបស់សមាគម ជំនាញថែទាំអគារនេះមានតម្រូវការដល់ទៅប្រមាណ ៩០ម៉ឺននាក់ ក្នុងនោះគេត្រូវការកម្លាំងពលកម្មពីក្រៅប្រទេសប្រមាណ ៣០,០០០នាក់។ លោក ហ៊ីរ៉ូស៊ី បានបញ្ជាក់ទៀតថា កន្លងទៅ សមាគមរបស់លោកបានជ្រើសរើសពលករជំនាញពីប្រទេសមីយ៉ាន់ម៉ា និងប្រទេសហ្វីលីពីន ប៉ុន្តែនៅឆ្នាំបន្ទាប់ទៅនេះ សមាគមរបស់លោកមានបំណងជ្រើសរើសពលករជំនាញពីប្រទេសកម្ពុជាវិញម្ដង។

ការលើកឡើងនេះត្រូវបានលោករដ្ឋមន្ត្រី អ៊ិត សំហេង សម្ដែងការគាំទ្រយ៉ាងខ្លាំង ដោយបានប្រគល់ការងារទៅឱ្យអគ្គនាយកដ្ឋានបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ និងអគ្គនាយកដ្ឋានការងារ ឱ្យសហការជាមួយសមាគមថែទាំអគារជប៉ុនឱ្យបានជិតស្និទ្ធ និងសហការជាមួយក្រុមហ៊ុនភ្នាក់ងារបញ្ជូនពលកររបស់កម្ពុជា ដើម្បីប្រកាសជ្រើសរើស បណ្ដុះបណ្ដាលភាសាជប៉ុន និងជំនាញ ប្រលងតេស្ត និងបញ្ជូនពលករទៅធ្វើការនៅប្រទេសជប៉ុន ។ ចំពោះទីតាំងសម្រាប់ការប្រលងតេស្ត ត្រូវបានលោករដ្ឋមន្ត្រីផ្ដល់ជម្រើសចំនួន ២៖ ទី១. សមាគមអាចយកគ្រឹះស្ថានបណ្ដុះបណ្ដាលណាមួយរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រៀបចំការប្រឡងតេស្ត ក្នុងនោះក្រសួងមានគ្រឹះស្ថានដែលបណ្ដុះបណ្ដាលជំនាញលើផ្នែកសំណង់ អគ្គិសនី រថយន្តចំនួន ៩កន្លែង។ ទី២. សមាគមថែទាំងអគារជប៉ុនអាចសហការជាមួយក្រុមហ៊ុនជ្រើសរើស បណ្ដុះបណ្ដាល និងបញ្ជូនពលករនៅកម្ពុជា ដើម្បីដំណើរការការប្រឡងតេស្តសមត្ថភាព។ លោករដ្ឋមន្ត្រីបានបញ្ជាក់ទៀតថា ចំពោះការងារជាក់ស្ដែងយ៉ាងណានោះ សូមឱ្យសមាគមថែទាំអគារជប៉ុនសហហាការ និងពិភាក្សាជាមួយអគ្គនាយកដ្ឋានបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ

និងអគ្គនាយកដ្ឋានការងាររបស់ក្រសួង និងក្រុមហ៊ុនជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករបន្តទៀត ហើយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងទទួលស្គាល់ជាផ្លូវការតាមក្រោយ។

សូមជម្រាបថា បច្ចុប្បន្នកម្ពុជាបានបញ្ជូនកម្មសិក្សាការី និងពលករជំនាញទៅប្រទេសជប៉ុនប្រមាណជិត ១៥,០០០នាក់ ដែលធ្វើនៅក្នុងវិស័យកសិកម្ម នេសាទ សំណង់ កែច្នៃចំណីអាហារ កាត់ដេរ ថែទាំមនុស្សចាស់ គ្រឿងយន្ត-លោហធាតុ និងវិស័យផ្សេងៗទៀត ប៉ុន្តែបើតាមការស្នើរបស់លោករដ្ឋមន្ត្រី អ៊ិត សំហេង នៅចំពោះមុខគណៈប្រតិភូជប៉ុន គឺសូមឱ្យខាងជប៉ុនបង្កើនការទទួលពលករពីកម្ពុជាឱ្យបាន ១០០,០០០នាក់ សម្រាប់រយៈពេលខាងមុខបន្តទៀត ពីព្រោះកម្ពុជាមានសក្តានុពលយ៉ាងច្រើន ដែលសមាគម ក៏ដូចជាក្រុមហ៊ុននៅប្រទេសជប៉ុនអាចជ្រើសរើសកម្លាំងពលកម្ម ដែលមានប្រភពនៅក្នុងប្រទេសស្រាប់ និងប្រភពដែលត្រលប់ពីក្រៅប្រទេសបន្ទាប់ពីពួកគេចប់កិច្ចសន្យាការងារ៕

## ទូតកម្ពុជានៅកូរ៉េ៖ រដ្ឋាភិបាលកូរ៉េ អនុញ្ញាតឲ្យពលករគំរូ ពន្យារពេលស្នាក់នៅបានដល់៥០ថ្ងៃ, ពលករខ្មែរគ្មានកន្លែងស្នាក់នៅ សូមទាក់ទងមន្ត្រីស្ថានទូត

https://khmerpress.news/ cily sokMarch 26, 2020 at 9:08 am

(កូរ៉េខាងត្បូង)៖ ស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ នៅព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០នេះ បានជូនដំណឹងថ្មីមួយដល់បងប្អូនពលករខ្មែរ ដែលកំពុងស្នាក់នៅប្រទេសកូរ៉េថា ដោយសារតែបញ្ហាការឆ្លងវីរុសកូរ៉ូណា (COVID-19) ក្រសួងការងារនៃសាធារណរដ្ឋកូរ៉េ បានចេញច្បាប់ថ្មី សម្រាប់ពលករគំរូ អាចពន្យារសុពលភាពបន្តស្នាក់ នៅកូរ៉េបានរហូតដល់៥០ថ្ងៃ ពីមុនបានតែជនជាតិថៃ, ចិន, និងវៀតណាមតែប៉ុណ្ណោះ ឥឡូវគឺអាចពន្យាបានទាំង១៦ប្រទេស ដែលបញ្ជូនពលករ មកបម្រើការងារនៅកូរ៉េ រួមទាំងប្រទេសកម្ពុជាផងដែរ។ ស្ថានទូតកូរ៉េបញ្ជាក់ទៀតថា ពលករគំរូដែលចប់៤ឆ្នាំ១០ខែ អាចដាក់ពាក្យស្នើសុំពន្យារការស្នាក់នៅបន្តក្នុងរយៈពេល១ខែ គិតត្រឹមថ្ងៃចាកចេញទៅស្រុកកំណើត។

ជាមួយគ្នានេះ ក្នុងករណីបងប្អូនពលករគ្មានកន្លែងស្នាក់នៅ សូមទំនាក់ទំនងមកមន្ត្រីស្ថានទូតខ្មែរ ប្រចាំសាធារណរដ្ឋកូរ៉េ ដើម្បីដោះស្រាយជូនបងប្អូនឲ្យបានមកស្នាក់ នៅឯផ្ទះស្នាក់នៅបណ្តោះ ដែលមានទីតាំងស្ថិតនៅតំបន់ស៊ូវ៉ុន អានសាន ក្វាងជូធំ និងសាសាងជាដើម៕ ផ្តល់សិទ្ធដោយ៖ Freshnews

## ពលករចំណាកស្រុកចំនួន៦០,០០០នាក់ត្រូវបានជម្លៀស បន្ទាប់ពីថៃប្រកាសបិទប្រទេស

http://ppd-news.net/ ថ្ងៃចេញផ្សាយ: March 26, 2020

**ថៃ ៖** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃបាននិយាយកាលពីថ្ងៃពុធថា ពលករចំណាកស្រុកប្រហែល ៦០,០០០ នាក់ដែលកំពុងរស់នៅក្នុងប្រទេសថៃបានភៀសខ្លួនចេញពីប្រទេស ចាប់តាំងពីអាជ្ញាធរបានបិទផ្សារ និងអាជីវកម្មជាច្រើនកាលពីចុងសប្តាហ៍ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសកូរ៉ូណា។ វិធានការណ៍ចុងក្រោយរបស់ប្រទេសថៃបានធ្វើឲ្យមនុស្សជាច្រើនគ្មានការងារធ្វើ និងជំរុញឲ្យមានការជម្លៀសយ៉ាងច្រើននៃពលករចំណាកស្រុកប្រមាណ ៤ ឬ ៥ លាននាក់របស់ប្រទេសនេះភាគច្រើនមកពីប្រទេសឡាវ មីយ៉ាន់ម៉ា និងប្រទេសកម្ពុជា។ ប្រទេសថៃបានបិទព្រំប្រទល់ដីរបស់ខ្លួន ហើយបានប្រាប់ប្រជាជនឲ្យស្នាក់នៅក្នុងផ្ទះ និងបានបិទអាជីវកម្មភាគច្រើនក្នុងកិច្ចប្រឹងប្រែងដើម្បីទប់ស្កាត់វីរុសនេះ ហើយលោកនាយករដ្ឋមន្ត្រី ប្រាយុទ្ធ ចាន់អូចា ត្រូវបានកំណត់ឲ្យប្រើអំណាចប្រកាសប្រទេសក្នុងភាពអាសន្ននៅថ្ងៃព្រហស្បតិ៍។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃបានប្រាប់រយទ័រថា ពលករចំណាកស្រុកប្រមាណ ៦០,០០០ នាក់មកពីប្រទេសឡាវ កម្ពុជា និងមីយ៉ាន់ម៉ាបានវិលត្រឡប់ទៅផ្ទះវិញ ហើយគិតត្រឹមថ្ងៃអង្គារខណៈដែលប្រទេសថៃបានរាយការណ៍ពីករណីវីរុសចំនួន៩៣៤ករណីដែលជាចំនួនខ្ពស់បំផុតទី២នៅអាស៊ីអាគ្នេយ៍។

ហ្វូងមនុស្សយ៉ាងច្រើនបានប្រមូលផ្តុំគ្នានៅព្រំដែនមីយ៉ាន់ម៉ាដោយកាន់វ៉ាលី និងស្ពាយឥវ៉ាន់នៅលើខ្នងរបស់ពួកគេ ចំពេលមានភាពរឹករវមួយចំនួន ខណៈដែលហ្វូងមនុស្សបានប្រញាប់ប្រញាលទៅកាន់ខ្លោងទ្វារព្រំដែន។

លោក Ye Min មកពីគណៈកម្មាធិការសម្ព័ន្ធភាពជំនួយក្នុងប្រទេសថៃបាននិយាយថា "អាជ្ញាធររដ្ឋកំពុងរៀបចំបញ្ជូនពលករទាំងនោះទៅរដ្ឋ និងតំបន់របស់ពួកគេវិញតាមរថយន្ត ប៉ុន្តែអ្នកខ្លះមិនអាចរង់ចាំ និងព្យាយាមឆ្លងកាត់តាមផ្លូវនោះ"។ លោកបាននិយាយថា មានមនុស្សប្រមាណ ៣ ម៉ឺននាក់បានឆ្លងកាត់ក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះតាមរយៈច្រកជាច្រើន។ ដោយដកស្រង់កំណត់ត្រាផ្លូវការសមាជិកសភានៅប្រទេសមីយ៉ាន់ម៉ាលោ Thant Zin Aung បាននិយាយថា ចំនួនអ្នកដែលបានឆ្លងកាត់ច្រកតែមួយគឺមានចំនួន ១៨,០០០ នាក់ដោយមានចំនួនប្រហាក់ប្រហែលនឹងច្រក ៣ ផ្សេងទៀត។

ប្រទេសមីយ៉ាន់ម៉ាបានរាយការណ៍ពីករណីទី ៣ នៃការឆ្លងវីរុសនេះនៅព្រឹកថ្ងៃពុធទៅលើបុរសអាយុ ២៦ ឆ្នាំម្នាក់ដែលបានហោះពីចក្រភពអង់គ្លេសតាមរយៈទីក្រុងបាងកក។ ពលករដែលត្រូវបានបញ្ជូនត្រឡប់មកវិញត្រូវទទួលការត្រួតពិនិត្យសុខភាព ហើយត្រូវបានបញ្ជាឲ្យរស់នៅផ្តាច់ខ្លួននៅតាមភូមិទូទាំងប្រទេសរយៈពេល ១៤ ថ្ងៃ។ យោងតាមការរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានឲ្យដឹងថា យ៉ាងហោចណាស់មានមនុស្សចំនួន ១១ នាក់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដោយមានអាការៈគ្រុនក្តៅខ្លាំង ហើយពលករមួយចំនួនធំក៏បានឆ្លងចូលប្រទេសកម្ពុជា និងឡាវផងដែរ៕

## ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២០

### សម្តេច ស ខេង៖ ត្រូវចាត់ទុកភូមិណាមានពលករខ្មែរមកពីថៃម្នាក់ក្តីជាគោលដៅក្តៅ និងតាមដានជានិច្ច

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១០:៣៦ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបញ្ជាក់ថា ថ្នាក់ដឹកនាំខេត្តទាំងអស់នៅទូទាំងប្រទេស ត្រូវចាត់ទុកភូមិណាមួយដែលមានពលរដ្ឋខ្មែរមកពីថៃម្នាក់ក្តី គឺជាគោលដៅក្តៅ ហើយត្រូវតាមដានជាប្រចាំចំពោះសុខភាព ចៀងវាង ការរីករាលដាលជំងឺកូវីដ១៩ នៅក្នុងភូមិ ។ មានប្រសាសន៍ក្នុងកិច្ចប្រជុំផ្សព្វផ្សាយ អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនានេះស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តការណ៍ចំពោះអំពើល្មើស និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នាព្រឹកថ្ងៃទី២៧ ខែមីនា នៅទីស្តីការក្រសួង ។

សម្តេច ស ខេង បានឲ្យដឹងថា គិតត្រឹមថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ មានពលករខ្មែរមកពីថៃមានចំនួន ៤៣០៧៤នាក់ ។ សម្តេចក៏បានលើកឡើងថា ទោះបីជាភាគីថៃប្រកាសបិទច្រកព្រំដែនជាមួយកម្ពុជាក៏នៅមានពលករខ្មែរចូលពីថៃមកកម្ពុជាតាមច្រករបៀងតូចៗផងដែរ ។ ចំណុចនេះសមត្ថកិច្ចកម្ពុជាត្រូវធ្វើការសហការជាមួយភាគីថៃ ដើម្បីសម្រួលឲ្យពួកគាត់បានចូលតាមច្រកព្រំដែន អន្តរជាតិ ដើម្បីអាចពិនិត្យសុខភាពគាត់បាន ។ ព្រោះថាបើកអ្នកវិភាគសិក្សាស្រាវជ្រាវវៀតណាមបានឲ្យដឹងថា អ្នកមានជំងឺកូវីដ១៩នេះអាចចម្លងបានមនុស្ស៥នាក់ ។ សម្តេចបន្តថា ការឆ្លងនេះនៅប្រទេសវៀតណាម គ្រាន់តែក្នុងភូមិមួយមានអ្នកឆ្លងតែម្នាក់បានចម្លងទៅមនុស្សប្រាំនាក់ហេតុដល់វៀតណាមសម្រេចបិទភូមិរបស់ខ្លួនតែម្តង ។ សម្តេចបញ្ជាក់ថា ៖«អីញ្ចឹងចំណុចនេះ ត្រូវចាត់ទុកភូមិណាមួយ ដែលមានពលករមកពីថៃម្នាក់ជាគោលដៅក្តៅ ហើយតាមដានជាសុខភាពជានិច្ច ដើម្បីចៀងវាងការឆ្លងទៅផ្សេងទៀត ។ ហើយបើករណីសង្ស័យត្រូវបញ្ជូនទៅមន្ទីពេទ្យបង្អែកស្រុក ឬ ខេត្ត ដើម្បីធ្វើការព្យាបាល» ៕

## សម្តេច ស ខេង៖ ពលករខ្មែរដែលបានចាកចេញពីប្រទេសថៃមានចំនួនប្រមាណ២១០០០នាក់

http://ppd-news.net/ ថ្ងៃចេញផ្សាយៈ March 26, 2020

**ខេត្តបាត់ដំបង ៖** ថ្លែងក្រោយបញ្ចប់ពីការជួបសំណេះសំណាលជាមួយមន្ត្រីរាជការ នៅឯខេត្តបាត់ដំបង នារសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ កាលពីម្សិលមិញនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានបញ្ជាក់ប្រាប់ដល់ក្រុមអ្នកសារព័ត៌មានថា តាមតួលេខដែលសម្តេច ទទួលបានពីអគ្គស្នងការនគរបាលជាតិ ចំនួនពលករខ្មែរដែលចាកចេញពីប្រទេសថៃ ក្រោយប្រទេសមួយនេះ បានប្រកាសបិទច្រកព្រំដែនជាបណ្តោះអាសន្នជាមួយកម្ពុជា មានចំនួន២១០០០នាក់។ ជាមួយគ្នានេះ សម្តេច ក៏បានណែនាំឲ្យអភិបាលរាជធានី-ខេត្តទាំង២៥ ត្រូវស្រង់បញ្ជីចំនួនពលករត្រឡប់មកពីប្រទេសថៃអោយបានច្បាស់លាស់។ សម្តេចក្រឡាហោម ស ខេង ក៏បានថ្លែងបញ្ជាក់ផងដែរថា ប្រសិនបើចំនួនអ្នកឆ្លងជម្ងឺកូវីដ-១៩ "COVID-១៩" នូវតែបន្តកើនឡើង ជៀសមិនផុតពីការដាក់ប្រទេសកម្ពុជា ក្នុងគ្រាអាសន្ននោះទេ៕ដោយ ៖ ហេង ឡុង

## សម្តេច ស ខេង បញ្ជាឲ្យអាជ្ញាធរ ចុះពិនិត្យពលរដ្ឋទើបមកពីក្រៅប្រទេស និងស្នើឲ្យពួកគាត់ នៅដាច់ដោយឡែក ១៤ថ្ងៃ

https://dap-news.com/ ByVNT108 Posted on March 26, 2020

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាឲ្យ អាជ្ញាធរចុះស្រាវជ្រាវ កំណត់អត្តសញ្ញាណ ប្រជាពលរដ្ឋទើបមកពីក្រៅប្រទេស ហើយស្នើសុំពួកគាត់ នៅដោយឡែក រយៈពេល១៤ថ្ងៃ ដើម្បីតាមដានសុខភាព ។ ក្នុងជំនួបសំណេះសំណាល ដោយផ្ទាល់ជាមួយមន្ត្រីនៃអង្គភាព និងស្ថាប័ននានា ដែលកំពុងបំពេញភារកិច្ច នៅតាមបណ្តាច្រកទ្វារព្រំដែន កម្ពុជា-ថៃ នៅខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ សម្តេច ស ខេង បានថ្លែងថា នៅតែមានពលរដ្ឋខ្មែរពីប្រទេសថៃ ឡាវ និងវៀតណាម ធ្វើដំណើរចូលមកប្រទេស ជាបន្តបន្ទាប់ ហើយដាច់ខាត មិនអាចបដិសេធមិនឲ្យពលរដ្ឋខ្មែរ វិលចូលប្រទេសបានឡើយ។ សម្តេច មានប្រសាសន៍ថា "សម្រាប់ពលរដ្ឋ ដែលបានវិលទៅដល់ភូមិកំណើតហើយនោះ អាជ្ញាធរភូមិឃុំ បានចុះស្រាវជ្រាវកំណត់អត្តសញ្ញាណពួកគាត់ និងបានស្នើសុំនៅដោយឡែក ដើម្បីតាមដានសុខភាព"។ សម្តេចបន្ថែមថា សម្រាប់ប្រជាពលរដ្ឋ ដែលមានការសង្ស័យ រាជរដ្ឋាភិបាល គ្មានជម្រើសអ្វី ក្រៅតែពីការនាំពួកគាត់ យកទៅដាក់ឱ្យនៅដាច់ដោយឡែក ដើម្បីតាមដាន និងពិនិត្យព្យាបាលឡើយ ហើយថា សម្រាប់ការដោះស្រាយបញ្ហានេះ ក្រៅតែពីមន្ទីរពេទ្យរដ្ឋ ដែលមានស្រាប់ រាជរដ្ឋាភិបាលបានចាត់តាំង ឱ្យអភិបាលខេត្តនានា រៀបចំទីកន្លែង សម្រាប់ការស្នាក់នៅដោយឡែក និងការពិនិត្យព្យាបាលជំងឺ ជូនពលរដ្ឋរួចនៅតាមទីរួមខេត្តនីមួយៗ ដោយយកអគារសាលារៀន មជ្ឈមណ្ឌលរដ្ឋ និងសណ្ឋាគារមួយចំនួន។

ឆ្លៀតឱកាសនោះដែរ សម្តេចក្រឡាហោម ស ខេង បញ្ជាក់ជាថ្មីថា ពលរដ្ឋខ្មែរនៅក្រៅប្រទេស សម្រុកចូលកម្ពុជាវិញ ដោយសារអាជ្ញាធរថៃ បានសម្រេចបិទការដ្ឋានការងារមួយចំនួនផង ពួកគាត់មានការភ័យខ្លាចផង ក៏សម្រុកវិលមកវិញ។ ជាមួយគ្នានេះ សម្តេច បន្តថា គោលការណ៍សហប្រតិបត្តិការរវាងកម្ពុជា និងថៃ មិនមានការប្រែប្រួលនោះទេ ពោលគឺអ្វីដែលបានកើតឡើងនេះ គឺដោយសារគ្រាអាសន្ន ប្រឈមនឹងជំងឺកូវីដ១៩ ដែលទាមទារឱ្យភាគីទាំងសងខាង មានការយោគយល់ឱ្យគ្នាទៅវិញទៅមក ដើម្បីជានាការពារ ផលប្រយោជន៍ប្រជាជន និងប្រទេសទាំងពីរ។ នាឱកាស នោះដែរ សម្តេច ក្រឡា ហោម ស ខេង ក៏បានបន្តជួបមន្ត្រីប៉ុស្តិ៍នគរបាល ច្រកទ្វារអន្តរជាតិអូរស្មាច់ ដោយ សម្តេច ណែនាំឲ្យរដ្ឋបាលខេត្ត ត្រូវត្រៀមមន្ត្រីពាក់ព័ន្ធ នៅតាមបណ្តាច្រករបៀងមួយចំនួន ដើម្បីធានាថា ប្រសិនពលរដ្ឋខ្លះ ងាកទៅឆ្លងដែនតាមច្រករបៀង គឺអាចគ្រប់គ្រងពួកគាត់បាន ទាំងការកំណត់អត្តសញ្ញាណ និងការពិនិត្យសុខភាព ។ សម្តេច បន្តថា រហូតដល់ពេលនេះ អាជ្ញាធរមូលដ្ឋានទូទាំងប្រទេស បានក្តាប់

ចំនួនប្រជាពលរដ្ឋ វិលពីប្រទេសថៃ ទៅដល់ស្រុកកំណើត មានប្រមាណជាង៤ម៉ឺននាក់ ។ សម្តេច បានមានប្រសាសន៍ថា "ការក្តាប់វត្តមានពួកគាត់ មានសារសំខាន់ណាស់ ដូច្នេះអភិបាលរាជធានីខេត្តទាំងអស់ ត្រូវយកចិត្តទុកដាក់ ឃោសនាអប់រំផ្សព្វផ្សាយ នៅចំណុចក្តៅៗ នៃបញ្ហានេះដល់ប្រជាពលរដ្ឋ ពិសេសការនៅជួបជុំគ្នា"៕ ដោយ៖ អេង ប៊ូ ឆេង

## សម្តេច ស ខេង៖ គិតមកដល់ថ្ងៃនេះប្រជាជនខ្មែរ បានវិលត្រលប់មកប្រទេសថៃ ប្រមាណជាង៤0000នាក់

https://www.fastnewsdaily.com/ ចេញផ្សាយ ថ្ងៃទី26 ខែMarch ឆ្នាំ2020

**(ឧត្តរមានជ័យ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០នេះ អាជ្ញាធរមូលដ្ឋានទូទាំងប្រទេស បានក្តាប់ចំនួនប្រជាពលរដ្ឋវិលពីប្រទេសថៃ ទៅដល់ស្រុកកំណើតមានប្រមាណជាង ៤ម៉ឺននាក់។ ការបញ្ជាក់ឱ្យដឹងបែបនេះរបស់សម្តេចក្រឡាហោម ស ខេង បានធ្វើឡើងនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០នេះ នៅក្នុងឱកាសដែលសម្តេច បានអញ្ជើញជួបសំណេះសំណាលដោយផ្ទាល់ ជាមួយមន្ត្រីនៃអង្គភាព និងស្ថាប័ននានា ដែលកំពុងបំពេញភារកិច្ចនៅតាមបណ្តាច្រកទ្វារព្រំដែនកម្ពុជា-ថៃ ស្ថិតក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ដែលពិធីជួបសំណេះសំណាលនេះ បានប្រារព្ធឡើងនៅប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិអូរស្មាច់។ សម្តេចក្រឡាហោម ស ខេង បានបន្តថា ក្នុងស្ថានភាពប្រឈមនឹងការរីករាលដំងឺនេះ មានពលរដ្ឋខ្មែរយើងមួយចំនួន បានសំរុកវិលត្រឡប់ពីប្រទេសថៃ មកប្រទេសកម្ពុជាវិញ ដូច្នេះ មន្ត្រីច្រកទ្វារព្រំដែនទាំងអស់ ត្រូវត្រៀមលក្ខណៈទទួលស្វាគមន៍ប្រជាពលរដ្ឋ ឱ្យបានល្អជាបន្តទៀត និងត្រូវមានវិធានការម៉ឺងម៉ាត់តាមក្បួនសុខាភិបាល។

សម្តេចក្រឡាហោម ស ខេង បានបន្ថែមថា អាជ្ញាធរខេត្តឧត្តរមានជ័យ ក៏ត្រូវស្នើសុំកិច្ចសហការជាមួយភាគីថៃ ដើម្បីកំណត់ដាក់លាក់ នូវច្រកអនុញ្ញាត ឱ្យពលរដ្ឋឆ្លងដែនវិលចូលប្រទេសដែរ។ យ៉ាងណាក៏ដោយសម្តេចក្រឡាហោម ក៏បានណែនាំឱ្យរដ្ឋបាលខេត្តត្រូវត្រៀមមន្ត្រីពាក់ព័ន្ធ នៅតាមបណ្តាច្រករបៀងមួយចំនួនដែរ ដើម្បីធានាថាប្រសិនពលរដ្ឋខ្លះងាកទៅឆ្លងដែនតាមច្រករបៀង គឺយើងអាចគ្រប់គ្រងពួកគាត់បាន ទាំងការកំណត់អត្តសញ្ញាណ និងការពិនិត្យសុខភាព ហើយតំណាលគ្នានេះ ក៏ត្រូវបន្តជំរុញការផ្សព្វផ្សាយអប់រំ ពួកគាត់ឱ្យបានដឹងពីសារៈសំខាន់ នៃការដាក់ឱ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃសិន ពេលធ្វើដំណើរទៅស្រុកកំណើត ដើម្បីទប់ស្កាត់ការឆ្លងជំងឺនេះដល់ក្រុមគ្រួសារសាច់ញាតិ និងអ្នកភូមិ។

បើតាមការបញ្ជាក់ពីអភិបាលឧត្តមមានជ័យឱ្យដឹងថា ប្រជាពលរដ្ឋ ដែលបានឆ្លងដែនពីប្រទេសថៃ ចូលប្រទេសវិញ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែមីនា គិតត្រឹមម៉ោង៤និង៣០នាទីរសៀល មានជាង១២០០នាក់ ក្នុងនោះជាង៤០០នាក់ គឺជាប្រជាពលរដ្ឋខេត្តឧត្តរមានជ័យ ហើយភាគច្រើន អាជ្ញាធរបានក្តាប់អត្តសញ្ញាណបាន ។ ដោយឡែកអាជ្ញាធរខេត្ត ក៏បានរៀបចំទីតាំងសម្រាប់ដាក់ឱ្យនៅដោយឡែកសម្រាប់ប្រជាពលរដ្ឋមានការសង្ស័យ រួមមានមន្ទីរពេទ្យបង្អែក ផ្ទះសំណាក់ វិទ្យាល័យ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។ ជាមួយគ្នានេះគណៈបញ្ជាការឯកភាពរដ្ឋបាលបានចុះអប់រំផ្សព្វផ្សាយណែនាំដល់គ្រប់ភូមិទូទាំងខេត្តឧត្តរមានជ័យដែរ៕

## ប្រមូលសំណាកពលករមកពីប្រទេសថៃជាង១០០នាក់ទៅពិនិត្យឃើញអវិជ្ជមាន

http://www.rasmeinews.com/ March 26, 2020, 7:49 PM

ដោយៈគ្រញូង/បាត់ដំបងៈ ពលករខ្មែរជាង១០០នាក់ ដែលទើបវិលត្រឡប់ពីប្រទេសថៃមកស្រុកកំណើត ហើយស្ម័គ្រចិត្តទៅរស់នៅប្រមូលផ្តុំ ត្រូវបានក្រុមគ្រូពេទ្យយកសំណាកទៅពិនិត្យនៅវិទ្យាស្ថានប៉ាស្ទ័រគឺលទ្ធផលអវិជ្ជមានទាំងអស់។ ដោយឡែកនៅក្នុងខេត្តបាត់ដំបងក៏មានអ្នកផ្ទុកនូវមេរោគប្រភេទcovit19សរុបចំនួន៨នាក់។ ប៉ុន្តែថ្មីៗនេះត្រូវបានក្រុមគ្រូពេទ្យជំនាញជួយព្យាបាលឱ្យជាសះស្បើយចំនួន២នាក់។ដូច្នេះនៅសល់តែ៦នាក់ទៀតដែលកំពុងសម្រាកព្យាបាលបន្តនៅក្នុងមន្ទីរពេទ្យបង្អែកខេត្ត ។

លោក ងួន រតនៈ អភិបាលខេត្ត និងជាប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺcovit19 ព្រមទាំងអនុប្រធាន និងសមាជិកបានចុះពិនិត្យទីតាំងសម្រាប់ដាក់អ្នកផ្ទុកនិងទីតាំងសម្រាប់ពិគ្រោះនិងពិនិត្យដោយយកវិទ្យាល័យមុនីវង្សមាន៣០បន្ទប់និងសណ្ឋាគារផាកនិងស្ត្រីងផាកមាន១៥០បន្ទប់ ។

នៅព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ លោកឱសថបណ្ឌិត រឿង ប៊ុនរ៉េត ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបងបានបញ្ជាក់តាមរយៈទូរស័ព្ទថាកន្លងមកនៅទូទាំងខេត្តគឺមានអ្នកផ្ទុកមេរោគកូវីដ១៩សរុប៨នាក់តែប៉ុណ្ណោះ។ បច្ចុប្បន្នមាន២ នាក់ បានជាសះស្បើយហើយបានអនុញ្ញាតឱ្យវិលត្រឡប់ទៅផ្ទះវិញហើយ។ លោកប្រធានមន្ទីរក៏បានផ្តាំផ្ញើតាមរយៈសារព័ត៌មានថា សូមបងប្អូនប្រជាពលរដ្ឋទាំងអស់កុំដាក់ការសង្ស័យទៅលើជំងឺកូវីដ១៩ ទាំងស្រុងពេកនៅពេលដែលមានជំងឺឈឺថ្កាត់អ្វីមួយត្រូវទៅទៅពិគ្រោះយោបល់និងពិនិត្យ ព្យាបាលនូវជំងឺ ដែល យើង ឈឺ នោះ សិន ព្រោះ ជួនកាល វា មិន មែន ជា រោគសញ្ញា ឆ្លង៕S/

## អាជ្ញាធរថាៈការគ្រប់គ្រង់បានហ្មត់ចត់រួចហើយលើពលករនិងពលរដ្ឋពីការបង្ការមេរោគកូវីត១៩

http://www.rasmeinews.com/ March 26, 2020, 7:44 PM

ដោយៈភ្នំស្វាយ/បន្ទាយមានជ័យៈ អាជ្ញាធរដែនដី និងមន្ត្រីមានសមត្ថកិច្ចថា ការគ្រប់គ្រង់ត្រួតពិនិត្យបានហ្មត់ចត់ហើយលើពលករនិងពលរដ្ឋពីការបង្ការការរីករាលដាលមេរោគកូវីត១៩ ។

លោកអ៊ុំរាត្រីអភិបាលខេត្ត និងជាប្រធានគណៈកម្មការខេត្តបង្ការទប់ស្កាត់ការរីករាលដាលមេរោគកូវីត១៩ ខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី២៦ខែមីនា ឆ្នាំ២០២០។ លោកបានជម្រាបជូនគណៈប្រតិភូជាន់ខ្ពស់ក្រសួងមហាផ្ទៃនិងជាប្រធានគណកម្មការនេះថ្នាក់ជាតិដឹកនាំដោយសម្តេចក្រឡាហោមស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃកាលពីថ្ងៃទី២៦ ខែមីនាឆ្នាំ២០២០។ ខណៈចុះសួរសុខទុក្ខមន្ត្រីអាជ្ញាធរកងកម្លាំងតាមបណ្តោយព្រំដែនកម្ពុជាថៃក្នុងខេត្តបន្ទាយមានជ័យដែលធ្វើក្នុងនៅស្នាក់ការនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។ លោក អ៊ុំ រាត្រី បានបន្តថាៈក្នុងខេត្តនេះមានពលករខ្មែរពិសេសពលករដែលធ្វើការនៅប្រទេសថៃបង្ខំចិត្តខ្លួនឯងវិលត្រឡប់មកស្រុកកំណើតវិញ។ខណៈពេលការផ្ទុះឡើងនិងរីករាលដាសាកលក្នុងនិងក្រៅប្រទេសនិងការបិទព្រំដែន។ លោកបានបន្តថាៈគិតត្រឹមថ្ងៃទី២៥ ខែមីនាក្នុងខេត្តបន្ទាយមានជ័យបានទួលពលករខ្មែរត្រឡប់ពីថៃចំនួន៩.២៩៦នាក់ / ស្រី៤.៥៥៣នាក់ ។

ក្នុងនោះមន្ត្រីអាជ្ញាធរដែនដីមន្ត្រីនគរបាលអន្តោប្រវេសន៍កងកម្លាំងមន្ត្រីចត្តាឡីស័កមន្ត្រីសុខាភិបាលនិងគ្រូពេទ្យបានចុះស្រង់ទិន្ន័យគ្រប់គ្រង ត្រួតពិនិត្យតាមដានសុខភាពបាញ់កំដៅក្នុងខ្លួនរកការចម្លងមេរោគកូវីត១៩បានចំនួន៥.៣៤៣នាក់។ នៅសល់ពីនោះមន្ត្រីបាននឹងសកម្មចុះធ្វើការងារបន្តមានសមត្ថកិច្ចរាជរដ្ឋាភិបាលកម្ពុជាតាមរយៈគណៈកម្មការណែនាំឱ្យបង្កើនការគ្រប់គ្រង់ត្រួតពិនិត្យហ្មត់ចត់លើពលករ និងពលរដ្ឋ ដើម្បីបង្ការការពារការរីករាលដាលមេរោគកូវីត១៩ ។

សម្តេចក្រឡាហោមសខេងឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការនេះថ្នាក់ជាតិមានប្រសាសន៍ថ្លែងអំណរគុណនិងលើកទឹកចិត្តដល់មន្ត្រីអាជ្ញាធរកងកម្លាំងមន្ត្រីសុខាភិបាល និងគ្រូពេទ្យដែលបានខិតខំទ្រាលការងារសន្តិសុខសណ្តាប់ធ្នាប់ សេដ្ឋកិច្ចសង្គម ។ ចុងក្រោយនេះ លើការងារគ្រប់គ្រង់ ត្រួតពិនិត្យ ថែទាំសុខភាពពលរដ្ឋនិងពិសេសពលករក្នុងការប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីត១៩ ។

ក្នុងនោះ ពលករខ្មែរត្រឡប់ពីធ្វើការនៅប្រទេសថៃ ដែលវិលត្រឡប់មកកម្ពុជាវិញ មាន៣៥.០០០នាក់ហើយត្រឹមថ្ងៃទី២៥ ខែមីនា។ រំពឹងថា នឹងមានពលករវិលមកបន្ថែមទៀតក្រោយបិទព្រំដែននេះ ព្រោះជំងឺកូវីត១៩បាននឹងរាល់ដាលខ្លាំងនៅប្រទេសថៃ និងម្យ៉ាងកន្លែងធ្វើការរបស់ពលករខ្មែរយើងនៅទីនោះ ក៏ត្រូវបានបិទ។ នាឱកាសនោះខុទ្ទកាល័យសម្តេចក្រឡាហោមបានរៀបចំថវិកាសម្ភារនិងគ្រឿងឧបភោគបរិភោគជូនមន្ត្រីរាជការកងកម្លាំងនៅតាមច្រកព្រំដែនបណ្តោយព្រំដែននិងភូមិសាស្ត្រជាប់ព្រំដែនប្រមាណ១០អង្គភាពផងដែរ ៕ទ/

## ពលករ១៨០នាក់ត្រូវរស់នៅដាច់ដោយឡែក១៤ថ្ងៃ ដើម្បីតាមដានរកវីរុសកូវីដ១៩

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១៦:៤៤ យ៉ាន់ ចាន់ថេត

ខេត្តកំពង់ចាម ៖ បើតាមសេចក្តីរាយការណ៍បឋមបានឱ្យដឹងថា នៅក្នុងកិច្ចប្រជុំប្រយុទ្ធប្រឆាំងនឹងជំងឺ Covid-19 ដោយបានធ្វើឡើងនៅសាលាស្រុកបាធាយ នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ក្នុងនោះអាជ្ញាធរខេត្តបានឱ្យកម្លាំងប៉ុស្តិ៍រដ្ឋបាលនៅមូលដ្ឋានត្រូវសហការជាមួយមេឃុំ ដើម្បីធ្វើការតាមដានពលករចំនួន១៨០នាក់ដែលទើបនឹងត្រឡប់មកពីធ្វើការនៅបរទេស ។ ពោលគឺឲ្យរស់នៅដាច់ដោយឡែកពីសមាជិកក្រុមគ្រួសារ ដើម្បីតាមដានរកមើលអ្នកផ្ទុក Covid-19។

លោក ផេន សុផល អភិបាល ស្រុកបាធាយ បានលើកឡើងថា ដោយអនុវត្តតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នឹងប្រសាសន៍ណែនាំពីលោក អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ស្រុកបានខិតខំធ្វើការប្រជុំផ្សព្វផ្សាយ និងតាមដានស្រង់ស្ថិតិប្រជាពលរដ្ឋចំណូលស្រុកទាំងក្នុងប្រទេសនិងក្រៅប្រទេស ជាប់ជាប្រចាំ ជាក់ស្តែងគិតមកត្រឹមថ្ងៃទី២៥ មីនា ចំណូលស្រុកសរុបមានចំនួន២២៥នាក់ ក្នុងនោះចំណូលស្រុកក្នុងប្រទេសមានចំនួន៤៥នាក់ និងចំណូលស្រុកមកពីក្រៅប្រទេសមានចំនួន១៨០នាក់ ។ ប៉ុន្តែមិនទាន់មានមុខសញ្ញាសង្ស័យណាមួយនៅឡើយទេ។

លោក កែវ នាឬទ្ធិ អភិបល រងខេត្តមានប្រសាសន៍ឲ្យដឹងថា ប្រសិនណាបើមានការសង្ស័យទៅលើពលករចំណូលស្រុកមកពីបរទេសណាម្នាក់ ត្រូវតែយកចេញពីសហគមន៍មកកាន់មណ្ឌលសុខភាព ឬក៏មន្ទីរពេទ្យបង្អែកស្រុក ដោយដាក់នៅដាច់ដោយឡែកពីគេ ដើម្បីចៀសវាងកុំឲ្យមានការចម្លងជំងឺ។ ជាមួយនោះដែរ មន្ត្រីឃុំ និងមន្ត្រីបម្រើការងារនៅតាមមណ្ឌលសុខភាព ត្រូវតែបង្កើនការប្រុងប្រយ័ត្នត្រូវពាក់ម៉ាសការពារ ដើម្បីកុំឱ្យឆ្លងជំងឺCovid-19 ប្រយោជន៍ជៀសវាងកុំឲ្យឆ្លងនៅក្នុងសហគមន៍។ លោកកែវ នាឬទ្ធិ អភិបាលរងខេត្ត មានប្រសាសន៍បន្តឲ្យដឹងទៀតថា ដោយសារតែកត្តាអាកាសធាតុនៅតំបន់អាស៊ីអាគ្នេយ៍ក្តៅ ហើយមេរោគនេះឆាប់ងាប់ តែក៏មិនត្រូវធ្វេសប្រហែសដែរ បើតំបន់ត្រជាក់នៅអឺរ៉ុបវិញ មេរោគនេះរស់នៅបានជាច្រើនម៉ោង។ ហើយដោយទទួលបានការណែនាំពីសំណាក់លោកអភិបាលខេត្ត អាជ្ញាធរមូលដ្ឋាន រួមនឹងប៉ុស្តិ៍រដ្ឋបាលទាំង១២ឃុំ ត្រូវបន្តសកម្មភាពចុះអប់រំផ្សព្វផ្សាយពីវិធានការការពាប្រយុទ្ធប្រឆាំងនឹងជំងឺ Covid-19 ក្នុងនោះត្រូវណែនាំដល់ពលករទាំង១៨០នាក់ ដែលត្រឡប់មកពីធ្វើការនៅបរទេសធ្វើយ៉ាងណាឧស្សាហ៍លាងដៃនឹងសាប៊ូ ឬជែល និងពាក់ម៉ាស់ ដើម្បីការពារខ្លួនឯងនិងអ្នកដទៃ។

ជាមួយនោះ តាមរយៈការចាក់ស្ពតជាសំឡេង អប់រំដោយបានធ្វើឡើងគ្រប់ឃុំនៅក្នុងស្រុកបាធាយ ហើយប្រជាពលរដ្ឋកាន់តែមានការយល់ដឹងច្រើនឡើងៗ។ សព្វថ្ងៃបើក្រឡេកទៅមើលប្រទេសអ៊ីតាលី ប្រជាពលរដ្ឋ

បាត់បង់ជីវិតច្រើន ដោយសារតែពលរដ្ឋរបស់ខ្លួនមិនគោរពតាមការណែនាំរបស់អាជ្ញាធរដូចជា មានការបំពានជួបជុំគ្នាផឹកស៊ីជាដើម ចំណែកនៅសហរដ្ឋអាមេរិកវិញ ក៏មានអត្រាការឆ្លងជំងឺ Covid-19 ច្រើន និងបណ្ដាលឱ្យបាត់បង់ជីវិតជាបន្តបន្ទាប់ ហើយមេរោគនេះបន្សុំខ្លួនទៅនឹងអាកាសធាតុត្រជាក់ដោយរស់នៅបានជាច្រើនម៉ោងថែមទៀត។ លោកអភិបាលរងខេត្តបានបញ្ជាក់ទៀតថា ប្រសិនណាបើមានប្រជាពលរដ្ឋរស់នៅតាមភូមិ-ឃុំណាមួយក្នុងស្រុកបាធាយ មានបញ្ហាសុខភាពមិនស្រួលត្រូវប្រញាប់មកកាន់មណ្ឌលសុខភាព ដែលអាចនឹងត្រូវបញ្ជូនបន្តមកសង្គ្រោះនៅមន្ទីរពេទ្យបង្អែកស្រុក ។សព្វថ្ងៃម៉ាសលក់នៅលើទីផ្សារថ្លៃហើយ ប្រសិនបើយើងមិនមានម៉ាសប្រើអាចប្រើក្រមាខ្មែរជំនួសក៏បានដែរ។ រូបលោកសូមស្នើសុំឲ្យលោកវរសេនីយ៍ឯក សំ ណាល អធិការនគរបាលស្រុកបាធាយ ត្រូវតាមដានពិនិត្យមើលនាយប៉ុស្តិ៍រដ្ឋបាលទាំង១២ឃុំ ត្រូវរួមសហការជាមួយលោកមេភូមិមេឃុំ ដោយចុះអប់រំពលករដែលមកពីបរទេស មិនឲ្យមានការជួបជុំគ្នាផឹកស៊ី ដើម្បីបញ្ចៀសកុំឲ្យមានការឆ្លងជំងឺនៅក្នុងសហគមន៍។ ដោយឡែកសហជីពវិញ ក៏បានចូលរួមផ្សព្វផ្សាយអប់រំទៅដល់កម្មករ កម្មការិនីបម្រើការងារនៅតាមរោងចក្រនៅក្នុងស្រុកបាធាយ បានគ្រប់កន្លែង ប្រសិនណាបើយើងសហការគ្នាធ្វើបានល្អយ៉ាងម៉ត់ចត់រំពឹងថា នៅក្នុងខែមេសាខាងមុខនេះ នឹងកាត់បន្ថយជំងឺ Covid-19 ឲ្យមានការថមថយ។ ហើយការិយាល័យសុខាភិបាលស្រុកបាធាយ ត្រូវតែដោះស្រាយជាបន្ទាន់ដោយទិញអាកុល ឬជែល មកប្រើប្រាស់នៅតាមការិយាល័យ និងដាក់នៅតាមមណ្ឌលសុខភាពដើម្បីឲ្យប្រជាពលរដ្ឋមករកសេវាសុខាភិបាល បានប្រើលាងដៃសម្លាតសម្លាប់មេរោគ ហើយសូមឱ្យអាជ្ញាធរភូមិ-ឃុំ-ស្រុក រួមទាំងខេត្ត ត្រូវសហការគ្នាឲ្យបានល្អប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ៕ (កែសម្រួលដោយ ៖ បុប្ផា)

## ស្ថានទូតកម្ពុជា៖ ក្នុងពេលដាក់ប្រទេសក្នុងភាពអាសន្ន ថៃអនុញ្ញាតឱ្យពលករខ្មែរស្នាក់នៅលើសពេលកំណត់

http://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ: 26/03/2020 - 12:50 ដោយ៖វណ្ណ សុគន្ធា

នៅថ្ងៃទី២៦ ខែមីនានេះ ថៃបានដាក់ប្រទេសក្នុងភាពអាសន្នដោយសារតែការរាលដាលរបស់ជំងឺកូវីដ-១៩។ ការដាក់ប្រទេសក្នុងភាពអាសន្ននេះ ថៃមិនអនុញ្ញាតឱ្យមានការឆ្លងកាត់ព្រំដែនកម្ពុជា-ថៃឡើយដែលធ្វើឱ្យពលករខ្មែរមួយចំនួនជាប់នៅថៃ។ ប្រឈមនឹងបញ្ហានេះ ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃបានជូនដំណឹងដល់ពលករខ្មែរ ដែលកំពុងស្នាក់នៅប្រទេសថៃកុំឱ្យមានការព្រួយបារម្ភពីការស្នាក់នៅព្រោះថៃអនុញ្ញាតឱ្យស្នាក់លើសពេលកំណត់បាន។

តាមរយៈសេចក្ដីជូនដំណឹងមួយនៅថ្ងៃព្រហស្បតិ៍នេះ ស្ថានទូតទូតកម្ពុជាប្រចាំនៅប្រទេសថៃ បានប្រកាសប្រាប់ដល់ពលករខ្មែរដែលទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារអស់សុពលភាពថា ក្រសួងការងារថៃនឹងបន្តឱ្យស្នាក់នៅជាបណ្ដោះអាសន្នដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពោល គឺលើកលែងការផាកពិន័យលើការស្នាក់នៅលើសកំណត់។ ជាមួយគ្នានេះ ស្ថានទូតកម្ពុជាក៏បានបញ្ជាក់ឱ្យដឹងផងដែរថា ក្នុងករណីពលករខ្មែរត្រូវការធ្វើការងារបន្ត ត្រូវឱ្យនិយោជកបញ្ជូនបញ្ជីឈ្មោះ ទៅក្រសួង ឬមន្ទីរការងារក្រុង/ខេត្ត តាមរយៈប្រព័ន្ធអនឡាញឲ្យបានរួចរាល់ ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ដើម្បីបន្តធ្វើការជាបណ្ដោះអាសន្នបានរហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

សូមជម្រាបជូនថា រដ្ឋាភិបាលថៃបានប្រកាសដាក់ប្រទេសក្នុងភាពអាសន្នចាប់ពីថ្ងៃទី២៦ ខែមីនា រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩នៅក្នុងប្រទេសថៃ។ ការដាក់ប្រទេសក្នុងភាពអាសន្ននេះ គឺអាជ្ញាធរថៃមិនអនុញ្ញាតឱ្យមានការចេញចូលឆ្លងកាត់ព្រំដែនរវាងកម្ពុជា និងថៃឡើយ។ ហេតុដូច្នេះហើយ ទាំងពលករខ្មែរ និងជនជាតិខ្មែរដែលទៅទេសចរណ៍នៅប្រទេសថៃពុំអាចចាកចេញ

មកកម្ពុជាបានទេ។ ចំពោះអ្នកទេសចរខ្មែរ ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃក៏បានមានចំណាត់ការជួយដល់ពួកគេផងដែរ។

តាមរយៈសេចក្តីជូនដំណឹងដាច់ដោយឡែកមួយទៀត ស្ថានទូតកម្ពុជា បានប្រកាសថា ប្រជាពលរដ្ឋខ្មែរ ដែលចូលទៅប្រទេសថៃជាប្រភេទទេសចរណ៍ អាចស្នើសុំបន្តការស្នាក់នៅនៅប្រទេសថៃបានរយៈពេល៣០ថ្ងៃ។ បើតាមស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ ប្រជាពលរដ្ឋខ្មែរដែលមានបំណងបន្តការស្នាក់នៅនៅថៃត្រូវស្នើសុំ លិខិតបញ្ជាក់ពីស្ថានទូតកម្ពុជានៅទីក្រុងបាងកក ឬស្ថានអគ្គកុងស៊ុលនៅខេត្តសាកែវបាន។

គួរបញ្ជាក់ឱ្យដឹងថា មុនថៃប្រកាសដាក់ប្រទេសក្នុងភាពអាសន្ននេះ ពលករខ្មែរនៅថៃជាច្រើនពាន់នាក់ បានសម្រុកចូលមកប្រទេសកម្ពុជាវិញ។ គិតមកដល់ថ្ងៃទី២៦ ខែមីនានេះ ពលករខ្មែរចំនួនជាង៤ម៉ឺននាក់ ហើយបានចូលមកដល់ប្រទេសកម្ពុជា។ នេះបើតាមការបញ្ជាក់ឱ្យដឹងរបស់លោកឧបនាយករដ្ឋមន្ត្រីស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា៕

## ថៃឲ្យពលករខ្មែរស្នាក់នៅដល់ចុងខែមិថុនា ខណៈពួកគេជាង៤ម៉ឺននាក់សម្រុកមកប្រទេសវិញ

https://khmer.voanews.com/ 26 មិនា 2020 ស៊ុន ណារិន

ភ្នំពេញ៖ ខណៈរដ្ឋាភិបាលថៃដាក់ប្រទេសក្នុងគ្រាអាសន្ន ចាប់ពីថ្ងៃព្រហស្បតិ៍នេះ ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃឲ្យដឹងថា ថៃបានអនុញ្ញាតឲ្យពលករខ្មែរអាចបន្តរស់នៅនិងធ្វើការរហូតដល់ចុងខែមិថុនា បើទោះជាឯកសារហួសសុពលភាពក៏ដោយ។ ប្រទេសថៃកំពុងតែរឹតបន្តឹងការធ្វើដំណើរក្នុងប្រទេស និងបានបិទព្រំដែនជាមួយកម្ពុជាកាលពីថ្ងៃច័ន្ទ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរាតត្បាតវីរុសកូរ៉ូណា។ បើតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃចេញផ្សាយនៅថ្ងៃព្រហស្បតិ៍នេះ ពលរដ្ឋខ្មែរនៅប្រទេសថៃអាចបន្តស្នាក់នៅបណ្ដោះអាសន្នដល់ថ្ងៃទី៣០ ខែមិថុនាដោយលើកលែងការផាកពិន័យចំពោះការស្នាក់នៅលើសកំណត់។ ស្ថានទូតខ្មែរបញ្ជាក់ថា ការដាក់ប្រទេសក្នុងគ្រាអាសន្នរបស់ថៃអាចធ្វើរហូតដល់ថ្ងៃទី៣០ខែមេសា។ ការណ៍នេះអាចធ្វើឲ្យពលរដ្ឋខ្មែរមួយចំនួនប្រឈមនឹងការផុតសុពលភាពស្នាក់នៅ និងបណ្ណអនុញ្ញាតការងារ ដោយសារពួកគេមិនត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរនោះទេ។ ស្ថានទូតខ្មែរបន្តថា ក្នុងករណីពលករខ្មែរត្រូវការធ្វើការបន្ត ថៅកែត្រូវបញ្ជូនបញ្ជីឈ្មោះទៅក្រសួង ឬមន្ទីរការងារក្រុង/ខេត្ត តាមរយៈប្រព័ន្ធអនឡាញឲ្យបានរួចរាល់ត្រឹមថ្ងៃទី៣១ ខែមីនា ដើម្បីបន្តធ្វើការជាបណ្ដោះអាសន្នបានរហូតដល់ចុងខែមិថុនា។ រដ្ឋាភិបាលថៃ កាលពីថ្ងៃច័ន្ទ បានចាប់ផ្តើមបិទច្រកព្រំដែនកម្ពុជាថៃសំខាន់ៗ ដែលនាំឲ្យពលករ និងពលរដ្ឋខ្មែររាប់ពាន់នាក់ធ្វើដំណើរត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ដែលការណ៍នេះនាំឲ្យមានការព្រួយបារម្ភអំពីលទ្ធភាពច្រើននៃការរីករាលដាលនៃវីរុសកូរ៉ូណា។

បើតាមលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រហូតមកដល់ថ្ងៃព្រហស្បតិ៍នេះប្រជាពលរដ្ឋខ្មែរជាង៤ម៉ឺននាក់ហើយបានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានទៅស្រុកកំណើតរបស់ពួកគេនៅទូទាំងប្រទេស។ ក្នុងពិធីសំណេះសំណាលមួយដែលធ្វើឡើងនៅខេត្តបាត់ដំបង កាលពីថ្ងៃពុធ លោក ស ខេង បានថ្លែងថា អាជ្ញាធរកម្ពុជាត្រូវតែទទួលស្វាគមន៍អ្នកវិលត្រឡប់មកវិញ បើទោះជាមានការព្រួយបារម្ភអំពីការចម្លងវីរុសកូរ៉ូណាក៏ដោយ។ លោកមានប្រសាសន៍ថា៖ «ប៉ុន្តែប្រសិនបើគាត់មកទៀត នៅមកទៀត យើងអត់មានជម្រើសទេ។ អត់មានជម្រើសណាផ្សេងក្រៅពីស្វាគមន៍គាត់ទេ ពីព្រោះជាជនជាតិខ្មែរ។ យើងអត់មានជម្រើសផ្សេងពីហ្នឹង។ បដិសេធគាត់មិនឲ្យមកអាហ្នឹងប្រហែលមិនបានទេ»។ លោក ស ខេង ក៏បានទទួលស្គាល់ថា កម្ពុជាមិនអាចពិនិត្យសុខភាពរបស់ពួកគេទាំងអស់នោះទេ ហើយក៏មិនអាចដាក់ពួកគេទាំងអស់ឲ្យនៅកន្លែងណាមួយ ដាច់ដោយឡែករយៈពេល១៤ថ្ងៃ ដើម្បីតាមដានសុខភាពដែរ។

លោក ស៊ុំ ច័ន្ទគា មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុកប្រចាំខេត្តបន្ទាយមានជ័យ បានប្រាប់ VOA នៅរសៀលថ្ងៃព្រហស្បតិ៍នេះថា ពលករខ្មែរនៅប្រទេសថៃមិនអាចទ្រាំបាននឹងស្ថានភាពគ្មានការងារធ្វើ ហើយពួកគេត្រូវបង្ខំចិត្តត្រឡប់មកប្រទេសវិញ។ លោកមានប្រសាសន៍ថា៖ «អ៊ីចឹងអត់ការងារធ្វើដឹងតែដាច់បាយហើយ!អ៊ីចឹងហើយបានយើងឃើញពួកខ្មែរយើងមួយចំនួនហ្នឹងត្រូវរត់ត្រឡប់មកវិញ ត្រឡប់មកកម្ពុជាវិញ។ គាត់មកដល់នេះមានស្រូវចង្រុកអីសម្រាប់ញ៉ាំទៅ។ តែនៅកន្លែងថៃមានអី?ពួកគាត់ជួបការលំបាក បើគេបិទ គេអត់ឲ្យចេញក្រៅ មានន័យថា គាត់អត់បានទៅធ្វើការ អត់បានទៅធ្វើការ ពួកគាត់ហ្នឹងដាច់បាយតែម្តង»។ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃមានជាង១លាននាក់។

កាលពីថ្ងៃច័ន្ទ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឲ្យអភិបាលខេត្តទាំងអស់ រៀបចំតទឹក តភ្លើង និងបង្គន់អនាម័យនៅតាមសាលារៀន ដើម្បីធ្វើជាមន្ទីរពេទ្យជាបន្ទាន់។ បើតាមលោកនាយករដ្ឋមន្ត្រី កម្ពុជាបានរៀបចំបន្ទប់ជាង៣ពាន់រួចមកហើយនៅទូទាំងប្រទេសដើម្បីដាក់ពលរដ្ឋណាដែលត្រូវបានសង្ស័យថា មានផ្ទុកវីរុសកូរ៉ូណា ឬត្រូវសម្រាកព្យាបាលជំងឺកូវីដ១៩នេះ៕

## ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

### ប្រមុខរដ្ឋាភិបាល៖ អ្នកមកពីថៃ គួរសរសេរដាក់មុខផ្ទះថា ទើបមកពីថៃ កុំឲ្យគេចូលលេង

https://thmeythmey.com/ 30, Mar 2020 , 10:26 am ដោយ: ថ្មីៗ

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវឲ្យពលករខ្មែរ ដែលទើបមកពីថៃ សរសេរអក្សរដាក់នៅមុខផ្ទះ ឲ្យគេបានដឹងថា ទើបមកពីថៃ។ សម្តេច យល់ថា វិធីសាមញ្ញនេះ អាចទប់ស្កាត់ ការចម្លងវីរុសកូវីដ-១៩ ទៅអ្នកដទៃ ក្នុងករណីអ្នកទើបមកពីថៃនោះ មានវីរុសកូវីដ-១៩។ ក្នុងសន្និសីទកាសែតនៅវិមានរដ្ឋសភានាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ សម្តេចនាយករដ្ឋមន្ត្រី មានប្រសាសន៍ថា៖«មានកន្លែងខ្លះ សរសេរអក្សរនៅមុខផ្ទះតែម្តងថា ខ្ញុំ ទើបនឹងមានបងប្អូនមកពីប្រទេសថៃ សូមអធ្យាស្រ័យ មិនអាចចូលលេងបានទេ...ខ្ញុំលើកទឹកចិត្តឲ្យធ្វើបែបនេះ។ ប្រមុខរដ្ឋាភិបាល អះអាងថា មកដល់ពេលនេះ មានពលករខ្មែរជាង៥ម៉ឺននាក់ហើយ ដែលទើបមកពីថៃ។ ប្រមុខរដ្ឋាភិបាល បានជំរុញឲ្យពួកគេ នៅដាច់ដោយឡែកពីសមាជិកគ្រួសាររយៈពេល១៤ថ្ងៃសិន។ ជាមួយគ្នានេះ ប្រមុខរដ្ឋាភិបាល លើកឡើងដូចរដ្ឋមន្ត្រីមហាផ្ទៃដែរថា បើភូមិណា មានការរាលដាលវីរុសកូវីដ-១៩ ភូមិនោះ អាចនឹងត្រូវបិទជាបណ្តោះអាសន្ន៕

### ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ២៤០នាក់, ស្រី ១៤១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 29-03-2020

នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ ការរាតត្បាតនៃជំងឺឆ្លងកូវីដ ១៩។ ដោយឡែកភាគីថៃ ក៏បានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ, ពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ២៤០នាក់, ស្រី ១៤១នាក់៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ចំនួន ៥២៣នាក់ ស្រី ១៩៥នាក់ កុមារ ០៨នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 29-03-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនអនុញ្ញាតឲ្យអ្នកដំណើរ ជាតិ អន្តរជាតិ ចេញ-ចូលនោះទេ។ ចំណែកមធ្យោបាយដឹកទំនិញ គឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ចំនួន ៥២៣នាក់ ស្រី ១៩៥នាក់ កុមារ ០៨នាក់។ ប្រជាពលរដ្ឋខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរចូលប្រទេសតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ០៣នាក់ ស្រី ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 29-03-2020

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរចូលប្រទេសតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ០៣នាក់ ស្រី ០២នាក់។ បន្ទាប់មកក្រុមចត្តាឡីស័ក វាស់កំដៅពុំមានសញ្ញាអ្វី គួរឲ្យកត់សំគាល់ឡើយ និងបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការទប់ស្កាត់ ក្នុងការចម្លង មេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ដោយឡែកមធ្យោបាយ ទំនិញ ចូល-ចេញ ពុំមានចរាចរទេ៕

## ប្រជាពលរដ្ឋខ្មែរ ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសថៃ តាមច្រករបៀង ស្លាបស្តាំ របស់ប៉ុស្តិ៍ សរុបចំនួន ១៥នាក់ ស្រី ០៥នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 29-03-2020

នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង៣០នាទី កម្លាំងប៉ុស្តិ៍នគរបាល ច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី និងផ្នែកចត្តាឡីស័កចបានធ្វើការទទួល និងពិនិត្យកំដៅប្រជាពលរដ្ឋខ្មែរ ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសថៃ តាមច្រករបៀង ស្លាបស្តាំ របស់ប៉ុស្តិ៍ សរុបចំនួន ១៥នាក់ ស្រី ០៥នាក់ និងមិនមាននរណាម្នាក់ ឡើងកម្តៅខុសប្រក្រតីនោះទេ។ ដោយឡែក នៅប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ខេត្តបាត់ដំបង ខាងភាគីថៃ នៅតែបន្តបិទច្រក ដោយពុំអនុញ្ញាតឲ្យមានអ្នកដំណើរ និងទំនិញ ចេញ-ចូល ឆ្លងកាត់ដដែល៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ៣៥២នាក់ ស្រី ១៦១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI March 28 3:12 PM

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ០៨និង០០នាទី តាមការចាត់បញ្ជូន របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ លោកឧត្តមសេនីយ៍ទោ ឌី ដាម៉ង់ អនុប្រធាននាយកដ្ឋានច្រកទ្វារទី១ បានអញ្ជើញចុះមកក្តាប់ស្ថានការណ៍ទូទៅនៅប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិអូស្មាច់ ខេត្តឧត្តរមានជ័យ បានត្រួតពិនិត្យមើល ទៅតាមគ្រប់គោលដៅបំពេញភារកិច្ច របស់កងកម្លាំងក្រោមឱវាទប៉ុស្តិ៍។ ដោយឡែកភាគីថៃ នៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិចង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិន

អនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិ ចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាត នៃជំងឺឆ្លងកូវីដ១៩ លើកលែងតែ ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ, ពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន និងមានពលរដ្ឋខ្មែរបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ៣៥២នាក់ ស្រី ១៦១នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI March 27 5:23 PM

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង៤០នាទី ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០៤នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១. ឈ្មោះ សោ មុំ ភេទស្រី អាយុ ៣៧ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ, ២. ឈ្មោះ ហេង រិទ្ធ ភេទប្រុស អាយុ ៤៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិដកពោធិ៍ ឃុំបឹងត្រាញ់ខាង ត្បូង ស្រុកសំរោង ខេត្តតាកែវ, ៣. ឈ្មោះ ខេង ដែន ភេទប្រុស អាយុ ៣៦ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិដកពោធិ៍ ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ និង៤. ឈ្មោះ មាន ស្វាយ ភេទប្រុស អាយុ ៤៧ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិប៉ោយប៉ែត ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្ត បន្ទាយមានជ័យ។ ក្នុងនេះក៏មានការចូលរួមពី មន្ត្រីចត្តាឡីស័កត្រួតពិនិត្យសុខ ភាពផងដែរ បន្ទាប់មកកម្លាំង នគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ប្រជាពលរដ្ឋខ្មែរ ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសថៃ តាមច្រករបៀង ស្លាបស្ដាំ របស់ប៉ុស្តិ៍ សរុបចំនួន ១២នាក់

https://www.facebook.com/GDIOfficial/ GeneralDepartment of Immigration–GDI March 28 4:37 PM

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១៦៖០០នាទី កម្លាំងប៉ុស្តិ៍នគរបាល ច្រកទ្វារព្រំដែនអន្តរជាតិ ភ្នំដី និងផ្នែកចត្តាឡីស័ក បានធ្វើការទទួល និងពិនិត្យកំដៅប្រជាពលរដ្ឋខ្មែរ ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសថៃ តាមច្រករបៀងស្លាបស្ដាំ របស់ប៉ុស្តិ៍សរុបចំនួន១២នាក់ ដោយមិនមាននរណាម្នាក់ ឡើងកម្ដៅខុសប្រក្រតីនោះទេ។ ដោយឡែកភាគីថៃ នៅតែបន្តបិទច្រក ដោយពុំអនុញ្ញាតឲ្យមានអ្នកដំណើរ និងទំនិញចេញ-ចូល ឆ្លងកាត់ដដែល៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ GeneralDepartment of Immigration–GDI March 28 5:27 PM

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង៥០នាទី ថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០៣នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១. ឈ្មោះ ខេង សូរិយា ភេទស្រី អាយុ ៤០ឆ្នាំ មានទីលំនៅ បច្ចុប្បន្នស្ថិតក្នុងភូមិដកពោធិ៍ ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ, ២. ឈ្មោះ ជឿង ធឿន ភេទប្រុស អាយុ ៣២ឆ្នាំ មានទី លំនៅបច្ចុប្បន្ន ស្ថិតក្នុងភូត្រា ឃុំកំពង់អំពិល ស្រុកពារាំង ខេត្តព្រៃវែង និង៣. ឈ្មោះ ពុធ ដាណា ភេទប្រុស អាយុ ៣៦ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិត្រពាំងព្រីងខាងជើង ឃុំត្រពាំងព្រីងខាងជើង ស្រុកទឹកឈូ ខេត្ត

កំពត។ ក្នុងនេះក៏មានការចូលរួមពី មន្ត្រីចត្តាឡីស័កត្រួតពិនិត្យសុខ ភាពផងដែរ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀង ស្លាបធ្វេង-ស្លាបស្តាំ ចំនួន ៣០៦ នាក់ ស្រី ១៣៩នាក់ កុមារ ១៥នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI **March 27 4:58 PM**

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ភាគីថៃបានធ្វើការបិទច្រកព្រំដែន មិនអនុញ្ញាតឲ្យអ្នកដំណើរ ជាតិ អន្តរជាតិ ចេញ-ចូលនោះទេ។ ចំណែកទំនិញ គឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀង ស្លាបធ្វេង-ស្លាបស្តាំ ចំនួន ៣០៦ នាក់ ស្រី ១៣៩នាក់ កុមារ ១៥នាក់៕

## ពលរដ្ឋខ្មែរចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ០៥នាក់ ស្រី ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI**March 27 4:50 PM**

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ០៥នាក់ ស្រី ០៣នាក់។ ក្រុមចត្តាឡីស័កវាស់កំដៅ ពុំមានសញ្ញាអ្វីគួរឲ្យកត់សំគាល់ឡើយ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំ ណែនាំ ដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លង មេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន ដោយឡែកមធ្យោបាយ ទំនិញ ចូល-ចេញ ពុំមានចរាចរទេ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ៣៣៩នាក់ ស្រី ១០១នាក់

https://www.facebook.com/GDIOfficial/General Department of Immigration-GDI **March 27 4:45 PM**

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ភាគីថៃនៅតែបន្ត បិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិ ចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ ការរាតត្បាត នៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកទ្វារនេះ ភាគីថៃបានលើកលែង៖ ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគីកម្ពុជា-ថៃ បានត្រឹមត្រូវ។ ពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ៣៣៩នាក់ ស្រី ១០១នាក់៕

## ពលករខ្មែរម្នាក់ដេកស្លាប់ដោយមិនដឹងមូលហេតុនៅក្នុងបន្ទប់ស្នាក់នៅ ស្ថិតក្នុងខេត្តឈុនបុរី ប្រទេសថៃ

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន 28-03-2020

ពលករខ្មែរម្នាក់ដេកស្លាប់ដោយមិនដឹងមូលហេតុនៅក្នុងបន្ទប់ស្នាក់នៅ ស្ថិតក្នុងខេត្តឈុនបុរី ប្រទេសថៃ

អ្នកស្លាប់មានឈ្មោះ កងរី គេទប្រុសអាយុ34ឆ្នាំស្រុកកំណើតរស់នៅខេត្តតាកែវ មុខរបរជាពលករខ្មែរធ្វើការនៅក្នុងរោងចក្រផលិតគ្រឿងបន្លាស់រថយន្តបានដេកស្លាប់បាត់បង់ជីវិតនៅវេលាម៉ោង12យប់លានចូលថ្ងៃច័ន្ទ ទី30 ខែមិនា ឆ្នាំ2020។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន) ខ្ញុំសូមចូលរួមរំលែកទុកដល់គ្រួសារនៃសពផង។

## ពលរដ្ឋខ្មែរចូល ប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ៤២នាក់

https://www.facebook.com/GDIOfficial/General Department of Immigration-GDIMarch 28 4:32 PM

នៅរសៀលថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរចូល ប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ៤២នាក់។ ក្រុមចត្តាឡីស័កវាស់កំដៅ ពុំមានសញ្ញាអ្វីគួរឲ្យកត់សំគាល់ឡើយ បន្ទាប់មក កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការទប់ស្កាត់ ក្នុងការចម្លង មេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## កូវីដ១៩៖ អាជ្ញាធរថ្នាក់ក្រោមជាតិបង្កើតក្រុមការងារដើរស្រង់ឈ្មោះពលរដ្ឋខ្មែរ ដែលមកពីក្រៅប្រទេស

http://www.rfi.fr/km/ 25/03/2020 - 08:08 អ៊ឹង ប៊ុនថន

បន្ទាប់ពីពលករខ្មែររាប់ពាន់នាក់សម្រុកវិលចូលប្រទេសកម្ពុជាវិញនាប៉ុន្មានថ្ងៃមកនេះអាជ្ញាធរថ្នាក់ក្រោមជាតិបានបង្កើតក្រុមការងាររបស់ខ្លួនដើម្បីដើរស្រង់ឈ្មោះពលរដ្ឋខ្មែរទាំងនោះដែលភាគច្រើនមកពីប្រទេសថៃ។ ចំណាត់ការនេះធ្វើឡើងដើម្បីស្វែងរកមុខសញ្ញាជនសង្ស័យដែលមានឆ្លងជំងឺកូវីដ១៩ ឲ្យនៅដាច់ដោយឡែកពីគេ១៤ថ្ងៃ ខណៈអាជ្ញាធរមិនអាចត្រួតពិនិត្យបានល្អិតល្អន់នៅតាមច្រកព្រំដែន។

ផ្ដើមចេញពីខេត្តសៀមរាប រដ្ឋបាលក្រុងទេសចរណ៍មួយនេះ បានបង្កើតក្រុមការងារសរុបជាង១០០នាក់ ចុះស្រង់ស្ថិតិពលករត្រឡប់មកពីក្រៅប្រទេសនៅក្នុងសង្កាត់ទាំង១២ របស់ក្រុងសៀមរាប ដោយមួយក្រុមៗមានគ្នាពី៨ទៅ១១នាក់។ ក្រៅពីក្រុងសៀមរាប នៅតាមស្រុកនីមួយនៃខេត្តសៀមរាបក៏ត្រូវបានបង្កើតក្រុមការងារដូចគ្នានេះដែរដោយមួយក្រុមៗមានគ្នាប្រមាណ១០ដើម្បីដើរស្រង់ឈ្មោះមនុស្សដែលមកពីក្រៅប្រទេស ជាពិសេសពលករខ្មែរដែលមកពីប្រទេសថៃនៅពេលថ្មីៗនេះ។ ចំណែកសមត្ថកិច្ចនៅខេត្តកំពតវិញក៏បានដើរស្រង់ឈ្មោះពលករខ្មែរដែលមកពីប្រទេសថៃនេះផងដែរដើម្បីស្វែងរកមុខសញ្ញាជនសង្ស័យណាដែលឆ្លងជំងឺកូវីដ១៩ ឲ្យនៅដោយឡែកពីគេ។

បញ្ហាកូវីដ១៩នេះ បានធ្វើឲ្យអាជ្ញាធរថៃបិទព្រំដែនជាមួយកម្ពុជា បានញាំងឲ្យពលរដ្ឋខ្មែរប្រមាណជាង១ម៉ឺន៥ពាន់នាក់ បានវិលចូលមកក្នុងប្រទេសកម្ពុជាវិញ កាលពីថ្ងៃទី២៣ ខែមីនា។ បើតាមលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរកម្ពុជានៅតាមព្រំដែនមិនមានលទ្ធភាពពិនិត្យសុខភាពរបស់ពលករត្រឡប់មកពីប្រទេសថៃវិញ ឱ្យបានដិតដល់នោះទេ ទើបលោកស្នើសុំគោលការណ៍ពីនាយករដ្ឋមន្ត្រី ឲ្យមានមន្ត្រីសុខាភិបាលទៅពិនិត្យសុខភាពពួកគេនៅតាមភូមិនីមួយៗ។ ហើយប្រសិនបើរកឃើញករណីកើតមានជំងឺកូវីដ១៩នៅភូមិណាមួយ២ឬ៣ករណី គឺអាចឈានទៅបិទការចេញចូលបណ្ដោះអាសន្ននៅភូមិនោះតែម្ដង។ នេះជាការលើករបស់លោក ស ខេង កាលពីថ្ងៃទី២៤មីនា។

ទោះជាយ៉ាងណា បើតាមរដ្ឋមន្ត្រីមហាផ្ទៃដដែល កម្ពុជាមិនទាន់មានវិធានការចាប់បង្ខាំងមនុស្សទុកដូចនៅតាមបណ្ដាប្រទេសផ្សេងនោះឡើយ ប៉ុន្តែកម្ពុជានៅប្រើវិធានការអំពាវនាវជាមុនសិន តាមរយៈការឃោសនាតាមមេក្រូ ដើម្បីផ្សព្វផ្សាយប្រាប់ប្រជាពលរដ្ឋពីវិធានការបង្ការ និងការដាក់ខ្លួនឯងនៅដាច់ដោយឡែកពីគេ១៤ថ្ងៃសម្រាប់ពលករដែលមកពីក្រៅប្រទេស៕

# រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បញ្ជាឱ្យអាជ្ញាធរបង្កើនការសហការជាមួយថៃ ដើម្បីទប់ស្កាត់ការឆ្លងដែនតាមបណ្តាច្រករបៀង

https://www.information.gov.kh/ ថ្ងៃទី 28 ខែ មីនា ឆ្នាំ 2020 ៖លោក ជួន បូណា

MC៖ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានបញ្ជាឱ្យអាជ្ញាធរបង្កើនការសហការជាមួយថៃ ដើម្បីទប់ស្កាត់ការឆ្លងដែនច្រករបៀងនានា ក្នុងគោលដៅជានាការត្រួតពិនិត្យសុខភាពឲ្យបានជិតដល់ទប់ស្កាត់ការរីករាលដាលជំងឺកូវិត១៩ នៅក្នុងមូលដ្ឋាន។ សម្តេចក្រឡាហោម សខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំឱ្យអាជ្ញាធរខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ត្រូវបន្តតាមដានយកចិត្តទុកដាក់ចំពោះលំហូរ នៃការវិលត្រឡប់ចូលប្រទេសរបស់ពលរដ្ឋដោយត្រូវសហការជាមួយភាគីថៃ ដើម្បីកំណត់ច្រកទ្វារព្រំដែនជាក់លាក់សម្រាប់ការវិលចូលប្រទេសវិញ។ ជាមួយគ្នានេះក៏ត្រូវត្រៀមសម្រាប់លទ្ធភាព ដែលអាចមានពលរដ្ឋខ្លះងាកទៅឆ្លងកាត់តាមបណ្តាច្រករបៀងនានា ដោយត្រូវកំណត់អត្តសញ្ញាណ និងពិនិត្យសុខភាពពួកគាត់ឱ្យអស់ពីលទ្ធភាព មុនពេលពួកគាត់បន្តដំណើរទៅស្រុកកំណើត។

សម្តេចក្រឡាហោមបានជំរុញឱ្យអភិបាលរាជធានីខេត្តទាំងអស់ ត្រូវរៀបចំតារាងកត់ត្រាអំពីសវតានៃការធ្វើដំណើរ និងសុខភាពរបស់ពលរដ្ឋដែលបានទៅដល់មូលដ្ឋាន ហើយត្រូវរៀបចំការចុះអប់រំផ្សព្វផ្សាយដល់ពួកគាត់ឱ្យបានដឹងច្បាស់ អំពីវិធានការដាក់នៅដោយឡែករយៈពេល១៤ថ្ងៃ ក្រោមការសង្កេតតាមដានសុខភាពម៉ត់ចត់បំផុត ពិសេសគ្រោះថ្នាក់នៃការឆ្លងជំងឺនេះដល់ក្រុមគ្រួសារ និងសាច់ញាតិ ប្រសិនបើពួកគាត់មិនគោរពតាមវិធានណែនាំរបស់អាជ្ញាធរ និងក្រសួងសុខាភិបាល៕

# រដ្ឋបាលខេត្តត្បូងឃ្មុំ បង្កើតក្រុមការងារចុះពិនិត្យនៅតាមមូលដ្ឋានដល់ខ្នងផ្ទះ ចំពោះប្រជាពលរដ្ឋ ដែលវិលត្រលប់មកពីប្រទេសថៃ ដើម្បីបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19

http://www.freshnewsasia.com/ 2020-03-28

**(ត្បូងឃ្មុំ)៖** អនុវត្តតាមការណែនាំរបស់ក្រសួងមហាផ្ទៃ នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០នេះ លោក ជាម ច័ន្ទសោភ័ណ អភិបាលខេត្តត្បូងឃ្មុំ បានបើកកិច្ចប្រជុំវិសាមញ្ញគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ស្តីពីការបង្កើតគណៈកម្មការប្រយុទ្ធប្រឆាំងជម្ងឺCOVID 19 ដើម្បីទទួលខុសត្រូវសម្របសម្រួល ណែនាំទៅដល់ប្រជាពលរដ្ឋ ដែលវិលត្រលប់មកពីប្រទេសថៃ ក្នុងការបង្ការនិងទប់ស្កាត់ពីជំងឺដោយនៅដោយឡែករយៈពេល 14ថ្ងៃ ។ ក្នុងនោះដែរ ក៏មានអញ្ជើញចូលរួមពីឯកឧត្តមអភិបាលរងខេត្ត លោកនាយករដ្ឋបាលសាលាខេត្ត លោកស្នងការនគរបាលខេត្ត លោកមេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត លោកប្រធានមន្ទីរ/អង្គភាពពាក់ព័ន្ធ អភិបាលក្រុង/ស្រុក នាយកទីចាត់ការចំណុះសាលាខេត្ត និងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត។

មានប្រសាសន៍ក្នុងកិច្ចប្រជុំនោះ លោក ជាម ច័ន្ទសោភ័ណ អភិបាលខេត្ត បានណែនាំដល់មន្ទីរអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរក្រុង ស្រុក ត្រូវត្រួតពិនិត្យអោយបានហ្មត់ចត់ នៅតាមមូលដ្ឋាននីមួយៗ ពិសេសអាជ្ញាធរក្រុង ស្រុក ត្រូវមានការយកចិត្តទុកដាក់ ចំពោះបញ្ហាប្រជាពលរដ្ឋ ដែលទើបឆ្លងមកពីប្រទេសថៃថ្មីៗនេះ ត្រូវអប់រំផ្សព្វផ្សាយណែនាំ អនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាល ឱ្យប្រជាពលរដ្ឋទាំងនោះ ត្រូវតែអនុវត្តសម្រាកនៅនឹងកន្លែងក្នុងផ្ទះរយៈពេល១៤ថ្ងៃ និងពង្រឹកការអនុវត្តតាមដានត្រួតពិនិត្យជាប្រចាំនូវជនបរទេសដែលទើបធ្វើដំណើរចូលមកក្នុងខេត្តយើងនេះ ចាត់ចែងក្រុមការងារចុះពិនិត្យ និងតាមដានសភាពការណ៍តាមបណ្តាក្រុងស្រុក ដើម្បីឆ្លើយតបឲ្យបានទាន់ពេលវេលាបើមានប្រជាពលរដ្ឋណាម្នាក់មានអាការៈមិនប្រក្រតីពាក់ព័ន្ធនឹងរោគ

សញ្ញាកូវីដ១៩។ លោក ជាម ច័ន្ទសោភ័ណ អភិបាលខេត្ត បានផ្តាំផ្ញើ និងជំរុញដល់ក្រុមការងារដែលទទួលខុសត្រូវសម្របសម្រួលបងប្អូនប្រជាពលរដ្ឋមកពីប្រទេសថៃ ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ត្រូវចុះតាមខ្នងផ្ទះ ដែលប្រជាពលរដ្ឋទើបមកពីប្រទេសថៃ ដោយណែនាំ ពួកគាត់ឲ្យដាក់ខ្លួនដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ស្របតាមនីតិវិធីកំណត់របស់ក្រសួងសុខាភិបាល និងបង្កើនសកម្មភាពផ្សព្វផ្សាយអំពីវិធីបង្ការ និងទប់ស្កាត់ការឆ្លងវីរុសកូវីដ១៩ នៅតាមមូលដ្ឋានរៀងៗខ្លួនផងដែរ។

**សូមជម្រាបថា៖ លោក ជាម ច័ន្ទសោភ័ណ អភិបាលខេត្តត្បូងឃ្មុំ បានចាត់វិធានការ និងបែងចែកក្រុមការងារតាមដានយ៉ាងម៉ត់ចត់បំផុត និងបានគាំទ្រយ៉ាងពេញទំហឹង ចំពោះមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ ដោយបានរៀបចំកន្លែងពិនិត្យព្យាបាលអ្នកជំងឺកូវីដ១៩ ចំនួន០៤ទីតាំង៖**

១៖ មន្ទីរពេទ្យបង្អែកពញាក្រែក

២៖ មន្ទីរពេទ្យបង្អែកមេមត់

៣៖ មន្ទីរពេទ្យបង្អែកព្រះនរោត្តមសីហនុត្បូងឃ្មុំ

៤៖សណ្ឋាគារឆៃណាមេមត់ មាន៥០បន្ទប់ គ្រែ០២ ១២បន្ទប់ និងគ្រែ០១ ៣៨បន្ទប់។

នៅទូទាំងខេត្តត្បូងឃ្មុំ អ្នកមានរោគសញ្ញាសង្ស័យផ្ទុកវីរុសកូរ៉ូណា មន្ត្រីសុខាភិបាលបានយកសំណាកបានចំនួន ៣១៥នាក់ ទៅកាន់វិទ្យាស្ថានប៉ាស្ទ័រ ជាលទ្ធផលក្នុងនោះមានវិជ្ជមាន០៤នាក់។ ក្រោមការពិនិត្យព្យាបាលយ៉ាងយកចិត្តទុកដាក់ពីសំណាក់ក្រុមគ្រូពេទ្យតាមបែបវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ រហូតមកដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ អ្នកជំងឺកូវីដ១៩ ទាំង០៤នាក់ បានជាសះស្បើយ ហើយក៏បានអនុញ្ញាតឲ្យទៅផ្ទះវិញផងដែរ ប៉ុន្តែមន្ត្រីសុខាភិបាលក៏នៅតែតាមដានសុខភាពពួកគេ ជាបន្តទៀតផងដែរ៕

## ក្រសួងការងារស្នើក្រុមហ៊ុនជប៉ុនបង្កើនការទទួលពលករខ្មែរផ្នែកថែទាំអគារ

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2020-03-28

មន្ត្រីជាន់ខ្ពស់ក្រសួងការងារ ស្នើដល់ក្រុមហ៊ុនជប៉ុន ឱ្យបង្កើនការទទួលពលករពីកម្ពុជាឱ្យបាន ១០ម៉ឺននាក់ នាពេលខាងមុខ ខណៈដែលប្រទេសជប៉ុន មានគម្រោងជ្រើសរើសពលករជំនាញផ្នែកថែទាំអគារសំណង់ប្រមាណ ៣ម៉ឺននាក់ ពីប្រទេសកម្ពុជា។ គេហទំព័រផ្លូវការរបស់ក្រសួងការងារឱ្យដឹងថា សំណើនេះ ធ្វើឡើងក្នុងជំនួបពិភាក្សាមួយរដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង ជាមួយគណៈប្រតិភូនៃមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) និងសមាគមថែទាំអគារជប៉ុន កាលពីថ្ងៃទី២៦ ខែមីនា ថា នៅទីស្តីការក្រសួងការងារ។

នាយកគ្រប់គ្រងសមាគមថែទាំអគារជប៉ុន លោក ហ៊ីរ៉ូស៊ី ហូរីហ្គូឈិ (Hiroshi Horiguchi) ឱ្យដឹងថា ក្នុងមួយឆ្នាំៗ ប្រទេសជប៉ុន ត្រូវការកម្លាំងពលករជំនាញផ្នែកថែទាំអគារសំណង់ប្រមាណ ៩០ ម៉ឺននាក់ ក្នុងនោះ នាំចូលកម្លាំងពលករពីក្រៅប្រទេសប្រមាណ ៣ម៉ឺននាក់។ លោក ហ៊ីរ៉ូស៊ី បន្តថា កន្លងទៅសមាគមលោកបានជ្រើសពលករជំនាញពីប្រទេស មីយ៉ាន់ម៉ា ឬភូមា (Myanmar) និងប្រទេសហ្វីលីពីន (Philippines) ប៉ុន្តែគម្រោងនៅឆ្នាំបន្ទាប់ទៅនេះ សមាគមលោក មានបំណងជ្រើសរើសពលករជំនាញពីប្រទេសកម្ពុជាវិញ។ លោក ហ៊ីរ៉ូស៊ី បន្ថែមទៀតថា ការថែទាំអគារគឺជាកិច្ចការជំនាញចាំបាច់មួយនៅប្រទេសជប៉ុន រួមមាន ការគ្រប់គ្រងគុណភាព សុវត្ថិភាពសំណង់ ការថែទាំអនាម័យបរិស្ថាន ទាំងការសំអាតក្នុងអគារនិងបរិវេណជុំវិញអគារជាដើម។

ក្នុងជំនួបនេះដែរ លោក អ៊ិត សំហេង ក៏បានស្នើដល់ភាគីជប៉ុនឱ្យបង្កើនការទទួលពលករពីកម្ពុជាឱ្យបាន ១០ ម៉ឺននាក់ សម្រាប់រយៈពេលខាងមុខបន្តទៀត ពីព្រោះកម្ពុជាមានសក្តានុពលក្នុងការជ្រើសរើសកម្លាំងពលកម្មគ្រប់គ្រាន់ ដែលមានស្រាប់ក្នុងប្រទេស និងអ្នកដែលត្រឡប់ពីក្រៅប្រទេស។ លោកក៏បានជំរុញឱ្យមន្ត្រីកម្ពុជា និង

សមាគមថៃទាំងអគារជប៉ុនសហការជាមួយក្រុមហ៊ុនភ្នាក់ងារបញ្ជូនពលកររបស់កម្ពុជា ដើម្បីប្រកាសជ្រើសរើស បណ្ដុះបណ្ដាលភាសាជប៉ុន និងជំនាញធ្វើការប្រឡងតេស្ត ដើម្បីបញ្ជូនពលករទៅធ្វើការនៅប្រទេសជប៉ុន។

មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុកនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារកម្ពុជា ហៅកាត់ ថា សង់ត្រាល់ ប្រាប់កាសែតក្នុងស្រុកថា កន្លងទៅពលករកម្ពុជា កម្រទទួលបានការងារដែលមានជំនាញច្បាស់លាស់ ព្រោះភាគច្រើន កម្លាំងពលកម្មទៅធ្វើការនៅក្រៅប្រទេស គឺធ្វើការដោយប្រើកម្លាំង ហើយត្រូវទទួលរងនៃការរំលោភបំពានថែមទៀតផង។ លោកបន្តថា រដ្ឋាភិបាល គួរផ្ដោតការយកចិត្តទុកដាក់ បង្កើនសាលាជំនាញ ដល់ប្រជាពលរដ្ឋ ឬសិស្សណា ដែលចង់រៀនជំនាញបច្ចេកទេសណាមួយ។

របាយការណ៍របស់ក្រសួងការងារឱ្យដឹងថា បច្ចុប្បន្នមាននិស្សិត និងពលករជំនាញ ប្រមាណជិត ១ម៉ឺន ៥ពាន់នាក់ ( ១៥,០០០ ) ទៅរៀននិងធ្វើការនៅប្រទេសជប៉ុន ផ្នែកវិស័យកសិកម្ម នេសាទ សំណង់ កែច្នៃចំណីអាហារ និងវិស័យកាត់ដេរ ជាដើម៕

## ពលករខ្មែរមួយក្រុមធ្វើការលើទូកនេសាទនៅម៉ាឡេស៊ី ស្នើសុំអាជ្ញាធរកម្ពុជា ជួយបញ្ជូនពួកគេមកកម្ពុជា

https://www.rfa.org/khmer/ ដោយ វ៉ែន សុមេធ 2020-03-29

ពលករខ្មែរចំនួន១២នាក់ ដែលកំពុងធ្វើការនៅលើទូកនេសាទនៅក្នុងប្រទេសម៉ាឡេស៊ី អំពាវនាវដល់អាជ្ញាធរកម្ពុជា ជួយសម្របសម្រួលបញ្ជូនពួកគេមកកម្ពុជាវិញ។ ពួកគេចង់វិលមកកម្ពុជាវិញនេះ ដោយសារតែថៅកែទូកនេសាទ បានផ្អាកការងារមួយរយៈហើយ ក្រោយផ្ទុះរីករាលដាល ជំងឺកូវីដ-១៩នៅក្នុងប្រទេសម៉ាឡេស៊ី។ មន្ត្រីសង្គមស៊ីវិលអះអាងថា រដ្ឋាភិបាលមានកាតព្វកិច្ចដោះស្រាយចំពោះសំណើរបស់ពលករទាំងនេះ។ ពលករ១២នាក់អះអាងថា ពួកគេកំពុងរស់នៅលើទូកនេសាទក្នុងប្រទេសម៉ាឡេស៊ី ប៉ុន្តែពុំមានការងារធ្វើ ដើម្បីបានប្រាក់ខែសម្រាប់ផ្គត់ផ្គង់គ្រួសារដូចមុនឡើយ ដូច្នេះហើយទើបពួកគេ ចង់វិលត្រឡប់ទៅស្រុកកំណើតវិញ ដើម្បីស្វែងរកការងារក្រែងបានប្រាក់ចំណូលខ្លះសម្រាប់ជួយគ្រួសាររបស់ពួកគេដែលកំពុងខ្វះខាត។

ពលករលើទូកនេសាទម្នាក់ គឺលោក ជា វណ្ណៈ អាយុ៣៥ ឆ្នាំ រៀបរាប់ថា ថៅកែទូកនេសាទរបស់លោកបានផ្អាកការងារមួយរយៈ ហើយលោកមិនដឹងថា ថៅកែនឹង បើកដំណើរការវិញពេលណានោះទេ។ ពលកររូបនេះបន្តថា ពួកលោកចង់វិលត្រឡប់ទៅស្រុកកំណើតវិញ ប៉ុន្តែពួកលោក មិនអាចចាកចេញពីម៉ាឡេស៊ី ត្រឡប់ទៅប្រទេសកម្ពុជាវិញដោយខ្លួនឯងបានទេ ដោយសាររដ្ឋាភិបាលម៉ាឡេស៊ី បានបិទប្រទេសបណ្ដោះអាសន្នដើម្បីបង្ការជំងឺឆ្លងកូវីត១៩។ លោកអំពាវនាវឲ្យអាជ្ញាធរកម្ពុជា ជួយសម្របសម្រួលជាមួយអាជ្ញាធរម៉ាឡេស៊ី ដើម្បីបញ្ជូនពួកលោកទាំង១២នាក់ ត្រឡប់ទៅកម្ពុជាវិញ៖ «ខ្ញុំចង់ឲ្យអាជ្ញាធរជួយដោះស្រាយឲ្យពួកខ្ញុំបានទៅផ្ទះវិញឆាប់ៗនេះ ព្រោះឥលូវគេបិទអស់ហើយ។ គេលែងទិញត្រីអស់ហើយ គេផ្អាកមួយរយៈពេល។ យើងអត់មានការងារធ្វើហើយ យើងនៅដេក តែថៅកែឲ្យអង្ករ បាយទឹកអីហូបរហូតដែរ។ គ្រួសារយើងនៅស្រុកខ្វះខាតច្រើន ដូច្នេះយើងមិនអាចនៅទីនេះបានទេ»។

ពលករខ្មែរទាំងពីរ១២ នាក់ គឺជាអ្នករស់នៅក្នុងឃុំព្រៃញ៉ា ស្រុកពារាំង ខេត្តព្រៃវែង ។ ពួកគេទើបតែចាកចេញពីស្រុកកំណើត ធ្វើដំណើរតាមរថយន្តឈ្នួលឆ្លងកាត់ប្រទេសថៃ ដើម្បីទៅធ្វើការជាកម្មករលើទូកនេសាទនៅប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០។ ប៉ុន្តែនៅពេលពួកគេទៅដល់ថៅកែទូកនេសាទ បានផ្អាកការនេសាទតែម្ដង។ ពួកគេធ្លាប់ធ្វើជាកម្មករលើទូកនេសាទនៅប្រទេសម៉ាឡេស៊ីជាច្រើនឆ្នាំមកហើយ។ កម្មករលើទូកនេសាទម៉ាឡេស៊ីម្នាក់ទៀត និយាយថា ពួកលោក គឺសុទ្ធតែជាអ្នកក្រីក្រខ្វះខាតក្នុងជីវភាព ហើយប្រសិនបើពួកគាត់ខំចំណាកស្រុក ប៉ុន្តែគ្មានការងារធ្វើដដែល គឺកាន់តែធ្វើឲ្យពួកគាត់ ជួបការលំបាកក្នុងជីវភាពបន្ថែមទៀត៖ «យើង

នៅក៏មិនដឹងធ្វើអីដែរ ខាតតែពេលវេលា។ យើងនៅនេះមានតែគ្នាយើងប៉ុន្មាននាក់នេះ គ្មានការព្រួយបារម្ភរឿង ឆ្លងជំងឺកូវីដអីទេ ប៉ុន្តែយើងនៅទីគ្មានការងារធ្វើ ដូច្នេះវិលទៅជួបគ្រួសារវិញក៏ល្អដែរ។សំណូមពរចង់ឲ្យគេជួយរកផ្លូវ ចេញទៅផ្ទះវិញ»។ កម្មករលើទូកនេសាទទាំងនេះ មិនទាន់ដឹងថា ត្រូវទាក់ទងទៅអាជ្ញាធរតាមប្រភពណានៅឡើយទេ។

អាស៊ីសេរី បានព្យាយាមទាក់ទងលេខទូរស័ព្ទបីខ្សែ សម្រាប់កិច្ចការកុងស៊ុល និងកិច្ចការពលករ របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ប៉ុន្តែពុំមានអ្នកទទួលនោះទេ នៅថ្ងៃទី២៨ ខែមីនា។ ចំណែកអ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង ក៏មិនទទួលទូរស័ព្ទដែរ។

មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសន៍នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា ការងារចុះទូកនេសាទគឺជាប្រភេទការងារប្រឈមគ្រោះថ្នាក់ខ្លាំងជាងគេបំផុតក្នុងចំណោមការងារចំណាកស្រុកនៅក្រៅប្រទេស ខណៈស្ថានទូតកម្ពុជាប្រចាំនៅបរទេស ហាក់មិនសូវយកចិត្តទុកដាក់ដោះស្រាយនោះទេ។ លោកបន្តថា ចំពោះសំណើសុំអន្តរាគមន៍របស់ក្រុមពលករទាំងនោះ រដ្ឋាភិបាលកម្ពុជា ត្រូវមានកាតព្វកិច្ចដោះស្រាយជាបន្ទាន់៖ «វាគឺជាកាតព្វកិច្ចរបស់រដ្ឋ ដែលត្រូវការពារផលប្រយោជន៍ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ ប៉ុន្តែនៅខាងក្រៅយើងស្តាប់ទៅហាក់ដូចជាគេយកចិត្តទុកដាក់ល្អណាស់ ប៉ុន្តែអ្នកដែលធ្វើការផ្ទាល់ និងអ្នកជួបរឿងផ្ទាល់លើរឿងនេះ ហើយទៅសុំអន្តរាគមន៍គឺពិបាកណាស់ គេមិនអើពើ គេមិនឲ្យតម្លៃលើអាយុជីវិតរបស់ពលរដ្ឋខ្មែរយើងទេ ។ តែជាកាតព្វកិច្ចក្នុងនាមជារដ្ឋាភិបាល ត្រូវតែការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ នៅពេលដែលពលរដ្ឋមានបញ្ហាបែបនេះ គួរតែត្រូវមានវិធានការហើយទោះបីជាក្នុងកាលៈទេសៈនេះ ប្រទេសម៉ាឡេស៊ី បិទបម្រាមគោចរក្តី ព្រោះបើយើងមើលទៅលើជាតិសាសន៍ដទៃនៅពេលដែលជាតិសាសន៍គេមានបញ្ហាកន្លែងណាមួយ គឺគេត្រៀមនឹងជួយសង្គ្រោះរហូតដល់បញ្ជូនយន្តហោះទៅយកមកទៀតផង»។

រដ្ឋាភិបាលម៉ាឡេស៊ី បានប្រកាសបិទប្រទេសមិនឲ្យមានការចេញចូលចាប់ពីថ្ងៃទី១៨ ខែមីនា ដល់ថ្ងៃទី១៤ ខែមេសា ។ ទោះជាយ៉ាងណា កាលពីថ្ងៃទី២៥ ខែមីនា រដ្ឋាភិបាលម៉ាឡេស៊ី ទើបតែសម្របសម្រួលជាមួយអាជ្ញាធរកម្ពុជា ដើម្បីបញ្ជូនយន្តហោះពិសេសមួយគ្រឿងមកទទួលពលរដ្ឋរបស់ខ្លួន ដែលជាប់នៅកម្ពុជាចំនួន ១១១ នាក់ ទៅម៉ាឡេស៊ីវិញ។ ប៉ុន្តែគេនៅមិនទាន់ដឹងថា តើរដ្ឋាភិបាល កម្ពុជានឹងសម្របសម្រួលជាមួយអាជ្ញាធរម៉ាឡេស៊ី ដើម្បីបញ្ជូនពលករខ្មែរមកកម្ពុជាវិញដែរ ឬយ៉ាងណានោះទេ។

មាត្រា៣៣នៃរដ្ឋធម្មនុញ្ញ ចែងថា ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅនៅឯបរទេស ត្រូវបានរដ្ឋគាំពារ។ ចំណែកមាត្រា៣៥ ចែងថា សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយដោយហ្មត់ចត់ដោយអង្គការរដ្ឋ៕

## ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

### កម្លាំងប៉ុស្តិ៍នគរបាល ច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានល្បាតឃើញ និងឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន ០៩នាក់ ស្រី ០៣នាក់ និងមេក្លោង ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 30-03-2020

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១០និង៤០នាទី កម្លាំងប៉ុស្តិ៍នគរបាល ច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានល្បាតឃើញ និងឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន ០៩នាក់ ស្រី ០៣នាក់ និងមេក្លោង ០១នាក់ ជាអ្នកដឹកនាំឆ្លងដែនខុសច្បាប់ ចេញពីប្រទេសកម្ពុជា ទៅប្រទេសថៃ តាមច្រករបៀង ស្លាបស្ពាំ របស់ប៉ុស្តិ៍។ ក្រោយពីទទួលបទបញ្ជារបស់ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជា ជា អគ្គនាយករងអន្តោប្រវេសន៍ និងលោកឧត្តមសេនីយ៍ឯក

យូរ សារុំ ប្រធាននាយកដ្ឋានច្រកទ្វារទី១ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ ដល់ប្រជាពលរដ្ឋទាំង ០៩ នាក់ខាងលើ និងអនុញ្ញាតឲ្យពួកគាត់ វិលត្រឡប់ទៅលំនៅដ្ឋានរៀងៗខ្លួន រីឯមេក្លោងខាងលើ ត្រូវបានធ្វើកំណត់ហេតុ និងបញ្ជូនទៅអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីបន្តចាត់ចែងអនុវត្ត តាមនីតិវិធីនៃច្បាប់៕

## ពលករខ្មែរបន្តវិលមកមាតុភូមិក្រោយព្រំដែនបានបិទព្រោះការរីករាលដាលនៃមេរោគកូវីត១៩

http://www.rasmeinews.com/ March 30, 2020, 7:39 PM

ដោយៈប.ជ័យ/បន្ទាយមានជ័យៈពលករខ្មែរធ្វើការនៅប្រទេសថៃបន្តវិលមកមាតុភូមិនៅក្រោយច្រកព្រំដែនបានបិទតាំងពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០កន្លងមក។ នាយទាហានម្នាក់បានប្រាប់កាសែតរស្មីកម្ពុជាថាៈ នៅរសៀលថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ពេលចេញមកកម្ពុជាតាមច្រករបៀងនៅស្រុកគោកស៊ូង ខេត្តស្រះកែវ។ មកវិញច្រករបៀងចម្ការគក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ ពលករខ្មែរ១២៤នាក់ត្រូវបានលោកឧត្តមសេនីយ៍ ឈុន ម៉ៅ មេបញ្ជាការរងយោធភូមិភាគទី៥ ទទួលជាមេបញ្ជាការតំបន់ទី១ បន្ទាយមានជ័យ និងនាយទាហាន,។ លោកឧត្តមសេនីយ៍ យួន ជឿន មេបញ្ជាការរងពលទាហាននៃកងការពារព្រំដែនលេខ៥០៣បានអប់រំណែនាំពីវិធានក្រសួងសុខាភិបាលក្នុងការបង្ការការពារមេរោគកូវីត១៩។ក្នុងនោះត្រូវមានការបាញ់កម្តៅក្នុងខ្លួនការពាក់ម៉ាស់,លាងសម្អាតដៃបាញ់អាលកុល,ជូតដៃជាមួយសាប៊ូលាងដៃការដាក់ខ្លួនឱ្យនៅដាច់ដោយឡែករយៈ១៤ថ្ងៃជាដើម។បន្ទាប់មកត្រូវបានដឹកជញ្ជូនទៅមណ្ឌលសំចតនៅក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ៕S/

## អភិបាលខេត្តព្រៃវែង ប្រាប់អាជ្ញាធរត្រូវក្តាប់ឱ្យបាន រាល់ការវិលត្រឡប់របស់អ្នកចំណាកស្រុក ដើម្បីការពារ COVID-19 កុំឲ្យមានការរីករាលដាល

http://www.freshnewsasia.com/ 2020-03-30

**(ព្រៃវែង)៖** លោក ជា សុមេធី អភិបាលខេត្តព្រៃវែង បានក្រើនរំលឹកដល់អាជ្ញាធរ ក្រុង ស្រុកទាំងអស់ត្រូវខិតខំផ្សព្វផ្សាយ តាមដាន និងក្តាប់ឱ្យបានរាល់ការវិលត្រឡប់មកវិញ របស់ប្រជាពលរដ្ឋចំណាកស្រុក ដើម្បីការពារទប់ស្កាត់ជំងឺ COVID-19 កុំឲ្យមានការរីករាលដាល។ នៅក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត នៅរសៀលថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ លោកអភិបាលខេត្ត បានថ្លែងនូវការកោតសរសើរចំពោះការខិតខំប្រឹងប្រែងធ្វើការអស់កម្លាំងកាយចិត្ត របស់មន្ទីរអង្គភាព អាជ្ញាធរពាក់ព័ន្ធទាំងអស់ នៅតាមភូមិសាស្ត្ររៀងៗខ្លួន ដើម្បីធ្វើយ៉ាងណាបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋបានល្អប្រសើរ ជាពិសេសសកម្មភាពក្នុងការចុះផ្សព្វផ្សាយព័ត៌មានអំពីការការពារទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានបានយ៉ាងល្អប្រសើរគួរជាទីមោទនៈ។

លោកបានណែនាំ ដល់កងកម្លាំងទាំងបី អាជ្ញាធរ ក្រុង ស្រុក ទាំងអស់ត្រូវបន្តខិតខំប្រឹងប្រែងតាមដាន និងក្តាប់ឱ្យបាន រាល់ការវិលត្រឡប់ចូលស្រុករបស់ប្រជាពលរដ្ឋ ដែលគាត់បានធ្វើចំណាកស្រុកទៅធ្វើការនៅឯក្រៅប្រទេស ឬកន្លែងផ្សេងៗក្តី ត្រូវធ្វើការផ្សព្វផ្សាយណែនាំ អំពីវិធីការពារ និងទប់ស្កាត់អំពីបញ្ហា នៃការ រីករាលដាលនៃជំងឺ COVID-19 តាមការណែនាំរបស់ក្រសួងសុខាភិបាល។ សូមរំលឹកផងដែរថា រដ្ឋបាលខេត្តព្រៃវែង បានត្រៀមទីតាំងកន្លែងជូនប្រជាពលរដ្ឋដែលសង្ស័យថាមាន COVID-19 ដើម្បីពិនិត្យព្យាបាល និងដាក់ដោយឡែកចំនួន ៣ កន្លែង សរុប ១០៣បន្ទប់មានអាគារ សណ្ឋាគារចុងប៉ម មានបន្ទប់ចំនួន ៤៨បន្ទប់អាគារ ផ្ទះសំណាក់គ្រូបង្រៀនមានបន្ទប់ចំនួន ២២បន្ទប់អាគារ សាលាបឋមសិក្សាសម្តេចតេជោ ហ៊ុនសែន ព្រៃវែងក្រុង មានបន្ទប់ចំនួន ៣៣ បន្ទប់ផងដែរ៕

## ឯកឧត្តម អម សុភា អញ្ជើញដឹកនាំក្រុមការងារចុះជួបសំណេះសំណាល និងសួរសុខទុក្ខពលករ ដែលត្រលប់មកពីប្រទេសថៃ នៅភូមិកណ្តាល ឃុំត្រពាំងចាន់ ស្រុកបរិបូណ៌

https://gdlf-kh.com/ Sam Sophearum កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង ៖ នៅព្រឹកថ្ងៃទីថ្ងៃចន្ទ ៧កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ឯកឧត្តម អម សុភា ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តកំពង់ឆ្នាំង, លោកជំទាវ ប៊ិន សុភី អនុប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តកំពង់ឆ្នាំង, លោក ប្រាក់ វ៉ុន លេខាធិការ គណៈកម្មាធិការសាខាខេត្តកំពង់ឆ្នាំង មន្ត្រីសាខា និងអនុសាខាស្រុកបរិបូណ៌ បានចុះជួបសំណេះសំណាល និងសួរសុខទុក្ខពលករដែលត្រលប់មកពីប្រទេសថៃ ចំនួន ១០ នាក់ ដែលមានទីលំនៅ នៅភូមិកណ្តាល ឃុំត្រពាំងចាន់ ស្រុកបរិបូណ៌។

ក្នុងនោះផងដែរ ឯកឧត្តម ក៏បានណែនាំអោយគាត់ដាក់ខ្លួននៅដាច់ដោយឡែកពីបងប្អូន ញាតិមិត្ត និងមិនដើរចេញរហេតរហូតរយៈពេល ១៤ថ្ងៃ ដើម្បីតាមដានអាការៈនៃជំងឺកូវីដ ១៩ ព្រមទាំងបានអប់រំណែនាំ អំពីរបៀបថែទាំសុខភាព ក៏ដូចជាការលាងសម្អាតដៃជាមួយសាប៊ូ ទឹកអាល់កុល ឬទឹកដែលលាងដៃ ពាក់ម៉ាស និងការបរិភោគអាហារដែលចម្អិនបានល្អ ការក្អក ក្រដាស់ ត្រូវខ្ទប់មាត់ ច្រមុះនិងក្រដាស ក្រមា កែងដៃ តាមការណែនាំត្រឹមត្រូវពីក្រសួងសុខាភិបាល ដើម្បីចៀសវាងការឆ្លងរាលដាលជំងឺកូវីដ ១៩ ថ្មីនេះ ៕

## កិច្ចប្រជុំបង្កើតក្រុមការងារសម្របសម្រួល ដើម្បីត្រួតពិនិត្យជំងឺកូវីដ-១៩ នៅច្រកព្រំដែនអន្តរជាតិ កម្ពុជា-ថៃ

https://grandnewsasia.com/ 30-03-2020

ពោធិ៍សាត់៖ នៅសាលប្រជុំវេទិកាសាធារណៈ នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ លោក អ៊ឹង គីមលាង តំណាងលោក ម៉ៅ ធនិន អភិបាលខេត្ត បានដឹកនាំកិច្ចប្រជុំសម្រេចស្តីពីការបង្កើតក្រុមការងារ សម្របសម្រួលទទួលប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ តាមច្រកព្រំដែន «ថ្មដា_បានថាសេន» និងទទួលខុសត្រូវដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ តាមច្រកព្រំដែនគោក កម្ពុជា-ថៃ តាមច្រកផ្សេងៗមកកាន់ខេត្តពោធិ៍សាត់ ដែលមានការចូលរួមពីប្រធានមន្ទីរនានាជុំវិញខេត្ត កងកម្លាំងសមត្ថកិច្ចទាំងបីប្រភេទ និងអភិបាលក្រុង/ស្រុក។ ក្នុងនោះ លោក អ៊ឹង គីមលាង ក៏បានផ្តាំផ្ញើដល់សមាជិក សមាជិកាក្នុងអង្គប្រជុំឱ្យមានការសហការ បង្ការការពារ ពិនិត្យឱ្យបានម៉ត់ចត់ស្របទៅតាមនីតិវិធីដែលក្រសួងសុខាភិបាលបានណែនាំ ៕

## ពលករមកពីថៃខ្លះដាក់ខ្លួនឯងដាច់ដោយឡែកនៅឆ្ងាយពីអ្នកផ្ទះ១៤ថ្ងៃ ដើម្បីតាមដានសុខភាព

https://www.rfa.org/khmer/  ដោយ អាស៊ីសេរី 2020-03-29

ក្រុមពលករខ្មែរ ត្រលប់មកពីធ្វើការនៅប្រទេសថៃ មួយចំនួនបានដាក់ខ្លួនឯងឱ្យនៅឆ្ងាយពីអ្នកផ្ទះ ដើម្បីត្រួតពិនិត្យសុខភាព។ ពួកគេ ឱ្យដឹងថា អាជ្ញាធរបានចុះទៅត្រួតពិនិត្យនិងតាមដានសុខភាពរបស់ពួកគេដល់បន្ទប់ស្នាក់នៅរាល់ថ្ងៃ។ ពលករស៊ីឈ្នួលលក់ស្បែកជើងនៅក្នុងផ្សាររុងក្លឿម្នាក់ លោក ស៊ុន ចិន និយាយថា លោកបានវិលចូលកម្ពុជា នៅយប់ថ្ងៃទី២២ មីនា ដោយភាពប្រញាប់ប្រញាល់ព្រោះអាជ្ញាធរថៃ ប្រកាសបិទព្រំដែននៅពេលនោះ។ លោកថា នៅពេលឆ្លងកាត់ប៉ុស្តិ៍ព្រំដែន ទាំងនៅខាងថៃ និងនៅប៉ោយប៉ែត គ្មានការត្រួតពិនិត្យសុខភាពពលករទេដោយសារពលករមានគ្នាច្រើនហើយប្រជ្រៀតគ្នាសម្រុកចូលព្រោះខ្លាចចូលមិនទាន់ការកំណត់បិទព្រំដែន។ នៅពេលមកដល់ក្នុងទឹកដីខ្មែរ ម្តុំព្រំដែនប៉ោយប៉ែត ពលកររូបនេះ ឱ្យដឹងថា អាជ្ញាធរក៏មិនបានពិនិត្យសុខភាពដែរ ហើយពលករទាំងអស់បាននាំគ្នាបន្តដំណើរទៅស្រុកកំណើតរៀងៗខ្លួន។ ប៉ុន្តែ លោកអះអាងថា ក្រុមពលករខ្លះក៏

មានការប្រយ័ត្នប្រយែងខ្លួនឯងដែរ។ សម្រាប់រូបលោក បានយល់ដឹងពីការចម្លងជំងឺកូវីដ១៩ (Covid-19) និងបានរក្សាអនាម័យតាំងពីស្នាក់នៅ កន្លែងធ្វើការក្នុងប្រទេសថៃមក។ លោក បានធ្វើដំណើរចូលមកកម្ពុជា ២នាក់បងប្រុស ហើយសុទ្ធតែពាក់ម៉ាស់ និងមានអាកុលដាក់តាមខ្លួនសម្រាប់លាងដៃ ញឹកញាប់ នៅពេលធ្វើដំណើរ។

តែយ៉ាងណា នៅពេលធ្វើដំណើរមកដល់ភ្នំពេញ លោកស្នាក់នៅបន្ទប់ជួលជាមួយបងប្រុស នៅម្តុំភូមិទួលពង្រ ហើយអាជ្ញាធរសង្កាត់ចោមចៅទី១ បានចុះទៅស្ទង់កម្តៅ ឃើញ លោក មានកម្តៅ៣៧.៥ អង្សាសេ ទើបអាជ្ញាធរណែនាំឱ្យលោក ស្នាក់នៅក្នុងបន្ទប់មួយរយៈ តែមិនបានយកសំណាកទៅពិសោធន៍ទេ។ លោកថា មូលហេតុឡើងកម្តៅ ដោយសារអាជ្ញាធរចុះទៅវាស់កម្តៅនៅពេលថ្ងៃត្រង់ ហើយលោកទើបត្រលប់មកពីក្រៅ ក្រោមអាកាសធាតុក្តៅខ្លាំង និងការរស់នៅក្នុងបន្ទប់ជួលតូច និងក្តៅ ដូច្នេះធ្វើឱ្យកម្តៅ លោកឡើងខ្លាំង។ តែមួយថ្ងៃក្រោយមក កម្តៅលោកបានថយចុះវិញរហូត៖ «ខ្ញុំមកពីថៃ ដេកបានមួយយប់។ ស្អែកឡើងទិញម៉ូតូនៅចោមចៅហើយមកវិញក្តៅថែស។ ចូលដល់ក្នុងបន្ទប់គេមកវាស់កម្តៅពួកខាងក្រសួងគេហ្នឹង ហើយដឹងស្រាប់ហើយ នៅភ្នំពេញក្តៅ។ គេមិនឱ្យដើរទៅណាទេ រយៈពេល១៤ថ្ងៃហ្នឹង។ បើសិនជាអត់មានបញ្ហា ឬគ្មានអាមេរោគនៅក្នុងខ្លួនហ្នឹងទេ យើងអាចដើរចេញទៅក្រៅបាន។ តែខ្ញុំអត់ដឹងទេ លក្ខណៈការពារហ្នឹង គេការពាររបៀបម្តេចទេ ខ្ញុំអត់យល់ទេ។ ម្នាក់ៗមកពីថៃ គឺគេរើសអើង គេថា អត់ឱ្យដើរចូលផ្ទះគេផ្តេសផ្តាសអ៊ីចឹង វាពិបាកដែរ វាខ្លាំងមែនទែនតែម្តង។ ពិបាកណាស់ ទៅណាក៏មិនរួច ដេកនៅតែក្នុងផ្ទះ មើលទូរស័ព្ទ។ អាទូរស័ព្ទហ្នឹង គ្មានសេវាទៀត»។

អ្នកទើបត្រលប់ពីប្រទេសថៃមួយក្រុមទៀត គឺជាបុគ្គលិកក្រុមហ៊ុនឯកជនមួយ ដែលទៅរៀនវិធីផលិតស្បែកជើង នៅក្នុងរោងចក្រជាយទីក្រុងបាងកក។ ពួកគេ បានប្រាប់ថា បានត្រលប់មកប្រទេសកម្ពុជាវិញ ភ្លាមៗតាមយន្តហោះនៅថ្ងៃទី២២ មីនា ព្រោះខ្លាចមិនទាន់ការកំណត់បិទព្រំដែន។ ពលករមួយក្រុមនេះមានគ្នា៤នាក់ ក៏ត្រូវបានអាជ្ញាធរសង្កាត់ចោមចៅទី១ វាស់កម្តៅលើស៣៧អង្សាសេដែរ នៅពេលត្រលប់មកដល់បន្ទប់ជួលវិញ។

លោក សួង ផា ប្រាប់ថា នៅមុនពេលឡើងយន្តហោះ នៅក្រុងបាងកក អាជ្ញាធរថៃ បានវាស់កម្តៅលោកលើស៣៧អង្សាសេ ហើយក្រោយមកអាជ្ញាធរបានឱ្យលោកសម្រាកបន្តិច។ ជាងមួយម៉ោងក្រោយមក កម្តៅលោកថយចុះក្រោម៣៧ ទើបអាជ្ញាធរថៃ អនុញ្ញាតឱ្យលោកឡើងយន្តហោះ។ លោកតែងពាក់ម៉ាស់រាល់ពេលធ្វើដំណើរ ហើយនៅលើយន្តហោះ លោកបានប្រើអាល់កុល បាញ់នៅលើកៅអីអង្គុយ និងមានការប្រយ័ត្នប្រយែងគ្រប់ពេលរាល់ពេលធ្វើដំណើរ។ នៅពេលមកដល់ព្រលានយន្តហោះភ្នំពេញ កម្តៅលោក ក្រោម៣៧អង្សាសេ។ លោកបានស្នាក់នៅបណ្តោះអាសន្ន ជាមួយពលករដែលមកជាមួយគ្នា ក្នុងបន្ទប់ជួល នៅជាយក្រុង ហើយអាជ្ញាធរមូលដ្ឋានបានចុះទៅស្ទង់កម្តៅពួកលោក ហើយរកឃើញពួកលោក សុទ្ធតែលើស៣៧អង្សា។ អាជ្ញាធរបានណែនាំឱ្យពួកលោក កុំចាកចេញពីបន្ទប់មួយរយៈ ដើម្បីបន្តការតាមដានកម្តៅ តែមិនបានយកសំណាកទៅពិនិត្យទេ។ តែដោយសារការរស់នៅបន្ទប់ជួលតូចចង្អៀតពេកលោកបានស្នើសុំអាជ្ញាធរដើម្បីទៅរស់នៅស្រុកកំណើតក្នុងឃុំស្រែអំបិល ស្រុកស្អាង ខេត្តកណ្តាលវិញ។

បច្ចុប្បន្នពលកររូបនេះ បានរស់នៅក្នុងកូនរោងមួយ នៅខាងក្រោយផ្ទះ ដើម្បីដាក់ខ្លួនឯង ឱ្យនៅដាច់ដោយឡែក ចេញពីគ្រួសារ ១៤ថ្ងៃ។ យ៉ាងណា លោកយល់ថា កម្តៅក្នុងខ្លួនលោក ក្តៅខ្លាំង ដោយសារការរស់នៅក្នុងបន្ទប់តូចចង្អៀតនៅជាយក្រុងរួមទាំងអាកាសធាតុក្តៅខ្លាំង តែក្រោយពេលលោក បានទៅដល់ស្រុកកំណើត កម្តៅក្នុងខ្លួនលោក ថយមកជាធម្មតា គឺក្រោម៣៧ អង្សា៖ «ឥឡូវកម្តៅខ្ញុំធម្មតាវិញហើយបង។ សុខភាពខ្ញុំធម្មតា អត់មានក្អក អត់មានឈឺក្បាល ហើយអត់មានឈឺកអ្វីទេបង អត់មានផ្តាសាយទេ ធម្មតា ហើយខ្ញុំនៅដាច់ដោយឡែកពីគ្រួសារ។ ធ្វើរោងនៅក្រោយផ្ទះ។ ខ្ញុំការពារគ្រួសារខ្ញុំហ្មង»។

ចំណែកមិត្តភក្តិរបស់លោក ជាពលករ៣នាក់ទៀត ដែលវាស់កម្តៅលើស៣៧អង្សាសេដែរនោះ កំពុងរស់នៅជុំគ្នា ៣នាក់ក្នុងបន្ទប់ជួលជាយក្រុងដដែល។ ម្នាក់ក្នុងចំណោម៣នាក់ គឺ លោក រ៉ិត វ៉ាន់ ឱ្យដឹងថា អាជ្ញាធរបាន

ចុះទៅវាស់កម្តៅពួកគេរាល់ថ្ងៃ នៅបន្ទប់ជួលនិងផ្តាំកុំឱ្យដើរចេញក្រៅ បើគ្មានការចាំបាច់ ហើយរង់ចាំលិខិតបញ្ជាក់សុខភាពសិន។ ទោះយ៉ាងណា លោកថា កម្តៅក្នុងខ្លួនលោកទាំង៣នាក់ បានថយចុះមកនៅកម្រិតធម្មតាវិញហើយ និងមិនបានដើរចេញក្រៅបន្ទប់ទេ ក្រៅពីទៅទិញម្ហូបអាហារក្បែរបន្ទប់ជួល នៅម្តុំរោងចក្រក្បែរនោះ។ លោកអះអាងថា ការដើរចេញក្រៅទៀតសោត លោកតែងពាក់ម៉ាស់ និងមានអាកុលលាងដៃជានិច្ចៈ «ខាងភូមិឃុំខ្ញុំប្រាប់គេថា នៅរយៈពេល១៤ថ្ងៃសិន ដើម្បីគេ(ពិនិត្យ)អាការៈយើង សុខភាពល្អ (សិន) អ៊ីចឹងគេនឹងចាំឱ្យយើងយកក្រដាសបញ្ជាក់សិន ចាំឱ្យទៅផ្ទះ»។

ពលករម្នាក់ទៀត ជាកម្មករបេះផ្លែឈើ ក្នុងប្រទេសថៃ កញ្ញា ខេង សៀកហេង ដែលបានវិលចូលកម្ពុជាវិញកាលពីកន្លះខែមុន គឺនៅថ្ងៃទី១៣ មីនា ក៏ត្រូវបានអាជ្ញាធរតាមដានសុខភាពផងដែរ និងបានវាស់កម្តៅកាលពីថ្ងៃទី២៤ មីនា បង្ហាញថា នាងលើស៣៧អង្សា។ ឪពុករបស់កញ្ញា សៀកហេង គឺជាអ្នកលក់ម្ហូរ និងចម្រិតលីងនៅមុខរោងចក្រម្តុំភូមិទួលពង្រ ឱ្យដឹងថា កម្តៅកូនស្រីលោក លែងចោទជាបញ្ហាហើយ ព្រោះធ្លាក់មកក្រោម៣៧អង្សាវិញហើយ។ យ៉ាងណា លោកថា នាងកំពុងស្នាក់នៅក្នុងបន្ទប់ ដោយមិនឱ្យដើរហើរចេញក្រៅទេៈ «កាលហ្នឹងមក ខ្ញុំក៏មិនសូវចាប់អារម្មណ៍ដែរ។ មកធម្មតាកាលហ្នឹងមិនទាន់បែកអារឿងហ្នឹងខ្លាំងផង ដល់កូនខ្ញុំមកបានប៉ុន្មានថ្ងៃ ចាប់ផ្តើមប្រធានភូមិប្រធានអ្វី គេ ប៉េអឹមប៉ូលិសគេហ្នឹង គេចុះល្បាតតាមភូមិ ថា អ្នកមកពីថៃ មកពីអ្វីអ៊ីចឹង គេមកពិនិត្យមកអ្វីអ៊ីចឹងណា។ កាលអាភ្លាមៗហ្នឹង (ត្រួតពិនិត្យ)បាន២នាក់ កូនខ្ញុំមួយ ហើយប្រុសម្នាក់ទៀត នៅទួលពង្រនេះដែរ ខាងត្បូងនេះ មកពីថៃដែរ។ តែលើកក្រោយៗមកទៀត ខ្ញុំអត់ដឹងផង»។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង បានថ្លែងក្នុងពេលចុះជួបមន្ត្រីនគរបាលអន្តោប្រវេសន៍នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅថ្ងៃទី២៨ មីនា ថា ពលរដ្ឋខ្មែរវិលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាក្នុងអំឡុងពេលថៃបិទព្រំដែនមានប្រមាណ មួយម៉ឺន ប្រាំពាន់ (១៥ ០០០) នាក់ហើយបានត្រឡប់ចូលយ៉ាងគំហុកដែលមិនអាចគ្រប់គ្រងបាន។ យ៉ាងណា លោក ស ខេង បានបញ្ជាឱ្យអាជ្ញាធរមូលដ្ឋានធ្វើយុទ្ធនាការអប់រំពលរដ្ឋឱ្យបានច្រើន ឬអាចបិទភូមិប្រសិនបើរកឃើញថា មានឆ្លងជំងឺកូវីដ១៩ ច្រើន នៅក្នុងភូមិនោះ។ ប៉ុន្តែទោះជាយ៉ាងណា មកដល់ពេលនេះ ក្រសួងសុខាភិបាល មិនទាន់រកឃើញពលរដ្ឋខ្មែរទើបត្រលប់ចូលប្រទេសកម្ពុជាណាម្នាក់ មានផ្ទុកជំងឺកូវីដ១៩ទេ។ មូលហេតុនៃការវិលត្រឡប់ ចូលកម្ពុជា របស់ពលរដ្ឋខ្មែរ យ៉ាងគំហុកដោយសារតែថៃប្រកាសបិទព្រំដែនឯកន្លែងធ្វើការរបស់ពលករស្ទើរទាំងអស់ ក៏បិទទ្វារឈប់ធ្វើការដែរដូចជាហាងខារ៉ាអូខេ ភោជនីយដ្ឋានហាងកាត់សក់ហាងសាំងហាងម៉ាស្សា ហាងលក់ទំនិញជាដើម។ ការបិទនេះ បានជះឥទ្ធិពលដល់ពលករខ្មែរដែលធ្វើការនៅទីនោះគ្មានលទ្ធភាពបន្តការស្នាក់នៅក្នុងប្រទេសបាន។

ទោះជាយ៉ាងណា ក្រុមពលករ និងអ្នកឃ្លាំមើលឱ្យដឹងថា ពលរដ្ឋខ្មែរវិលចូលកម្ពុជាភាគច្រើន គឺជាអ្នករកស៊ីនៅម្តុំព្រំដែន ឯពលករធ្វើការនៅក្នុងក្រុងបាងកក និងខេត្តមួយចំនួនទៀត នៅឆ្ងាយពីព្រំដែន មិនបានវិលត្រលប់ចូលកម្ពុជាទេ។ ទន្ទឹមគ្នានេះ មន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃបានស្នើសុំពលរដ្ឋខ្មែរទាំងកំពុងសិក្សា កំពុងធ្វើការ និងប្រកបមុខរបរក្នុងទឹកដីថៃអនុវត្តការណែនាំរបស់រដ្ឋាភិបាលថៃ ក្នុងការទប់ស្កាត់ជំងឺកូវីដ១៩ និងស្នើសុំឱ្យពលរដ្ឋខ្មែរកុំចាកចេញពីទឹកដីថៃ បើសិនមិនមានភាពចាំបាច់៕

## កម្លាំងនគរបាលប៉ុស្តិ៍ បានទទួលប្រជាពលរដ្ឋខ្មែរលួចឆ្លងដែនខុសច្បាប់ ដែលទាហានឈុតខ្មៅថៃចាប់បានបញ្ជូនមកវិញចំនួន ០៦នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 30-03-2020

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង៣០នាទី កម្លាំងប៉ុស្តិ៍នគរបាល ច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី និងផ្នែកចត្តាឡីស័ក បានធ្វើការទទួល និងពិនិត្យកំដៅប្រជាពលរដ្ឋខ្មែរ ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេស

ថៃ តាមច្រករបៀង ស្លាបស្តាំ របស់ប៉ុស្តិ៍ សរុបចំនួន ០៣នាក់ ដោយមិនមាននរណាម្នាក់ ឡើងកម្តៅខុសប្រក្រតីនោះទេ។ ក្រៅពីនេះ កម្លាំងនគរបាលប៉ុស្តិ៍ បានទទួលប្រជាពលរដ្ឋខ្មែរលួចឆ្លងដែនខុសច្បាប់ ដែលទាហានឈុតខ្មៅថៃ ចាប់បានបញ្ជូនមកវិញចំនួន ០៦នាក់ និងបន្តបិទច្រកដោយពុំអនុញ្ញាតឲ្យមាន អ្នកដំណើរ និងទំនិញ ចេញ-ចូល ឆ្លងកាត់ឡើយ៕

**ពលរដ្ឋខ្មែរចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន ចំនួន ១៧នាក់ ស្រី ១៥នាក់**

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 30-03-2020

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ១៧នាក់ ស្រី ១៥នាក់។ ក្រុមចត្តាឡីស័កវាស់កំដៅ ពុំមានសញ្ញាអ្វីគួរឲ្យកត់សំគាល់ឡើយ បន្ទាប់មកបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន ដោយឡែកមធ្យោបាយ ទំនិញ ចូល-ចេញ ពុំមានចរាចរទេ៕

**ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ចំនួន ២៧២នាក់ ស្រី ១១៨នាក់ កុមារ ០៩នាក់**

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 30-03-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ភាគីថៃនៅតែបន្តបិទច្រក មិនអនុញ្ញាតឲ្យអ្នកដំណើរ ជាតិ អន្តរជាតិ ចេញ-ចូលនោះទេ។ ចំណែកមធ្យោបាយដឹកទំនិញ គឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ចំនួន ២៧២នាក់ ស្រី ១១៨នាក់ កុមារ ០៩នាក់។ ប្រជាពលរដ្ឋខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

**ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ៣១០នាក់ ស្រី ១២៥នាក់**

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 30-03-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិ ចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគីកម្ពុជា-ថៃ បានត្រឹមត្រូវ ចំណែកឯពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ ចូលប្រទេសរៀងៗខ្លួន។ ដោយឡែកពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ៣១០នាក់ ស្រី ១២៥នាក់ គិតត្រឹមវេលាម៉ោង ១៤និង៣០នាទីថ្ងៃនេះ៕